# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ អន សុភាព ភេទស្រី អាយុ៥៨ឆ្នាំ
## និង ឆោម សែ ភេទប្រុស ត្រូវជាប្តី
## មុខងារសម័យខ្មែរក្រហមៈ «យោធាវរសេនាធំ៨០៤ កងពល៨០១»
## សព្វថ្ងៃរស់នៅភូមិលំទងថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ
## ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២
## សម្ភាសន៍ដោយៈ ឌី ខាំបូលី
## ០២:៥៩:៣០
## ០២:៤២:៣៧
## ០២:២៦:៥០
## ២២៤ទំព័រ

០២:៥៩:៣០

បូលី ៖ ចឹងខ្ញុំសុំស្គាល់ឈ្មោះមីងផង?

ភាព ៖ ឈ្មោះ អន សុភាព ។

បូលី ៖ សព្វថ្ងៃមីងអាយុប៉ុន្មានហើយ?

ភាព ៖ អាយុ៥៨ឆ្នាំ ។

បូលី ៖ មីងមានស្រុកកំណើតនៅខេត្តណាដែរ?

ភាព ៖ ខ្ញុំនៅភូមិព្រៃឈើទាល ។

បូលី ៖ ឃុំ?

ភាព ៖ ឃុំប្រភ្នំ ស្រុកអង្គរជ័យ ខេត្តកំពត ។

បូលី ៖ ចុះបច្ចុប្បន្ននេះនៅភូមិណាដែរ?

ភាព ៖ សព្វថ្ងៃខ្ញុំនេះ រស់នៅភូមិលំទងថ្មី ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

បូលី ៖ ហើយចុះពូអ្នកខាងណាវិញ ឈ្មោះអីដែរ?

ភាព ៖ គ្រួសារខ្ញុំនៅស្រុកគិរីវង្ស ។

បូលី ៖ គាត់ឈ្មោះអីដែរ?

ភាព ៖ ឈ្មោះ ឆោម សែ ។

បូលី ៖ គាត់នៅទេ?

ភាព ៖ នៅ ។

បូលី ៖ គាត់ធ្វើអីដែរ?

ភាព ៖ គាត់ខាងសមាគមន៍អតីតយុទ្ធជន ។

បូលី ៖ សមាគមន៍នឹងបង្កើតតែស្រុកអន្លង់វែងមួយទេ ឬក៏?

ភាព ៖ អត់ទេ ទូទាំងខេត្ត ប៉ុនគាត់នៅក្នុងស្រុក ។

បូលី ៖ ចឹងគាត់ប្រធានសមាគមន៍អតីតយុទ្ធជនស្រុកអន្លង់វែង?

ភាព ៖ ស្រុក ។

បូលី ៖ ដល់មីងសមាជិក?

ភាព ៖ សមាជិកក្រុមប្រឹក្សាឃុំ ។

បូលី ៖ សមាជិកនឹង តាំងពីអាណត្តិណាមកហើយ?

ភាព ៖ ត្រឹមអាណត្តិទី២ អាណត្តិទី១ខ្ញុំជំទុក២ ។

បូលី ៖ ដល់ពេលអាណត្តិទី២នេះ មកដល់ឥឡូវនេះសមាជិកក្រុមប្រឹក្សា?

ភាព ៖ ចា៎!

បូលី ៖ មកពីអីបានជាលែងធ្វើជាជំទុក ឬវិគ្រែត?

ភាព ៖ វាមិននេះទេ វាពាក់ព័ន្ធនឹងការមុនភូមិនេះបេក្ខជន-ក្រុមប្រឹក្សាឃុំគណបក្សតែមួយ សព្វថ្ងៃវាមាន២ក្នុងអាណត្តិទី២ ទី៣ មាន២ ។ ដល់មាន២ មួយគេចូលមកជាជំទុកទៅ យើងចុះមកខាងក្រោម ។

បូលី ៖ ចឹងពីមួយអាណត្តិទៅមួយអាណត្តិ ធ្លាក់ចុះមកវិញ ឬយ៉ាងម៉េច ឬនៅដដែលទេ?

ភាព ៖ ឥឡូវនឹងនៅនឹងដដែល ដូចអាណត្តិទី២ដែរ គេជំទុក២ដដែល ។

បូលី ៖ ចឹងកាលពីតូចៗមក មីងរៀនសូត្រអីដល់ថ្នាក់ណាដែរ?

ភាព ៖ ខ្ញុំរៀនបានដល់ថ្នាក់ទី៧ ។

បូលី ៖ ទី៧ចាស់ ហើយថ្មី?

ភាព ៖ ចាស់ ។

បូលី ៖ បើយើងគិតមកថ្មី ទីប៉ុន្មាន គិតមកប្រព័ន្ធថ្មីយើង?

ភាព ៖ រាល់បញ្ច្រាសមកយើង ទី១២ ទី១១ ទី១០ ទី៩ ទី៨ ទី៧ ។

បូលី ៖ ថ្នាក់ទី៦?

ភាព ៖ ចា៎!

បូលី ៖ នៅសាលាណាដែរកាលនឹង?

ភាព ៖ ខ្ញុំរៀននៅសាលាវត្តប្រភ្នំ ។

បូលី ៖ ចឹងមីងរៀនបានច្រើនណាស់ កាលនឹង?

ភាព ៖ តែខ្ញុំឈប់ តាំងពី៦៨ ៦៧ ៦៨នោះ ។

បូលី ៖ ឆ្នាំប៉ុន្មានឈប់រៀននឹង៦៧ ៦៨?

ភាព ៖ ឆ្នាំ១៩៦៧ ខ្ញុំឈប់ជំនាន់សម័យនោះ វារាំងប្រទេសខ្មែរយើងដាច់ស្បៀងហូបអង្ករតែ កំបោះៗធំៗចេះ ។ បានខ្ញុំទៅនៅជាមួយបងខ្ញុំឯកំពត ។

បូលី ៖ ដែលដាច់ស្បៀងនឹង មកពីដោយសារអាកាសធាតុរាំងស្ងួត ឬដោយសារដែរ?

ភាព ៖ រាំងស្ងួត មិនមែនដោយសារប្រជាជនយើងធ្វើនេះទេ ដល់អត់ទឹកទៅ ធ្វើអត់បាន យើង ត្រូវទិញអង្ករពីប្រទេសក្រៅមកហូប ។ ហើយខ្ញុំអាយុ១២ឆ្នាំ ខ្ញុំនៅចាំដែរ ។ ខ្ញុំឈប់រៀន អាយុ១២ឆ្នាំ ។

បូលី ៖ កាលនឹងឪពុកម្ដាយមីងគាត់ធ្វើអីដែរ?

ភាព ៖ គាត់ធ្វើស្រែ ប៉ុនខ្ញុំប្រឡងឡើងថ្នាក់ទី៦ជាប់ហើយ ប៉ុនសាលាវាឆ្ងាយ ទៅរៀននៅតានី១២ គីឡូ ។ កាលនោះអាយុ១២ឆ្នាំ តាមផ្លូវជាតិចេះវាឡានម៉ូតូអីចឹង ឪពុកម្ដាយគាត់បារម្ភ ។ ម្យ៉ាងយើងសម័យនោះ មិនមានការចេះដឹងចេះគិតដូចសម័យឥឡូវទេ ក្មេងឥឡូវឲ្យវាឈប់ វាអត់ឈប់ ។ សម័យនោះជឿតាមឪពុកម្ដាយច្រើន មិនហ៊ានតវ៉ានឹងគាត់ៗឲ្យឈប់ៗ ហើយ អត់បានរៀនទៀតទេ ។

បូលី ៖ ត្រូវហើយ ឥឡូវនេះ ក្មេងៗចង់ទៅរៀន?

ភាព ៖ ចាំ! ចង់ទៅរៀន យើងចំណាស់នេះហើយ វាចេះតែសោកស្ដាយ តែវាហួសពេល ចេះ ជម្រុញកូនថា សំណាងណាស់ដែលកើតមកទាន់សម័យគេឥឡូវគេរីកចំរើនខាងអក្សរសាស្ត្រ ខាងអីចឹងៗឲ្យកូនយកចិត្តទុកដាក់រៀន ។

បូលី ៖ ហើយមីងមានកូនប៉ុន្មានដែរឥឡូវ?

ភាព ៖ កូន៤នាក់ ។

បូលី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភាព ៖ ស្រី៣ ប្រុស១ ។

បូលី ៖ បានកូនប្រុសទោល?

ភាព ៖ ប្រុសកណ្ដាលមួយ ការពិតខ្ញុំកូន៧ ប៉ុនស្លាប់អស់៣ នៅស្រុកយើងសង្គ្រាមវារវល់ដើរចុះ ឡើងចឹងកូនវាឈឺគ្រុន ។

បូលី ៖ មីងការឆ្នាំប៉ុន្មានដែលរៀបការ?

ភាព ៖ ខ្ញុំការឆ្នាំ១៩៧៧ ។

បូលី ៖ ចឹងការតាំងពីសម័យ៣ឆ្នាំនោះ?

ភាព ៖ ចា៎! ការសម័យ៣ឆ្នាំ ការជាហ្គូង ១២គូ ។

បូលី ៖ គេរៀបការយ៉ាងម៉េច កាលពីសម័យនឹង?

ភាព ៖ សម័យនឹង គេហៅមកការយើងអត់ស្គាល់គ្នាទេ ។

បូលី ៖ ហើយយើងសុខចិត្តដែរចឹង?

ភាព ៖ វាពិបាកចេះ អ្នកខ្លះក៏មានការតវ៉ាបានទៅ ក៏វារៀងលំបាកដែរ សម័យខ្លះគេរៀបចំឲ្យគេ គោរពបក្ស រៀងលំបាកនឹងការតវ៉ា វាប្រកែកវាអស់ច្រើនដែរ យើងថាមិនយក បដិសេធ មិនយកពេលដល់ថ្ងៃការគេហៅចូលទៅតែម្តង វាអត់បានសួរ វាលំបាកកន្លែងនឹង ។ ចេញ ពីប្រជុំរៀនសូត្រម៉ោង៥ ហៅចូលរោងការម៉ង អត់មានដឹងរឿង ។

បូលី ៖ ហើយចុះមីងអារម្មណ៍ម៉េចដែរ ពេលនឹង?

ភាព ៖ អារម្មណ៍ចេះស្មុគស្មាញដែរនឹង មិនជ្រះស្រឡះក្នុងចិត្ត ប៉ុននឹកឃើញថា ដូចជាយើងរស់នៅ ក្នុងរបបចឹង មិនដឹងគេចទៅណា ។

បូលី ៖ ដល់ពេលចូលមកដល់ក្នុងរោងនឹង ក៏ជួបមុខពូទៅ?

ភាព ៖ អត់ស្គាល់គ្នាទេ ទាល់តែគេហៅឈ្មោះ ឡើងចាប់ដៃ មិនចង់ហ៊ានមើលមុខផង ។

បូលី ៖ ហើយពូក៏មិនដែលស្គាល់មីងដែរ?

ភាព ៖ គាត់អាចស្គាល់ខ្ញុំខ្លះ ធ្លាប់ឃើញខ្ញុំខ្លះ ។

បូលី ៖ គាត់អ្នកស្នើ តាមមើល?

ភាព ៖ អត់ទេ ខាងលើរៀបចំតែម្តង ។

បូលី ៖ មិនមែនគាត់ស្នើមីង?

ភាព ៖ អត់ទេ ។

បូលី ៖ ខាងថ្នាក់ត្រឹមណាដែលអាចមានសិទ្ធិរៀបចំមង្គលការឲ្យបាន?

ភាព ៖ កងពល ។

បូលី ៖ កងពល?

ភាព ៖ ចា៎! ព្រោះកាលនឹងនៅក្នុងអង្គភាពកងទ័ពនៅឡើយ ។

បូលី ៖ ចុះថ្នាក់ត្រឹមលេខាតំបន់អីមានសិទ្ធិឲ្យស្នើការបានទេ?

ភាព ៖ មាន គេខាងនៅការិយាល័យមូលដ្ឋាន គេមានៗតាំងពីស្រុកទៅនោះ ។

បូលី ៖ ស្រុកក៏មានសិទ្ធិដែរ?

ភាព ៖ ចា៎!

បូលី ៖ ប៉ុនមានសិទ្ធិនៅក្នុងវង្វង់ស្រុករបស់គាត់?

ភាព ៖ នៅស្រុករបស់គាត់ ។

បូលី ៖ បើតំបន់មានសិទ្ធិនៅក្នុងតំបន់របស់គាត់?

ភាព ៖ មានសិទ្ធិរបស់គាត់ ។

បូលី ៖ បើតំបន់ មានសិទ្ធិនៅក្នុងវង្វង់តំបន់របស់គាត់?

ភាព ៖ ចា៎!

បូលី ៖ កងពលនៅក្នុងកងពលទៅ?

ភាព ៖ ចា៎!

បូលី ៖ ចុះឃុំ មានសិទ្ធិស្នើរៀបការនៅឃុំទេ?

ភាព ៖ ព្រោះអីខ្ញុំរស់នៅអង្គភាពយោធាចឹង វាដាច់ស្រយាលពីមូលដ្ឋានគ្រប់ៗ អត់បានទេ សម័យនោះកងទ័ពគេដាក់ដោយឡែក អង្គភាពដោយឡែក ។

បូលី ៖ ខ្ញុំចង់ដឹងពីរយៈពេលនៃការរៀបពិធីមង្គលការប៉ុន្មានម៉ោង តាមមីងស្មានមើលទៅ?

ភាព ៖ មិនយូរទេ ប្រហែលជាមួយម៉ោង កាលថ្ងៃគេប្រជុំប្រាប់ថាត្រូវរៀបអាពាហ៍ពិពាហ៍ ថ្ងៃនេះហៅមករៀបអាពាហ៍ពិពាហ៍ចឹងទៅ ហើយយើងធ្វើការគោរពឡើងចាប់ដៃគ្នា ហើយនឹងធ្វើការប្តេជ្ញាចិត្តតែប៉ុននឹង អត់មានអីទៀត ចេញមកកម្មវិធីបាយទឹកតិចតួច ការខ្លះអត់មានផង ការខ្លះក៏មាន តាមជាក់ស្តែងទៅ ។

បូលី ៖ ចឹងបើយើងគិតទៅ ទី១គេហៅចូលមកក្នុងរោងប្រជុំ?

ភាព ៖ ចា៎!

បូលី ៖ ចូលមកដល់គេឲ្យយើងអង្គុយយ៉ាងម៉េច?

ភាព ៖ អង្គុយ បុរសអង្គុយមួយជួរ១ចំហៀងទៅ នារីអង្គុយមួយចំហៀងមក ។

បូលី ៖ ២ជួរចេះ?

ភាព ៖ ចា៎!

បូលី ៖ បន្ទាប់មក?

ភាព : ២ជួរ ឧបមាថានារីអង្គុយ២ជួរឬ៣ជួរ ឬបុរស២ជួរឬ៣ជួរចឹង ព្រោះគ្នាច្រើន១២គូ ១៥គូ ដាក់ស្តែង តិចណាស់ ដែលការ២គូ៣គូ ។

បូលី : ចឹងអង្គុយដង្ហែរចឹងទៅ?

ភាព : ចា៎! អង្គុយដង្ហែរដូចយើងអង្គុយប្រជុំចឹង ទុកតែប្រឡោះកណ្ដាលសម្រាប់គណៈអធិបតី គេដើរចូលមក ។

បូលី : គណៈអធិបតីមានប៉ុន្មាននាក់ដែរ?

ភាព : គណៈអធិបតី មាន២នាក់អីនឹង ឬ១នាក់ប្រធានកងពលក៏មាន ។

បូលី : កាលនឹងពីណាគេគណៈអធិបតីនៅក្នុងពិធីមង្គលការរបស់មីង?

ភាព : ឈ្មោះ សូ សារឿន ។

បូលី : តា០៥?

ភាព : ចា៎! តា០៥ ។

បូលី : គាត់អ្នកការឲ្យមីងម៉ង?

ភាព : ចា៎!

បូលី : តែគាត់ម្នាក់ទេ ឬក៏មានអ្នកផ្សេងទៀត?

ភាព : តែគាត់ តែគាត់បានឯកភាពនៅក្នុងប្រចាំការកងពល គាត់ហើយស្រេច ប៉ុនរៀងសាម៉ីខ្លួនដូចអត់ដឹងទេ ។

បូលី : ពេលដែលសាម៉ីខ្លួនទាំងសងខាងចូលមកអង្គុយជាជួរនឹង គណៈអធិបតីមិនទាន់ចូលមកទេ?

ភាព : ចា៎!

បូលី : ហើយគេបានគណៈធិបតី តា០៥ គាត់ដើរតាមក្រោយ?

ភាព : ចា៎! ថ្ងៃការខ្ញុំគាត់មកមុន ចេញតែពីរៀនមក គាត់ជិះម៉ូតូស៊ីភ្លេដាក់ខ្ញុំៗអត់មានដឹងផង ។ មកដល់ទៅមុជទឹកផ្លាស់ខោអាវរៀបទុក ហើយគេឲ្យខោអាវចូលរួមប្រជុំ ។

បូលី : ដល់ពេលមកដល់ តា០៥ គាត់ថាម៉េចទៅ គាត់និយាយថាម៉េចខ្លះ?

ភាព : ពេលគាត់ហៅយើងឡើងចាប់ដៃគ្នា គាត់រៀងថានិយាយដូចបញ្ញើឱយើង គាត់ថា ហ៎ី! មិត្តភាព ព្រមរៀបការហើយតើមេឃភ្លៀងបាក់មេឃបាក់ដីហើយ ព្រមយកប្ដី ពីព្រោះកន្លងមកគាត់តែងតែឲ្យគេសួរខ្ញុំច្រើននាក់ដែរ ថាខ្ញុំអត់ឯកភាពនឹងយក ។ ពេលរឿងគាត់ចេះលើកហេតុផលដែរ អ្នកអើយប្ដីចេះចុះ គាត់ចេះលើកហើយ ចេះមើលមុខខ្ញុំៗមិនសូវធ្វើដឹងធ្វើព្រួទេ ថាម៉េចថាទៅ ។

បូលី ៖ គាត់លើកយ៉ាងម៉េច?

ភាព ៖ លើកថា មាននារីខ្លះរើសប្តីចិន សួររៀបឲ្យអានេះក៏មិនត្រូវ សួររៀបឲ្យអានោះក៏មិនត្រូវ ប៉ុនបន្ទាប់បន្ទោសគេ សួរឲ្យអានេះថាមិនយកទេ មើលពីចំងាយទៅឃើញតែធ្មេញ គាត់ចេះលើកហេតុផល លើកដាក់យើងឲ្យនេះទៅ។ គាត់ថាអត់អីទេ សម្រាប់អ្នករើស ទុកឲ្យគាត់អ្នកគិត ដល់ថ្ងៃការបានគាត់ថា ភាព ព្រមយកប្តីហើយតើ ភ្លៀងបាក់មេឃបាក់ដី។ បានគាត់ថាចេះ ព្រោះអីមុននឹងខ្ញុំការនឹង មានកន្លែងការងារហ្គារ៉ាសឡាននឹង គាត់ស្នើខ្ញុំមុននឹង គាត់ចេញដឹកគ្រាប់ទៅសមរភូមិ។ កាលនឹងយួនចូលមកព្រំដែនរតនគិរី ដល់ហើយគាត់ថា ងាប់ហើយ ដាងកន់ឯងមកវិញ យំធ្វើបាបអុកបន្ទោសឯងងាប់ហើយ គេស្នើហើយ ឯងថាការនឹងគេ ឥឡូវការឲ្យអ្នកនេះ តែខ្ញុំមិនបានដឹង ព្រោះនិយាយបានការរួច បានគាត់ប្រាប់ ការណែនាំគាត់ចុះឲ្យខ្ញុំចុះមកតាមគ្រួសារខ្ញុំ នៅឆ្ងាយដែល៤៨គីឡូ ខ្ញុំថា ខ្ញុំអត់ទៅ។ គាត់ថាម៉េចបានអត់ទៅ ការហើយ? ខ្ញុំថាការមិនចេះសួរគេសួរឯង។ ខ្ញុំថាចុះឯងអង្គការអណ្តាតអត់ឆ្អឹង ថាឲ្យគាត់ច្រើនដែរ ខ្ញុំអត់ចិត្ត។

បូលី ៖ គាត់អត់ថាអីដែរ?

ភាព ៖ ចា៎! គាត់ថា ចុះកាលសួរមុនៗក៏ប្រកែក សារនេះហៅមកម៉េចក៏មក? បើហៅមិនប្រាប់រឿងមិនមក។ ខ្ញុំថាមិនបាច់និយាយទេ ហួសពេលហើយ មិនបាច់ឲ្យខ្ញុំទៅណា។ ខ្ញុំគ្រាន់ថាជាមួយគាត់ថា បើសិនទុកដាក់ឲ្យខ្ញុំ បើខុសដូចអ្នកមុន បើជាប់ខ្សែអ្នកក្បត់ អ្នកអីអត់ឲ្យគេជូនទៅណា ខ្ញុំឲ្យកាប់រណ្តៅខ្លួន ខ្ញុំបាញ់ទម្លាក់ក្នុងរណ្តៅ។ ខ្ញុំថាជាមួយគាត់។

បូលី ៖ ចង់និយាយថា បាញ់ផ្ទាល់ដៃមីងម៉ង?

ភាព ៖ ចា៎! ខ្ញុំនិយាយជាមួយគាត់។ គាត់ថាមិនអីទេ នៅជាមួយគាត់ទៅ។

បូលី ៖ គាត់តំណែងជាអីពេលការ?

ភាព ៖ គ្រួសារខ្ញុំគាត់ចេញពីទ័ពហើយ គាត់នៅខាងគ្រប់គ្រងគេហៅពួកសមាសភាព ពួកប្រឆាំងអីចិន។ ប៉ុនការពិតវាមិនទៅប្រឆាំងអីណាស់ណា គ្រាន់ថា ដូចថា អ្នកខ្លះទំរុនការងារ អ្នកខ្លះវាមានពាក់ព័ន្ធឥទ្ធិពលពីភូមិមក គេទៅក្តាប់ប្រវត្តិរូបដល់ឪពុកម្តាយ ដូចថាមានឪពុកម្តាយទំនាស់ជាមួយសហករណ៍ ទំនាស់អីចិន មានពាក់ព័ន្ធនិន្នាការបងធ្វើទាហាន ឪពុកធ្វើគ្រូអីពីមុនចិន គេដកដាក់សមាសភាពផ្សេង ចិនទេ។

បូលី ៖ ខ្ញុំសុំបកទៅក្រោយតិច មុននឹងយើងពិភាក្សាពីរឿងមីងកាលនៅ៧៧នឹង កាលដែលមីងចេញពីផ្ទះដំបូងនៅឆ្នាំប៉ុន្មាន?

ភាព ៖ ខ្ញុំចេញឆ្នាំ១៩៧១ ។

បូលី ៖ ចេញនឹង ចេញដោយស្ម័គ្រចិត្ត ឬមានគេបង្ខំឲ្យចេញ?

ភាព ៖ អត់មានគេបង្ខំទេ ព្រោះអីកាល៧០នឹង ការពិតទៅខ្ញុំអាយុទើបពេញ១៦ឆ្នាំ ។ ខ្ញុំនៅភូមិនឹង ខ្ញុំជាប់ដឹកនាំប្រធាននារីភូមិតាំងពីក្មេង ព្រោះខ្ញុំក្មេងជាងគេ ប៉ុនគេមើលទៅថា ខ្ញុំឆ្លាត ក៏គេរៀបចំឲ្យគ្រប់គ្រងនារីភូមិពីនាក់បងស្រីនៅភូមិ ។ ប៉ុនឥឡូវគាត់ស្លាប់ហើយបងស្រី ។ ដល់ហើយស្រុកគេហៅទៅរៀនទៅ ខាងសមាគមន៍នារីស្រុកគេហៅទៅធ្វើវគ្គបណ្តុះបណ្តាលច្រើនលើកច្រើនសារដែរចុះមកវិញវាឲ្យគ្រប់គ្រង៣ភូមិ ក្រោយមកគេយកមកដាប់នៅសមាគមន៍នារីភូមិ ។

បូលី ៖ សមាគមន៍នឹង ជាសមាគមន៍នៅក្នុងសម័យណា?

ភាព ៖ សម័យរដ្ឋប្រហារហើយភ្លាមៗចេញមកវិញ ។

បូលី ៖ ចឹងរដ្ឋប្រហារហើយភ្លាម គឺខេត្តកំពតនឹងស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមហើយ?

ភាព ៖ ចលនាតស៊ូតាមនឹង យើងមិនដឹងច្បាស់លាស់ថា ខ្មែរក្រហមធ្វើជាមួយអ្នកណា វាពិបាក វាមិនចេញមុខ គេហៅថាការតស៊ូធ្វើបដិវត្តន៍ ។

បូលី ៖ ចឹងខាងបដិវត្តន៍?

ភាព ៖ ចា៎! ខាងការងារបដិវត្តន៍ ។

បូលី ៖ ហើយមីងធ្វើប្រធានសមាគមន៍នារីភូមិនឹង តាំងពី៧១មក?

ភាព ៖ តាំង៧១ ។

បូលី ៖ ដល់ក្រោយមក បានគេឲ្យគ្រប់គ្រង៣ភូមិ?

ភាព ៖ ចា៎!

បូលី ៖ ៣ភូមិមានភូមិអីគេខ្លះ?

ភាព ៖ មានភូមិព្រៃឈើទាលនឹង ហើយភូមិព្រៃស្គរ ហើយភូមិពងទឹក នៅក្នុងឃុំប្រភ្នំដូចគ្នា ភូមិជិតៗគ្នាជាប់ៗគ្នា ។

បូលី ៖ ដល់ក្រោយមកទៀតបានឡើង?

ភាព ៖ ចា៎! បានដកមកអនុប្រធានសមាគមន៍នារីឃុំ ។

បូលី ៖ ឃុំប្រភ្នំហ្នឹង?

ភាព ៖ អត់ទេ ខ្ញុំទៅធ្វើការនៅឃុំអង្គរជ័យវិញទៀត ទៅដាក់នៅនឹង ។

បូលី ៖ ហើយសមាគមន៍នារីនឹងធ្វើអីខ្លះទៅ?

ភាព ៖ សមាគមន៍នារីនឹង ចុះទៅប្រជុំផ្នែកនារី ប្រជុំនារីនឹងទៅចងក្រង តែផ្នែកសមាគមន៍អប់រំឲ្យនារីៗនឹងចេះជួយគ្នា ចេះសង្គ្រោះគ្នាចឹង ឲ្យដឹងទុកធុរៈគ្នា ។

បូលី ៖ នៅក្នុងមុនពេលទៅធ្វើជាប្រធានសមាគមន៍ មីងធ្លាប់មានទៅរៀនទៅសូត្រដែរ?

ភាព ៖ បានរៀន ស្រុកហៅមករៀន ខាងសមាគមន៍នារីស្រុក ។ គាត់ស្លាប់បាត់ហើយ បងបូ កាលនោះគាត់នៅគ្រប់គ្រង ។

បូលី ៖ ប្រធានសមាគមន៍នារីស្រុក?

ភាព ៖ ចាំ!

បូលី ៖ បូ ហ្នឹង?

ភាព ៖ ចាំ! បងបូ នឹងពីមុន ចាំ! គាត់គ្រប់គ្រងនៅស្រុកអន្លង់វែងនឹងឯង ។

បូលី ៖ ចឹងនៅខាងនិរតី?

ភាព ៖ និរតី ។

បូលី ៖ អន្លង់វែងនៅក្នុងតំបន់ប៉ុន្មានដែរ?

ភាព ៖ អន្លង់វែងនឹងនៅក្នុងខេត្តកំពត ដឹងគេដាក់តំបន់ទីប៉ុន្មាន ។

បូលី ៖ តំបន់១៣ អន្លង់វែង?

ភាព ៖ ចាំ!

បូលី ៖ ហើយមីងនៅក្នុងស្រុកអន្លង់វែង?

ភាព ៖ ចាំ!

បូលី ៖ ស្រុកអន្លង់វែងនឹង ហៅស្រុកប៉ុន្មានដែរ មានលេខទេ?

ភាព ៖ ខ្ញុំដូចជាភ្លេចមិនបានចាំ វាយូរពេក ចេញចោលស្រុកយូរដល់មកចឹងអត់ចាំ ។

បូលី ៖ តាមខ្ញុំដឹងស្រុកអន្លង់វែងនឹង ហៅស្រុក១០៦?

ភាព ៖ ចាំ! ទើបនឹងនឹកឃើញ ។

បូលី ៖ នឹកឃើញ?

ភាព ៖ ចាំ!

បូលី ៖ ពេលនឹងមាន៦ឃុំ មានទីរួមស្រុកនៅតានី, អានឹងមីងមិនអាចចាំ៦ឃុំ ឬប៉ុន្មានឃុំ?

ភាព ៖ ចាំ! ដឹងតែឃុំភ្នំកុង ឃុំមរោង ឃុំសំឡាញ់ ឃុំប្រភ្នំ ។

បូលី ៖ ខ្វះមួយទៀត?

ភាព ៖ ចាំ!

បូលី ៈ ចុះ តានី?

ភាព ៈ តានី ឃុំភ្នំកុង ។

បូលី ៈ នៅក្នុងឯកសារដែលខ្ញុំបានអាន ឯកសាររបស់ខាងកម្ពុជាប្រជាធិបតេយ្យដែរ បានបោះពុម្ព នឹង ដាក់ថាមាន៦ឃុំ ហើយមានទីរួមស្រុកនៅតានី អន្លុះដ័យនឹង?

ភាព ៈ ទីរួមស្រុកមិនហ៊ានថាក្នុងបើស្រុកអ្នកតស៊ូនៅឯងនេះ យើងទៅធ្វើការបានជាយៗស្រុកនឹង ជាយៗឃុំ មួយកំណាត់ៗ តែឃុំប្រភ្នំ ឃុំសំឡាញអីបានពេញនោះ ឃុំអន្លុះដ័យបានមួយ កំណាត់ត្រឹមថ្នល់រទេះភ្លើងមកដើងនឹង ថ្នល់រទេះភ្លើងមកត្បូងនៅពាក់ព័ន្ធនឹងទាហាន ភ្នំកុងក៏ យើងធ្វើបានមួយកំណាត់ ហើយមករោងនឹងបានយើងធ្វើបាននេះ ។ ហើយអ្ហ៎! នៅឃុំមួយ ទៀត អាខាងនោះដំណាក់ដើងគោហៅឃុំអីទេ ពីខាងកើតទន្លេទៅខាងនឹងមួយទៀត៦ ។

បូលី ៈ អ្នកណាគេលេខាស្រុកអន្លុះដ័យកាលនឹង ពីដំបូងមកតាំងពី៧១ ៧២មក?

ភាព ៈ កាលមុនកាល៧០ ៗឈ្មោះ តា និន នឹងចៅហ្វាយស្រុក ហើយអនុនោះឈ្មោះ អ៊ឹប៉ាល់ ។

បូលី ៈ ស្រុកអន្លុះដ័យនឹង?

ភាព ៈ ចា៎!

បូលី ៈ ទី១ឈ្មោះ តា និន?

ភាព ៈ ចា៎!

បូលី ៈ តា និន នឹងឈ្មោះពេញឈ្មោះអីគេ?

ភាព ៈ ស៊ីនិនទេ ខ្ញុំភ្លេចហើយយូរពេក នៅខាងត្បូងផ្ទះខ្ញុំដែរនឹង កាលនឹងភ្លេចគ្នា និយាយរួមថាខ្ញុំ ចេញមកវានៅក្មេង ។

បូលី ៈ ត្រូវហើយ៣០ឆ្នាំជាងហើយ?

ភាព ៈ ចា៎! គិតមើលតាំងពីខ្ញុំអាយុ១៦-១៧ឆ្នាំ ឥឡូវខ្ញុំ៥៨ហើយ ប្អូនឯងគិតទៅល្មមអស់រលីង ទៅខ្ញុំអ្នកស្រុកអត់ស្គាល់ខ្ញុំផង ។

បូលី ៈ ចឹងដំបូងបំផុតពី៧០មក តា និន នឹងលេខាស្រុក?

ភាព ៈ ចា៎! លេខាអី ចៅហ្វាយស្រុកម៉ង មុនគេ ។

បូលី ៈ ចៅហ្វាយស្រុករបស់ខាងបដិវត្តន៍?

ភាព ៈ ចា៎! ខាងបដិវត្តន៍ ។

បូលី ៈ ហើយអនុរបស់ តា និន?

ភាព ៈ អនុកាលនឹង អ៊ឹ ប៉ាល់ ដឹង ខ្ញុំភ្លេចអស់ហើយ ច្រើនពេក ។

បូលី ៖ អត់ទេ! ចាំបានប៉ុនណាយក ប៉ុននឹង ។

ភាព ៖ វាមិនច្បាស់ ។

បូលី ៖ នៅក្នុងរបបនាសម័្ពទ្ធបដិវត្តន៍ ក្រែងមួយកំណាត់នឹងវា៣នាក់?

ភាព ៖ មាន៣ ប៉ុនយើងចាំគេអត់អស់ព្រោះក្មេងអត់សូវបានចាប់អារម្មណ៍នេះទេ ។

បូលី ៖ តា និន, តា ប៉ាល់?

ភាព ៖ ចា៎!

បូលី ៖ តា ប៉ាល់ មិនមែន?

ភាព ៖ តា ប៉ាល់ ស្រួលនៅ១០៧ដឹង ស្រុកទ្រាំងដឹង ជាមួយពូគៀត ខ្ញុំភ្លេចអស់ហើយ វាច្រើនពេក ។

បូលី ៖ ច្រើន?

ភាព ៖ ចា៎! វាច្រើនឆ្នាំនិយាយរួម ។

បូលី ៖ ១០៧ អត់មានឈ្មោះ តា ប៉ាល់ ទេ ។

ភាព ៖ ចឹង១០៦ហើយចឹង អ៊ំ ប៉ាល់ ។ ១០៧ឈ្មោះ គៀត មួយ ។ តា គៀត នឹងក៏ខ្ញុំធ្លាប់ស្គាល់ដែរ ។

បូលី ៖ មានឈ្មោះ គៀត?

ភាព ៖ ចា៎!

បូលី ៖ ១០៧ មុនដំបូងឈ្មោះ តា វាំង។ដែលពូទេ លេខាចៅហ្វាយស្រុកទ្រាំង?

ភាព ៖ អត់ដឹងដែរ ។

បូលី ៖ ហើយក្រោយមក កូនប្រសារទី៣របស់ តា ម៉ុក ឈ្មោះ សឿន។នឹងឡើងជាលេខាស្រុក ។

ភាព ៖ កូនប្រសារ តា ម៉ុក?

បូលី ៖ បាទ! កូនប្រសារ ។

ភាព ៖ ប្ដីអ្នកណាគេ បើ តា ម៉ុក?

បូលី ៖ ខ្ញុំអត់ដឹងប្ដីអ្នកណា ដឹងថាឈ្មោះ សឿន ។

ភាព ៖ ចេះតែថា បើ តា ម៉ុក កូនប៉ុន្មាន ។

បូលី ៖ តា ម៉ុក កូន៤ ស្រីទាំង៤ ។

ភាព ៖ ចា៎! ហើយបងខ្ញុំនោះ ប្រពន្ធ តា មុត ហើយបងនេះប្រពន្ធ តាវ៉ែន ហើយមួយនោះប្រពន្ធ ពូ សាវ៉ាន ។

បូលី ៖ ឥឡូវចាំមើលខ្ញុំរាល់ទី១មីងខ្ញុំ គូជាមួយ តា មុត?

ភាព ៖ ចា៎!

បូលី ៖ មាស មុត ទី២ឈ្មោះអីគេ?

ភាព ៖ នែក! បងគ្រូ ប្រពន្ធ តារ៉ែន នោះ ។

បូលី ៖ អីរ៉ែន ត្រកូលគាត់?

ភាព ៖ មិនដឹងអីរ៉ែនទេ ភ្លេចហើយ ។

បូលី ៖ ដល់ទី៣ ហ៊ាញ?

ភាព ៖ បង ហ៊ាញ ប្រពន្ធ ពូបូរាណ នោះដឹង វាភ្លេចអស់ហើយខ្ញុំ ។

បូលី ៖ បូរាណ នឹងដែលឡើងជាលេខាភូមិភាគនិរតី បន្ទាប់ពី តា ម៉ុក មកកាន់នៅពាយ័ព្យនឹង?

ភាព ៖ ចា៎ៗ

បូលី ៖ ដល់ទី៤?

ភាព ៖ ទី៤ មិនដឹងអ្នកណាទេ ភ្លេចឈ្មោះអស់ ព្រោះខ្ញុំចេញមកដាច់ពី តា យូរហើយ ។

បូលី ៖ មានម្នាក់ដែលថាមានបញ្ហាខួរក្បាលនឹង ខមាទោសកូន តា ម៉ុក ពីណាគេ?

ភាព ៖ មាន តែខ្ញុំនឹងប៉ុនធ្វើទុក្ខ ។

បូលី ៖ ទេ! ខ្ញុំ នឹងស្លាប់យូរហើយតើ?

ភាព ៖ អឺ! មកពីរោងសរសៃប្រសាទអីដែង ។

បូលី ៖ តាំងពី៧០ជាងមកខ្ញុំ?

ភាព ៖ ចា៎! ខ្ញុំ គាត់កើតរោគចឹងយូរហើយតើ ។

បូលី ៖ ពុកគេថានៅអន្លង់វែងមានមួយទៀត?

ភាព ៖ គ្មានអ្នកណាទេ ។

បូលី ៖ ដែលមានបញ្ហាខួរក្បាលដែរ? បើអត់រកវិញឃើញនឹងភ្នែក បើរក?

ភាព ៖ ខ្ញុំអ្នកណាទេ ។

បូលី ៖ នេះឈ្មោះ ខ្ញុំ, ឈ្មោះ អ៊ូ! ៥នោះ មានច្រិចមួយទៀត ។

ភាព ៖ ច្រិច ពៅគេ ។

បូលី ៖ ច្រិច ពៅគេ?

ភាព ៖ ចា៎! ប្រពន្ធអាគី ខ្ញុំរាប់ឃើញតែ៤ ។

បូលី ៖ ច្រិចនឹង ប្រពន្ធពីណាគេ?

ភាព ៖ ប្រពន្ធ តា កី ប្ដីគេឈ្មោះ កី ។

បូលី ៖ អីគេ កី?

ភាព ៖ មិនដឹងស្អីកីទេ ជនជាតិ ។

បូលី ៖ កី នឹងជនជាតិ?

ភាព ៖ ចាស៎!

បូលី ៖ ជនជាតិអីគេ គ្រឹង ទំពួន ព្នង?

ភាព ៖ ដូចជនជាតិអីទេ នៅជាមួយខ្ញុំតាំងពីក្មេង ។

បូលី ៖ ហ្នឹង តា កី នឹងគាត់កាន់អីដែរ?

ភាព ៖ ខ្ញុំដល់ពួកខ្ញុំធំៗឡើង ខ្ញុំអត់បាននៅជាមួយទេ ខ្ញុំដាច់ឆ្ងាយពីគាត់ក្ដាប់អត់បានទេ ព្រោះនិយាយរួម តា ហើយនឹងខ្ញុំដាច់ពីគ្នាយូរណាស់ តាំងពីជ័យជំនះភ្នំពេញមក តាជូនមកដល់ត្រឹមចោមចៅ បែកគ្នារហូត ។ ទើបមកជួបនៅ អន្លង់វែងនឹង ។ ហើយអន្លង់វែងនឹងឆ្ងាយទៀត ខ្ញុំនៅទំនប់ដាច់ គាត់នៅអន្លង់វែង ឆ្ងាយគ្នា ក្ដាប់ជីវប្រវត្តិកូនចៅអត់បានទេ ។

បូលី ៖ ដឹងថា ខ្ញុំ នឹង បងគេ?

ភាព ៖ ចា៎!

បូលី ៖ បន្ទាប់គ្រូទី២?

ភាព ៖ ដឹងគ្រូ ហើយខ្ញុំទេ ខ្ញុំថាខ្ញុំឯងបងគេ ។

បូលី ៖ ចុះ ហ៊ាញ ទី៣?

ភាព ៖ ទី៣ ។

បូលី ៖ មានមួយទៀតឈ្មោះ ហូ?

ភាព ៖ អ៊ូ! ហូ ខ្ញុំភ្លេច ។

បូលី ៖ ហូ ទី៤?

ភាព ៖ មិនដឹងហូទី៤ ណាទី៤ទេ បើមើលទៅប៉ុនៗគ្នា ខ្ញុំមិនសូវបានសួរនាំប្រវត្តិផង ។

បូលី ៖ មួយទៀតឈ្មោះ នឹម ដែលព្ទទេ?

ភាព ៖ នឹម ដូចអត់ដែលព្ទ ។

បូលី ៖ មានតែ ខ្ញុំ, គ្រូ, ហ៊ាញ, ហូ, ច្រិច?

ភាព ៖ ចា៎! អត់ដែលព្ទសួរ នឹម ទេ ។

បូលី ៖ ប៉ុនគ្រឡប់មកវិញ អត់មានឈ្មោះ សឿន ទេ កូនប្រសារ តា ម៉ុក?

ភាព ៖ មិនដឹងមួយណា ប្ដី ហូ ហើយប្ដីណា ។

បូលី ៖ ចឹងអាចប្ដីហូ សឿន នឹង?

ភាព ៖ ព្រោះខ្ញុំអត់សួរដឹងដែរ ។

បូលី ៖ សឿន នឹងឡើងជាលេខាស្រុកទ្រាំង ស្រុក១០៧?

ភាព ៖ គេរៀបចំនឹង ខ្ញុំចេញផុតមកអស់ហើយ ព្រោះខ្ញុំមិននៅកងទ័ពអត់សួរដឹងទេ ខាងមូលដ្ឋាន ព្រោះខ្ញុំចូលទ័ពតាំងពី៧២ ខែ៦មកនោះ ។ បើចឹងអត់ដឹងប្រវត្តិអ្នកខាងក្រោយទេ ។

បូលី ៖ ប៉ុន្តខ្ញុំសាកសួរមីងលេង ក្រែងរលមីងឮ ឬចាំអី?

ភាព ៖ ចា៎!

បូលី ៖ នៅអន្លុងវែងឬ អន្គរជ័យនេះ ពី៧០មក មានតា និន និង តា ប៉ាល់?

ភាព ៖ ចា៎!

បូលី ៖ តា ប៉ាល់ មីងអាចថាប្រហែល ទោះបីថាមិនច្បាស់ យើងច្បាស់ តា និន មួយដែរ?

ភាព ៖ ចា៎! តា និន ។

បូលី ៖ បន្ទាប់មក គាត់កាន់ពីឆ្នាំណាដល់ឆ្នាំណា មីងមើលទៅអាចចាំទេ?

ភាព ៖ និន ដូចបានតែ២ឆ្នាំ ដូចបានតែត្រឹម៧០ មក៧១នឹងក៏កាលនោះមិនដឹងគាត់បាត់ខ្លួនដោយសារអី ឮថាគេចាប់គេអីម៉េចទេ ពាក់ព័ន្ធជាមួយវៀតណាមអីម៉េច ក៏គេចាប់បាត់ទៅ ក្រោយមកបានដឹកនាំស្រុកនឹង បានបង បូ ដែលស្រ្តីនេះ ។

បូលី ៖ បូ ហៅ ចាន់ មែន?

ភាព ៖ មិនដឹងស្អីបូ ភ្លេចឈ្មោះបាត់ហើយ ។

បូលី ៖ មីងដែលឮឈ្មោះ តា យ៉ន?

ភាព ៖ តា យ៉ន នឹងក្រោយដឹង ក្រោយពីបងបូគាត់ចេញមកកងទ័ព ព្រោះបងបូចាំមើលដល់ពេល៧២ ដែលវ៉ៃ តានីបែកហើយ គាត់នាំនារីកាលធៀវគី ដាក់នៅតានីច្រើន គាត់នាំនារីៗយកមកបង្កើតនៅមន្ទីរនៅម្តុំតាអាំ គេហៅមន្ទីរ១៥០ៗនឹង ទទួលបន្ទុកផ្នែកនារីនឹងតែម្តងដល់ខែ៦ ៧២នឹង ចាប់រៀបចំកងទ័ពនារី បំបែកទៅនិរសានោះមួយផ្នែក ពេទ្យនោះមួយផ្នែក កងទ័ពនឹងមួយផ្នែក ហើយនៅមន្ទីរនឹងនៅសល់ខ្លះ ។

បូលី ៖ មន្ទីរ១៥០នឹង?

ភាព ៖ ចា៎!

បូលី ៖ បំបែកទៅជា?

ភាព ៖ ជា៤ ។

បូលី ៖ កងទ័ពជង?

ភាព ៖ និរសាជង ពេទ្យជង ។

បូលី ៖ ពេទ្យ និរសា ហើយ?

ភាព ៖ នារីមន្ទីរ ។

បូលី ៖ ហើយនៅមន្ទីរ?

ភាព ៖ នៅសល់មន្ទីរខ្លះ ។

បូលី ៖ ហ្នឹងមន្ទីររបស់នារី?

ភាព ៖ ចា៎! មន្ទីរនារីតំបន់នៅនឹងគ្រប់គ្រងនៅនឹង ។

បូលី ៖ ចឹងមីង បូ នឹងប្រធានមន្ទីរនារីតំបន់?

ភាព ៖ ប្រធានមន្ទីរ១៥០មួយរយៈ ប្រហែលកន្លះឆ្នាំៗចុះ ។

បូលី ៖ ឆ្នាំ៧០ប៉ុន្មាន?

ភាព ៖ ៧២ ដល់ខែ៦នឹងយើងចាប់បំបែកកម្លាំងនឹង គាត់មកដឹកនាំកងទ័ពតែម្តង ប្រធានកាលនឹងនារីទើបរៀបបានមួយអនុសេនាធំទេ ហើយគាត់អ្នកស្នងការនយោបាយខាងកងទ័ពតែម្តង ។

បូលី ៖ ចឹងគាត់លេខាកងទ័ពតែម្តង?

ភាព ៖ ចា៎! គាត់ប្រធានតែម្តង ។

បូលី ៖ ប្រធានកងទ័ពនារី?

ភាព ៖ ចា៎!

បូលី ៖ គេហៅអីគេ?

ភាព ៖ អនុសេនាធំ ។

បូលី ៖ លេខប៉ុន្មានដែរ?

ភាព ៖ ២១ កើតដំបូងហើយខេត្តតាកែវ មាននារីមួយកង ។

បូលី ៖ មានតែប៉ុននឹងទេ នារីមួយកង?

ភាព ៖ ចា៎! កើត៧២ ។ ដល់ចុង៧២ បានពង្រីកទៀត ។

បូលី ៖ ចឹងដំបូងបំផុតថាឆ្នាំ៧២នឹង មាននារីតែមួយកងនឹងគត់ អនុសេនាធំ?

ភាព ៖ ចា៎! ចូលទៅសុទ្ធតែហាត់ រៀនបានមួយខែ ហាត់បច្ចេកទេសយោធា ។

បូលី ៖ ហ្នឹងជាកងទ័ពតំបន់?

ភាព ៖ ចាំ! ហាត់នឹងកន្លែងយុវជនខេត្តនឹង គេហៅថាមន្ទីរ១៦០ ។

បូលី ៖ យុវជនខេត្ត?

ភាព ៖ ហ្នឹងហើយ ។

បូលី ៖ យុវជនតំបន់?

ភាព ៖ តំបន់ ។

បូលី ៖ ចឹង១៥០ មន្ទីររបស់នារីតំបន់?

ភាព ៖ ចាំ!

បូលី ៖ ១៦០មន្ទីររបស់យុវជនតំបន់?

ភាព ៖ ចាំ!

បូលី ៖ មន្ទីរយុវជនតំបន់ នឹងយើងនិយាយពីតំបន់១៣?

ភាព ៖ ចាំ!

បូលី ៖ បង្កើតនៅឆ្នាំណាដែរ មន្ទីរយុវជនតំបន់?

ភាព ៖ មន្ទីរយុវជនតំបន់នឹង ដឹងបង្កើតពីអង្កាល់ តែខ្ញុំចេញមកហាត់ផ្នែកកងទ័ពនឹង គេបញ្ជូនទៅហាត់នៅមន្ទីរនឹងម៉ង ។

បូលី ៖ ទាំងស្រីទាំងប្រុស គឺហាត់នៅមន្ទីរនឹងទាំងអស់គ្នា?

ភាព ៖ ចាំ! នៅមន្ទីរនឹង ។

បូលី ៖ អ្នកណាគេជាប្រធានមន្ទីរ១០៦នឹង?

ភាព ៖ ឈ្មោះ បង ជឿន តែគាត់ស្លាប់បាត់ហើយ ។

បូលី ៖ ជឿន?

ភាព ៖ ចាំ! មិនដឹងស្អី ភ្លេចឈ្មោះគាត់ អ្នកភូមិជាមួយខ្ញុំដែរ ។

បូលី ៖ អ្នកអន្លុងវែងដែរ?

ភាព ៖ ចាំ! នៅភូមិព្រៃឈើទាលដូចគ្នា គាត់ស្លាប់បាត់ហើយ ។

បូលី ៖ គាត់ស្លាប់ឆ្នាំប៉ុន្មានដែរ?

ភាព ៖ អត់ដឹងស្លាប់ឆ្នាំប៉ុន្មាន ខ្ញុំមិនបានសួរ ទៅលេងផ្ទះទៅសួររកបានដឹងថាគាត់ស្លាប់បាត់ហើយ គាត់ស្លាប់នឹង គាត់ធ្វើកងទ័ពធ្វើអីដែរនឹង ដឹងស្លាប់ពីអង្កាល់ គាត់ចុះឈប់មកនៅមន្ទីរមក គេឲ្យមកដឹកនាំនៅ ដូចនៅឃុំ ហើយនៅស្រុកទេ កាលនឹងនៅនឹងអន្លុងវែងនឹងដែរ ។ ហើយក្រោយមកគាត់ចូលកងទ័ព ស្លាប់នៅទ័ព ។

បូលី ៖ ស្លាប់នឹងទ័ព?

ភាព ៖ ចាំ! ព្រោះយើងចេញផុតមក មានដឹងគេផ្លាស់ខាងមូលដ្ឋានរបៀបម៉េច អត់ដឹងទេ ព្រោះយើងគិតតែសមរភូមិ អត់មានគិតអ្នកក្រោយ ។

បូលី ៖ ចឹងខ្ញុំសរុបមកវិញ យើងគិតពីស្រុកអន្តរជ័យមុន សរុបមកវិញទី១គឺ តានិន តាប៉ាល់ ពី៧០មកថាប្រហែលជា៧២ ឬក៏៧១ មីងមើលទៅ?

ភាព ៖ ៧១ ៧២ណាគេចាប់ អ៊ីប៉ាល់នឹង ដាក់កន្លែងមន្ទីរ២០៨ហើយ មន្ទីរសមាសភាព ។

បូលី ៖ មន្ទីរ២០៨?

ភាព ៖ ចាំ! ថាគាត់ជាប់និន្នាការតាំងពីជាមួយ បង និន នឹងមក ។

បូលី ៖ ចឹង និន និង ប៉ាល់ ចាប់ជាមួយគ្នា?

ភាព ៖ ហ៊ាំ! បង និន នឹងចាប់តាំងពីដើម៧១ម៉េះ បានប៉ុន្នាន ពាក់ព័ន្ធគេចាប់បាត់ទៅ ។ ដល់ប៉ាល់នេះ មក៧២គេចាប់ដាក់មន្ទីរអប់រំ គេហៅមន្ទីរ២០៨នោះ ។

បូលី ៖ មន្ទីរ២០៨នៅម្តុំណាដែរ?

ភាព ៖ ខាងលិចត្រពាំងអណ្តើកផ្លូវទៅតាអាំដែរ ជាប់គ្នានឹងមន្ទីរ១៥០នឹងដែរ ខុសត្រូវគ្នាប្រហែល ២០០-៣០០ម៉ែត្រ ។

បូលី ៖ បើគិតពីភូមិនៅភូមិណា ឬក៏ឃុំក៏បានដែរ?

ភាព ៖ ឃុំស្រង៉ែ ខាងលិចបឹងសាវ៉ាយ ព្រំប្រទល់កំពង់ស្ពឺនឹងនោះ ។

បូលី ៖ កំពង់ស្ពឺជាមួយ តាកែវ?

ភាព ៖ ជាមួយតាកែវ ម្ខាងអូរម្នាក់ ផ្លូវគេឡើងទៅតាកែវទៅ ។

បូលី ៖ ចុះមន្ទីរ១៦០ នៅណាវិញ នៅឃុំអីវិញ?

ភាព ៖ មន្ទីរ១៦០នៅក្នុងឃុំអីទេ ព្រោះដំណើរដើរមកកន្លែងមន្ទីរនឹងយប់ អាចេញទៅវិញក៏យប់ដែរពិបាកណាស់ គេជំនាន់នោះគេលាក់ការណ៍ មិនសូវឲ្យដឹងច្រើនកន្លែងគេ បើយើងចូលទៅហាត់ថ្ងៃរសៀល បានថាយើងត្រូវចេញទៅកន្លែងនេះចឹង ល្ងាចដើរទៅដល់កន្លែងនឹងគឺយប់ ព្រលប់ៗចេញផុតពីនោះមក ចូលដល់កន្លែងនឹងយប់ ពេលហាត់ហើយយើងចុះទៅសមរភូមិ ចេញដំណើរយប់ ។

បូលី ៖ មន្ទីរ២០៨នេះ អ្នកណាគេជាប្រធានមន្ទីរ?

ភាព ៖ អត់ដឹង ព្រោះខ្ញុំអត់ដែលចូល អត់ដឹង ។

បូលី ៖ អត់ស្គាល់ប្រធានមន្ទីរនឹង?

ភាព ៖ អត់ដែរ អត់ស្គាល់ ។

បូលី ៖ ចឹងខ្ញុំសរុបពីរឿងស្រុកអន្លង់វែងវាចេះតែបែក ពីព្រោះរឿងរ៉ាវច្រើន ហើយខ្ញុំអរគុណមីង ដែលបានជម្រាប ។ បន្ទាប់ពី តានិន តាប៉ាល់ ឥឡូវយើងថា៧០-៧១ចុះ?

ភាព ៖ ចាំ!

បូលី ៖ គណៈតំបន់ទោះបី តា និន គេចាប់មុន តា ប៉ាល់?

ភាព ៖ នែក! តា និន ចាប់មុន ហើយកាលនោះដល់ហើយគេប្តូរ តា ប៉ាល់ នឹងទៅនៅខាងស្រុក ត្រាំងមួយរយៈដែរ មុននឹងចាប់នឹង ។ ទៅនៅស្រុកត្រាំងមួយរយៈតើ បានគេចាប់មកខាង តា ប៉ាល់ តា គៀត អីនឹង ។

បូលី ៖ តា ប៉ាល់ ទៅកាន់ស្រុកត្រាំងមួយរយៈ?

ភាព ៖ ចាំ!

បូលី ៖ ជាលេខាស្រុកហ្នឹង?

ភាព ៖ អត់ដឹងគាត់ទៅខាងអី ប៉ុនគេថាប្តូរ ទំនប់ព្រោះអស់ពី តា និន ទៅ គេប្រគល់ការងារឲ្យខាង បង ប៊ូ នេះ ហើយណាទេ ប្រុសនេះ ប្រធានខ្ញុំមិនស្គាល់គេដែរ ។

បូលី ៖ ប៊ូ ដែលប្រធានកងទ័ពនារីនឹង?

ភាព ៖ ចាំ!

បូលី ៖ យាយ ប៊ូ ល្បីឈ្មោះ ព្រោះគាត់ក្លាហាន?

ភាព ៖ ចាំ! គាត់ចេញពីកងទ័ពទៅ ឈប់ពីកងទ័ពទៅនៅអភិបាលស្រុកគិរីវង្សមួយរយៈទៀត ។

បូលី ៖ ចឹងដំបូងគាត់នៅកាន់ស្រុកអន្លង់វែងសិន?

ភាព ៖ ចាំ!

បូលី ៖ ពីឆ្នាំណាដល់ឆ្នាំណាមីងអាចចាំទេមើលទៅ?

ភាព ៖ ពី៧១ដល់៧២នឹងឯង ពាក់កណ្តាល៧២ គាត់ចេញមកកងទ័ពជាមួយពួកខ្ញុំហើយ ។

បូលី ៖ ពាក់កណ្តាល ហើយមីងថាគាត់ទៅកាន់ស្រុកអីមិញ មួយរយៈគិរីវង្ស?

ភាព ៖ គិរីវង្ស អានឹងចេញពីកងទ័ពហើយ ។ ៧២នឹង គាត់មកនៅរយៈពេលតែប៉ុន្មានខែ មិនដល់ កន្លះឆ្នាំស្រួលដង ដែលខាង តា សោម តំបន់នេះ គាត់ថា បងប៊ូ គាត់ចាស់ហើយ មិនឲ្យ ទៅនៅសមរភូមិអីចឹង ។ មិនបាច់ឲ្យដឹកនាំនារីសមរភូមិ ឲ្យដឹកនាំមូលដ្ឋាន ហើយក៏ដកគាត់ មក ។

បូលី ៖ មកគិរីវង្សនេះ?

ភាព ៖ នៅខាងគិរីវង្ស ។

បូលី ៖ ចឹងគាត់ធ្វើចូលកងទ័ពនឹង បានប្រហែលរយៈពេលប៉ុន្មាន?

ភាព ៖ រយៈពេលតិចទេ ហៅថាមិនដល់កន្លះឆ្នាំផង ៣-៤ខែ គាត់គ្រាន់នាំហាត់ហើយចុះទៅមើលវៃនៅកំពង់ជ្រៃមួយសារ ហើយនឹងនៅអង្គតាសោមមួយសារ បានតែ២សារនឹង ។ គេដកគាត់ចេញមកវិញ ទោះបីគាត់ទៅកងទ័ព ក៏គាត់មិនដែលបានទៅសមរភូមិ គាត់គ្រាន់រៀបចំកូនចៅទៅវិញ ។

បូលី ៖ ចូលកងទ័ពនឹង ចង់និយាយថា ចូលកងពលណា?

ភាព ៖ នៅកាលនោះនៅវរៈគេហៅវរសេនាតូចត-៣ តំបន់គេហៅត១ ។

បូលី ៖ ត-៣?

ភាព ៖ ចាំ! នៅប្រធានវរៈនឹងឈ្មោះ ម៉េង តែគាត់ស្លាប់បាត់ហើយ ។

បូលី ៖ ក្នុងតំបន់១៣នឹង មានប៉ុន្មានវរសេនាតូចដែរ?

ភាព ៖ មើល កាលខ្ញុំនៅមានប៉ុន្មានទេ ចង់ភ្លេចអស់ហើយ ត-៣ ត-៤ ត-៦ ដូចតែមាន៤វរៈទេ ត-៣, ត-៤, ត-៥, ត-៦ គេដាក់ត១ភ្នាចឹងម៉ង ។

បូលី ៖ ចឹងពេលនឹង អត់ទាន់មានកងពលទេ?

ភាព ៖ ចាំ! មានតែវរសេនាតូច១ ។

បូលី ៖ ព្រោះយើងមិនទាន់មានកម្លាំងគ្រប់គ្រាន់?

ភាព ៖ ចាំ!

បូលី ៖ យើងនៅត្រឹមវរសេនាតូចសិន?

ភាព ៖ ចាំ!

បូលី ៖ ត-៣, ត-៤, ត-៥, ត-៦ចឹងទៅ?

ភាព ៖ ចាំ! មួយវរៈ១នឹង៣អនុសេនាធំនឹង មានអីច្រើន កាលនោះកងទ័ពទើបបានតិច បើយើងជ្រើសរើសពង្រឹកមកពីតំបន់ខ្លះ ទ័ពស្រុក ។

បូលី ៖ ហ្នឹងនិយាយតែតំបន់១៣តែមួយ?

ភាព ៖ ចាំ! និយាយតែតំបន់១៣ ។

បូលី ៖ មិនមែនភូមិភាគនិរតីទាំងមូល?

ភាព ៖ អត់ទេ១ ។

បូលី ៖ ភូមិភាគទាំងមូលអាចច្រើន?

ភាព ៖ ច្រើនៗដល់ឡើងភូមិភាគគេសុទ្ធតែកង១០០ជាងហើយ ។

បូលី ៖ សុទ្ធតែចូលអានឹងកងពល?

ភាព ៖ ចាំ!

បូលី ៖ នៅខ្ញុំសុំបកទៅអន្លង់វែងតិចសិន ដើម្បីកុំឲ្យភ្លេច។ ចឹងបន្ទាប់ពី តា និន តា ប៉ាល់ មក យាយ បូ?

ភាព ៖ ចាំ!

បូលី ៖ ប្រធានលេខាស្រុកអន្លង់វែងហ្នឹង បន្ទាប់មកពីណា តា យ៉ន តាមមើល?

ភាព ៖ ចាំ! តា យ៉ន នឹង តាំងពីជាមួយបងបូ ប៉ុន២នាក់នឹង មិនដឹងអ្នកណាប្រធាន ។ តាំងពីជាមួយគ្នានោះ ។

បូលី ៖ គាត់មកកាន់?

ភាព ៖ កាន់ក្រោយពី ដុត ពី តា និន ទៅនោះ ។

បូលី ៖ ដុតពី តា និន ទៅ?

ភាព ៖ ចាំ! បើយើងរស់នៅជាមួយនារី យើងអត់បានដឹង ដូចយើងឥឡូវយើងចេះគិតទេ យើងចង់និយាយថា ជំនាន់នោះអ្នកណាដឹកនាំយើងៗទៅតាមតែអ្នកនឹង អត់បានគិតពីរឿងអ្នកណាប្រធាន អ្នកណាអនុអីទេណា ចង់និយាយចឹង ។ មិនមែនដូចឥឡូវថាវាស្គាល់ណាមេណាវងអីណាច្បាស់លាស់ ។

បូលី ៖ ចឹងបន្ទាប់ពី តា និន, តា ប៉ាល់ ទៅ តា យ៉ន, យាយ បូ នឹងឯង?

ភាព ៖ ចាំ!

បូលី ៖ យាយ បូ មកកាន់ស្រុកគិរីវង្ស ពីឆ្នាំ៧២ដល់ឆ្នាំប៉ុន្មានដែរ?

ភាព ៖ អត់ដឹង ព្រោះអីខ្ញុំនៅសមរភូមិ ខ្ញុំឮតាមមិត្តភ័ក្តគេដែលមកលេងស្រុកមកអីនឹង មកជួបនឹងគាត់ៗ គេវិលទៅសមរភូមិវិញ គេប្រាប់ថាជួបម៉ែ បូ ឥឡូវគាត់នៅធ្វើការខាងស្រុកគិរីវង្សថាចឹង គេប្រាប់តែចឹងទេ រឿងគាត់ចេញពីឆ្នាំណា ពីនឹងទៀតទៅ ខ្ញុំអត់ដឹងដែរ ព្រោះបែកគ្នារហូត តាំងពីគាត់ចេញកងទ័ពមកបែករហូតទាល់តែគាត់ស្លាប់ មិនដែលឃើញគាត់មិនដែលឃើញគាត់ ។

បូលី ៖ បន្ទាប់ពី តា យ៉ន មកពីណាគេ លេខា?

ភាព ៖ អ្ហូ! អត់បានដឹងទេ ព្រោះអីនិយាយរួមខ្ញុំចូលកងទ័ពតាំងពី៧២នោះ ម៉េចដឹង ។

បូលី ៖ អ្ហូ! មីងចូលតាំងពី៧២មកហើយ?

ភាព ៖ ចា៎!

បូលី ៖ នៅ គ ប៉ុន្មានកាលនឹង ចូល?

ភាព ៖ នៅគ-៨ ។

បូលី ៖ អូ៎! មានដល់គ-៨ទៀត?

ភាព ៖ គ-៨នឹងរៀបៗក្រោយមកដើមឆ្នាំ៧៣នឹង រៀបនារីបានមួយវរសេនាតូច ។

បូលី ៖ ចឹងមាន៥ គ-៣, គ-៤, គ-៥, គ-៦, គ-៨?

ភាព ៖ ចា៎!

បូលី ៖ អត់មាន គ-៧?

ភាព ៖ មាន ។

បូលី ៖ មានដែរ?

ភាព ៖ មាន គ-៧នឹងពួកខាងកើតតាកែវ គេឈរជើងនៅនឹង ។

បូលី ៖ ប៉ុននៅក្នុងតំបន់១៣ដដែល?

ភាព ៖ ចា៎!

បូលី ៖ ចឹងវាឡើង១ ២ ៣ ៤ ៥ ៦ វរសេនាតូច?

ភាព ៖ ៦វរសេនាតូច ។

បូលី ៖ នៅក្នុងចំណោម៦វរសេនាតូចនឹង គ-៨នឹង គឺជានារីសុទ្ធ?

ភាព ៖ ចា៎!

បូលី ៖ អត់មានបុរស?

ភាព ៖ នារីសុទ្ធ ។

បូលី ៖ ពីណាគេប្រធានគ-៨នឹង?

ភាព ៖ នែក! ពីមុននោះ បងរី ឈ្មោះអី រីទេ ខ្ញុំភ្លេចបាត់ទៀតហើយ ហ្នឹងអស់ពីបងបូទៅ គាត់ផ្តល់ឲ្យ បង រី នឹងអ្នកគ្រប់ជាអនុសេនាធំជាមួយ បង ផល ។ ដល់ក្រោយមករៀបចំវរៈទៅបាន បង រី នឹងគាត់ឡើងវរៈ ។

បូលី ៖ ចឹង រី នឹងវរៈតាំងពីដើមមកម៉ង?

ភាព ៖ ចា៎!

បូលី ៖ គ្រាប់ថាពីមុននៅជាអនុសេនាធំនោះ គាត់ជាអនុរបស់ យាយ បូ?

ភាព : ចា៎! តែក្រោយមកគេដកគាត់ជាប់និន្នាការ ដកគាត់ឆ្នាំ៧៣ ។ ជាប់និន្នាការហើយ បានដក គាត់ចេញ បាននៅ បង ផល ។ ក្រោយមក ដកគាត់នឹងគេយកឲ្យ បង ឃីម នោះ ។

បូលី : ឃីម ឡើងជាប្រធានត-៨នឹង?

ភាព : ចា៎!

បូលី : ចុះ ផល?

ភាព : បង ផល នៅអនុសេនាធំ ។ បង ឃីម នឹងវរៈ ។

បូលី : អត់ជាអនុរបស់ បង ឃីមនឹង?

ភាព : អត់ទេ ។

បូលី : ចឹងបន្ទាប់ពី រី មក ឃីម?

ភាព : ចា៎!

បូលី : រី នឹងគេចាប់ ឬគេគ្រាន់តែដក?

ភាព : ដក ឲ្យទៅនៅសហករណ៍ខាងក្រោយ ។

បូលី : នៅជាប្រជាជនសាមញ្ញ?

ភាព : ចា៎! គេយកទៅដាក់មន្ទីរនៅណាទេ ខ្ញុំមិនដឹងដែរ គេដកៗ ។

បូលី : ឃីម ឡើងជាប្រធាន?

ភាព : ចា៎!

បូលី : ឃីម គាត់ប្រធានរហូតមកចឹង?

ភាព : អត់ទេ បង ឃីម ដល់ចុង៧៣នឹង គាត់ផ្លាស់ពីនឹងមក គាត់មកនៅភូមិភាគ គាត់ឡើងមក នៅកងពលទី២ នៅទួលគី-ចោមចៅនេះ ។

បូលី : ចុង៧៣ ឃីម មកកាន់ជាអី?

ភាព : បង ឃីម គាត់មកកាន់ ។

បូលី : អនុកងពល?

ភាព : វរសេនាធំដឹង ឃីម នោះមិនដឹងវរសេនាធំ-វរសេនាតូចទេ គាត់ឡើងមកភូមិភាគ ។

បូលី : ចាំមកកាន់ មកធ្វើការនៅកងពល២?

ភាព : ចា៎! កងពលទី២ ភូមិភាគ កាលនឹង កាល៧៣នឹង គេរៀបចំកងពលហើយតើ បងសឿន នោះ គាត់ប្រធានកងពលនៅតាកែវហើយ ។

បូលី : សឿន?

ភាព ៖ គេហៅ សឿន រថក្រោះៗ ដល់នេះគាត់ឡើងមកជាមួយ បង ឃីម នឹងមកនៅភូមិភាគ១ ២គេនោះ ។

បូលី ៖ បន្ទាប់ពី ឃីម ឡើងមកកងពលទី២ ពីណាគេកាន់វរៈ?

ភាព ៖ បង ខា ។

បូលី ៖ ខា ប្រធានត-៨?

ភាព ៖ ចា៎!

បូលី ៖ មានអ្នកណាបន្ទាប់ពី ខា ទេ ឬ ខា នឹងចុងក្រោយ?

ភាព ៖ បង ខា នឹងមកបែកក្នាជ័យជំនះ៧៥-៧៦នេះ គាត់បានប្ដីនៅកងរថក្រោះទៅ គាត់នៅជាមួយប្ដីគាត់នៅភ្នំពេញ ។

បូលី ៖ ចឹងគាត់ប្រធានត-៨នឹងរហូតដល់បែក៧៥?

ភាព ៖ ចា៎!

បូលី ៖ ចឹងខ្ញុំសរុបឲ្យមីងពិនិត្យមើលម្ដងទៀត រី ប្រធានត-៨ បន្ទាប់មក រី នឹងជាអនុរបស់យាយ បូ កាលដែលនៅអនុសេនាធំនារី ។

ភាព ៖ ចា៎!

បូលី ៖ ហើយ រី គេដកចេញឆ្នាំ៧៣ ឲ្យមកនៅសហករណ៍ធម្មតា បន្ទាប់មកបាន បង ឃីម ឡើងជាប្រធាន ហើយនៅចុង៧៣ ឃីម នឹងមកធ្វើការនៅកងពលទី២ មិនដឹងថា វរៈ ឬក៏អីទេ

ភាព ៖ អត់ដឹង ។

បូលី ៖ របស់ភូមិភាគនិរតីនឹង ខា ឡើងប្រធានត-៨រហូតដល់បែកឆ្នាំ៧៥ បែកភ្នំពេញ អានឹងនិយាយពីប្រវត្តិត-៨មួយមក ។

ភាព ៖ ចា៎!

បូលី ៖ ឥឡូវខ្ញុំបកទៅអង្គរជ័យ មួយតិចទៀត កុំឲ្យភ្លេច ។ អង្គរជ័យពីដំបូងមាន តា និន ហើយនឹង តាប៉ាល់ បន្ទាប់ពី តា និន, តា ប៉ាល់ហើយ ។ បាន តា យ៉ន, យាយ បូ?

ភាព ៖ តា យ៉ន, យាយ បូ ចា៎! ក្រៅពីនឹងមកអត់ដឹងទេ ព្រោះខ្ញុំដាច់ ។

បូលី ៖ ទី៣នេះ បន្ទាប់ឲ្យពី យាយ បូ មកកាន់គិរីវង្សនេះ ខ្ញុំគិតថាប្រហែល តា ញៀមៗ ប្ដីរបស់យាយថែមនេះ អាចទេ?

ភាព ៖ អាច តា ញៀម ចូលមកក្រោយ ។

បូលី ៖ តា ញៀម ប្ដីយាយថែមនេះ គាត់កាន់ពី៧៣រហូតដល់៧៧

ភាព ៖ ប្រហែលហើយចឹងនោះ ។

បូលី ៖ ប៉ុនពេលនឹងមីងអត់នៅទេ?

ភាព ៖ អត់នៅទេ ខ្ញុំអត់នៅទេ កាលនោះក្រោយជ័យជំនះទៅ យាយ ថែម គាត់នៅគណៈតំបន់ ១៣នឹង តា ញ៉ែម នឹងអាច ។

បូលី ៖ បន្ទាប់ពី៧៧មក បានយាយ រ៉ាន់ លេខាទ័ព ។

ភាព ៖ បង រ៉ាន់ ណា?

បូលី ៖ រ៉ាន់ យើងនៅ?

ភាព ៖ នៅត្រពាំងតាវ នៅស្វែងពណ៌ ។

បូលី ៖ អាចអីរ៉ាន់ គាត់ត្រកូល?

ភាព ៖ មិនដឹងណាទេ ។

បូលី ៖ យាយ រ៉ាន់ នឹងគឺលេខាបន្ទាប់ពី តា ញ៉ែម?

ភាព ៖ ចា៎!

បូលី ៖ ហើយចុងក្រោយ ឈ្មោះ ឌឹក លេខាចុងក្រោយស្រុកអង្គរជ័យ?

ភាព ៖ អត់ដែលស្គាល់ទេ ព្រោះខ្ញុំមិនដែលទៅសោះ ខ្ញុំទៅឆ្នាំ២០០១ ។ ចេញតាំង៧១ ចូល ២០០១ ។

បូលី ៖ ចឹង យាយ ថែម គាត់ធ្លាប់ជាគណៈតំបន់១៣នឹងដែរ?

ភាព ៖ ចា៎! កាលពីមុននោះ បង សោម ខ្ញុំដឹង ។ ដឹងតែ៧១ ៧២ ខ្ញុំជួបជាមួយ បង សោម គាត់គណៈតំបន់ គាត់នៅព្រៃតាដុក ផ្ទះគាត់ ។

បូលី ៖ នៅព្រៃតាដុក?

ភាព ៖ ចា៎! ខ្ញុំហើយទៅផ្ទះគាត់ ។

បូលី ៖ ប៉ុន សោម នឹងឈ្មោះពេញឈ្មោះអីគេ មីងដឹង?

ភាព ៖ ដឹតាគាត់ដឹងអីទេ ខ្ញុំស្គាល់តែតាសោម ។

បូលី ៖ សោម នឹងគាត់មានស្រុកកំណើតនៅខាងណាដែរ?

ភាព ៖ អត់ដឹង ខ្ញុំដឹងតែផ្ទះគាត់នៅម្តុំព្រៃតាដុក ឥឡូវមិនដឹងគេហៅភូមិអីវិញ ខ្ញុំមិនដឹងដែរ ។

បូលី ៖ តាដុកចឹងម៉ង?

ភាព ៖ ចា៎! ហ្នឹងឃុំញ៉ែងញ៉ងពីមុន តែឥឡូវដឹងឃុំអី ។

បូលី ៖ ឃុំញ៉ែងញ៉ងដដែរ?

ភាព ៖ បើអត់ដែលដឹង ឥឡូវទៅរកមិនឃើញទេ ប្លែកច្រើនណាស់ ។

បូលី ៖ ស្រុកអីគេ?

ភាព ៖ ស្រុកត្រាំកក់ ។

បូលី ៖ សោម នឹងគាត់លេខាពីដំបូងបំផុត ពី៧០ ?

ភាព ៖ ចា៎!

បូលី ៖ ប៉ុនមីងអាចដឹងថាដល់៧០ប៉ុន្មានទេ មើលទៅ?

ភាព ៖ អត់បានដឹងទេ ប៉ុនដឹងថា កាល៧២-៧៣នឹង នៅពុឈ្មោះគាត់នៅឡើយទេ គណៈតំបន់នោះ បើត្រឹម៧៤-៧៥មិនដឹងម៉េច ព្រោះ៧៥ ខ្ញុំមកភ្នំពេញបាត់ហើយ ។

បូលី ៖ អាចត្រឹម៧៣ ពីព្រោះឆ្នាំ៧៣ មាស មុត គាត់នៅជាអនុលេខាទេ ។ តា មុត នៅអនុរបស់តា សោម?

ភាព ៖ ចា៎!

បូលី ៖ បន្ទាប់មកបានគាត់គេផ្លាស់មកកាន់កងពលទី៣របស់ភូមិភាគ?

ភាព ៖ ចា៎!

បូលី ៖ ហើយ៧៥ បានគាត់ទៅកាន់កំពង់សោមកងទ័ពជើងទឹក?

ភាព ៖ តា មុត ។

បូលី ៖ ប៉ុនកងពលទី៣នឹងឯង ដែលជាកងពល១៦៤ នៅខាងកំពង់សោមកងទ័ពជើងទឹកនឹង?

ភាព ៖ ចា៎!

បូលី ៖ ប៉ុន្តែបន្ទាប់ពីសោមមក ប្រពន្ធរបស់អ៊ំ មុត នឹង?

ភាព ៖ ខ្ញុំ ។

បូលី ៖ ខ្ញុំ នឹងឯងឡើងលេខាតំបន់?

ភាព ៖ អត់សូវដឹង ព្រោះយើងមកបាត់ហើយ មកមិនដែលទៅស្រុកផងបានអីដឹងរឿង ។

បូលី ៖ ប៉ុនគាត់ឡើងនៅឆ្នាំ៧៦ទេ ខ្ញុំ នឹងចឹងចន្លោះពី៧៣មក៧៦ ៣ឆ្នាំនឹងខ្ញុំមិនដែលដឹងថាអ្នកណាគេជាលេខាតំបន់១៣នឹង?

ភាព ៖ ចា៎! អត់ដឹងដែរ ។ ហ្នឹងបើសិនជាបានជួបជាមួយ បង វ៉ាន់, បង ចែម អាចដឹងប្រវត្តិ ។

បូលី ៖ ខ្ញុំធ្លាប់ជួបខាងយាយ ចែម ហើយៗ ។

ភាព ៖ បង វ៉ាន់?

បូលី : តែយាយវ៉ាន់ អត់ទាន់បានជួប ។ ខ្ញុំមិនដឹងដែរ ពីព្រោះគាត់អាចមានការព្រួយបារម្ភពីរឿង តុលាការអីចឹង ។ ដល់ចឹងគាត់អត់ចង់ជួប ប៉ុន្តែពួកខ្ញុំនេះអត់ទាក់ទងជាមួយតុលាការទេ ។ ដូចខ្ញុំជម្រាបមីងចឹង ពួកគាត់អាចមានការព្រួយបារម្ភរឿងតុលាការអីចឹង ។ ដល់ចឹងគាត់អត់ចង់ជួប ប៉ុន្តែពួកខ្ញុំនេះអត់ទាក់ទងនឹងរឿងតុលាការទេ ។ ដូចខ្ញុំជម្រាបមីងចឹង គឺធ្វើតែរឿង ប្រវត្តិសាស្ត្រជាមួយសាលាស្រុក ។ ហើយដូចមីងជម្រាបស្រាប់ បើសិនជាមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋ ពូផាន់ណា មិនឲ្យធ្វើទេ ។

ភាព : ចា៎! អត់ឲ្យធ្វើទេ ព្រោះដឹកបុសដឹកគល់ច្រើនពេក បងថែម គាត់មានពាក់ព័ន្ធណាដល់ ហើយដល់ឲ្យនាំទៅជួបប្រជាជនថា ប្រជាជនស្អប់បងថែមរាយការណ៍ចេះចុះ ដល់ពេលទៅ ជួបប្រជាជនរត់អោបយំផងអីផង កន្លែងនឹងហើយអង្គការនឹងស្រងាកចិត្តដែរ អានឹងរឿង របស់តុលាការផ្សេង ។

បូលី : ពួកខ្ញុំអត់ទាក់ទងទេ ពួកខ្ញុំគិតទៅលើរឿងសរសេរសៀវភៅប្រវត្តិ សាស្ត្រ ហើយបើបាន មីងយល់ ខ្ញុំអរសឹងអី ពីព្រោះបើសិនជាព័ត៌មាននេះអាច២០ឆ្នាំទៀត មិនអាចមានពត៌មាន បាត់សូន្យម៎ង ។

ភាព : ចា៎! ព្រោះវាភ្លេច គិតមើលខ្ញុំរយៈពេលប៉ុននឹង ខ្ញុំភ្លេចអស់ ការពិតវាច្រើនឆ្នាំដែរ ពី៧១ មកដល់យើងឥឡូវ២០១២ ។

បូលី : វា៣២ឆ្នាំ ការចងចាំរបស់មនុស្សវាមិនប្រាកដថានៅមានទេ ។

ភាព : ចឹងបានថាវាភ្លេច ហើយយើងរវល់ការងារច្រើនចឹងទៅ យើងអត់បានចាប់អារម្មណ៍ពីអឌិត កាលនឹងទេ អត់បានគិតទេ ។

បូលី : សូម្បីតែសម័យសតវត្សរ៍ទី១២សម័យអង្គរ គេនៅស្រាវជ្រាវដើម្បីសិក្សា ចុះយើងថ្មីៗ បើសិនជាយើងមិនចាប់ផ្ដើមកត់ទុកទេ វាបាត់ហើយ ។ ចឹងបានជាយើងខំប្រឹងប្រែងកត់ត្រា ទុក ។ ខ្ញុំ នឹងក៏អនុលេខាតំបន់ទេ មិនមែនលេខាតំបន់១៣ទេ ។ ចឹងបន្ទាប់ពី សោម មកខ្ញុំ មិនដឹងថា អ្នកណាគេជាលេខាមក?

ភាព : ៧៥ បងថែម កាលនោះ ។

បូលី : ៧៥?

ភាព : ចា៎! ព្រោះឃើញជ័យជំនះ៧៥ហើយ ឃើញបង ថែម ថតនៅសាលាខេត្តចុះទស្សនាវដ្ដី បង ថែម គណៈតំបន់១៣ ក្រោយពីជ័យជំនះភ្នំពេញរួច ។

បូលី : ចឹង សោម ៧០មក៧៥?

ភាព ៖ ដឹងម៉េចអី ។

បូលី ៖ ហើយបន្ទាប់ពី៧៥មក បានយាយ ចែម គាត់មកការ៉ាន់?

ភាព ៖ ក្រោយពី៧៥ហើយ ឃើញយាយ ចែម ។

បូលី ៖ អត់ច្បាស់ទេ?

ភាព ៖ ព្រោះខ្ញុំនៅរតនគិរី ខ្ញុំនៅតាមទស្សនាវដ្តីដែលគេចុះ ឃើញគាត់ថតមានដើមដូងមួយនៅក្រុង តាកែវដែរ ។

បូលី ៖ គេដាក់ថាម៉េចកាលនឹង?

ភាព ៖ ថាឈ្មោះ អ៊ឹម ចែម គណៈតំបន់១៣ ហើយគេចុះថតអាកន្លែងបង្កបង្កើតផលកន្លែង តា ចាយ ធ្វើនោះ ដាំសណ្តែកដាំអីល្អនៅភ្នំដីរមាលនោះ ។

បូលី ៖ តា ចាយ អីគេ?

ភាព ៖ ឈ្មោះ តា ចាយៗនឹង មិនស្រួលការងារជាមួយយាយចែមនឹងដែរក៏មិនដឹង ដែលគាត់ប៉ុន ខាងដាំដុះផ្នែកសេដ្ឋកិច្ចបង្កបង្កើនផលបានល្អ ។

បូលី ៖ បើសិនជាមីងមានប្រសាសន៍ចឹង អាចពេញហើយតាមមើល តា សោម ពី៧០មក៧៥?

ភាព ៖ ចា៎! ៧៥ ។

បូលី ៖ អានឹងខ្ញុំស្មាន មិនដឹងជា៣មិនដឹងជា៥ទេហើយ?

ភាព ៖ តែ៧៣ ដឹងតែនៅពេញអស់ហើយ ។

បូលី ៖ នៅពេញអស់?

ភាព ៖ ចា៎!

បូលី ៖ បន្ទាប់ពី៧៥មក អាចថាគេចាប់គាត់អីចឹង?

ភាព ៖ ចា៎! អាច៧៥ ផ្លាស់ប្តូរ ។

បូលី ៖ ទាល់តែខ្ញុំទៅមើលចម្លើយសារភាពគាត់ បើសិនជាមាន បានយើងដឹងថាតើគាត់ត្រូវបានគេ ចាប់ពេលណាៗ?

ភាព ៖ ចា៎!

បូលី ៖ បន្ទាប់មកបាន យាយ ចែម គាត់ពី៧៥មក៧៨ ។ ព្រោះចុង៧៧អីនឹងគាត់ខាងព្រះនេត្រ ព្រះហើយ ។

ភាព ៖ ចា៎! មកខាងនេះហើយ ។

បូលី ៖ ខាងតំបន់៥ ពាយ័ព្យ?

ភាព ៖ ចាំ!

បូលី ៖ ចឹងបន្ទាប់ពីគាត់ចេញមក បាន តា ទិត ឡើង យឹម ទិត នេះ ។

ភាព ៖ ចាំ! អាចហ្នឹងឯង ។

បូលី ៖ ពីព្រោះខ្ញុំដឹងច្បាស់ថា យឹម ទិត នេះ គាត់ឡើងជាលេខាតំបន់១៣នឹងនៅឆ្នាំ៧៨ ។

ភាព ៖ បង ចែម អាចបានតែ២ឆ្នាំទេ តាមមើល ។

បូលី ៖ ៧៥ ៧៦ ៧៧ ។

ភាព ៖ ចាំ! អាចថា៧៧ គាត់មកនេះហើយ ។

បូលី ៖ ៧៧មកនេះហើយ?

ភាព ៖ ៧៧ ៧៨មកខាងព្រះនេត្រព្រះនេះ ។

បូលី ៖ ចឹងអា តា ទិត ឡើងជំនួសគាត់?

ភាព ៖ ចាំ!

បូលី ៖ ប៉ុន៧៧នឹង ក៏មិនមែនពាក់កណ្ដាលដែរ អាចុងតាមមើល ។

ភាព ៖ មិនដឹងម៉េចអី ខ្ញុំអត់សូវដឹងដែរ បើបែកគ្នាឆ្ងាយហើយ បង ចែម ខ្ញុំ ទើបជួបគ្នានៅអន្លង់វែង ។ បែកៗគ្នាមែនទែន ជាមួយបង វ៉ាន់ អីនេះ ទើបមកជួបៗនឹងដោយការចងក្រងថា បង វ៉ាន់ នឹងគាត់គ្រប់គ្រងខាងសមាគមន៍នារីស្រុកអន្លង់វែង គាត់ប្រធានសមាគមន៍នារីស្រុកអីចឹងទៅ គាត់ចុះទៅធ្វើការខាងខ្ញុំៗកាលនោះនៅត្រពាំងប្រាសាទ សមាគមន៍នារីដែរ ចឹងវាបណ្ដាញជាប់គ្នា ។

បូលី ៖ ចឹងមីងប្រធានសមាគមន៍នារីត្រពាំងប្រាសាទ?

ភាព ៖ ខ្ញុំប្រធាននឹង មិត្ត មុត ។

បូលី ៖ មីង មុត ប្រធាន?

ភាព ៖ ហ្នឹងហើយ ។

បូលី ៖ ចុះមីង?

ភាព ៖ ខ្ញុំសមាជិក ។

បូលី ៖ ហ្នឹងឆ្នាំប៉ុន្មានដល់ឆ្នាំប៉ុន្មាន?

ភាព ៖ ហ្នឹងមើល៩០ប៉ុន្មានទេ ៩៤ ។

បូលី ៖ ចឹងបកមកអន្លង់វែងវិញ ខ្ញុំគិតថា បន្ទាប់ពី តា យ៉ន, យាយ បូ ហើយ តា ញ៉ែនៗ ប្ដីយាយ ចែម ។

ភាព ៖ ចា៎!

បូលី ៖ តា ញ៉ែន ប្តី យាយ ចែម?

ភាព ៖ ប្តី ចែម ។

បូលី ៖ ដល់ទី៤ បាន យាយ វ៉ាន់?

ភាព ៖ ហ្នឹងហើយ បង វ៉ាន់ ចូលក្រោយ ។

បូលី ៖ ទី៥ បាន ឌិត នេះ មិនដឹងជាយ៉ាងម៉េច?

ភាព ៖ ឌិត នឹងមិនដឹងនៅណាផង ។

បូលី ៖ មីងអត់ដែលស្គាល់ពីមុនទេ?

ភាព ៖ ចា៎!

បូលី ៖ តែមីងអាចអត់ស្គាល់ ពីព្រោះវា៧៨ទៅហើយ ៧៨មីងអត់នៅផងនឹង ។

ភាព ៖ ចា៎!

បូលី ៖ ចឹងគេផ្លាស់ប្តូរ?

ភាព ៖ បើបងដីដូនមួយខ្ញុំបានគាត់នៅជាមួយរហូត ។

បូលី ៖ នៅត្រាំកក់នឹងរហូត?

ភាព ៖ ចា៎! គាត់នៅឯផ្ទះ នៅព្រៃឈើទាលនឹង ។

បូលី ៖ មីងអាចដឹងខ្លះៗពីស្រុកគិរីវង្ស គណៈស្រុកគិរីវង្ស?

ភាព ៖ អឺ! ក្តាប់អត់បានទេ អូន ព្រោះឆ្ងាយពីគ្នាណាស់ អត់ដែលបានទៅជួបគ្នាទេ ។

បូលី ៖ តាមដែលខ្ញុំដឹង គឺថាគណៈស្រុកគិរីវង្សនេះ គឺ តា ទិត ប្អូនថ្លៃរបស់តាៗ ម៉ុក ជាគណៈស្រុក គិរីវង្ស មុនពេលគាត់មកកាន់តំបន់១៣ ឆ្នាំ៧៨ ។ ប្រពន្ធគាត់ឈ្មោះ អ៊ុងៗ កេន ។

ភាព ៖ អត់ស្គាល់ ។

បូលី ៖ អត់ស្គាល់ យាយ កេន?

ភាព ៖ អត់ទេ ។

បូលី ៖ យាយ កេន នឹង ប្អូនស្រី តា ម៉ុក តែគាត់ស្លាប់ហើយ ។ ហើយយាយ កេន នឹងជាប្រធានមន្ទីរពេទ្យស្រុកគិរីវង្សដែរ ។ មីងអត់ដែលដឹងពីណាក្រៅពីនឹង?

ភាព ៖ អត់ ។

បូលី ៖ យាយ បូ កាន់មួយរយៈ?

ភាព ៖ កាន់មួយរយៈ ប៉ុនមិនដឹងបានប៉ុន្មានឆ្នាំអត់ដឹងទៀត ។

បូលី ៖ ខាងកោះអណ្តែតមីងស្គាល់ទេ មើលទៅ?

ភាព ៖ អត់ស្គាល់ទេ ។

បូលី ៖ ចុះខាងត្រាំកក់ ស្រុករបស់ តា ម៉ង?

ភាព ៖ ត្រាំកក់ក៏អត់ស្គាល់ ព្រោះអត់សូវបានប្រឡូកជាប់ជាមួយ គ្រាន់នៅស្រុកនឹង មិនសូវបាន នេះផង មកធ្វើការមកឡើងកន្ទែង បង បូ អត់ដែលបានទៅជួបនេះទេ រៀនសូត្រអីមក ត្រឹមនឹងៗ ។

បូលី ៖ ចឹងកូនប្រសារ តា ម៉ុក មិនដែលមានឈ្មោះ សឿន, មានតែ តា មុត, តា វ៉ែន, បូរាណ, តា កិ, អត់ដែលមានឈ្មោះ សឿន កូនប្រសារ តា ម៉ុក?

ភាព ៖ កូនប្រសារ តា ម៉ុក មានឈ្មោះអីឈ្មោះ វិៗមួយ ប៉ុនមិនដឹងប្តីណាទេ ។

បូលី ៖ បាទ! វិនៗ?

ភាព ៖ មានឈ្មោះ វិន ។

បូលី ៖ វិន លេខាកងពល៦០៣?

ភាព ៖ ចា៎!

បូលី ៖ ដែល តា ម៉ុក សម្លាប់ចោល រឿងលក់ស្រីទៅថៃ?

ភាព ៖ រឿងលក់ស្រីនៅថៃ ។

បូលី ៖ បាទ! ត្រូវហើយ មានឈ្មោះ វិន មួយទៀត?

ភាព ៖ ហ្នឹងហើយ ឈ្មោះ វិន ហ្នឹងលក់ច្រក១០០៣នេះ ។

បូលី ៖ ប៉ុន វិន ប្រពន្ធឈ្មោះអី?

ភាព ៖ ប្រពន្ធ វិន មិនដឹង យាយ ហូ ហើយណា មិនដឹង យាយ ហូ, យាយ ហេង ពីរនាក់នឹង ខ្ញុំច្រឡំនឹងគ្នា ប្រពន្ធ បូរាណ ហើយប្រពន្ធ វិន ។ ខ្ញុំទើបនឹកឃើញ វិន ភ្លេចយូរទៅ គេកង ពលនោះ ។ យូរៗទើបនឹកឃើញ កូនប្រសារតា ។

បូលី ៖ អឺ! មិញយើងនិយាយពី ត-៨ ឥឡូវចូលត-៣ មីងអាចដឹងទេ ត-៣, ត-៤, ត-៥, ត-៦, ត-៧ នឹង ប្រធានៗគេកាលនឹង?

ភាព ៖ អឺ! ភ្លេចអស់ហើយអូន កាលត-៩នោះមាន ពូ ឈានៗ ។

បូលី ៖ មាន ត-៩ មួយទៀត?

ភាព ៖ ចា៎! ហ្នឹងរៀបឡើងថ្មី រៀបចំកងចេញពីស្រុក ហើយជ្រើសរើសអគ្គភាពចាស់ខ្លះទៅគ្រប់ គ្រងអនុសេនាធំ អនុសេនាតូច យើងសម្តែងចេញពីឈ្លបស្រុក ។

បូលី ៖ ត-៩នឹង គឺជាវរសេនាតូច របស់តំបន់១៣?

ភាព ៖ តំបន់១៣ ។

បូលី ៖ ពីណាគេប្រធានត-៩?

ភាព ៖ ឈ្មោះ ឈាន ។

បូលី ៖ មីងចាំអនុរបស់ ឈាន?

ភាព ៖ មិនដឹងណាទេ ភ្លេចអស់បាត់ហើយ ។

បូលី ៖ បាទ! អត់អីទេមីង ចុះ ត-៨?

ភាព ៖ ត-៨ កាលនោះនៅបង រឺ នៅឡើយ កាលនោះ ។

បូលី ៖ អូ! សុំទោស ត-៧, ត-៨ យើងនិយាយហើយ?

ភាព ៖ ត-៧ អ្នកណាគេកាលនោះ ភ្លេចឈ្មោះអស់ហើយ ត-៧ ពូ ឡូញ ដឹងកាលនោះ ។ យូរពេកតាំងពី៧២មកឥឡូវសួរលែងចង់ឃើញ ។

បូលី ៖ អត់អីមីង តាមសំរួលពីព្រោះវាយូរពេក ។

ភាព ៖ ចាំ! យូរពេក ភ្លេចគ្នាអស់ ។

បូលី ៖ ត-៧ ប្រធានបើសិនមីងចាំអនុរបស់គាត់ ជួយប្រាប់ខ្ញុំផង ។ ត-៦ អាចចាំទេ?

ភាព ៖ ត-៦ មានពីណាទេ ភ្លេចអស់ ។ នៅចាំត-៤ នៅចាំ ត-៤ឈ្មោះ ហ៊ិន ។

បូលី ៖ ហ៊ិន ប្រធាន ត-៤រួចហើយ ។ នៅសល់ត-២, ត-៣?

ភាព ៖ ត-៣ ពីមុន ម៉ាញ ប៉ុន ម៉ាញ ឡើងមកនេះមកៗភូមិភាគមកនៅ នឹកឃើញឈ្មោះ ឆន ត-៣ ។

បូលី ៖ ម៉េង ប្រធានក្រោយនេះទី១ ទី២ ឆន?

ភាព ៖ ចាំ! ឆន នឹងចេញពីអនុសេនាធំ កាលនឹង ។

បូលី ៖ ឆន ប្រធាន ម៉េង នឹងមកភូមិភាគ?

ភាព ៖ ម៉ាញ មិនមែនម៉េងទេ ។ ម៉ាញ មកភូមិភាគ ។

បូលី ៖ កាន់អីគេ ភូមិភាគ?

ភាព ៖ គាត់ឡើងមកជាមួយ បង ឃឹម ជាមួយ សឿន អីនឹង តែមិនដឹងថាគាត់កាន់ខាងអី ។

បូលី ៖ ឡើងមកជាមួយ ឃឹម, សឿន?

ភាព ៖ ចាំ!

បូលី ៖ ឡើងមកភូមិភាគនិរតីនឹង?

ភាព ៖ ចា៎! ភាគនិរតីនឹង កងពលទី២ហើយ ។

បូលី ៖ មកកងពលហ៎?

ភាព ៖ ចា៎! មកនៅកងពលទី២ ។

បូលី ៖ មកនៅកងពលទី២ សឿង ឬក៏សឿន?

ភាព ៖ សឿន ។

បូលី ៖ សឿន?

ភាព ៖ ចា៎! គេហៅ សឿន រថក្រោះៗ ។

បូលី ៖ សឿន រថក្រោះ?

ភាព ៖ សឿន នឹងនៅព្រៃក្អែក ។

បូលី ៖ កងពលទី២?

ភាព ៖ ចា៎!

បូលី ៖ អូ! សុំទោស តា សឿន កងពលទី១ទេ ។ ប៉ែន សឿន?

ភាព ៖ ហ្នឹងហើយ គេហៅ សឿន រថក្រោះៗ ។

បូលី ៖ សឿន រថក្រោះប្រធានកងពលទី២?

ភាព ៖ ពេលគាត់នៅមិនដឹងធ្វើអី ប៉ុនគេថាឡើងមកនៅគ្រប់គ្រងកងពលនឹង ។

បូលី ៖ ចឹងមាន សឿន មាន ឃឹម ហើយនឹង មាន ម៉ាញ នឹង?

ភាព ៖ ចា៎!

បូលី ៖ ដែលមកកាន់កងពលទី២នឹង?

ភាព ៖ គេកងពលគេស្លាប់ហើយ ប៉ុនយកមកមិនដឹងគេយកមកបញ្ចូលក្នុងអនុ ឬសមាជិកអី យើងអត់ដឹងដែរ ។ យកមកសុទ្ធតែវរៈហើយនឹងកងពលៗទើបរៀបបានប៉ុន្មាន បងសឿន នឹង ផឡូវ នាយកគាត់មកឡើងមកពីវៀតណាម ។

បូលី ៖ គាត់អាចនៅរស់ខ្លះទេ សឿន, ឃឹម, ម៉ាញ?

ភាព ៖ បង ឃឹម ថានៅរស់ ប៉ុនឮថាទៅនៅស្រុក តែ បង ម៉ាញ ស្លាប់ហើយ ហើយ សឿន នោះស្លាប់ដែរ ។

បូលី ៖ សឿន ស្លាប់?

ភាព ៖ ចា៎!

បូលី ៖ កងពលទី២របស់ភូមិភាគនិរតី ពីព្រោះខ្ញុំដឹងថាកងពលទី៣ គឺ តា មុត អ្នកកាន់ ។ ហើយ កងពលទី១ឈ្មោះ ប៉ែន សឿង ។ នៅនិរតីមាន៣កងពល មានទី១ ទី២ ទី៣ ។

ភាព ៖ ចា៎!

បូលី ៖ ចឹង ត-៣នេះ មុនដំបូង ម៉ាញ បន្ទាប់មក ឆន?

ភាព ៖ ចា៎!

បូលី ៖ ត-៤ ហ៊ិន?

ភាព ៖ ចា៎!

បូលី ៖ នៅសល់ត-៥, ត-៦?

ភាព ៖ ត-៦ មិនដឹងពីណា កាលនឹងខ្ញុំភ្លេចបាត់ហើយ ។

បូលី ៖ ត-៧ ឡូញ ។ ត-៥ ក៏អត់ដឹង?

ភាព ៖ ឡូញ, ឡាំ ហើយ កាលនឹង ត-៧ ព្រោះបងប្អូនគេពីរនាក់នឹង ។

បូលី ៖ ឡូញ និង ឡាំ នឹង នៅត-៧ទាំងពីរនាក់?

ភាព ៖ ចា៎! ពីមុននៅអនុសេនាធំដូចគ្នា ។

បូលី ៖ ឡាំ ហើយនឹង ឡូញ ពីណាបងពីណាប្អូន?

ភាព ៖ តា ឡាំ បង ។

បូលី ៖ តា ឡាំ បង តាឡូញ ។ ត-៥, ត-៦ មីងនឹកអត់ឃើញទេ?

ភាព ៖ នឹកអត់ឃើញ ត-៦ មិនដឹងពីណា ។

បូលី ៖ ចាំមើលនិយាយលេងនឹកគ្នាតិចទៀតមើល ក្រែងលរអាចនឹកឃើញតាមក្រោយ ។ នៅតំបន់ ១៣នឹង វាមានមន្ទីរ១៥០ មន្ទីរ១៦០ មន្ទីរ២០៤ អាចមានមន្ទីរអីផ្សេងទៀតទេ ដែល មីងអាចរកនឹកឃើញ?

ភាព ៖ មាន ប៉ុនមន្ទីរ១៨០នឹងមានដែរ តែមិនដឹងមន្ទីរខាងអី ខ្ញុំភ្លេចទៅ ។

បូលី ៖ មន្ទីរ១៨០មួយទៀត?

ភាព ៖ ចា៎! ប៉ុនមិនដឹងគេហៅមន្ទីរអី វាភ្លេច ។

បូលី ៖ ឲ្យតែបានប៉ុននឹងក៏បានដែរ ខ្ញុំអាចសួរបន្តឥឡូវក៏បានទៀត ឥឡូវមីងប្រឡូយបាន២៨០ តែ មិនដឹងមន្ទីរអី ។ មានអីទៀតដែលមីងអាចនឹកឃើញមន្ទីររបស់តំបន់១៣នឹង?

ភាព ៖ ខ្ញុំនឹកមិនឃើញ ។ លំបាកត្រង់យើងចេញផុតមក ក្តាប់វាអត់សូវបានដូចគេអ្នកនៅនឹងនរនៅ មូលដ្ឋានទេ ។

បូលី ៖ អូ! មិញ មីងថា សឿន រថក្រោះ?

ភាព ៖ ចាំ! គេហៅ សឿនៗរថក្រោះៗ ។

បូលី ៖ ហេតុអីបានគេហៅគាត់ចឹង?

ភាព ៖ ព្រោះគាត់មានស្នាដៃធ្លាប់បាញ់រថក្រោះនេះ ។

បូលី ៖ សឿន នឹងឈ្មោះពេញគាត់មីងដឹង?

ភាព ៖ ដឹតាគាត់មិនដឹងឈ្មោះអី ដឹងតែសឿន ។

បូលី ៖ សឿន រថក្រោះ គាត់មកកាន់កងពល ។ គាត់ចេញមកកាន់កងពលប្រហែលជាឆ្នាំប៉ុន្មាន?

ភាព ៖ ៧៣ មកចូលនៅកងពលទី២ មិនដឹងជាកាន់ផ្នែកអី ។

បូលី ៖ មិនដឹងជាកាន់អីទេ?

ភាព ៖ ចាំ! យើងអត់ដឹង ។

បូលី ៖ ចុះនិយាយពី ប៉ុនរឿងកងពល១ ២ ៣នេះ អត់មានទាក់ទងជាមួយ តអស់នេះ?

ភាព ៖ អត់ទេ អត់មាន ។

បូលី ៖ វាជាកម្លាំងដាច់ពីគ្នា?

ភាព ៖ ដាច់ពីគ្នា ។

បូលី ៖ មានន័យថា តំបន់ក៏គេមានកម្លាំងរបស់គេដែរ?

ភាព ៖ ចាំ!

បូលី ៖ បើភូមិភាគ មានកម្លាំងរបស់ភូមិភាគ?

ភាព ៖ ចាំ!

បូលី ៖ មិនមែនតំបន់កាន់តែប្រជាជន មិនទាក់ទងនឹងកងទ័ពទេចឹង?

ភាព ៖ តំបន់ ការពិតពាក់ព័ន្ធជាមួយកងទ័ពដែរនឹង ព្រោះគាត់គ្រប់គ្រងដឹង រៀបចំអីនៅក្នុងនោះ ជំនាន់នោះតំបន់គេគ្រប់គ្រងកងទ័ពដែរតើ ព្រោះគេពង្រីកកងទ័ព គេត្រូវការចង់បង្កើនកងទ័ព អីចំរាញ់ពីឈ្លបឃុំឈ្លបស្រុកមកគេរៀបចំឡើងទៅហាត់យកមកអនុសេនាធំ ឬមួយវរសេនាតូចទៀត គេរៀបចំពីក្រោយទៅនឹង ហើយយើងកងទ័ពដឹងតែឈរជើងសមរភូមិ ការពង្រីកទ័ព នៅលើកងពលគេអ្នករៀប លើតំបន់គេពង្រីកទៅ ។

បូលី ៖ ចឹងខ្ញុំសុំបកមករឿងមីងវិញ ។ មីងចេញពីស្រុកភូមិទៅចូលទ័ពនឹងឆ្នាំ៧២?

ភាព ៖ ៧២ ចូលទ័ព ខែ៦ ។

បូលី ៖ ៧២ ខែ៦?

ភាព ៖ ចា៎!

បូលី ៖ ថ្ងៃដឹងទេ?

ភាព ៖ ថ្ងៃមិនដឹងថ្ងៃប៉ុន្មាន ថ្ងៃ២៨ ថ្ងៃប៉ុន្មានទេខ្ញុំដូចភ្លេចព្រោះខ្ញុំបានសរសេរប្រវត្តិដែរនឹង មិនដឹងដាក់ទៅណាអី ។

បូលី ៖ នៅទេសៀវភៅនឹង?

ភាព ៖ អត់ទេ ខ្ញុំគ្រាន់ធ្វើប្រវត្តិសង្ខេបកាលយើងឈរឈ្មោះក្រុមប្រឹក្សាឃុំដំបូង គេសួរអំពីយើងធ្លាប់បំពេញតួនាទីអី ដាក់សង្ខេបៗឲ្យគេតាមឆ្នាំ ៧១មកធ្វើអី ៧២មកធ្វើអី ៧៣មកដាក់ចឹងៗ សង្ខេប ប៉ុនដឹងតែខែ៦ ។

បូលី ៖ បាទ! ចឹង៧២ មឹងចូលមកកងទ័ព នៅជាមួយយាយបូ?

ភាព ៖ ចា៎!

បូលី ៖ បន្ទាប់មកចេញពីនឹងមក កងនារីនឹងមកទៅណាវិញ?

ភាព ៖ កងនារីនឹងផ្លាស់មកនៅរតនគិរី ។

បូលី ៖ ឆ្នាំប៉ុន្មានមករតនគិរី?

ភាព ៖ ៧៦ ។

បូលី ៖ ប៉ុនមុននឹងមិនទាន់មកដល់នឹងទេ?

ភាព ៖ នែក! ៧៥ចេញពី តាកែវ មកនៅភ្នំពេញ ។

បូលី ៖ កាលនៅតាកែវ ៧៤ ៧៥ នៅក្នុងកងណា?

ភាព ៖ នៅជាមួយ ត-៦ ។ អូ! នឹកឃើញហើយ ឈ្មោះ ប៉ាវ ។

បូលី ៖ ត-៦?

ភាព ៖ ត-៦ ចេះនឹកឃើញ ។

បូលី ៖ ប៉ាវ ប្រធាន?

ភាព ៖ ចា៎!

បូលី ៖ ខ្ញុំថាតែអន្កុយនិយាយយូរៗចេញហើយ ។ ចុះអនុរបស់ ប៉ាវ ដឹងទេ?

ភាព ៖ អត់ទេ ។

បូលី ៖ មានតែ ប៉ាវ មួយ?

ភាព ៖ ចា៎!

បូលី ៖ ឈ្មោះពេញអីគេ ប៉ាវ?

ភាព ៖ អត់ដឹងឈ្មោះអី ប៉ាវ ទេ ។

បូលី ៖ ប៉ាវ អ្នកស្រុកណា អ្នកភូមិណា?

ភាព ៖ ត្រាំកក់ ស្រុកត្រាំកក់ នៅឃុំ ។

បូលី ៖ ញ៉ែញ៉ង់ដែរ?

ភាព ៖ អត់ទេ អាចនៅលាយបូទេ ម៉្លុំភូមិមីងថែម ភូមិអីនឹង ភូមិរ៉ាន់ ភូមិអីនឹង ។

បូលី ៖ ចឹងមីងអត់នៅត-៨ នៅត-៦វិញ?

ភាព ៖ មកនៅជុំគ្នា ត-៨, ត-៦ នឹងឈរជើងនៅព្រំដែន យួនខាងត្បូង គីរីវង្សភ្នំដិននឹង រៃ សមរភូមិភ្នំដិន ។

បូលី ៖ ត-៦ និង ត-៨ ឈរជើងការពារព្រំដែនភ្នំដិន?

ភាព ៖ ភ្នំដិន ៧៤-៧៥ ។

បូលី ៖ ចឹង៧៤-៧៥ មីងនៅនឹង?

ភាព ៖ ចា៎!

បូលី ៖ មីងបានកាន់អនុសេនាធំអីនឹងគេទេ កាលនឹង?

ភាព ៖ អត់ទេ កាលនឹងខ្ញុំនៅពេទ្យ ។

បូលី ៖ មីងជាពេទ្យ?

ភាព ៖ ចា៎!

បូលី ៖ ពេទ្យកងទ័ព?

ភាព ៖ ចា៎!

បូលី ៖ មីងហាត់ពេទ្យពីអង្កាល់បានដល់ចូលពេទ្យបាន?

ភាព ៖ ខ្ញុំការពិតនោះ រៀនសូត្រពេទ្យបានតិចណាស់ រៀនចឹងបានថាប្រវត្តិថាវែងឆ្ងាយ ចូលរៀនដំបូងខ្ញុំអត់ទាន់បានរៀនទេ ខ្ញុំដែលនៅសមាគមន៍នារីឃុំនឹង ក្នុងនឹងមានពេទ្យ៣នាក់នៅជាមួយ ។ ហើយនារីពីរនាក់ទេ មានបង សាន ហើយខ្ញុំ ។ ដល់ចឹងទៅ៥នាក់នឹង យើងចុះដំណើរទៅណា ពេទ្យទៅតាមជាមួយរហូតទាំងយប់ទាំងថ្ងៃ ។ ដល់ពេលកន្លែងទៅដល់ផ្ទះអ្នកជម្ងឺ យើងមើលពេទ្យចាក់ថ្នាំ មើលអីឲ្យប្រជាពលរដ្ឋយូរៗយើងរៀនតាមនឹង រៀនចាក់រៀនអីជាមួយគេនឹង ហើយយើងមើលសៀវភៅគេរៀន យើងរៀនតាមនឹងមុនដំបូង ។ ហើយក្រោយមក គេយកទៅបណ្តុះបណ្តាលនៅមន្ទីរបានមួយរយៈខ្លីទេ ដល់ចាកចេញមកធ្វើការនៅកងទ័ពនឹង ។ ខ្ញុំរៀនបានតិច ប៉ុនអនុវត្តន៍ជាក់ស្តែងបានច្រើន ។

បូលី ៖ ចឹងមីងដើរតាមព្យាបាលកងទ័ពរហូត?

ភាព ៖ ចា៎!

បូលី ៖ ៧៣ ៧៤ ៧៥ នឹង?

ភាព ៖ ចា៎!

បូលី ៖ កាលនឹងពី៧៣ ៧៤ ៧៥ យើងមានបានពើបប្រទះច្បាំងគ្នាជាមួយវៀតណាមខ្លាំងទេមើលទៅ កាលនោះ?

ភាព ៖ វ៉ៃគ្នាខ្លាំងនៅភ្នំដិននឹងឯង ។

បូលី ៖ ប៉ុន្មានថ្ងៃដែរ កាលនឹង?

ភាព ៖ អឺ! ខ្ញុំនៅនឹង២ឆ្នាំ មិននេះទេ វាគ្រាន់ថាវាចូលមកធ្វើដី ឧបមាថាដីបឹងយើងមុខផ្លូវដាច់នឹង វាមកធ្វើស្រែខាងយើងចឹង យើងអត់ឲ្យធ្វើ វានៅចូលមកធ្វើ យើងកំទេចរបស់វាមក យើងមិនឲ្យវាមកដាក់មង ដាក់អីយកត្រីខាងយើងចឹង បើមកដាក់ចឹងយើងមកសារមង សារអី ដាក់ចំរូងដាក់អីកុំឲ្យវាមក ។ ហើយដល់ពេលកម្លាំងវាចុះមកដែរ កម្លាំងរថក្រោះ កម្លាំងទាហានវាចុះដែរ តែយើងវ៉ៃខ្ទប់ទៅវិញ ព្រោះយើងដាក់កាំភ្លើងធំ ដេកា នៅលើភ្នំនឹងឯង ។

បូលី ៖ នៅលើភ្នំដិនតែម៉ង?

ភាព ៖ ចា៎!

បូលី ៖ វាចេះមកលុកយកដី?

ភាព ៖ វាមកលុកចង់ចូលមកយកដល់ភូមិយើង ប៉ុនយើងមិនឲ្យចូលមកបាន ព្រោះយើងមានធ្វើការ ឧបមាថាយើងជីកខ្សែលឹងការពាររហូត យើងរត់តាមខ្សែលឹងយើងបានវាអត់មើលឃើញទេ ព្រោះប្រឡាយខ្សែលីញយើងលិចៗក្បាលម៉ង ហើយត្រង់សេរដែលយើងនៅនេះ កន្លែងនៅដូចផ្ទះចឹង គេជីកល្អមមួយគ្រែធំចឹងដេក៣-៤នាក់ហើយ យើងធ្វើដំបូលឈើចំរុះចឹងទៅ អាខាងៗរបស់យើងសុទ្ធតែបំរឹងឈើទាំងអស់ ហើយយើងដាក់ដីបិទមក អត់ដឹង ។

បូលី ៖ ហើយយើងសម្រាកក្នុងនឹង?

ភាព ៖ សម្រាកក្នុងនឹង ហើយចេញពីកន្លែងសម្រាកទៅ ចេញពីខ្សែលឹងទៅនោះ ខ្សែលីញវ៉ៃ ។

បូលី ៖ មីងអត់ខ្លាចទេ ទៅសមរភូមិ?

ភាព ៖ អត់ទេ ធម្មតាដឹងចឹង អត់មានគិតរឿងស្លាប់ រឿងរស់អីទៀត រឿងធម្មតា ។ ហើយយប់ឡើងយើងទៅល្បាត យើងចូលទៅដល់ផ្ទះយួន យប់ឡើង ។

បូលី :   ចូលៗធ្វើអី?

ភាព :   យើងចូលទៅមើលស្ថានភាពក្នុងស្រុកវារបៀបម៉េចៗ ។

បូលី :   គេអត់ចាប់យើង មិនចូលទៅដីគេ?

ភាព :   យើងចូលដេកលក់អស់ ម៉ោង១២ម៉ោងអីវាដែលបាននៅអីវា ។

បូលី :   យើងចូលស្ងាត់?

ភាព :   យើងចូលស្ងាត់ ម៉េចហៅឈ្លប ទៅលួចឆ្មាំងបាយ ប៉ុន្តែផ្លូវយើងបើថាមកដល់ដីយើងហើយនៅតែមួយផ្លូវរត់ តែខុសគ្រោះថ្នាក់ខ្លួនឯង ។ ខ្ញុំបាត់នារី មិនបាត់នារីទេ បាត់ផ្នែកយុវជនម្នាក់បែបខ្លាចរត់មកទៅធ្លាក់រណ្តៅខ្លួនឯងក៏របៀបម៉េចរកអត់ឃើញ ហើយក៏វាចាប់យកទៅហៅថាវាវរបួសហើយអាចថាវាចាប់យកទៅហើយ ព្រោះយើងកាលរត់មកហើយ យើងអត់អាចបកទៅវិញបានទេ ខ្លាចគ្រោះថ្នាក់អត់មានកន្លែងក្រាបកន្លែងនេះទេ ព្រោះជុំវិញដីយើងចាក់បេតុង ហើយយើងកាប់គ្រឡុកទទឹង១ម៉ែត្រ ឬ៧-៨តឹក បណ្តោយ១ម៉ែត្រចឹងទៅយើងចាក់ចំរូងពេញតែនឹង ភ្លាត់ភ្លឹប អត់មានរឿងនៅទេ ។

បូលី :   ចំរូង តែមុតទៅចុចទៅ?

ភាព :   ចំរូងសុទ្ធតែមុខ៣ ឬស្សី ដល់ចឹងទៅវាពិបាក ដល់ស្អែកឡើងយើងទៅរក ពួកខាងកាំភ្លើងធំយប់ស្អែកយើងទៅរកអត់ឃើញ ថាប្រយ័ត្នណាស់រឿងចូលទៅ ។ ដល់ចាំផ្លូវ អ្នកមិនចាំផ្លូវអត់ដើរបណ្តោយទេ ។

បូលី :   ធ្លាប់ចូលទៅដែរ?

ភាព :   ធ្លាប់តើ ។

បូលី :   ឆ្លងកាត់ចឹងទៅមីងលែងដូចថាមិនសូវជាខ្លាចរៀងតូចតាច?

ភាព :   ធម្មតា ខ្ញុំបើនិយាយពីមួយឆាកជីវិតខ្ញុំ ការតស៊ូឆ្អែតលំបាក ខ្ញុំគ្រោះថ្នាក់ថាមិនរស់ផង ។

បូលី :   ពេលណាគ្រោះថ្នាក់ហ្នឹង?

ភាព :   ខ្ញុំ៧៣ ត្រូវរបួស ។

បូលី :   ដោយសារអី?

ភាព :   គ្រាប់ផ្លោង ។

បូលី :   អំបែងខ្ទាត់ត្រូវ?

ភាព :   ធ្លាក់ជិត ធ្លាក់ត្រង់សេរ ជិតនឹង ។

បូលី :   មីងជួយប្រាប់ពីយ៉ាងម៉េច កាលនឹងច្បាំងគ្នាប៉ុន្មានថ្ងៃ ត្រូវគ្រាប់ផ្លោង?

ភាព ៖ យើងនៅក្នុងខ្សែត្រៀមរហូតរាប់ខែតែម្ដង សមរភូមិមួយៗ លុះត្រាតែបែកសមរភូមិនឹង បានយើងឡើងដីកត្រង់សេរសមរភូមិថ្មីទៀត ។

បូលី ៖ អ៊ូ! ចេះតែរុលទៅមុខ?

ភាព ៖ ចាំ! ត្រង់សេរយើងដាក់ត្រៀមចាំរហូត ទាល់វ៉ៃបែកនៅកន្លែងនឹងហើយ យើងឡើងទៅវ៉ៃ នៅខាងមុខទៀត ។

បូលី ៖ កាលនឹងយើងចេះតែរំកិលទៅមុខបាន ឬក៏នៅតែមុំទេ មិនអាចរំកិលទៅបានទេ ឬយ៉ាង ម៉េច?

ភាព ៖ និយាយរួមសមរភូមិមួយៗយូរណាស់ ១ខែ ឬ២ខែបានបែក មិនងាយទេ យើងនៅក្នុង ខ្សែត្រៀមនឹងរហូត ។ ដល់ពេលកាលនឹងយើង៧៣ យើងឈប់ស្មាក់វ៉ៃហើយ ដល់ខ្សែ ត្រៀមដីកត្រង់សេរ ត្រៀមដេញតែម្ដង យើងរំកិលតែម្ដង វ៉ៃបែកយើងឡើងទៅទៀត ។

បូលី ៖ ហើយដែលត្រូវរបួសនឹង ត្រូវយ៉ាងម៉េច ធ្ងន់ធ្ងរប៉ុនណាដែរ?

ភាព ៖ ខ្ញុំនិយាយរួមទៅដល់មន្ទីរពេទ្យនឹងគេថា ឈាម៤៧ ដល់ពេលឈប់មើល ម៉ោង៤កន្ទះល្ងាច ទៅដល់ពេទ្យខ្ញុំលែងដឹងខ្លួន ព្រោះខ្ញុំត្រូវគាំងពីម៉ោង៣រសៀល ម៉ោង៧យប់បានយកបាន ។ ព្រោះប្រហែលនៅផ្ទះគេមើលឃើញ ត្រង់សេរខ្ញុំប្រហែលដី១០០ម៉ែត្រពីគ្នាទេ ជ្រុងស្រែ ម្ខាងម្នាក់ និយាយរួម ។ យើងនៅភ្លឺស្រែខាងនេះ គេនៅខាងនោះ គេនៅក្នុងភូមិគេមាន ចេតិយមានអីចឹង ហើយគេមានភូមិមានដើមឈើអីសម្រាប់លួចមើលយើង ។ យើងមាន ណាមានតែភ្លឺស្រែ ហើយគុម្ពរំពាក់នឹង ហើយយើងដីកត្រង់សេរបាំងភ្លឺស្រែ គេមានដើម ត្នោតក្បែរនឹងមក វាផ្ចង់គោលមកចំ ។

បូលី ៖ ចំត្រង់សេរម៉ង?

ភាព ៖ ចំពីក្រោយ ។ ខ្ញុំនៅពីក្រោយត្រង់សេរ ។ ព្រោះក្រោយត្រង់សេរ គេមានគ្រឡុកមួយទៀត ហើយមានត្រពាំងទឹកមួយ ។

បូលី ៖ ហូរឈាមច្រើន?

ភាព ៖ ឈាមច្រើន នេះកខ្ញុំស្នាមរបួស ដកស្រែកអត់រួចណាច ដកអំបែងមកអំបែងប៉ុននេះមុត មួយជ្រុង ពេលដាក់ទឹកដូងទៅចេញតាមទឹកឡើងមកតាមច្រកបំពង់ក ត្រង់នេះឈាមហូរចូល ក្នុង ពោះកកឈាមប៉ុនមេដៃមេជើង ។ ហើយម៉ោង៧បានអ្នកទៅយកបាយទៅសែងចេញ មកយប់ បានអ្នកយកបាយមកឲ្យ ។

បូលី ៖ ហេតុអីបានជាមិនសែងចេញភ្លាមៗ ពេលត្រូវរបួសនឹង?

ភាព ៖ វាលចេះនឹង វាលស្រែ ។

បូលី ៖ អត់មានពីណាហ៊ានចូលទៅ?

ភាព ៖ អត់ទេ ហើយអត់មានអ្នកចេះចាក់ថ្នាំទៀត ខ្ញុំឲ្យអ្នកនៅជាមួយនឹង លូនចូលទៅហៅគេត្រង់សេរ ប្រហែលនេះផ្ទះគេខៀវនឹង មួយត្រង់សេរ មួយចន្លោះៗប៉ុននឹងឆ្ងាយៗពីគ្នា ។ គ្នាលូន ឡើងរលាត់ដៃរលាត់ជើងអស់ ទៅហៅអ្នកនោះមកចាក់ថ្នាំឲ្យ ។ មកអត់ចេះចាក់ទៀតអត់ ដែលកាន់សឺរ៉ាំង អត់ដែលស្គាល់ថ្នាំ ។ មកដល់ខ្ញុំយកសែសាំងកាដុងខ្ញុំមករើថ្នាំពេទ្យឲ្យគាត់ចាក់ឲ្យ គាត់រុំឲ្យ ។

បូលី ៖ មឹងនៅមានកម្លាំងរើទៀត?

ភាព ៖ ចា៎! ខ្ញុំនៅស្មារតីខ្ញុំនៅបាន ប៉ុនដឹងថាត្រូវផ្ទុងចឹង ខ្ញុំវិលៗខ្វល់បានខ្ញុំដួល ។

បូលី ៖ ត្រូវណាខ្លះ ត្រូវកនឹងមួយ?

ភាព ៖ ត្រូវក ត្រូវត្រគៀកអស់សាច់ត្រគៀកមួយចំហៀង ឆ្អឹងចំនីរ ជើង ។

បូលី ៖ បាក់អត់?

ភាព ៖ អត់បាក់ទេ បាក់តែមេជើង ។

បូលី ៖ ហើយលែងដឹងឈឺហើយ ឬក៏ឈឺខ្លាំងកាលនឹង?

ភាព ៖ ត្រូវក្លាមអត់ដឹងឈឺទេ ប៉ុនយើងមើលទៅឈាមវាហូរ មើលទៅខោដាច់អស់ចឹង សាច់មើលក្រហមឈាមហូរ ខ្ញុំដោះក្រមាដែលរុំក្បាលយកមកចងចង្កេះខ្ញុំដែលឈាមនោះ ។

បូលី ៖ នៅមានស្មារតីចងបានទៀត?

ភាព ៖ ចា៎! ហើយបានខ្ញុំហៅអ្នកនៅក្នុងត្រង់សេរឲ្យគេមកយកខ្ញុំ ។

បូលី ៖ ទាល់តែម៉ោង៧យប់បានហ៊ានចូលមកយក?

ភាព ៖ ចា៎! អ្នកបាយមកដល់ អ្នកយកបាយមកឲ្យតាមត្រង់សេរ មកដល់បានសែងខ្ញុំ ។ សែងទៅតាមផ្លូវ បងដែលចាក់ថ្នាំឲ្យខ្ញុំនឹង គាត់អត់ចេះ ខ្ញុំចេះប្រាប់ឲ្យចាក់អានេះចាក់អានោះ ចឹងខ្ញុំស្អិតកៗ វាស្ងួតកវាឈាមជោគដង រៀងដូចហើមពោះនឹកឃើញថាគ្មានសង្ឃឹមរស់ កាលនឹងកាច់សារ៉ូមមកដឹកៗ អាសារ៉ូមអំពូលធំៗ២០សេសៗ ខ្ញុំទារគាត់ បងកាចសារ៉ូមឲ្យខ្ញុំដឹកមួយអំពូលមើល គេថាប្អូនណាគេអត់ឲ្យដឹកទឹកទេ អ្នករបួស ទៅសារ៉ូមអត់អីទេ ខ្ញុំកុហកគាត់ក៏គាត់កាច់ថាប្អូនណាមិនដឹងណាណីទេ បងអត់ដឹងទេ ខ្ញុំថាអាណាអំពូលធំជាងគេយកមកកាច់ឲ្យខ្ញុំ គាត់ដូចថាជីវិតមិនត្រូវរស់ គាត់មិននឹកឃើញថាអាអំពូលធំ គាត់ដឹងតែអាបាច់ធំដែលខ្ញុំចង់ភ្លាប់ចេះ អាគីណូហ្វូមសម្រាប់គ្រុននោះ ។ ដល់ចឹង គាត់យកមកកាច់ ប្អូនឯងហា

មាត់មក បងពុះដាក់ឲ្យ កាច់ម្នាងទឹកថ្នាំហូរចូល ខ្ញុំលេប ខ្ញុំថាខុសហើយ អត់សារ៉ូមទេ គឺណូហ្វូមហើយ ខ្ញុំនឹកឃើញក្នុងចិត្ត បើសិនជាខ្ញុំឈាមចូលក្នុងពោះ ច្បាស់មួយសន្ទុះទៀតក្អួតហើយ ។ សែងបានប្រហែល៥០ម៉ែត្រ ក្អួតមកនិយាយពីឈាមទាំងកន្ត្រៃ វឹកមក ពួកនឹងស្រែកយំ អ្នកសែងខ្ញុំភ័យៗថាកាច់ថ្នាំឲ្យដឹកខុស ។

បូលី : ប៉ុនការពិត ឈាមកកនឹងទេ?

ភាព : ហ្នឹងហើយ ឈាមកកក្នុងពោះមកអស់ធូរពោះ រៀងមានកម្លាំងចឹងទៀត ។

បូលី : ហេងចឹងវិញ ដូចគេរៀបចំទុកដាក់?

ភាព : ចា៎!

បូលី : ឲ្យគាត់យកខុសថ្នាំ ដើម្បីឲ្យមិនអាចក្អួចបាន?

ភាព : ចា៎! បានមកដល់កន្លែងពេទ្យៗប្រធានឃុំប្រចាំការណ៍នៅខាងក្រោយ មិត្តភ័ក្តិខ្ញុំដែរ ប្រុសអាឡែងទៅមុជទឹកទៀត ខ្ញុំនៅស្មារតីនៅនឹង ដោះគ្រាន់មកដល់ ឈ្មោះពេទ្យ ឈិនៗ ពួកនឹង ស្រែកហៅពេទ្យ ឈិន ហើយ ភាព ត្រូវរបួស រត់មករដាត់ភីង មកដល់អត់មានគិតរឿងចាក់ថ្នាំ អប់យំបណ្តោយ ។ លើកចេញពីអង្រឹងបីយំ ចុះបើនិយាយពីល្ងាចខ្ញុំមកសមរភូមិក្រោយ ខ្ញុំឡើងមកម៉ោង៣ពីសមរភូមិមកលេងផ្ទះបាយៗ ស្រាប់តែបង ម៉ាញៗ ដូចខ្ញុំថានេះ កាលនោះគាត់នៅវរសេនាតូចនៅនឹង គាត់ពុទ្ធិរសាប្រាប់ថាខ្ញុំមកក្រោយៗក៏គាត់មកតាម ថាខ្ញុំឃើញបង ភាព ដើរមកមិញ មកពីសមរភូមិមិនទាន់ភ្លឺផង ។ អឺ! ចុះវាមកធ្វើអី បើថ្មពិលក៏ផ្ញើឲ្យ ថ្នាំពេទ្យអីផ្ញើឲ្យមកធ្វើអីទៀតថាចឹង ។ ហើយខ្ញុំនេះអីដូចថាប្រថ្នូរ ទៅដល់មុជទឹកមុជអីហើយ អង្គុយហូបបាយពាក់អាវវាលឃ្មៀក ស្លៀកសារុងពីលើអាវទៀតអត់ដឹងថាគាត់ដើរទៅក្រោយ គាត់ទៅអើតមើលខ្ញុំហូបបាយ ។ ឆ្ងាញ់ណាស់ បាយទាំងក្រោកចឹង ខ្ញុំងើបទៅ បង ។ អ្នកណាឲ្យឯងមក? ខ្ញុំថានេះចាំឲ្យមក នៅត្រង់សេរឡើងរាប់ខែហើយ យកគ្នាទៅដាក់ក្រោមរកពន្លឺថ្ងៃតិចមិនបាន ។ ចុះអញផ្ញើថ្នាំពេទ្យ ផ្ញើថ្មពិលអីទៅ ។ ហើយដល់រៀបវៃនឹង រៀបសមរភូមិ រៀបដល់ស្នែងអីស្រេច កាប់ឬស្សីអីដាក់ក្នុងមួយត្រង់សេរមានស្នែងមួយ ឬស្នែងពីរស្រគួរស្រេច ។ ដើម្បីមានគ្រោះថ្នាក់ត្រង់សេរណាយើងចងអង្រឹង សែងចេញមក ។ ដល់ខ្ញុំចេះនិយាយលេងជាមួយគាត់ ស្នែងប៉ុននឹងបានគ្រប់មួយមុខព្រួញ យើងនឹងមិនគ្រប់ទេ បើមានតែគេបានអីសែងខ្ញុំ ។ ខ្ញុំនិយាយចឹងគាត់ទះស្មាខ្ញុំ ដូង គាត់ថាឯងឆ្កួតដឹង អាណាគេឲ្យនិយាយលេងឆ្កួតៗ ។ គាត់ថា ហើយខ្ញុំអត់មាននឹកឃើញអីថានិយាយសើច ។ គាត់មកវិញ មិត្ត ឈិន នឹងថាអប់ខ្ញុំនឹងគាត់

និយាយលេងអា ភាព ហ៊ា! ប្រយ័ត្នតិចណា បង ម៉ាញ នឹងគាត់មកតាមខ្ញុំ គេរាយការណ៍ថាពេលនាំសារនឹង ទៅត្រង់សេរមួយៗពួកនោះ អត់ហ៊ានឡើងទេ ខ្ញុំទេ! នាំសារយកទៅឲ្យ ថ្ងៃត្រង់ក៏ខ្ញុំហ៊ានឡើងដែរ ។ ចឹងវាឃើញយើងឆ្លងចុះឆ្លងឡើង ចឹងពេលណាកន្លែងណាវាលទៅ ខ្ញុំព្រួទៅកន្លែងណា ភ្លឺស្រែរវើគុម្ពបរត់ឆ្លងផុត កន្លែងណាមានព្រៃគុម្ពរំពាក់ ខ្ញុំរត់ទៅទៀតទៅ ។ ចឹងពីត្រង់សេរនីមួយៗ ម៉្លេះហើយគាត់អប់រំខ្ញុំថាឈប់ឲ្យខ្ញុំឡើង គាត់ផ្ដាំគេអូប្រាប់គេខាងមុខដែរនឹង ថាកុំ ឲ្យខ្ញុំខស្សាហ៍ឡើងនាំសារពេក ព្រោះត្រង់សេរនឹង វាសម្គាល់ហើយ ឲ្យខ្ញុំសារ៉េត្រង់សេរ សារ៉េអីចេញ មិនទាន់សារ៉េណា ដល់ចឹងគាត់មកធ្វើការណែនាំហើយ ទៅដល់ពិតទៅណែនាំ ទៅបានមួយយប់ទៅតែម្ដង ។ គ្មានអ្នកណាថារស់ទេខ្ញុំនោះ ពេទ្យក៏ដោយ មន្ទីរពេទ្យតំបន់គេ ចោលនឹង ។

បូលី : មន្ទីរពេទ្យតំបន់ទុកចោល?

ភាព : ចា៎! មន្ទីរពេទ្យតំបន់អីខាងលិចស៊ឹងសារ៉ាយ ដែលខ្ញុំថាលិចត្រពាំងអណ្ដើកនឹងទៀត មិនជិតទេ ហើយសែងតាំងពីខាងត្បូងតាកែវក្បាលថ្នល់វត្តដើងចាប ។

បូលី : ប៉ុន្មានម៉ោងមកដល់ សែង?

ភាព : គិតទៅសែងចេញម៉ោង៧យប់ មកភ្លឺយើងបៀនថ្នល់បែកគូស វាងសែងមកព័ទ្ធវាងរហូតមកដល់ថ្នក់បែកគូសភ្លឺៗ ហើយមកដល់កន្លែងមន្ទីរពេទ្យនឹង ម៉ោង៨ល្ងាច ម៉ោង៨ជាង ។

បូលី : អូ៎! ឡើង១ថ្ងៃ២៤ម៉ោងហើយចឹង?

ភាព : ចា៎! មួយយប់ម៉ាថ្ងៃ មកដល់ពេទ្យមើលឃើញគេលែងធ្វើបណ្ដោយ គេឲ្យយកទៅដាក់គ្រែផ្សេង សូម្បីតែមិត្តភ័ក្កកងជាមួយគ្នា ដេកកងជាមួយគ្នា ក៏គេអត់ស្គាល់ខ្ញុំដែរ ព្រោះវាអស់ឈាមហើយ វាស្លេក ដល់ហើយគេយកទៅដាក់ចោលចឹង ឈ្មោះ ផានីៗ នៅជាមួយខ្ញុំវាមិនអស់ចិត្ត វាថាមើលទៅយើងប្រើពងប៉ារ៉ាពងឆ័ត្រយោងនោះ ឃើញបើកពងប៉ារ៉ានឹងថាទេ! ដូចថាសង្ស័យ គាត់ទៅម្ដងទៀតៗទាញពងមើលបានវាស្គាល់អាវខ្ញុំវាវឃ្មៀកក្រណាត់អូស្ត្រាលី ។ បានរត់ទៅប្រាប់គ្នាឯងឲ្យមកជួយមើលៗ បានស្រែកឡូឡា ហៅពេទ្យឲ្យទៅសែងយកទៅដាក់ជិត ហើយពេទ្យក៏រាយការណ៍ឲ្យអ៊ំប្រធានមន្ទីរនឹងៗគាត់ចាស់ហើយ ។

បូលី : ពីណាគេ?

ភាព : ឈ្មោះ អ៊ំ ចែម ប្រុស ។

បូលី : ចែម ប្រុស?

ភាព : ចា៎! ហ្នឹងប្រធានមន្ទីរភូមិភាគ មានមិនមែនតំបន់ទេណា ។

បូលី ៖ អូ! មន្ទីរពេទ្យភូមិភាគ?

ភាព ៖ ចា៎! មិនមែនតំបន់ទេ។

បូលី ៖ ចុះមន្ទីរពេទ្យតំបន់ពីណាវិញ?

ភាព ៖ មន្ទីរពេទ្យតំបន់នៅក្រោម ឈ្មោះអីទេមន្ទីរពេទ្យ ភ្លេចបាត់ហើយ មន្ទីរពេទ្យមុនឈ្មោះសោម ដែរនឹង ខាងមន្ទីរពេទ្យនឹង ប៉ុនក្រោយមកមិនដឹងណា ខ្ញុំចេញមកដុតមក ឈ្មោះ ចែម ប្រពន្ធគាត់ឈ្មោះអីទេ ខ្ញុំភ្លេចបាត់ទៀតហើយ នឹកឃើញថ្ងៃមុន អត់មានកូនទេ។ គាត់នឹងប្រាថ្នាថា ត្រូវមាននិស្ស័យកូនហៅ គាត់ត្រូវថែមើលខ្ញុំរស់ គាត់ធ្វើតែ២នាក់អនុប្រធានគាត់ទេ ៣នាក់ប្រពន្ធគាត់។

បូលី ៖ មើលមីងនឹង?

ភាព ៖ ចា៎! ធ្វើឲ្យខ្ញុំនឹង ធ្វើរបួសខ្ញុំនឹង។

បូលី ៖ ព្យាបាលរបួសមីង?

ភាព ៖ ចា៎!

បូលី ៖ តា ចែម នឹង ប្រធានមន្ទីរភូមិភាគផ្ទាល់មកមើលមីង?

ភាព ៖ ចា៎! គាត់មកធ្វើទាំងប្ដីទាំងប្រពន្ធគាត់ទាំងយប់ ហើយអនុប្រធានគាត់កាលនោះឈ្មោះ ខែម

បូលី ៖ ខែម?

ភាព ៖ ឈ្មោះ ខែម កាលនោះគាត់អាយុ២៨ឆ្នាំទេ អនុប្រធាននឹងមិនទាន់មានប្រពន្ធផង ដល់ខ្ញុំជាហើយបានគាត់ការប្រពន្ធ តែគាត់ចេញពីនឹងមកនៅកន្លែងភូមិភាគ មកកន្លែងមន្ទីរពេទ្យកណ្ដាលសមរភូមិ ឧបមាថាទីសមរភូមិចឹងហើយមកដល់មន្ទីរក្រោយគាត់នៅចំកន្លែងកណ្ដាល យកទៅដាក់ជាពីរដំណាក់ គាត់ធ្វើគ្នាគាត់៣នាក់នឹង។ គាត់ដាក់សារ៉ូមដាក់អីឲ្យ របួសខ្ញុំគាត់ដេរនៅទាំងអស់ ចុះបើខ្ញុំអត់ដឹងខ្លួនផង គាត់ដាក់សារ៉ូម ដាក់ផ្លាស្មាដាក់ដៃទាំងសងខាង ដើម្បីឲ្យមានឈាមទៅ គាត់ធ្វើរបួស។ គ្រាន់មានឈាម គាត់ឲ្យពួកនឹងចំហ៊ុយប្រដាប់អីសព្វគ្រប់លើគាត់។ គាត់ធ្វើទាំងប្ដីទាំងប្រពន្ធគាត់ ហើយពូអនុប្រធាន។

បូលី ៖ ខែម?

ភាព ៖ ចា៎! ៣នាក់នឹង អ្នកមកដេរដៃខ្ញុំនេះ។

បូលី ៖ គាត់ដេរឲ្យ?

ភាព ៖ ចា៎! ដេរខ្ញុំស្រែក ពូមាត់ខ្ញុំស្រែក ពូដូចថាខ្ញុំស្រែកចឹង អូយ! ឈឺណាស់ដេររបួសអញទាំងនៅ។ តែខ្ញុំអត់ដឹងខ្លួនខ្ញុំថាទេ អត់ដឹងទេ គាត់ទេ ជាអ្នកដំណាលប្រាប់។

បូលី ៖ អ្នកប្រាប់មីង?

ភាព ៖ គាត់ថាប៉ុននឹងសង្ឃឹមថារស់ហើយ ។ ហើយគាត់ហៅខ្ញុំតែកូនៗ ។ អ្ហ៎! ឈ្មោះ ស៊ុន ប្រពន្ធគាត់ ។

បូលី ៖ ស៊ុន នឹងក៏ជាពេទ្យភូមិភាគដែរ?

ភាព ៖ ចា៎! ប្រពន្ធគាត់នឹងពេទ្យដែរ ។

បូលី ៖ តំណែងជាអី អាចថាជាអនុទេ?

ភាព ៖ អនុនឹង ខែម នោះទេ ស៊ុន នឹងដឹងគាត់ខាងអីទេ ប៉ុនឃើញចេញសំបុត្រពីមន្ទីរពេទ្យពីអីលើគាត់នឹងឯង ។

បូលី ៖ ស៊ុន ដែរ?

ភាព ៖ ចា៎! បានគាត់នឹងហើយព្យាបាលយកចិត្តទុកដាក់ព្យាបាលខ្ញុំ ទាល់ បើខ្ញុំហូបអីកើតកុម្មុងមួយសេរី មួយស្រឡាញ់ ។

បូលី ៖ បើខុសពី ចែម, ស៊ុន នឹង អាចធ្ងន់ធ្ងរដែរតាមមីងគិតមើល?

ភាព ៖ អាចបោះបង់ចោលតែម្តង ។

បូលី ៖ ព្រោះគាត់នេះ ដូចថាជាអ្នកជំនាញដែរតាមមើល?

ភាព ៖ ចា៎!

បូលី ៖ គាត់រៀនពេទ្យបានជ្រៅជ្រះទេ តា ចែម, ខែម, ស៊ុន?

ភាព ៖ ហឺ! គាត់មនុស្សចាស់ដែរ ពេទ្យពីដើមក៏មិនដឹងម៉េចដឹង បើខ្ញុំអត់ដឹងដែរ បើកាលនោះគាត់អាយុរៀង៥០ជាងហើយនឹង ។

បូលី ៖ អ្ហ៎! រៀងចាស់ទុំហើយ?

ភាព ៖ ចា៎!

បូលី ៖ អ្នកស្រុកមកពីណាដែរ?

ភាព ៖ ខ្ញុំអត់បានសួរប្រវត្តិគាត់ទេ ។

បូលី ៖ គ្រាន់ដឹងថាគាត់ប្រធានមន្ទីរពេទ្យភូមិភាគ?

ភាព ៖ ចា៎! ប្រពន្ធគាត់នឹងខ្ទង់៥២ ៥៣ដែរនឹង ចំណាស់ៗអស់ហើយ ។

បូលី ៖ មែនទែនទៅ មន្ទីរពេទ្យភូមិភាគទីតាំងធំនៅណា?

ភាព ៖ ហ្នឹងនៅខាងលិចបឹងសាព៍យនឹង គេហៅ ។

បូលី ៖ ក្នុងស្រុកអីបើយើងនិយាយឲ្យចំទៅ?

ភាព ៖ ហ្នឹងក្នុងស្រុកត្រាំកក់ ។

បូលី ៖ ចុះឃុំអាចដឹង?

ភាព ៖ ហ្នឹងឃុំបឹងស្រង៉ែ ។

បូលី ៖ ហើយមន្ទីរពេទ្យនឹងជាអគារចាស់ ឬក៏អគារដែលសង់សម័យ៣ឆ្នាំនឹង?

ភាព ៖ អត់ទេ យើងធ្វើសម័យនៅព្រៃប្រក់ស្បូវ យើងធ្វើតែឈើៗប្រក់ស្បូវនឹង ។

បូលី ៖ មិនមែនមានអគារអីត្រឹមត្រូវ?

ភាព ៖ អត់ទេ នៅនឹងព្រៃដំឡូងព្រៃអីនឹង ដាំដំឡូងដាំអីនឹងពេញទួលស្វាត់នៅនឹង ព្រៃលាក់ការណ៍ ខ្លាចយន្តហោះខ្លាចអីទម្លាក់គ្រោះថ្នាក់ អ្នកដេកពេទ្យនឹង ។ ប៉ុន១ខែគេប្រជុំជីវភាពអ្នកជម្ងឺម្ដង ។

បូលី ៖ ចឹងអ្នកជម្ងឺនឹងប្រជុំដែរ?

ភាព ៖ ប្រជុំៗកុំឲ្យថាដូចជាកងទ័ពអីនឹងវាមានភាពសេរី គាត់មិនសូវគោរពសិទ្ធិពេទ្យអីចឹង ពេទ្យហាមមិនស្ដាប់ មិនអីចឹងគេប្រជុំធ្វើការកសាងខ្លះ ដឹកនាំប្រជុំខ្លះ ។

បូលី ៖ ពីណាគេអ្នកដឹកនាំប្រជុំកាលនឹង?

ភាព ៖ ប្រធាននឹងហើយ ។

បូលី ៖ តា ចែម នឹង?

ភាព ៖ ចា៎! ប្រធាន ។

បូលី ៖ មីងអត់ដែលស្គាល់ត្រកូលគាត់?

ភាព ៖ អត់ ។

បូលី ៖ ចុះមន្ទីរពេទ្យតំបន់វិញ នៅណាវិញ?

ភាព ៖ មន្ទីរពេទ្យតំបន់កាលមុននៅភ្នំជីសូរមាលដែរ តែដល់ក្រោយមកគេចុះមកនៅណាទេ ខ្ញុំអត់បានតាមដានច្បាស់ដែរ ។

បូលី ៖ ក្រោយមកដូរទីតាំង?

ភាព ៖ ចា៎! ដូរទីតាំង ។

បូលី ៖ ព្រោះភ្នំជីសូរមាលនេះ តាំងពីជំនាន់ឆ្នាំ៧៣ ៧៤ នោះទេ?

ភាព ៖ ចា៎!

បូលី ៖ មិនមែនក្រោយ៧៥មកទេ?

ភាព ៖ តាំងពីនិយាយរួមតាំងពី៧០នោះ ៧០ ៧១ មន្ទីរពេទ្យរៀបចំដំបូង តាំងពី តា និន នៅ ជ្រើសរើសទៅរៀនពេទ្យ ។ បងស្រីខ្ញុំមួយ កូនស្រី តា និន មួយ ។

បូលី ៖ ទៅរៀនពេទ្យ?

ភាព ៖ ចា៎!

បូលី ៖ ហើយពីណាគេប្រធានមន្ទីរពេទ្យតំបន់?

ភាព ៖ តា នឹងឈ្មោះ សោម ដែរដឹង ។

បូលី ៖ សោម ដែរ?

ភាព ៖ ចា៎!

បូលី ៖ ប្រុសហេ៎! សោម?

ភាព ៖ សោមៗ ប្រុស ប្រពន្ធគាត់ឈ្មោះអី គៀត ហើយអីម៉េចទេ ភ្លេចហើយ យូរពេកខ្ញុំនៅក្មេងដែរ មិនសូវចាំកាលនឹងឲ្យខ្ញុំទៅរៀននៅនឹង ។

បូលី ៖ មីងអាចរៀបរាប់បន្តទៀតបានទេ បន្ទាប់ពីព្យាបាលហើយយ៉ាងម៉េច មីងសម្រាន្តស្នាក់នៅពេទ្យប៉ុន្មានខែអី?

ភាព ៖ ខ្ញុំសម្រាកពេទ្យ២ខែ ខ្ញុំរៀនដើរពេទ្យបង្រៀនខ្ញុំដើរ ព្រោះដើរអត់បានទេ ព្រោះយើងត្រូវក្បាលជង្គ ៗ និយាយរួមមួយដងខ្លួនយើងនេះ ត្រូវនៅសល់មួយចំហៀង១នេះ ដៃជើងយើងនៅស្ពឹក ដៃយើងនេះត្រូវរបួស ស្នាមរបួស ។ ដល់ចឹងដៃនៅត្រង់ចឹង អត់មាននេះអីកើត ហើយជើងស្ពឹកដើរអត់កើត គាត់នឹងឲ្យពេទ្យគ្រាខ្ញុំរៀនដើរ ម្នាងមួយៗ ហើយគាត់ឲ្យពេទ្យជួសទឹកដាក់នៅម្ជប់ដើមដំឡូង ឲ្យខ្ញុំចេះទៅមុជទឹកខ្លួនឯង ។ គាត់បណ្ដោយឲ្យមុជទឹកទាំងជើងអី អត់ទាន់សះស្រួល គាត់ថាចាំមើលវិធីខ្ញុំមុជទឹកធ្វើម៉េចអីម៉េច គាត់ឲ្យពេទ្យទៅនៅឈរមើលនឹងពេទ្យ២នាក់ខ្លាចខ្ញុំដួលនោះ ហើយខ្ញុំមានហ៊ាននេះអី ខ្ញុំជ្រលក់ក្រមាក្រណាត់ហើយ ខ្ញុំជូតខ្លួនខ្ញុំ មិនហ៊ានចាក់ទឹក ខ្លាចទឹកវាទទឹកមុខរបួស ពេលយើងជ្រលក់ក្រមា យើងយកមក ដាក់លើក្បាលើអីជុសលាងខ្លួនចឹងទៅណា ។ កន្លងមកគាត់ប្រើតែពេទ្យឲ្យសំអាតឲ្យដល់រយៈ ពេលបាន៦-៧ខែ អត់ទាន់ជាសះស្រួលទេ ជើងអីវាបានសះ ប៉ុននៅត្រគៀកចឹងទៅខ្ញុំសុំ គាត់ចេញ នឹកអង្គភាពពេក ។ ធ្លាប់នៅមុខ ដល់មកនៅក្រោយវាស្ងាត់អត់ចេះនៅ គាត់ចេះអង្វរ ខ្ញុំអត់ឲ្យនេះទេ មុននឹងខ្ញុំចេញនឹងខ្ញុំជួយព្យាបាលបាន២ខែ ។ ខ្ញុំដើរព្យាបាលគេ២ខែ ប៉ុនគាត់មិនប្រើឲ្យធ្ងន់ធ្ងរទេ គាត់គ្រាន់ថា ឥឡូវកូនឯងទៅដើរជាមួយពេទ្យ

ទៅតែយប់ពុក អត់ឲ្យដើរទេ ទៅព្យាបាលអត់ឲ្យចាក់ថ្នាំឲ្យគេទេ កូនឯងចាំតែបូមថ្នាំឲ្យគេបាន ហើយ ។

បូលី : ហេតុអី?

ភាព : គាត់អត់ចង់ឲ្យដើរខ្លាចយើងនៅងងឹតមុខនៅអីចឹង ដល់ហើយគាត់អត់ឲ្យដើរឆ្ងាត់ឆ្ងែង ណែនាំខ្ញុំជួយព្យាបាលបាន២ខែដែរ ។ ហើយនឹងខ្ញុំទៅបានរៀនបន្តនៅកន្លែងនឹងឯង ។

បូលី : រៀនពេទ្យនឹង?

ភាព : ចា៎! រៀននៅកន្លែងនឹង ។

បូលី : ស្ថានភាពនៅក្នុងមន្ទីរពេទ្យយ៉ាងម៉េចដែរ មីងរវល់ខ្លាំងទេ ហើយមនុស្សច្រើនទេអ្នករបួស?

ភាព : រវល់ណាស់ អ្នករបួសច្រើនណាស់ ចុះតំបន់ផង ភូមិភាគផង ពីកងពលទី២ ទី១ ក៏ដេកនៅនឹងដែរជុំគ្នា ។

បូលី : ទី១ ទី២?

ភាព : ចា៎!

បូលី : ទី៣?

ភាព : ខ្ញុំមិនអាចស្គាល់គេអស់ទេ ដឹងថាកងពលទី១ ទី២ ព្រោះនារីៗដេកពេងជាប់គ្នា កងពលតំបន់ពួកភូមិភាគគេដាក់ខាងនេះចឹង ដាក់ដេក ។ ហើយបើថាពេងអ្នកជម្ងឺ ប្រុស៧៥-៦ ពេង១នីមួយៗ២០ម៉ែត្រអីនោះ មិនចេះតិចទេ អ្នករបួសមួយថ្ងៃមួយយប់ ចូលជួនកាល ១០ ជួនកាល៦-៧ អត់ដែលបាន ។ ប៉ុនការហូបចុកគ្រប់គ្រាន់ កាលនោះយើងនៅចង់និយាយ ថាសង្គមគេមិនទាន់ឈប់ចាយលុយទេ កាលនឹងខ្ញុំត្រូវរបួស នៅទេ ។

បូលី : នៅធូរ?

ភាព : ចា៎! ខ្ញុំម្តាយខ្ញុំទៅលេង បង សោម គណៈតំបន់គាត់អ្នកជូនទៅ ។

បូលី : ម៉េចបានគាត់ស្គាល់ បានគាត់ជូនទៅ?

ភាព : ម៉ែខ្ញុំគាត់ស្គាល់ដឹង គាត់ទៅជួបនៅត្រពាំងអណ្តើក ជួបគាត់សួរថាមីងទៅណា ។ ថាទៅលេងជាមួយកូន ដេកពេទ្យ ។ ថាកូនមីងឯងឈ្មោះអី នៅកងណា? ថានៅ២១ ។ អ៊ូ!កងនារី ។ ថាមីងឯងស្គាល់មន្ទីរពេទ្យអត់? ថាខ្ញុំអត់ស្គាល់ទេ ព្តែគេថាដេកនៅខាងលិចបឹងសាវ៉ាយ ក៏គាត់ជូន ម្តាយខ្ញុំបរទេះដឹកបន្លែ ដឹកដូងអីមកជួយមន្ទីរពេទ្យ ក៏គាត់ជូនទៅដល់ផ្លូវចូល ។ គាត់ឲ្យចូល ម៉ែខ្ញុំថាអត់ចូលទេ ។ គាត់ថា ចូលទៅស្រណោះ ឃើញរណ្តូករណែលអ្នករបួស

ចឹង ។ គាត់អត់ចូលទេ គាត់ថាចុះមកឲ្យខាងពេទ្យនឹងឲ្យជូនខ្ញុំទៅជួបគាត់វិញ ។ ដល់ឃើញសំបុត្របង សោម នឹងគាត់ផ្ញើមកកន្លែងអ៊ំប្រធានមន្ទីរនឹង បានឲ្យខ្ញុំចេញទៅជួប ។

បូលី : សរសេរថាម៉េច សំបុត្រនឹង?

ភាព : សុំអនុញ្ញាតិឲ្យឈ្មោះនេះចេះៗមកជួបម្តាយៗមកលេងចឹង នៅកន្លែងនេះៗចឹង ឲ្យមានពេទ្យជូនមកផង ក៏គាត់ឲ្យពេទ្យជូនមក ។

បូលី : ហើយដល់ពេលគាត់ជូនម្តាយមីងមកនឹង ជិះអីមក ឡានហើយអី?

ភាព : អត់ទេ ដើរ ព្រៃផ្លូវចូលព្រៃ មិនមែនមានផ្លូវភ្លឹងចូលបានទេ ព្រោះកន្លែងលាក់ការណ៍ គេខ្វាចគីញចូលទៅមានគ្រោះថ្នាក់ដល់យុទ្ធជន យុទ្ធនារីដែលស្នាក់នៅនឹង ។ ដល់ចឹងបានខ្ញុំមកជួប ប៉ុនខ្ញុំទៅដេកពេទ្យបាន២៥ថ្ងៃ បងស្រីខ្ញុំស្លាប់ ។

បូលី : ម៉េចចឹង?

ភាព : ចា៎!

បូលី : គាត់ឈឺហើយម៉េច?

ភាព : អត់ទេ នៅកងជាមួយគ្នា ទាហានដូចគ្នា ។

បូលី : របួសដែរ?

ភាព : គាត់ត្រូវស្លាប់ម៎ង គ្រាប់មីនត្រយូងបាក់មួយចំហៀង គាត់ឈរបាញ់បង់ត្រឡោកមាត់ត្រង់សេរ ហើយវាដាក់មីនត្រយូងតមក ត្រូវចំស្មាខាងនេះបាក់ ។

បូលី : ស្លាប់ភ្លាមនៅកន្លែង?

ភាព : ចា៎! ត្រូវចឹងទៅ អុកគូថ ញាប់ចូលក្នុងត្រង់សេរ ឈាមវរមកអ្នកនៅក្នុងត្រង់សេរបានដឹង ព្រោះត្រង់សេរ យើងជីកសសរៗយើងជីកប៉ុននឹងៗ ជីកតៗគ្នាទៅ ហើយអ្នកនៅអង្គុយក្នុងមួយ យាម២ ដល់២នាក់នោះគេនៅនេះ គាត់ឡើងទៅឯង ។ ខ្ញុំត្រូវរបួសភ្លាម គេដកគាត់ ។ ដកមកនៅក្រោយ ។ តែគាត់អារម្មណ៍គាត់មិនល្អ រឿងខ្ញុំត្រូវរបួសបានគាត់ទៅសមរភូមិវិញ គេមិនឲ្យទៅ ។ ទៅបានមួយអាទិត្យនឹង គាត់ស្លាប់ ។

បូលី : អ្នកនៅក្នុងត្រង់សេរជាមួយមីង និយាយប្រាប់មីង?

ភាព : ចា៎! ម៉ែខ្ញុំអត់និយាយទេ ប៉ុនខ្ញុំដឹង ព្រោះអ្នកត្រូវរបួសទៅពីនេះគេនិយាយប្រាប់ និយាយប្រាប់អនុសេនាធំនៅជាមួយខ្ញុំនេះក៏គាត់ស្លាប់ ហើយបងស្រីខ្ញុំក៏ស្លាប់ដែរ ។ ដល់នេះខ្ញុំដឹងថាម៉ែខ្ញុំមកលេង ក៏ខ្ញុំទៅនិយាយលេងជាមួយគាត់មួយសន្ទុះហើយក៏ខ្ញុំធ្វើសួរៗ ថាចុះបងស្រីម៉េចហើយ មុនដំបូងខ្ញុំសួរគេអ្នករបួសនៅកងជាមួយខ្ញុំទេ ។ ពុថាបងក្រីងនឹងស្លាប់ហី ម៉ែ?

គាត់ថា ហ្អឹងហើយស្លាប់កូន ។ ដល់ហើយគ្រាន់សួរចឹង គាត់ចាប់ផ្ដើមនិយាយ ថាមិនបាច់គិតអីច្រើនទេ កូន គិតតែខំមើលតែរបួសកូនឯងឲ្យឆាប់ជាទៅ ។ បងកូនឯងក៏សុខសប្បាយដែរ គាត់និយាយចឹង គាត់អត់ហ៊ានប្រាប់ថាស្លាប់ទេ ។ ដល់ខ្ញុំថា ម៉ែៗចាំលាក់ខ្ញុំអីខ្ញុំដឹងតាំងពីថ្ងៃដំបូងនោះ ហើយម៉ែឯងបានទៅពូនផ្នូរ បានទៅរៀបចំទុកដាក់គាត់ស្រួលហើយអត់ ។ ម៉ែបានទៅ ដល់ចឹងបានគាត់ឆ្លើយថា ម៉ែបានទៅ មុនដំបូងគាត់លាក់ថា ខ្លាចខ្ញុំមានអារម្មណ៍មិនល្អ ។ ខ្ញុំថាធម្មតាទេ ម៉ែអើយ ជះទឹកដាក់គ្នា ខ្ញុំថាបើមិនទទឹកគេ ក៏ទទឹកយើងដែរ ។ ខ្ញុំអត់មានតូចចិត្តទេ ថាម៉ែឯងកុំភ្លេចថា ទោះបីបងស្លាប់ក៏មាននៅខ្ញុំនេះដែរ ។ គាត់មកលេងដែរ ជួបបានប្រហែលមួយម៉ោង គាត់ទៅវិញ គាត់ឲ្យអីវ៉ាន់ពេទ្យដឹកទៅចូលកន្លែងមន្ទីរពេទ្យទៅ ។ ក្រោយមកខ្ញុំមកសមរភូមិវិញ អត់ទាន់ជាផង សុំគាត់ចេញ ពុកខ្ញុំនឹងគាត់អត់ឲ្យចេញទេ ពីយប់ខ្ញុំទៅសុំចេញគាត់មិនឲ្យចេញសុំ២នាក់ប្ដីប្រពន្ធ ។ ដល់ខ្ញុំដេកគិតមួយយប់មិនដឹងរកវិធីម៉េចដោះទេ ពិបាកខ្ញុំមិនចង់នៅទេ មន្ទីរពេទ្យខាងក្រោយ ដូចថាស្ងប់ស្ងាត់ណាស់ សុខចិត្តទៅនៅមុខចុះគ្នាឯងមុខនឹកឃើញថាកំសត់កម្រ ធ្លាប់នៅត្រង់សេរជាមួយគ្នា ធ្លាប់លំបាកវេះនឹកឃើញ ។ ដល់ព្រឹកឡើងទៅសុំគាត់ទៀត ។ សុំគាត់ថាឥឡូវសួរម៉ែឯងទៅ ឲ្យគេពិនិត្យរបួសពិនិត្យអី ទៅដល់កុហកគាត់ថា ពុកឲ្យចេញហើយ ចេញសំបុត្រខ្ញុំមួយមកទៅតាំងព្រឹកអរពេកអត់ហូបបាយទេ ។ ខ្ញុំថាថ្ងៃណាដែលខ្ញុំនេះ ខ្ញុំមកលេងជាមួយពុកឯងវិញ ខ្ញុំអត់ភ្លេចទេ ។ ដល់មកតាមផ្លូវចុះយើងត្រូវរបួសចឹងយើងវាខ្សោយនោះ ដើរបានដីប្រហែល២៣គីឡូដី អស់កម្លាំងដេកនៅក្រោមម្លប់ដើមធ្លកៗ គាត់ឲ្យនិរសាមកតាម ។ និរសាក្មេងៗអាយុ១៤-១៥ឆ្នាំកងមក២ ខ្ញុំចេញមកពីរនាក់បងស្រីមួយនៅស្រុកទ្រាំងនៅខាង១០៨នឹងឈ្មោះ បង ធីៗ គាត់រាប់អានខ្ញុំជាប្អូន បាន អា ហេង ហើយ លី គេមកតាមនឹង បងៗអ៊ំឲ្យមកតាមបងឯងទៅវិញ គាត់អត់ឲ្យចេញទេ ។ បងឯងចង់ចេញ ចាំជាចាំចេញ ព្រោះគាត់អាចគាត់ជួបជាមួយប្រពន្ធគាត់ ខ្ញុំសុំចេញ គាត់ឲ្យកំប្រេះ ឲ្យបង់លាងខ្លួនឯងឲ្យថ្នាំឲ្យអីមក ។ ថាខ្ញុំអត់តាមទេ ខ្ញុំថាអង្វរ បើប្អូនឯងស្រឡាញ់បង មិនបាច់ឌុបបងទៅមន្ទីរពេទ្យវិញទេ ឥឡូវប្អូនឯងឌុបទៅកន្លែងមន្ទីរនិរសានៅត្រពាំងអណ្ដើកនឹង ។

បូលី : មន្ទីរនិរសាៗភូមិភាគ?

ភាព : មន្ទីរនិរសាតំបន់ ។ ដល់ចឹងទៅ ឌុបទៅនិរសាត្រពាំងអណ្ដើកនឹង និរសានឹង ឌុបទៅត្រពាំងធំបន្ត ។

បូលី : ទៅធ្វើអីត្រពាំងធំ?

ភាព ៖ គេកន្លែងនិរសានីងមួយកន្លែងទៀត ។

បូលី ៖ និរសាភូមិភាគនឹង?

ភាព ៖ និរសាតំបន់ដូចគ្នា ។

បូលី ៖ មានពីរផង?

ភាព ៖ និរសាភូមិភាគអត់មានទេ មានតែតំបន់ទេ ។

បូលី ៖ ចឹងហេ៎?

ភាព ៖ ចា៎! កន្លែងត្រពាំងអណ្ដើកនឹងក៏របស់តំបន់ដែរ ។

បូលី ៖ នៅត្រពាំងអណ្ដើកមួយ?

ភាព ៖ នៅត្រពាំងធំ នៅត្រាំកក់ ។

បូលី ៖ ៣កន្លែងផង?

ភាព ៖ ចា៎!

បូលី ៖ ត្រពាំងធំស្រុក តា ម៉ុក?

ភាព ៖ ចា៎!

បូលី ៖ របស់តំបន់១៣?

ភាព ៖ ចា៎! ដល់និរសាជូនទៅដល់ផ្ទះ ។

បូលី ៖ ជូនទៅដល់ផ្ទះទៅ?

ភាព ៖ ចា៎!

បូលី ៖ ផ្ទះម្ដាយ ឪពុកមីង?

ភាព ៖ ចា៎! ទៅផ្ទះម្ដាយខ្ញុំៗទៅដេកផ្ទះម្ដាយខ្ញុំបាន២យប់ ខ្ញុំរកទៅដំណើរមិនស្អាតទេ ខ្លាចពេទ្យតាម ។ ចឹងខ្ញុំចេញម៉ោង៧ ម៉ោង៩ពេទ្យមកដល់ ។

បូលី ៖ ខ្លាចមិនស្អាតយ៉ាងម៉េច?

ភាព ៖ ខ្លាចគាត់ថាមិនដល់ គាត់ដឹងផ្ទះហើយ ប៉ុនខ្លាចយើងអត់ជា ហើយសម័យនោះបើសិនជាអ្នកជម្ងឺចេញទៅអត់ជា អង្គភាពគេបន្ទោសគាត់ មានចឹងទេ គាត់ខ្លាចអង្គភាពធ្វើការស្ដីបន្ទោសគាត់ណា តែព្យាបាលអត់ទាន់ជា យើងឲ្យវិលត្រឡប់ទៅវិញ ធ្វើអីវាមិនកើត ។ ដល់ហើយខ្ញុំចេញម៉ោង៧ព្រឹក ម៉ោង៩ ទៅដល់ឲ្យយកម៉ូតូទៅឌុបខ្ញុំមក ។

បូលី ៖ ពីណាគេ?

ភាព ៖ កន្លែងអ៊ីប្រធានមន្ទីរនឹង ឲ្យបង ផ្ទួរៗ គាត់នៅកងពលទី៧ដែរ គាត់ទៅដេកពេទ្យនោះ គាត់ស្គាល់ផ្ទះខ្ញុំ គាត់ស្គាល់ម៉ែឪខ្ញុំ គាត់មកតាម ។ ហើយខ្ញុំទៅហួស ខ្ញុំទៅអគ្គភាព ទៅបាន១០ថ្ងៃ ទៅបានដល់មួយថ្ងៃ ខ្ញុំចូលទៅនៅសមរភូមិកណ្ដាលជាមួយការភ្លើងធំ ។ ទៅអត់ទាន់ជាផង លាងរបួសលាងអ៊ីខ្លួនឯង ដល់ហើយវារើរបួស ទៅជាក្ដៅវាអត់ទាន់បានចាក់ថ្នាំទៀងទាត់នោះ យើងវាមិនលេប ព្រោះគ្មានពេទ្យណាតែម្នាក់ឯង គ្មានបានចាក់ថ្នាំ ។

បូលី ៖ ដងំប៉ោ?

ភាព ៖ ចាំ! គេសែងមកដេកពេទ្យកន្លែងតំបន់វិញទៀត ។

បូលី ៖ ពេទ្យតំបន់ម្ដងនេះ?

ភាព ៖ ចាំ! គេហៅកន្លែងវរៈរួម មន្ទីរពេទ្យវរៈរួម គេចុះពីតំបន់មក មានវរៈរួមគេមួយគេហៅមន្ទីរពេទ្យវរៈរួម គេទទួលរួមសមរភូមិកណ្ដាលនឹង មុននឹងបញ្ជូនឡើងទៅតំបន់ បានមកដេកនៅនឹងមួយខែទៀត បានជា ។ តែខ្ញុំសរសេរសំបុត្រផ្ញើទៅ គាត់អ៊ីប្រធានភូមិភាគ គាត់សរសេរតបមកវិញ ថាកូនឯងអត់ជឿឪពុក នៅឲ្យជាទៅរៀនបានជ្រៅជ្រះតិច គាត់លើកហេតុផលច្រើនដែរ អនាគត មានកូនឯង មក ។ ប៉ុនការពិតក្រយ៉ោយើងកម្ម មិនត្រូវបានស្រណុក តែពេលវេលានឹងតិច ។

បូលី ៖ ហើយនៅមន្ទីរនិរសាតំបន់១៣នេះ ពីណាគេប្រធានមន្ទីរនិរសា?

ភាព ៖ អត់ដែលស្គាល់ផង នៅក្នុងតំបន់គេដឹងតែមួយកន្លែងៗវាក្មេងទៀត មួយកន្លែងនោះបង រុំៗធ្លាប់នៅមន្ទីរ១៥០ជាមួយគ្នា ។

បូលី ៖ ភាគច្រើនស្រី ហើយប្រុស និរសា?

ភាព ៖ ស្រីៗ ។

បូលី ៖ ស្រីទាំងអស់?

ភាព ៖ ចាំ!

បូលី ៖ ម៉េចអត់យកប្រុសចឹង?

ភាព ៖ អត់ ប្រុសសមរភូមិ ស្រីៗទៅតាមគេខាងក្រោយ និរសា ជំនាន់នោះគារៀបឲ្យសុទ្ធតែប្ដីពិការ ។

បូលី ៖ អ៊ូ! ម៉េចចឹង?

ភាព ៖ មិនដឹងម៉េច តា បើមិនរៀបឲ្យខាងពួកពិការនឹង អ្នកណាយក ពិការៗសមរភូមិ ពិការដើម្បីជាតិ គាត់ចឹង ។

បូលី ៖ ចុះអានឹងយើងទទួលស្គាល់ហើយ ថាពិការដើម្បីជាតិ?

ភាព ៖ ចា៎!

បូលី ៖ តែយកអនាគតមនុស្សស្រីទៅយកទៅលេងសើចយ៉ាងម៉េចដែរ មីងយល់ថាយ៉ាងម៉េចកាលនឹង យើងកុំអាលគិតមកឥឡូវ កាលនោះវិញ?

ភាព ៖ វាកាលពិតទៅវាមិនហ៊ាន ម្នាក់ៗសុទ្ធតែគោរពហើយ វាមិនហ៊ានប្រឆាំងទេ ខ្លាចៗមានការខ្លាច គេបន្ទុំយកខ្លះពិការភ្នែកនឹង គ្នាដឹកដៃដើរទៅណាមកណា យ៉ាប់ដែរ ។ បើគេអ្នកពិការដៃពិការជើងគ្រាន់តិច អាពិការភ្នែកទាំងពីរនេះ ដឹកដៃ ឈ្មោះគ្នារហូត អាប្តីប្រច័ណ្ឌផងតាំងពីស៊ីចុក សម្ពស្សស្ទៅរមាន់ស្ទៅរអី ថាសុទ្ធតែប្រពន្ធដាក់ឲ្យសុទ្ធតែឆ្អឹង វាមានបញ្ហាច្រើនដែរកាលនោះ ។

បូលី ៖ មានមាន់ហូបចុកហើយ ធូរដែរកាលនឹង?

ភាព ៖ សម័យនោះ និយាយរួមជីវភាពយើងអត់យ៉ាប់ទេ សម័យសង្គ្រាម សូម្បីតែពួកខ្ញុំនៅសមរភូមិក៏មិនយ៉ាប់ដែរ បាយស្ងួតបាយកញ្ចប់មែនទែន តែម្ហូបបរិបូរណ៍ អត់ពិបាកទេ ព្រោះអីខាងមូលដ្ឋានគេផ្តល់ឲ្យរហូតតាមភូមិតាមឃុំណា ។

បូលី ៖ ហើយដែលជួប តា ទេកាលសម័យនឹង?

ភាព ៖ សម័យនោះ អត់បានជួបទេ ថាជួប តា ម្តងម្កាលក្នុងនាមថាយើងនៅក្នុងជួរ ជួបពេលធ្វើមេទិញផ្នែកកងទ័ពម្តងៗដែរ ។ ថាជួបញឹក តែបង សោម ទេគណៈតំបន់គាត់ឡើងទៅធ្វើគណៈអធិបតី គាត់មានចំណាប់អារម្មណ៍មានអីនៅក្នុងនឹង ។

បូលី ៖ ជាទូទៅ គាត់មានចំណាប់អារម្មណ៍យ៉ាងម៉េចខ្លះ តា សោម?

ភាព ៖ ចំណាប់អារម្មណ៍គាត់ពាក់ព័ន្ធ លើកពីហេតុផលពីចលនាតស៊ូចិន ឲ្យយើងម្នាក់ៗបានយល់ដឹងថាពីរបបពីមុនមានការជិះជាន់ គៀបសង្កត់ពីមុនគេនិយាយថាវណ្ណៈមូលធន វណ្ណៈសក្តិភូមិអីចិន គេពង្រឹងយើងឲ្យយើងក្រោកឡើងតស៊ូអីចឹងទៅ ។ ហើយយើងចូលរួមការពារប្រទេសជាតិកុំឲ្យកាលនោះ គេនិយាយពីអាមេរិចហើយយួនធៀវគីនោះ វាឈ្លានពាននោះ ឲ្យយើងត តាំងជាមួយជនបរទេសដែលមកលេបទឹកដីចិន ។ សូម្បីតែលោកសីកអស់ដែរនឹង គ្មានអ្នកណាបន្ទុំទេ លោកសីកម៉ង មូលហេតុសីកថ្ងៃនោះ ថ្ងៃសន្និបាតធ្វើមេទិញរួមកងទ័ពឆ្នាំ៧២ លោកនៅវត្តត្រពាំងអណ្តើក លោកនៅពេញៗកុដិពេញយើងធ្វើបុណ្យនៅអូរសារ៉ាយនឹង កងទ័ពនារីដើរកាត់វត្តនឹងៗ ហើយកងទ័ពនារីកាលនោះអ្នកអាយុច្រើនហើយ ២៥នោះមាន ពីត្រឹម១៦ឡើងទៅ សុទ្ធតែក្មេងៗ ហើយគេស្រីៗគេលះបង់ធ្វើកងទ័ព ។

ដល់ពេលទៅចូល ដូរ សុទ្ធតែបុរស នារីតែមួយអនុសេនាធំទេ នៅប្រឡោះគេទៀត ។ ហើយកាំភ្លើងធំ កាំភ្លើង តូចអីដាក់តាំងពីមុខ ពួកខ្ញុំនៅកាំភ្លើងមួយដូរៗយកទៅចំរុះពីមុខ ចេះហើយថាគេថត ហើយថាកើតបក្សចិន ។ ហើយគេនិមន្តលោកទៅចូលរួម លោកនិមន្ត កាត់កង់ទ័ពនារី ហើយបង សោម ប៊ុនធ្វើការអធិប្បាយណាស់ គាត់លើកហេតុផល មើល សូម្បីនារីមានការភ្ញាករលីក កាន់អាវុធធ្វើកង់ទ័ពអីចឹង ដើម្បីរំដោះជាតិការពារទឹកដី ស្អីៗ គាត់លើកច្រើន ហើយយើងជា យុវជនដើមទ្រូ៥ហត្ថ យើងសុខចិត្តសំងំសុខនៅផ្ទះនៅអី ហើយសូម្បីតែលោកក៏ដោយ គេជគុណ និមន្តមើល ប្រមើលមើលៗ ថានារីមានចលនា តស៊ូភ្ញាក់រលឹកប៉ុនណាអី លើកហេតុផល ចុះឡើងៗ មានអីលោកសឹកខ្ទេចគ្មានសល់ទេ ។ គ្មានអ្នកណាបង្ខំលោកទេ គាត់ថាចេះ គេជគុណ គួរតែខ្មាស់ មានការខ្មាស់អៀនដល់នារីៗ ។

បូលី : ថាឲ្យលោកចឹងម៉ង?

ភាព : ចា៎! ដែលនៅវ័យក្មេងស្ម័គ្រចិត្តលះបង់ក្រុមគ្រួសារ លះបង់រូបរាងកាយដែលមានសម្រប់ស្រស់ស្អាត ប៉ុនណាស់ ។

បូលី : និយាយពូកែ?

ភាព : ចា៎! គាត់អធិប្បាយអស់ទាស់របស់គាត់ ល្មមលោកខ្លះអត់ហ៊ានមើលមុខនារីទេ ដល់ហើយលោកចាប់ផ្ដើមសឹកៗ គ្រប់វត្ត គ្មានអ្នកណាបង្ខំលោកទេ ការពិត ខ្មាស់ ។

បូលី : តា សោម ពូកែនិយាយ?

ភាព : ចា៎! ប៉ុនណាស់គាត់ តែកម្មវិធីហើយ គាត់ចូលអធិប្បាយហើយ មិនបាច់ទេ ដូចពិធីករចំណានរបស់គាត់ម៉ង ។ មានអីមានកាំភ្លើងតូចកាំភ្លើងធំ គាត់អធិប្បាយតាមនឹង ឡើងក្បោះក្បាយ ។ ហើយគេយកសិល្បៈយកទៅសម្ដែង នារីភ្ញាក់រលឹកចូលធ្វើកង់ទ័ពវ៉ៃអាពួកធៀវគីអី បាញ់ផាប់អីគេសម្ដែងនៅលើឆាកប៉ុនណាណី ហើយទំនួញទួញសោករបស់កសិករ ហើយឈ្មោះ គន្ធាៗ ច្រៀងពិរោះផង អស់ទាស់ហើយសិល្បៈតំបន់ កាលនឹងគួរសម មិនមែនល្មមទេ ។

បូលី : ពីណាគេប្រធានសិល្បៈតំបន់កាលនឹង?

ភាព : កាលនោះ ណាទេខ្ញុំស្គាល់មិនអស់ទេ ភ្លេចឈ្មោះគេដែរ ដល់នៅក្នុងស្រុកនឹងស្គាល់លោកគ្រូ ឆាំ អ៊ី តែស្លាប់ហើយ ។

បូលី : តែប្រធានសិល្បៈស្រុក?

ភាព : ហ្នឹងសិល្បៈស្រុក តំបន់នឹងមិនដឹងណាទេ ។

បូលី ៖ ស្រុកអន្លុងវែង?

ភាព ៖ ចា៎! នេះ ឈិន ឈាង អីនៅសិល្បៈនៅអន្លុងវែងដែរ ស្រុកអន្លុងវែងខាងច្រៀងអាយ៉ៃនោះ។

បូលី ៖ ឈិន ឈាង យើងនឹង?

ភាព ៖ ចា៎!

បូលី ៖ អ្នកច្រៀងអាយ៉ៃ?

ភាព ៖ ចា៎! សួរគាត់មើល។

បូលី ៖ កូនចៅរបស់ ឆាំ អ៊ី នឹង?

ភាព ៖ កាលនឹងគាត់នៅក្រុមភ្លេង ក្រុមវង់ជាមួយ ឆាំ អ៊ី ដែរនឹង។ ប៉ុនដល់ហើយគាត់ស្រឡាញ់ស្រីគាត់ ពង្រត់មកបាត់មិនដឹងទៅណាណី ចូលមកតាំងពី៧១មកនឹង គាត់មកនៅក្នុងនឹងរហូតមកនឹង។

បូលី ៖ ឈិន ឈាង សិល្បៈអាយ៉ៃយើងរាល់ថ្ងៃនឹង?

ភាព ៖ ចា៎! ចុង៧០ដឹង គាត់រត់មក ហើយនេះអាចុង៧០នឹងហើយគាត់ចូលមកក្នុងវិញ។ គួរសមដែរនឹង ទៅខាងនោះពិចារណា។

បូលី ៖ កាលនឹងក្នុងចិត្តគិតយ៉ាងម៉េច ដែលយើងចូលរួមតស៊ូបដិវត្តន៍ ប្រយុទ្ធប្រឆាំងជាមួយវៀតណាម។ តើក្នុងចិត្តនឹងស្អីជាកម្លាំង ដែលធ្វើឲ្យមីងមានចិត្តក្លាហាន មិនចង់នៅពេទ្យ ចង់នៅសមរភូមិវិញ?

ភាព ៖ ការពិតទៅ យើងថាយើងមិនដែលឆ្លងកាត់ទេ រឿងសមរភូមិនោះ ប៉ុនចិត្តនឹងវាចង់តែទៅកាន់អាវុធផ្ទាល់ខ្លួនឯងចឹងម៉ង។ អត់មានអ្នកណាបង្ខិតបង្ខំទេ ការស្ម័គ្រចិត្តរបស់ម្នាក់ៗពេលប្រជុំជារួមនារីរាប់រយនាក់មិនតិចទេ បង បូ គាត់ប្រជុំ។ ដល់ចឹងស្ម័គ្រចិត្ត អ្នកណាខាងស្ម័គ្រចិត្តទៅកងទ័ពលើកដៃទៅកងទ័ព ព្រឹកឡើងមកចុះឈ្មោះនឹងកន្លែងគាត់ អ្នកណាទៅនិរសាព្រឹកឡើងមកចុះឈ្មោះកន្លែងគាត់បែងចែក។

បូលី ៖ ដូចថាមីងសុខចិត្តចេញពីផ្ទះចោលឪពុកម្ដាយបងប្អូន អត់ខ្លាចគ្រាប់ខ្លាចព្រៃខ្លាចផ្សែងអីទេសុខចិត្តទៅប្រយុទ្ធនៅនឹង?

ភាព ៖ ចា៎!

បូលី ៖ អ្វីដែលជាកម្លាំងដែលជម្រុញឲ្យមីងចូលទៅ ដោយសារអី គិតថាខទាហរណ៍ថាដើម្បីតស៊ូរំដោះជាតិ ឬយ៉ាងម៉េច?

ភាព ៖ អានឹងសំខាន់យើងថាយើងដូចជាប់ឥទ្ធិពលនយោបាយបំពាក់បំប៉នរបស់ខាងគេ ខាងអ្នកដឹកនាំនេះក៏បានដែរ តែមួយទៀតយើងសន្និះឃើញថា ការឈ្លានពានរបស់អាមេរិចកាំងហើយពួកយួនធៀវគី ដែលវាចូលមកដឹបូងវាធ្វើបាបប្រជាជនយើងពិតប្រាកដនឹងភ្នែកធ្វើឲ្យយើងមានការឈឺចាប់ ចាប់រំលោភស្ត្រីនៅក្នុងវត្តក្នុងអីចឹង ។ វាមកធ្វើឲ្យយើងមានហេតុផលចឹង ដែលយើងមិនអាចទ្រាំទ្របាន យើងនាំគ្នាក្រោកធ្វើការតស៊ូថាកុំឲ្យបរទេស វាមកគៀបសង្កត់ដល់ប្រជាជនយើងចឹង ។ នឹកឃើញថាពេលនេះ វាធ្វើប៉ុននេះ បើយើងគ្រប់គ្នានៅតែក្រោមវាមិនក្រោកឈរ វារិតតែទន្រ្ទានខ្លាំងថែមទៀត វាមកសម្លាប់លោកសង្ឃ វាមកចាប់ស្រីយកទៅសម្រាតសេពកាមនៅវិហារវត្តនៅអីចឹង ធ្វើឲ្យយើងនេះ ។ ហើយវាមកហើយវាគប់មាន់ គប់អីស៊ី បាញ់ប្រទូសប្រទះ ខ្ញុំខ្លាចយើងម្ចាស់ផ្ទះមិនតិចទេ យើងទេដែលខ្លាចវាម៉្លេះហើយនឹកឃើញថា បើសង្គមនៅតែរបៀបនេះ ទៅថ្ងៃមុខប្រជាជនយើងគ្មានសិទ្ធិសេរីភាពនឹងដើរហើរ នឹងធ្វើស្រែចំការបានទេ ។ ចុះថ្ងៃណាក៏ថ្ងៃរត់ៗ តែវាមកហើយ រត់ចោលផ្ទះដែលហ៊ាននៅៗជួបខ្លាចគ្រោះថ្នាក់ ឆែកឆេរយកឃើញមាសឃើញប្រាក់អីគ្មានសល់ផងមាន់កាប់ស៊ីតាមចិត្តជ្រូកចាក់កស៊ីមុខយើង អត់មានសល់អីទេ ។ ភ្លេអីវ៉េរូលដុតស៊ីមុខយើងមិនមាត់មិនក ពាងអង្ករអីវាស៊ីដូចវាម្ចាស់ចឹង ។ ហើយរថក្រោះវាបរកិនចេកកិនអំពៅខ្ទេចខ្ទី អត់មានសល់ទេ បើផ្ទះណាមានកូនក្រមុំហើយ ច្បាស់តែលង់ហើយ ចេញមិនរួចទេ ខូចខ្លួនខូចប្រាណដោយសារពួកវាចឹងឯង ចាប់យកតែ២-៣នាក់ចឹង យកនាំគ្នាដេកសប្បាយវាមួយយប់២-៣នាក់ ខ្លះមានដល់ស្លាប់ ខ្លះទ្រុឌទ្រោមសុខភាពចឹងទៅ ។ ហ្នឹងហើយបានយើងមានការឈឺចាប់ណាស់ បើយើងនៅខ្លាចថ្ងៃក្រោយយើងគ្រោះថ្នាក់ចឹងទៀត ដល់ឃើញស្រស់ៗនឹងភ្នែកយើងទ្រាំមិនបាន មិនមែនចេះថាចេញទៅអត់មានមូលហេតុទេ ។ វាមានមូលហេតុចឹង បានយើងថាមានកំហឹង ។

បូលី ៖ ហើយជាលទ្ធផលមីងយល់ឃើញយ៉ាងម៉េចដែរ បន្ទាប់ពីក្រោយ៧៥ ចន្លោះឆ្នាំ៧៥ដល់៧៩ តើយើងទទួលបានសេរីភាពរស់នៅសុខសប្បាយ ដូចដែលយើងចង់បានគិតកាលតស៊ូទេ?

ភាព ៖ តាមពិតទៅខាងបើយើងនិយាយសម័យ៣ឆ្នាំនោះ វារបបកងទ័ព ហើយនឹងមូលដ្ឋានខុសប្លែកគ្នាឆ្ងាយណាស់ មិនដូចគ្នាទេ ។ ខាងកងទ័ពនោះ គេអត់មានគៀបសង្កត់អីណាបង្អត់បាយបង្អត់អីទេ ។ បាយឆ្នាំងរួមមែន ប៉ុន្តែគេមានសេដ្ឋកិច្ចគេដាំស្ល្រស្រួល ។ ប៉ុនគ្រាន់ថា វាដំណាក់កាលក្នុងការខ្វះស្បៀងក្នុងឆ្នាំ៧៧ ៧៨នេះ យើងហូបបាយលាយដំឡូង លាយ

ពោត ។ បើ៧៦ យើងនៅហូបបាយសុទ្ធនៅឡើយ យើងចេញទៅយើងដឹកអង្ករដឹកអីបានទៅច្រើន ។

បូលី : ប៉ុនមីងយល់ថាម៉េចដែរ ដូចបំណងដែលយើងចង់បានទេ បន្ទាប់ពី៧៥មក?

ភាព : ថាដូចទៅ ក៏វាមិនបានដូចទាំងស្រុងទេ ព្រោះយើងមិនទាន់មានអីអភិវឌ្ឍន៍អីរីកចំរើន ហើយបន្ទូរដៃពីការងារព្រោះនៅក្តាប់អាវុធនៅឡើយ ។ ខ្ញុំរហូតដល់៧៩រត់ បានឈប់កាន់អាវុធខ្ញុំមានផ្ទៃពោះ៦ខែ ខ្ញុំប្រគល់អាវុធទៅឲ្យប្តីខ្ញុំៗមាន៧ខែត្រូវរត់ចេញពីរតនគិរី ។ ខ្ញុំមកសម្រាលនៅកុងប៉ិញនេះ គិតទៅដើរពីរតនគិរីតាំងកូន៧ខែ មកសម្រាលនៅកុងប៉ិញ កន្លែងផ្ទះដើមស្វាយកុងប៉ិញ ដើរឡើងពងជើងអស់ ។

បូលី : ៧៩?

ភាព : ចា៎! ៧៩ ។

បូលី : ៧៩ វៀតណាមមិនទាន់កាន់កាប់អន្លង់វែងនៅឡើយទេចឹង?

ភាព : នៅទេ ។

បូលី : នៅខាងខ្មែរក្រហមយើងនៅឡើយទេ?

ភាព : ចា៎!

បូលី : ឆ្នាំប៉ុន្មាន បានវៀតណាមវ៉ៃយកអន្លង់វែងយើងបាន?

ភាព : អន្លង់វែងនេះ ការពិតខ្ញុំរត់ផុតពីនេះទៅ ខ្ញុំមិនមែនមកសម្រាលហើយនៅនឹងទេ ខ្ញុំសម្រាលម៉ោង៤ម៉ោង៥ភ្លឺ ម៉ោង៧ខ្ញុំចេញដំណើរទៅទៀត ។

បូលី : អ៊ូ! មិនមែននៅមួយកន្លែងបាន២-៣ថ្ងៃអីទេ?

ភាព : អត់ទេ ខ្ញុំនោះទៅដល់ភ្នំតាង៉ុកនោះ ទៅយើងបៀតខ្សែម បៀតអីនោះ ។

បូលី : អ៊ូ! នៅជិតប៉ៃលិននោះ សំឡូតនោះ?

ភាព : ហ្នឹងម្តុំភ្នំតាង៉ុក ម្តុំបារាំងធ្លាក់ អូរអន្ទក់ ។

បូលី : អាចសំឡូត?

ភាព : ចា៎! ខ្ញុំទៅដល់នឹង បីកូនទៅដល់នឹង មិនដែលបានអាំងភ្លើង មិនដែលបានដឹកទឹកឆ្អិន កំសត់ណាស់បើនិយាយពីប្រវត្តិ ហើយប្តីនៅរតនគិរី ។

បូលី : នៅនោះនៅឡើយទេ?

ភាព : ចា៎! មកតែឯងជាមួយនារីៗ ។

បូលី :	កំសត់ ប៉ុនសម្រាប់ខ្ញុំៗស្តាប់សាច់រឿងរបស់មីង ឆ្ងាញ់ជាងបាយទៀត ខ្ញុំសុខចិត្តអត់បាយ ឲ្យតែមីងព្រមនិយាយឲ្យខ្ញុំស្តាប់ ។

ភាព :	ខ្ញុំទៅដល់នោះ និយាយរួមខ្ញុំបែកគ្រួសារតាំងពីកូន៧ខែក្នុងពោះ កូនកើតបានមួយឆ្នាំ កូនស្លាប់ ៦ខែបានជួបមុខគ្នា បែកគ្នា បានជួបគ្នាវិញ ។

បូលី :	ខ្ញុំចង់បកមក៧៥តិចមីង ពេលដែលយើងឥឡូវមីងចេញពីពេទ្យមក មីងត្រឡប់ទៅសមរភូមិវិញ នៅតែនឹងរយៈពេលប៉ុន្មានទៀត?

ភាព :	ខ្ញុំចេញមក ខ្ញុំត្រូវរបួសនៅសមរភូមិខាងត្បូងតាកែវ ដល់ចេញមកអង្គភាពផ្លាស់មកនៅខាងជើងតាកែវវិញ ។ ការពិតខាងជើងតាកែវវា២ត្រឡប់ មិនមែនត្រឡប់ទេ ។ វៃមុនដំបូងខាងជើងតាកែវវៃម្តុំស្វាយព្រៃ មួយសារ ដល់ហើយបានទៅខាងត្បូងតាកែវវិញ ។ ដើរចុះដើរឡើងៗកងទ័ព យើងដើរបង្វិលចង់ជុំហើយ ពីខាងកើតខាងច្រកតុំខាងច្រកអីនឹងក៏ទៅវៃដែលគ្រប់កន្លែង ។ ដល់ហើយក្រោយមក៧៨ ខ្ញុំទៅនៅភ្នំដិន មុនដំបូងទៅនៅជើងទឹកៗទៅនៅជាមួយពួក ត-៧នេះឯង នៅជាមួយ តា បាវ តាអីនេះ ប៉ុនមិនដឹងណាទេប្រធានកងពល ។

បូលី :	តា បាវ យើងនៅភូមិអភិវឌ្ឍន៍?

ភាព :	ចា៎! តា បាវ យាយ ណៃ ។

បូលី :	ខ្ញុំសម្ភាសន៍គាត់ដែរតើ ។

ភាព :	ចឹងគាត់នៅខាងជើងទឹកខាងនឹង ។

បូលី :	គាត់ថាគាត់នៅខាងជើងទឹកដែរ ខាង ។

ភាព :	ពួកខ្ញុំទៅហាត់ជើងទឹកបានប៉ុន្មាន ស្រាប់ជិតមួយខែស៊ូមិនរួចទេពិបាកណាស់ ទៅនៅព្រំដែនតែម្តង ។

បូលី :	តា បាវ គាត់នៅកងពល ឬក៏នៅវរសេនាតូចរបស់តំបន់?

ភាព :	ហ៎េ! កាលនោះ នៅវរសេនាតូចទេៗ ពួកត-៧ទេ កាលនឹង ។

បូលី :	តា បាវ នៅត-៧ដែរ?

ភាព :	ចា៎!

សែ :	តា បាវ តា ភាព ស្លាប់ ។

បូលី :	តា ភាព ប្រធានកងពលមែន?

ភាព :	មិនដឹងទេ សុទ្ធតែវរៈ ។

បូលី ៖ អត់ទេ ក្រោយមកក្រោយ៧៩?

សែ ៖ ហ្នឹងហើយឡើងកងពល ។

បូលី ៖ កងពល៩១៩?

ភាព ៖ ៩១២ ។

បូលី ៖ តា បាវ គាត់៩៨០?

ភាព ៖ ៩៨០ ។ បាន បង ណៃ គាត់ទៅនៅកងកាំភ្លើងធំជាមួយកងនឹងឯង ។

បូលី ៖ ប្រពន្ធ តា បាវ នៅនឹងដែរ?

ភាព ៖ បង ណៃ នឹងគាត់ កាន់តេអូ ។

បូលី ៖ ប្រពន្ធ តា បាវ នឹង?

ភាព ៖ ចា៎! នៅអគ្គភាពជាមួយខ្ញុំចាស់ នៅផ្ទះបៀតជាមួយខ្ញុំដែរ គាត់កាន់តេអូ ដល់នេះកន្លែងតេអូគេត្រូវការ កន្លែងកាំភ្លើងធំគេត្រូវការតេអូ បានយកទៅនៅតេអូ ។

បូលី ៖ ចឹង ណៃ ប្រពន្ធតា បាវ នេះ កាន់តេអូ?

ភាព ៖ ចា៎!

បូលី ៖ តែគាត់មិនទាន់ការកាលនឹង?

ភាព ៖ នៅទេ ។

បូលី ៖ នៅជាមិត្តភ័ក្តទេ?

ភាព ៖ នៅជាមិត្តភ័ក្តរួមសមរភូមិ ពួកនឹងការនឹងជ័យជំនះដែរតាមមើល ខ្ញុំមិនបានសួរគាត់ ។ ហើយបានខ្ញុំទៅនៅភ្នំដិន ទៅឈរភ្នំដិន២ឆ្នាំ ។

បូលី ៖ ៧៣?

ភាព ៖ ៧៤ ៧៥ ។

បូលី ៖ នៅលើភ្នំតែម្តង?

ភាព ៖ ខ្ញុំនៅពីមុខភ្នំតែម្តង កន្លែងត្រពាំងទឹកពីមុខភ្នំ ជាប់ជើងភ្នំ ។

បូលី ៖ នៅបន្តប្រយុទ្ធបន្តទៀត?

ភាព ៖ ចា៎!

បូលី ៖ កាលនឹងតប៉ុន្មានខ្លះទៅខាងនឹង?

ភាព ៖ ២ ត-៦ ហើយត-៨ ។

បូលី ៖ តែ២នឹងទេ?

ភាព ៈ ចា៎!

បូលី ៈ គ-៦ ហើយ គ-៨?

ភាព ៈ ចា៎!

បូលី ៈ ចុះ គផ្សេងៗទៀតគេទៅខាងណា?

ភាព ៈ នៅកន្លែងទីរួមខេត្ត ព័ទ្ធទីរួមខេត្ត ។

បូលី ៈ គេនៅការពារខាងទីរួមខេត្តវិញ?

ភាព ៈ ចា៎! ព្រោះវានៅទីរួមខេត្តគាកែវនឹងវាអត់នៅឆ្ងាយបែក ហើយយើងអន្តគាសោមនឹងវានៅខ្លះទៀត ទាល់តែ អាគាកែវនេះទាល់តែភ្នំពេញបែកខ្ទាំងហើយបានវាសារភាពនោះ ។ បានវាដាក់អាវុធអត់ព្រមទេ ។

បូលី ៈ ចឹង គ-៦ហើយនឹង គ-៨ទេ ដែលទៅព្រំដែន?

ភាព ៈ ចា៎!

បូលី ៈ គ-៣, គ-៤, គ-៥ គ-៧នេះ ៤នេះគឺនៅ?

ភាព ៈ គ-៧នឹង គៀកព្រំដែនជើងទឹក ។

បូលី ៈ គ-៧ព្រំដែនជើងទឹក?

ភាព ៈ ជើងទឹក ។

បូលី ៈ ចឹងពួកខាង តា បាវ, តា ភាព នឹង?

ភាព ៈ ហ៊េ! ភាព មិនមែនគ-៧ទេ ។

បូលី ៈ ភាព ៩១២?

ភាព ៈ ៩១២ បងភាព មិនដឹងចេញគាមកងពលណាទេ ព្រោះខ្ញុំបែកគាត់ ព្រោះកាលនេះ គាត់នៅគ-៣ ។

បូលី ៈ ភាព?

ភាព ៈ ចា៎! គ-៣ប៉ុន្តែក្រោយមកគេដកទៅលិចនោះ ។

បូលី ៈ ទៅខាង?

ភាព ៈ ព្រោះកងទ័ពត្រូវដកឡើងភូមិភាគ ។ ពីដើមកំណើតគ-៣ គាត់នៅជាអនុសេនាធំទេ កង១៦ ហៅអនុសេនាធំ១៦ ។

បូលី ៈ គាត់នៅអនុសេនាធំ១៦?

ភាព ៈ ចា៎! ១៦នៅជាមួយ ឆន គេឡើងប្រធានវរសេនាតូចក្រោយនឹងឯង ។

បូលី :  ឆន ឡើងវរសេនាតូច បន្ទាប់ពី ម៉ាញ?

ភាព :  ចា៎! តែគេនេះនៅ១៦ដដែល

បូលី :  ពូអាចចាំទេ ត-៥?

សែ :  ខ្ញុំនៅភូមិភាគ ។

បូលី :  ពូនៅភូមិភាគមិនចាំដូចមីង ។

សែ :  ខ្ញុំអង្គភាពទើបទទួលបែកភ្នំពេញហើយ ។

បូលី :  ទាល់បែកចឹង បានគេទាំងអស់នឹងគេបញ្ជូលមកកងភូមិភាគ ។

ភាព :  គេជ្រើសរើសមកតែមួយកងវរៈនារីនឹងឯង  កន្លែងភូមិភាគនឹងគេមាននារីមួយវរសេនាតូចដែរ តែ បង រឿន គាត់អត់ព្រម គាត់យកមកពីតាកែវវិញ ។ ពួកនោះឲ្យនៅខាងកាត់ដេរកង យាយ វិន ។ អាណិតពួកខ្ញុំក្មេងៗតូចៗ ឲ្យយកមកនៅក្រុង ។ ចូលមកគេសើចចង់ងាប់ របេះរប៉ោះតូចៗ ។

បូលី :  ពីណាគេសើច?

ភាព :  ពួកកងពលនឹងបន្ទាប់គ្នា ងាប់ហើយមើលពួកតាកែវ មកធំតែជើងខោ ចុះ១៦ បើរើសពួកក្រោយកាលខ្ញុំទៅនៅភ្នំដិននឹងខ្លះទើប១៥នឹង ពួកយកពីនារីដឹក គេហៅនារីកុប្បកម្ម អ្នកដឹកជញ្ជូន អ្នកស្នាក់ការសែងរបួសយកទៅបញ្ចូលជ្រើសរើសចេញពីភូមិទៅក្មេងៗ ។ ចឹងទៅរបេះរប៉ោះហើយអ្នកចាស់បំបែកចេញអស់ហើយ មកកងពលទី២ផង ទៅយើងកោះកុងកំពតនោះផង បំបែកអស់មេក្រុមអីទៅកាន់អនុសេនាធំ ទៅកាន់អីអស់ តាមកងនោះគេជ្រើសរើសទៅស្រែអំបិលអីអស់ ។ បានចឹងរើសអាក្រោយមកពង្រឹង ។

បូលី :  តូចហ្នឹង?

ភាព :  ចា៎! តូចៗ ។

បូលី :  ចឹងមិញមីងនិយាយថា យាយ រឿនៗកាត់ដេរនឹង នៅខាងណាវិញ?

ភាព :  យាយ វិន កាត់ដេរ នៅចក្រអង្រែ នៅភ្នំពេញ ។

បូលី :  គេហៅមន្ទីរអីគេនឹង ឬរោងចក្រអីគេអានឹង?

ភាព :  មិនដឹងគេហៅអី គេហៅកន្លែងកាត់ដេរចឹងម៎ង ។

បូលី :  គាត់ប្រធាន?

ភាព :  ប្រធានវរសេនាធំ យាយ វិន ប្រពន្ធ តា សាន ។

បូលី :  តា សាន ណា?

ភាព ៖ តា សាន ជន្ទូ តារឿន តា សាន០៦ ។

បូលី ៖ ចឹង យាយ វិន នឹងប្រធានរោងចក្រកាត់ដេរនៅចក្រអង្រែ អាចទេមើលមើលទៅ?

សែ ៖ មិនមែនទេ គ-១ត្រូវបំបែកយើងជិតពេទ្យលោកសង្ឃ ។

បូលី ៖ អីគេ គ-១?

សែ ៖ គ-១ តម្បាញ រោងចក្រតម្បាញយើងនឹង ។

ភាព ៖ ប៉ុនពួកនឹងមិនមែនតម្បាញទេ ខាងកាត់ដេរទេ ។

បូលី ៖ កាត់ដេរ យាយ វិន?

ភាព ៖ ចាំ! ចូលទៅកាត់ដេរទេ មួយវរៈនឹង ។

បូលី ៖ យាយ វិន ប្រពន្ធ តា០៦?

ភាព ៖ ចាំ!

បូលី ៖ ប្រពន្ធតា០៦ ប្រធានរោងចក្រកាត់ដេរ ខ្ញុំដាក់ចឹងសិន?

ភាព ៖ ចាំ!

បូលី ៖ នៅម្តុំណា រោងចក្រកាត់ដេរ?

ភាព ៖ កាលនឹងគេថាយកទៅដាក់កន្លែងចក្រអង្រែ ខ្ញុំអត់ដឹងដែរ បើខ្ញុំអត់បានទៅផង មិនដែលស្គាល់គ្នាផង ។ គេក៏នៅអង្គភាពផ្សេង ។ អត់ទៅ កាលនោះ ចាំថាឲ្យទៅចក្រអង្រែ ។

បូលី ៖ ហើយយាយ វិន ប្រធានវរសេនាធំទៀត?

ភាព ៖ ចាំ!

បូលី ៖ វរសេនាធំខាងកាត់ដេរនឹង?

ភាព ៖ ដល់នេះគាត់ ប្រធានខាងកងទ័ព ។

បូលី ៖ ខាងកងទ័ពទេ?

ភាព ៖ ខាងកងទ័ព យាយ វិន គ្រប់គ្រងជាមួយយាយ រ៉ាន់ នេះ តា ស៊ុង ។

បូលី ៖ វរសេនាធំលេខប៉ុន្មាន?

ភាព ៖ មិនដឹងលេខប៉ុន្មានទេ គេភូមិភាគ ខ្ញុំអត់ដឹងដែរ ។

បូលី ៖ កងពលណា?

សែ ៖ កងពល៨១១ ។

ភាព ៖ ៨១១ដែរ ។

បូលី ៖ ប៉ុនរបស់ភូមិភាគណា ភូមិភាគនិរតី?

សែ ៖ របស់មជ្ឈិម ។ នៅភូមិភាគពិសេស មិនមជ្ឈិមជាអ្នកគ្រប់គ្រង ។

បូលី ៖ អូ! ចឹងគាត់ពិសេស?

សែ ៖ ហ្នឹងហើយភូមិភាគពិសេស ប្រចាំក្រុង ។

បូលី ៖ ប៉ុនពិសេស វាមាន១១, ១២, ១៣, ១៤?

ភាព ៖ ចាំ! ១៤ ។

សែ ៖ យកលេខ១១នឹងមកបូក១៤ ។

ភាព ៖ ១១បូកចូល១៤ ជ័យជំនះហើយ ។

បូលី ៖ ហេតុអីបានគេបូកចូលគ្នា?

សែ ៖ បូកចូលគ្នាមកពីគេទាមទារកម្លាំង ។ កម្លាំង១៤ច្រើនជាង មករៀប១៤ក្រោយ ។

បូលី ៖ ១៤មិនរបស់ តា០៥?

សែ ៖ ហ្នឹងហើយ១៤នឹងវាកើតមកក្រោយមកវាមិនទៅជា៨០១ ។

បូលី ៖ ហើយ១១ទៅជាអីវិញ?

សែ ១១នឹង ៦០៥ ។

បូលី ៖ ១១ក្លាយទៅជា៦០៥?

សែ បាទ! ៦០៥ កង តា ណាត នេះ ៧០៣ ។

បូលី ៖ បាទ! កង តា ណាត ១២នេះ៧០៣?

សែ ៖ ហ្នឹងមានតែ៣នឹងទេ ។

បូលី ៖ ចុះ១៣?

សែ ៖ ១៣នឹង អត់មានកើត អត់មានកងពល១៣ ។

បូលី ៖ អត់មានទេ?

សែ ៖ បាទ! កងពល១៣នេះ វាចងជាប់ជាមួយកងពលសម័យ លន់ នល់ នោះណា កងសិរីមតៈ កងពលលេខ១៣នេះ អត់យកលេខនឹងទេ ។

បូលី ៖ អត់យល់សុំបញ្ជាក់ម្តងទៀត ។ កងពលទី១៣ ដោយសារវាជាន់លេខជាមួយនឹងកងរបស់សិរីមតៈ?

សែ ៖ ហ្នឹងហើយ កងចាស់ ។

បូលី ៖ កងចាស់សិរីមតៈ?

សែ ៖ ហ្នឹងកងចាស់ ។

ភាព ៖ គេអត់យកលេខនឹងប្រើទេ ។

បូលី ៖ អត់យកលេខនឹងមកប្រើទេ?

ភាព ៖ ចា៎! ប្រើតែ១២ ១១ ១៤ ។

បូលី ៖ មានតែ១១ ១២ ១៤ទេ?

ភាព ៖ ចា៎!

បូលី ៖ អត់មាន១៣ទេ?

ភាព ៖ អត់ ។

បូលី ៖ ខ្ញុំយល់ហើយ មូលហេតុដែលអត់មានកងពល១៣ ដោយសារវាជាន់ជាមួយកងរបស់សិរីមគ្គៈនេះ?

ភាព ៖ ចា៎!

បូលី ៖ ចឹងគេមិនប្រើលេខនឹងទេ កំពុងតែវ៉ៃគ្នា កុំឲ្យវាច្រឡំគ្នា?

សែ ៖ បាទ!

បូលី ៖ ចឹងមានតែ១១ ១២ ១៤?

ភាព ៖ ១៤ ។

បូលី ៖ ១១ពីណាគេមេកងពល ពូ?

សែ ៖ តា ពៀច ។

បូលី ៖ តា ពៀច?

សែ ៖ បាទ!

បូលី ៖ តា ពៀច ពីណាគេ?

សែៈ តា ពៀច ជា ។

បូលី ៖ មានជាប់ខ្សែជាមួយ សុន សេន ទេ?

សែ ៖ អត់ទេ ។

បូលី ៖ នៅក្នុងនេះខ្ញុំឮសួរ សារឿន ជាមេកងពល ព្រោះ សារឿន នឹងជាក្មួយរបស់ សុន សេន កងពលលេខ១១?

សែ ៖ មានតា ពៀច ហើយនឹង តា សោម ពីរនាក់នឹង ។

បូលី ៖ តា ពៀច ហើយនឹង តា សោម?

សែ ៖ បាទ!

បូលី ៖ តា សោម តំបន់១៣នឹង?

សែ ៖ បាទ! តា សោម នឹងពីមុនសាស្ត្រាចារ្យផង ។

បូលី ៖ សាស្ត្រាចារ្យខាងអី តា សោម?

ភាព ៖ តា សោម ណាអត់ដឹងដែរ ។

បូលី ៖ តា សោម ច្រើន?

ភាព ៖ ចាំ! សោម

បូលី ៖ ប៉ុនអាចដែល ពួកគាត់ពូកែនិយាយ?

ភាព ៖ ចាំ! តា សោម នឹងហើយគេដក តា សោម នឹងគ្រប់គ្រងខាងទាហានដែរនឹង ខាងកងទ័ព ប៉ុនមិនដឹងនៅណា ផ្លាស់ពីតំបន់មកនោះ បង្កើតភូមិភាគមែននឹង ។

បូលី ៖ ចឹងអាចកងពល១១នេះ តា សោម ហើយនឹង តា ពៀច?

សែ ៖ តា ពៀចៗយោធា ។

បូលី ៖ តា ពៀច យោធា, តា សោម នយោបាយ?

សែ ៖ ហ្នឹង ។

ភាព ៖ ១៤ នឹង០៥ ០៦នឹងម៉ង ។

បូលី ៖ ចុះ១៧ តា ណាត?

ភាព ៖ តា ណាត ។

បូលី ៖ តា ណាត នឹងក៏ក្មួយ សុន សេន ដែរ ។ អនុរបស់ តា ណាត ពីណាគេ?

ភាព ៖ (មិនឆ្លើយ)

បូលី ៖ ដល់ពេល១៤ ពីមុនក្រែង ចេង អន ១៤?

សែ ៖ ចេង អន គាត់នៅភូមិភាគ អត់មានកាន់ទ័ពទេ ។

បូលី ៖ អត់មានកាន់ទ័ព?

ភាព ៖ ១៤ សូ សារឿន ។

បូលី ៖ សូ សារឿន?

ភាព ៖ ចាំ!

បូលី ៖ អនុរបស់គាត់ពីណាគេ តា០៦?

ភាព ៖ តា សាន ០៦ ស្អី សាន ទេ ។

បូលី ៖ យ៉ែម សាន ត្រកូល យ៉ែម សាន?

សែ ៖ មិនបានដឹងត្រកូល ហ្នឹងហើយគាត់យោធា តា សាវឿន នយោបាយ ព្រោះគាត់ចាត់តាំងជាយោធា ។

បូលី ៖ បាទ! អនុកងពល ។

ភាព ៖ មួយសន្និបាតកងទ័ព មានតែពីរនាក់នឹងទេ ទីនុយឡើងខ្ពឹត ។

បូលី ៖ គាត់សង្ហារមែន ខ្ញុំឃើញរូបថតគាត់យកកូនគាត់នៅទំនប់ដាច់ ។

ភាព ៖ ចាំ! ស្អាតម៉ង រៀងពីរនាក់នឹងឲ្យស្រឡះមើលទៅ កាលជ័យជំនះ៧៥ ធ្វើសន្និបាតកងទ័ព ប៉ុល ពត មក ។

បូលី ៖ ចឹងក្រោយ៧៥ កងពល១១នេះក្លាយទៅជាកងពលលេខប៉ុន្មានពូថាមិញ?

សែ ៖ កងពល១១ កងពលពាក់កណ្តាលចូលមក១៨ ។

បូលី ៖ អូ! ពាក់កណ្តាលចូលមក១៨ អត់មានក្លាយទៅជាកងពលអីមួយ?

សែ ៖ ទេ! បាត់ៗអស់លើងមិនដឹងទៅណា ខ្ញុំវាលែងចាំហើយមកព្រំដែនមក ជួនកាលគេរំលាយ ១១នឹងទៅ៥០២ កងវរក្រោះ ។

បូលី ៖ ៥០២?

សែ ៖ បាទ!

ភាព ៖ ៥០២នឹងកងយន្តហោះ កងវរក្រោះនឹង ជាមួយពួក តា ភាព អីប្រធាន១១ ។

បូលី ៖ ៨០១ បានកងពល១៨?

ភាព ៖ ចាំ!

បូលី ៖ ចឹងមីងនៅខាងមុខភ្នំដិននឹង នៅបន្តវៃរហូតដល់៧៥?

ភាព ៖ ចាំ!

បូលី ៖ ដល់ពេលបែក៧៥?

ភាព ៖ ចាំ! ទៅតែបែកភ្នំពេញគេប្រកាសថា យប់ថ្ងៃនឹងបែកភ្នំពេញហើយ បានឃើញឡើងទៅយកពួកខ្ញុំម៉ោង៩យប់ ។

បូលី ៖ ទៅយកមកធ្វើអី?

ភាព ៖ យកឡើងមកភ្នំពេញ ។

បូលី ៖ យកមកភ្នំពេញប៉ុន្មានឡានដែរ កាលនឹង?

ភាព ៖ ច្រើនដែរ នារីមួយវរសេនាតូច ខ្ញុំមិនបានរាប់ឡានផង បើខ្ញុំជិះឡានមកមុនគេ ខ្ញុំនៅចុងគេឡើងឡានមុន បើឡានជួបខ្ញុំពេលខ្ញុំល្ងាតយប់នោះ ខ្ញុំមកដើរល្បាតស្រាប់តែឃើញភ្លើង

ឡានច្រើនឆ្វល់ នាំគ្នារែអបរកដើមត្នោតរកអីអែបហើយបានឡានមកដល់ឈប់កាក់ឡាន បាន សួរទៅស្គាល់គ្នាឯងអ្នកធ្លាប់នៅការធ្វើឈ្លបជាមួយខ្ញុំ ធ្វើនារីឃុំនោះឈ្មោះ ឈឿនៗ បើក ឡាន គេថាមកវើយទៅភ្នំពេញ ។ ហា៎! ទៅធ្វើអី? ជ័យជំនះភ្នំពេញគេឲ្យមកយកពួកមិត្ត ឯងនឹង ។ ថាមែនហើយកុហក? កុហកអីឡើងឡានមក ។ បានឡើងឡានមកកន្លែង ។

បូលី : អត់មានរៀបចំអ៊ីវ៉ាន់អីទាន់?

ភាព : អត់ទេ ប្រមូលដាក់ៗមានយកស្អីមក មកតាមគេទៀត ។ មកយកឆ្នាំងយកចានមកធ្វើស្អី ស្មានតែភ្នំពេញនឹងអត់ចានឆ្នាំងស៊ី តា ។

បូលី : តា នៅភ្នំពេញនេះទេ?

ភាព : អត់ទេ តា មកពីនោះដែរ ជូនមក គាត់រត់មុខ យកមកប្រគល់ឲ្យនៅត្រឹមចោមចៅ ។

បូលី : មកត្រឹមចោមចៅ?

ភាព : ហ្នឹងហើយ បានឡានពីកងពលទៅយក ។

បូលី : តា ម៉ុក ជូនទៅ?

ភាព : ចា៎!

បូលី : ហើយគាត់ដេរទៀត?

ភាព : អឺ! ដេរ ។

បូលី : គាត់ថាគ្រាន់តែភ្នំពេញនឹង អត់មានឆ្នាំងដាំបាយ?

ភាព : ចា៎! តា ឯងម៉េចក៏មិនប្រាប់មុន ។ ចុះចាំអញប្រាប់ជ័យជំនះទាំងស្រុង ។

បូលី : ជ័យជំនះ១៧មេសា ថ្ងៃប៉ុន្មានមេសា បានមីងគេដឹកទៅភ្នំពេញ?

ភាព : ថ្ងៃ១៨ បានមួយយប់ ។

បូលី : ១ថ្ងៃគត់?

ភាព : ចា៎!

បូលី : ហើយពីណាគេអ្នកមកពីភ្នំពេញទទួលមីងនៅចោមចៅ?

ភាព : ខាងកងបង សូ សារឿន នឹងគាត់ឲ្យឡានទៅយក ។

បូលី : ខាងកងពល១៨របស់ពិសេសនឹង?

ភាព : ចា៎! យកមកដាក់នៅស្ពាតតែម្តង ។

បូលី : ម៉េចក៏មិនឡានមកដល់ស្ពាតតែម្តងទៅ ចាំបាច់ដូរឡានធ្វើអី?

ភាព : អត់ គាត់ដូរឡាន វាចង្អៀត ។

បូលី ៖ ដាក់ឡានតូចវិញចឹង?

ភាព ៖ មកដេកនៅចោមចៅនឹងមួយយប់ បានឡានទៅយកទៀត ។

សែ ៖ យី! ផ្លូវកាលសម័យនោះវាចង្អៀត ។

ភាព ៖ វាសុទ្ធតែដាច់ ។

សែ ៖ ដាច់កង់ៗទៀត ។

ភាព ៖ ដាច់ស្ពានអស់ហើយនឹង មានមកអីរួច ទឹកនៅហូរ ។

បូលី ៖ ចោមចៅ ពីតាកែវទៅយើងទៅតាមផ្លូវជាតិលេខ៣ លេខ២ ។

សែ ៖ អាទឹកព្រែកត្នោតនឹង ។

បូលី ៖ អូ! ស្ពាននៅតាខ្មៅនឹងអី?

សែ ៖ អត់ទេ ផ្លូវជាតិលេខ៣ ។

ភាព ៖ ស្ទឹងព្រែកត្នោតនឹង ដាច់អស់រលីង ។

បូលី ៖ បានអីឆ្លងទៅ?

ភាព ៖ ដើរចុះដើរក្រោម បានយើងដើរមកដល់កន្លែងផ្លូវឈប់ដាច់ បានមានឡាននៅទទួលនឹង ។

បូលី ៖ ហើយគេយកពីនឹងទៅដាក់នៅស្តាតអូឡាំពិច?

ភាព ៖ ចា៎! នៅស្តាតយើងរាល់ថ្ងៃ ។

បូលី ៖ ស្តាតចាស់ ឬស្តាតថ្មី?

ភាព ៖ ស្តាតចាស់ ។

បូលី ៖ គល់ស្ពានជ្រោយចង្វារនឹង?

ភាព ៖ ចា៎!

សែ ៖ ដាក់នៅអូឡាំពិច ។

ភាព ៖ អ៊ូ! ដាក់នៅអូឡាំពិច មិនមែន ។

បូលី ៖ ពូ និងមីងទៅជាមួយគ្នា?

ភាព ៖ អត់ទេ ។

សែ ៖ ទេ! ខ្ញុំនៅភូមិភាគពិសេស ។

បូលី ៖ អូ! ពូនៅនឹងម៉ង?

សែ ៖ បាទ!

បូលី ៖ ពូអ្នកទៅទទួលដែរអត់ទេ កាលនឹង?

សែ ៖ អត់ទេ ។

បូលី ៖ ពូនៅកងពលប៉ុន្មាន?

សែ ៖ ៨០១ ។

បូលី ៖ ១៨ហ្នឹង?

សែ ៖ បាទ!

បូលី ៖ គេដូរមក៨០១នៅឆ្នាំប៉ុន្មាន គេដូរឈ្មោះ?

សែ ៖ ៧៥ហ្នឹងហើយ ។

ភាព ៖ ៧៥ ៧៦នឹង រៀបចេញមកនឹង គេផ្លាស់កងពល ។

បូលី ៖ ប៉ុនតាមពិតកងពល៨០១នេះ ពីដំបូងមកមិនមែនតា០៥ លេខាទេ ឈ្មោះមួយទៀត កែវ សារឿន?

ភាព ៖ អត់ទេ ។ កែវ សារឿន សមាជិក ។

សែ ៖ បង សូ សារឿន ប្រធាន ។

បូលី ៖ ចឹង សូ សារឿន នឹងប្រធានតាំងពីដើមមក?

សែ ៖ បាទ!

ភាព ៖ កែវ សារឿន នឹងសមាជិក ។ មុនវរសេនាធំនឹង វរសេនាធំ៨១នឹង ។

បូលី ៖ អ៊ូ! ចឹងគាត់ជាប្រធានវរសេនាធំ៨១?

សែ ៖ បាទ!

ភាព ៖ កែវ សារឿន នឹងទើបផ្លាស់ ពូ សាន ទៅហើយបានយក កែវ សារឿន ទៅបញ្ចូលនោះ យក កែវ សារឿន មក តា ស៊ុន តាថ្មបាំង ។

បូលី ៖ ចង់និយាយថាម៉េច មុនយកម៉េច?

ភាព ៖ ចេះពីភ្នំពេញមករតនគិរី មានបង សូ សារឿន ហើយបង សាន ដល់ក្រោយមកផ្លាស់ប្តូរ បង សាន ទៅខាងមណ្ឌលគិរី កម្លាំងមួយចំនួនទៅមណ្ឌលគិរី យើងជ្រើសរើសកងពលឡើង បន្ថែម យកមក ។ បង សាន ចេញទៅយក តា ស៊ុន វរសេនាធំនោះមក ។

បូលី ៖ តា ស៊ុន វរសេនាធំលេខប៉ុន្មាន?

ភាព ៖ ៨២ ។

បូលី ៖ អ៊ូ! មិនមែន ជរ?

ភាព ៖ មិនមែនទេ ស៊ុន អ្នកស្រុកថ្មបាំងនោះ ។

បូលី ៖ ចឹង ស៊ុន នឹង ហើយនឹង តា កែវ សារឿន នឹងឡើងជាកងពល?

ភាព ៖ ចា៎! ឡើងមកជាកងពល តែ តា កែវ សារឿន ឡើងមកក្រោយ តា ស៊ុន។

បូលី ៖ ចឹង បន្ទាប់ពី តា សាន ទៅមណ្ឌលគិរី ស៊ុន ឡើងជាអនុរបស់ តា សារឿន តា០៥?

ភាព ៖ ចា៎!

បូលី ៖ ស៊ុន ឡើងជាអនុកងពល ហើយ កែវ សារឿន នេះត្រឹមឋានៈជាសមាជិកទេ?

ភាព ៖ ចា៎!

បូលី ៖ ចឹង កែវ សារឿន គាត់វរសេនាធំលេខ៨១?

ភាព ៖ ចា៎!

បូលី ៖ វរសេនាធំលេខ៨១ មិនមែនឈ្មោះ ម៉ៅ ទេ លោក?

ភាព ៖ ម៉ៅ ក្រោយ ម៉ៅឡើងពីវរសេនាតូច១១ទៅ។

បូលី ៖ អូ! ចឹងទាល់តែ សារឿន នឹងគេចាប់ តា ម៉ៅ ឡើង?

ភាព ៖ ដល់ កែវ សារឿន ចេញទៅ បានបង ម៉ៅ។ អត់ទេ កែវ សារឿន ចាប់ទៅនៅកងពល ហើយ។

បូលី ៖ ម៉ៅ ជាលោក។

ភាព ៖ កាល ៨២ តា ស៊ុន ឡើងមក បង ធី គាត់ឡើង វរសេនាធំ។

បូលី ៖ ហើយពេល ស៊ុន ឡើងទៅជានេះ ពីណាគេឡើង?

ភាព ៖ ធី។

បូលី ៖ មិនមែន តា ឡែម ទេ?

ភាព ៖ តា ឡែម នឹងក្រោយនឹង ឡើងក្រោយ តា ធី។

បូលី ៖ តា ធី ឡើងជាលោក។

ភាព ៖ វាផ្លាស់ប្តូរៗ ធី នឹងដកមកនៅ៨១ដង ទៅ៨៣ដង បាន តាឡែត ឡើងតាមក្រោយ ទៀត វាចឹងផ្លាស់ប្តូរ។

បូលី ៖ ចឹង ធី នឹងគេដកទៅ៨១?

ភាព ៖ ចា៎! ទៅមួយរយៈនឹងបាន តា ឡែត ឡើង វល់ផ្លាស់ប្តូរចល័តលិចកើត។

បូលី ៖ តា ឡែត ប្រពន្ធគាត់ឈ្មោះ អួង រី នឹង?

ភាព ៖ ភ្លេចអស់ហើយ យូរពេក។

បូលី ៖ តា ឡែត ឡើងជាលេខា ។ ខ្ញុំសុំសួរកន្លែងនេះតិច ។ មីងដឹងច្បាស់មែនទែន ជាពិសេស ពូគាត់នៅ៤០៥ ។ អឺ! ៨០១នេះ មានទីតាំងនៅក្រុងវើនសៃ ឈរជើងការពារខេត្ត២ រតនគិរី និងស្ទឹងត្រែង ត្រូវទេពូ?

សែ ៖ ត្រូវ ។

បូលី ៖ ហើយកងពលនឹង ចែកចេញជា៣វរសេនាធំ មានវរសេនាធំ៨១ ឈរជើងនៅស្រុកអូរយ៉ាដាវ ខេត្តរតនគិរី?

សែ ៖ នៅស្រុកបរកែវ ។

បូលី ៖ ស្រុកបរកែវទេចឹង?

សែ ៖ បាទ! ដល់នឹងនែក! អូរយ៉ាដាវនឹងកើតក្រោយ ស្រុក ទើបកើតក្រោយទេ ស្រុកបរកែវ និងស្រុកអណ្តូងមាស ។

បូលី ៖ ពីមុនអត់មានអូរយ៉ាដាវទេ?

សែ ៖ អត់មានទេ ។

បូលី ៖ ចឹងកាលពី៧៥-៧៩នឹង អត់មានអូរយ៉ាដាវទេ ។

ភាព ៖ ហ្នឹងស្រុកបរកែវនឹង ។

បូលី ៖ បាទ! ចឹងវរសេនាធំ៨១នឹង គឺឈរជើងនៅស្រុកបរកែវខេត្តរតនគិរី ហើយមាន កែវ សារឿន ជាលេខាវរសេនាធំ ត្រូវទេពូ?

សែ ៖ ត្រូវ ។

បូលី ៖ អ៊ោ ជាលេខាបន្ទាប់ពី កែវ សារឿន ឡើងទៅជាសមាជិកកងពល ប្រហែលជាឆ្នាំប៉ុន្មាន ពូដឹងទេ មើលទៅ?

ភាព ៖ ឆ្នាំ៧៦ ។

សែ ៖ អ៊ោ ។

បូលី ៖ ចឹង សុខ ឡើងជាលេខាមួយទៀត?

ភាព ៖ សុខ ឡើងមុន ពី៨២មក វាច្របូលច្របល់គ្នាមក ។

បូលី ៖ សុខ ឬក៏សុត?

ភាព ៖ សុត ។

បូលី ៖ អ៊ូ! សុត មួយទៀត មិនមែន សុត ៨២នេះទេ?

ភាព ៖ មិនមែនទេ ។ ផ្លាស់ប្តូរៗចុះប្តូរឡើង ពីកងវរសេនាធំមួយទៅវរសេនាធំមួយ អត់សូវឈប់ផង ។

បូលី ៖ ចឹង សុត ឡើងលេខាមុន ម៉ៅ?

ភាព ៖ បាទ!

បូលី ៖ សុត ឡើងលេខាមុន ម៉ៅ បន្ទាប់មកបាន ម៉ៅ ឡើងតាមក្រោយ?

ភាព ៖ ឡើងតាមក្រោយ ។

សែ ៖ កងទ័ពបង្កើតមក វាអត់មានលេខា មានតែមេបញ្ជាការ ។

បូលី ៖ ម៉ៅ គាត់ស្លាប់នៅប្រហែលឆ្នាំ៨៥ នៅកោះកុង ។

ភាព ៖ ស្លាប់?

បូលី ៖ ដោយសារគាត់ឈឺ ។

ភាព ៖ អត់បានដឹងផង ។ ហើយកូនគេនៅរកស៊ីលក់ដូរនៅនេះ តែមិនដឹងម៉េចអីវាមិនដែលបានដឹងអី

បូលី ៖ កូនគាត់រកស៊ីនៅណា?

ភាព ៖ នៅអន្លង់វែងនេះ មិនដឹងនៅម្តុំណា ពូគេថាកូនម៉ៅ ។ ហ៎! ដូចមិនទាន់ស្លាប់ទេ ឆ្នាំទៅអីណាគេថា តា ម៉ៅ ហើយ ឈឿន មកលេងកូន ។

បូលី ៖ ចឹងប្រពន្ធ តា ម៉ៅ ឈ្មោះ ឈឿន?

ភាព ៖ ចា៎! នៅជាមួយខ្ញុំ ។

បូលី ៖ ដែលថានៅកាត់ដេរជាមួយមីង?

ភាព ៖ អត់ទេ នៅកងទ័ពជាមួយគ្នា ។

បូលី ៖ កងយោធាជាមួយគ្នា?

ភាព ៖ ចា៎!

បូលី ៖ ពេលមីងមកភ្នំពេញនឹង នៅយោធា ហើយនៅកាត់ដេរ?

ភាព ៖ នៅយោធាខ្ញុំ ។

បូលី ៖ យោធាដដែល?

ភាព ៖ យោធារហូតទាល់តែ៧៩ ។

បូលី ៖ យោធា កងពល១៨ ៨០១ហ្នឹង?

ភាព ៖ ចា៎!

បូលី ៖ ឥឡូវនេះច្បាស់ណាស់ វរសេនាធំ៨១ ឈរជើងនៅបរកែវ ខេត្តរតនគិរី?

សែ ៖ អណ្តូងមាសជង ស្រុកអណ្តូងមាសខាងជើង ទន្លេសេសាន ។

បូលី ៖ ស្រុកអណ្តូងមាសខាងជើង ទន្លេសេសាន ខេត្តរតនគិរី និងមាន កែវ សារឿន ជាលេខា?

សែ ៖ បាទ!

បូលី ៖ សុត ជាលេខា បន្ទាប់ពី កែវ សារឿន ឡើងជាសមាជិកកងពល ។ ម៉ៅជាលេខាទីពា បន្ទាប់ពី សុត?

សែ ៖ បាទ!

បូលី ៖ នេះខ្ញុំពូពីគេទេ ម៉ៅ ស្លាប់ឆ្នាំ៨៥ ដោយសារជម្ងឺនៅខេត្តកោះកុង ។ ឥឡូវចូលវរសេនាធំ ៨២ អ៊ូ! សុំទោស៨១នឹង ចែកចេញជាប៉ុន្មានវរសេនាតូច?

សែ ៖ ចែកចេញជា៣វរសេនាតូច ។

ភាព ៖ ១១, ១២, ១៣ ។

បូលី ៖ ១១, ១២, ១៣, អាចចាំវរសេនាតូចមួយៗប្រធានឈ្មោះអី?

ភាព ៖ វរសេនាតូច១១ ។

សែ ៖ មិនដឹងទេ ព្រោះនៅកន្លែងកងពល ចាំទាំងអស់ មីងនៅកន្លែងកងពល ។

បូលី ៖ អ៊ូ! ពូនៅមន្ទីរកន្លែងកងពល?

សែ ៖ មីង ។

បូលី ៖ មីងធ្វើអីនៅមន្ទីរកងពល?

ភាព ៖ ទេ! យោធាមួយវរៈនឹង ជុំវិញតាមគាត់ ។

បូលី ៖ ដែលកងពលនារីសុទ្ធនឹង?

ភាព ៖ វរសេនាតូចរបស់នារីនឹង ទៅនៅជាប់ជាមួយមន្ទីរកងពលតែម្តង គាត់យកទៅនៅជាប់កន្លែង មន្ទីរកងពល ។

បូលី ៖ មីងនៅវរសេនាធំ៨០ប៉ុន្មាន?

ភាព ៖ អត់ទេ មានតែវរសេនាតូចនារីនឹងទេ ។

បូលី ៖ អានឹងពិសេស?

ភាព ៖ ចា៎! ពិសេសនៅក្នុងកងពលតែម៉ង អត់មានចូលនៅក្នុងវរៈណាទេ ប្រចាំកងពលតែម៉ង ។

បូលី ៖ ចឹង វរសេនាតូច១១, ១២, ១៣ នេះ អត់ស្គាល់ប្រធាន?

ភាព ៖ អត់ ។ ផ្លាស់ប្តូរញឹកពេក ។

បូលី : ចឹងចូលមក៨២តែម្តង ។ វរសេនាធំ៨២ឈរជើងនៅស្រុកសៀមប៉ាំងមាន ស៊ុន អ្នកស្រុកថ្មបាំង ជាលេខា?

ភាព : ចាំ!

បូលី : ធី ឡើងជា មិនមែនលេខា គេឈប់ប្រើលេខាហើយ ។ បន្ទាប់ពី ស៊ុន នឹងឡើងជាអនុកងពល៨០១ ។ ហើយពេល ធី ត្រូវសួរថាដកទៅ៨១នោះ តា ឡែត?

ភាព : អឺ! តា ឡែត

បូលី : តា ឡែត ឡើងជាលេខា ។ តា ឡែត នឹងប្តីរបស់មីង អួង រី១ គាត់ប្រធានកងចល័តតំបន់ ១០៤ ស្ទឹងត្រែង?

ភាព : ចាំ!

បូលី : ត្រូវទេ ពូៗនៅ៨០ប៉ុន្មាន?

ភាព : ៨១ ។

បូលី : ពូនៅ៨១ ពូអាចស្គាល់វរសេនាតូច?

ភាព : វរសេនាតូច១១កាលនោះ យ៉ិន, ម៉ៅ នោះ ។

សែ : គ្គាប់បន្តគ្នា ខ្ញុំមកខាងក្រសួងអប់រំនេះវិញ ។

ភាព : បង ម៉ៅ ឡើងទៅវរសេនាតូច១១ បង វណ្ណា ។

បូលី : ម៉ៅ ដែលថា វរសេនាធំនឹង គាត់អតីតអីគេ?

ភាព : ប្រធានវរសេនាតូច១១ពីមុន ដល់ ម៉ៅ ឡើងទៅបង វណ្ណា នោះគាត់ឡើងបន្ត ។ ដល់អស់ពីបង វណ្ណា ទៅបាន បង យ៉ិន គេឡើងបន្តទៀត ៣ ។ ១១ ខ្ញុំស្គាល់ច្បាស់ ។

បូលី : មីងស្គាល់ច្បាស់?

ភាព : បងប្អូនខ្ញុំនៅជាមួយមន្ទីរគាត់ ហើយ បង វណ្ណា នៅផ្ទះជិតគ្នាដែរ ។

បូលី : ចុះ វណ្ណា ទៅណា បាន យ៉ុន ឡើង?

ភាព : បង វណ្ណា គាត់គេដកមកនៅកន្លែងអប់រំខាងក្រោយដែរ បាន បង យ៉ិន ឡើងគេពង្រឹង ។

បូលី : ចង់និយាយថា គេយកមកដោយសារគេធ្វើខុស?

ភាព : គ្រប់គ្រង១កន្លែង ដូចខ្ញុំប្រាប់គាត់ចឹង អ្នកដែលមានពាក់ព័ន្ធ ។ បាន បង យ៉ិន គាត់ឡើង ។ មិនដឹងម៉េច ភ្លេចអស់ហើយ បែកគ្នាយូរ១ ។

បូលី : ចុះ១២, ១៣ ពូអាចដឹងទេ ពូនៅ៨១? ចុះពូមានតំណែងជាអីដែរ នៅ៨១នឹង?

សែ : នៅ៨១នឹង រងអនុសេនាធំ ។

បូលី ៖ ពូរង អនុសេនាធំ?

សែ ៖ បាទ!

បូលី ៖ អនុសេនាធំលេខ៨១នឹង?

សែ ៖ លេខ១១ ។

បូលី ៖ ហ៎! ១១តូចតើ?

សែ ៖ វរសេនាតូចចឹង ។

ភាព ៖ វរសេនាតូច១១ តែអនុសេនាធំ១១ដែរ ។ អនុសេនាធំគេ១១, ១២, ១៣ ។

បូលី ៖ អ្ហ៎! ១១នឹង?

ភាព ៖ ចា៎!

សែ ៖ អនុសេនាធំ១១ វរសេនាធំ១១ ១១១វរសេនាតូច ។

បូលី ៖ វរសេនាតូច១១១ ឬក៏១១?

ភាព ៖ ១១១ ណាគេហៅ១១១នោះ គេហៅតែ១១, ១២ តែរហូត ។

បូលី ៖ ចឹងដាក់ស្ដែង វាត្រូវ១១១ ១១២ ១១៣?

ភាព ៖ ចា៎!

បូលី ៖ ចឹង ម៉ៅ គាត់ប្រធានវរសេនាតូច១១?

ភាព ៖ ចា៎!

បូលី ៖ ហើយពេល ម៉ៅ ឡើងទៅវរសេនាធំ៨១ វណ្ណា ឡើងជាលេខា?

ភាព ៖ ចា៎!

បូលី ៖ ហើយពេល វណ្ណា ដកមកកន្លែងអប់រំ អ្នកដែលថាមានសមាសភាពនឹង យិន ឡើងជាលេខា?

ភាព ៖ ចា៎!

បូលី ៖ ហើយ១១នឹង បែកចេញជាកងអនុសេនាធំ៣?

ភាព ៖ ៣ មាន១១, ១២, ១៣ ទៀត ដល់វរសេនាតូច១១២នឹង វាទៅជា២១, ២២, ២៣ អនុសេនាធំ ។

បូលី ៖ ហើយពូនៅ១១?

ភាព ៖ ១១ ។

បូលី ៖ រង១១? ពីណាគេមេ១១?

សែ ៈ    មេ១១ កាលនឹង ហុក ។

បូលី ៈ    អី យ៉ិន ក្រែង១១១ដែរ?

ភាព ៈ    ដល់ទៅនៅរតនគិរីទេ ។ មកដល់រតនគិរីនឹង បែកគ្នា ។

បូលី ៈ    ប៉ុន ពីណាគេប្រធានមុនគេ យ៉ិន ហើយ ហុក?

ភាព ៈ    ហុក ។

បូលី ៈ    ហុក ប្រធាន?

ភាព ៈ    ចា៎!

សែ ៈ    ហុក ប្រធាននយោបាយ, យ៉ិន ប្រធានយោធា ។

បូលី ៈ    ពូឈ្មោះអី?

សែ ៈ    សែ ។

ភាព ៈ    ឆោម សែ ។

បូលី ៈ    ឆោម សែ អនុនយោបាយ?

សែ ៈ    បាទ!

បូលី ៈ    ហើយពីណាគេមិញ អនុយោធា?

សែ ៈ    អនុយោធា ភ្លេចអស់ហើយ ៣០ប្លាយឆ្នាំហើយ ។

បូលី ៈ    ចុះ១១២ ដឹងពីណាគេទេ?

ភាព ៈ    នែក! តា អែម នៅអនុសេនាធំ ។

សែ ៈ    ហ៎េ! មុននឹងអនុសេនាធំ យន ។

ភាព ៈ    តា យន វឿន នេះ ។ យន ប្រពន្ធគាត់នៅត្រពាំងប្រាសាទរាល់ថ្ងៃ ។

បូលី ៈ    អី យន?

សែ ៈ    អត់ចាំត្រកូល ។

ភាព ៈ    អ្នកស្រុកត្រាំកក់ ដឹងអី យន ។

បូលី ៈ    អ៊ូ! ចឹង យន នឹងប្រធានវរសេនាតូច១១២?

ភាព ៈ    ចា៎!

បូលី ៈ    ហើយពីណាគេ?

ភាព ៈ    តា អែម ។

បូលី ៈ    អែម អនុរបស់គាត់?

ភាព ៖ ចា៎!

បូលី ៖ ចុះ១១២ ចែកជាប៉ុន្មាន?

ភាព ៖ ៣អនុសេនាធំដែរ ។

បូលី ៖ អនុសេនាធំមានអីខ្លះ?

ភាព ៖ ២១, ២២, ២៣ ។

បូលី ៖ ឥឡូវនឹងកងពលវរសេនាធំ៨១ដដែល ប៉ុន្តែចូលមកវរសេនាតូច១១២ មាន៣អនុសេនាធំ មានអីខ្លះ មីង?

ភាព ៖ ២១, ២២, ២៣ ។

បូលី ៖ ប្រធានៗមីងចាំទេមើលទៅ?

ភាព ៖ អឺ! អត់ចាំទេ ប្រធានអនុសេនាធំអត់ចាំទេ ។

បូលី ៖ ឥឡូវវរសេនាតូច១១៣ មាន៣អនុសេនាធំដែរ?

ភាព ៖ ចា៎! ៣១, ៣២, ៣៣ ។

បូលី ៖ អស់ហើយបានប៉ុននឹង?

ភាព ៖ តែវរសេនាតូចរបស់ខ្ញុំនេះមិនមែននៅកងមិញទេ ៨០៤ ។ ដុំវិញកងពលនឹងមាន២វរៈទៀត៨០៣, ៨០៤, ៨០៦ មាន៣ ។

បូលី ៖ មាន៣វរៈឯករាជ្យទៀត?

ភាព ៖ ចា៎! មានកងកាំភ្លើងធំ កងដឹកជញ្ជូនមួយកងទៀត ហើយកងនារី មាន៣ ។

បូលី ៖ អានឹងអត់ទាក់ទង៨១ ៨២ ៨៣ទេ?

ភាព ៖ អត់ទេ អត់ពាក់ព័ន្ធទេ ដុំវិញមន្ទីរ ។

បូលី ៖ ឯករាជ្យពីនឹង?

ភាព ៖ ចា៎! ឯករាជ្យដុំវិញពីមន្ទីរកងពល ៨០៥ ។

បូលី ៖ ចឹងសុំមួយម្តង លើកទី១គឺ?

ភាព ៖ ៨០៣ ។

បូលី ៖ វរៈអីអានឹង?

ភាព ៖ វរសេនាតូច ។

បូលី ៖ យើងអាចហៅវរសេនាតូចឯករាជ្យបានទេ មើលទៅ ព្រោះវាឯករាជ្យពីវរសេនាធំ?

សែ ៖ ដុំវិញមន្ទីរ ។

បូលី ៖ ជុំវិញមន្ទីរកងពល?

ភាព ៖ ចា៎!

បូលី ៖ ជុំវិញមន្ទីរកងពល៨០១?

ភាព ៖ ចា៎!

បូលី ៖ វរសេនាតូចលេខប៉ុន្មាន?

ភាព ៖ ៨០៣ ។

បូលី ៖ អានឹងជាអីទៅ?

ភាព ៖ កងកាំភ្លើងធំ ពួកនឹងអនុសេនាធំគេ ។

បូលី ៖ អានឹងអត់ស្ថិតចំណុះឲ្យវរៈណាមួយទេ?

ភាព ៖ អត់ទេ នៅមួយទៀត ៨០២មួយទៀត កងពិសេស ។

បូលី ៖ ហ្នឹងវរសេនាតូចដែរ?

ភាព ៖ ចា៎! មួយវរសេនាតូចកងពិសេសមួយទៀត ។

បូលី ៖ វរសេនាតូច៨០២ ។

សែ ៖ ៨០២, ៨០៣, ៨០៤, ៨០៥, ៨០៦ ។

ភាព ៖ ជិតួយកងពល ។

បូលី ៖ ហ្នឹងជុំវិញកងពល៨០១ដែរ?

ភាព ៖ ចា៎!

បូលី ៖ ជាកងវរៈពិសេស?

ភាព ៖ ចា៎! ពិសេសប្រចាំកងពល ។

បូលី ៖ ពិសេសចង់ន័យថាម៉េច?

ភាព ៖ កងចល័តសម្រាប់ធ្វើអន្តរាគមន៍ ។

សែ ៖ កន្លែងណាបញ្ហាការកងពលបញ្ជាទៅខ្លួនវា ។

បូលី ៖ បន្ទាប់មកវរសេនាតូច៨០៣?

ភាព ៖ ៨០២មុន ថាតាមលេខរៀង ។

បូលី ៖ អានេះ៨០២រួចហើយតើ?

ភាព ៖ ៨០២ ៨០៣ ៨០៤ ។

សែ ៖ ៨០៣ កងកាំភ្លើងធំ ។

បូលី ៖ ៨០៤?

ភាព ៖ ៨០៤ កងនារី ។

បូលី ៖ វរសេនាតូច៨០៤ ជុំវិញមន្ទីរកងពល៨០១?

ភាព ៖ ចាំ!

បូលី ៖ ដែលជាកងនារី?

ភាព ៖ កងនារី ។

បូលី ៖ កងពិសេស គ្រាន់នារីចឹង?

ភាព ៖ ដាក់កងនារី ។

បូលី ៖ មានតួនាទីជាអី ចល័តដែរ ឬក៏មេ៉ច?

សែ ៖ ស្រេចគេប្រើដែរ នៅជាអង្គភាពយោធា ។

បូលី ៖ នៅជុំវិញតំបន់?

ភាព ៖ ចាំ! គ្រាន់ការពារជុំវិញកងពល យាមល្បាត ។

បូលី ៖ បន្ទាប់មក៨០៥?

ភាព ៖ ៨០៥នឹង ពេទ្យ ។

បូលី ៖ ពេទ្យទទួលខុសត្រូវមន្ទីរពេទ្យ?

ភាព ៖ ចាំ!

បូលី ៖ មន្ទីរពេទ្យទាំងមុខទាំងក្រោយ ។ បន្ទាប់មក?

សែ ៖ ៨០៦ ។

បូលី ៖ ៨០៦?

ភាព ៖ កងដឹកជញ្ជូន ពួក ណាត ខាងសេដ្ឋកិច្ច ។

បូលី ៖ កងវរសេនាតូច៨០៦ ជុំវិញកងពល៨០១ ទទួលខុសត្រូវខាង?

ភាព ៖ សេដ្ឋកិច្ច ។

បូលី ៖ អានឹងដឹកជញ្ជូនរបស់ហូបចុកឲ្យគេ?

ភាព ៖ ហូបចុក គ្រាប់រំសេវស្អីៗទាំងអស់ នៅលើកងឡាននឹងឯង ដោះស្រាយត្រី ធ្វើត្រីប្រហុក ។

បូលី ៖ ដឹកជញ្ជូនស្បៀង និងគ្រាប់?

ភាព ៖ ចាំ!

បូលី ៖ ចឹងមាន៨០២, ៨០៣, ៨០៤, ៨០៥, ៨០៦?

ភាព : ចា៎!

បូលី : ហើយមានអីទៀត?

ភាព : អស់ហើយ ។

បូលី : មាន៧-៨អីទេ?

ភាព : អត់ទេ ។

បូលី : ខ្ញុំសុំតិចទៀត សុំទៅវរសេនាធំ៨២ ឈរជើងនៅស្រុកសៀមប៉ាង ។

សែ : អត់សូវស្គាល់ច្បាស់ ។

បូលី : ទៅខាងនឹងលែងសូវស្គាល់?

សែ បាទ!

ភាព : នៅសៀមប៉ាងមែននឹង ។

សែ : នៅសៀមប៉ាង បើយើងមិនស្គាល់ដែរ ដឹងតែ៨០១ ។

ភាព : ដែលតែឆ្លងកាត់ ប៉ុនវាមិនចុះដាប់ ។

បូលី : ខេត្តស្ទឹងត្រែង ។ ចឹងខ្ញុំសុំបកមកនេះតិច ។

ភាព : នៅត្រឹមអូរនោង ពួកនេះនៅស្រុកសៀមប៉ាង ។

សែ : នៅស្រុកសៀមប៉ាង?

បូលី : បាទ! នៅសៀមប៉ាង ។

សែ : សៀមប៉ាង សៀមបូក ។

បូលី : វរសេនាធំ៨២នឹង មាន ស៊ុន អ្នកស្រុកថ្មបាំងមីងថាមិញ ជាលេខា?

ភាព : ចា៎! មុនដំបូង ។

បូលី : បន្ទាប់មក ធី ឡើងជាលេខា បន្ទាប់ពី ស៊ុន ឡើងជាអនុកងពល ពេល ធី ដកទៅ៨១ តាឡែត ឡើងជាលេខា វរសេនាធំ៨២ ណាមីង?

ភាព : ចា៎!

បូលី : ហើយវរសេនាធំ៨២នេះ បែកចេញជា៣វរសេនាតូច មាន២១ ២២ ២៣?

ភាព : ចា៎!

បូលី : ត្រូវទេមីង?

ភាព : ចា៎!

បូលី : ២១ បែកចេញជា៣អនុសេនាធំ មាន១១ ១២ ១៣?

ភាព ៖ ចា៎!

បូលី ៖ ចុះ២២ មាន៣អនុសេនាធំដែរ?

ភាព ៖ ៣អនុសេនាធំ ២១ ២២ ២៣ ។

បូលី ៖ ២២១?

សែ ៖ ហ្នឹងហើយ ។

បូលី ៖ អ៊ូ! មិនមែន២១ទេរ ទេ?

សែ ៖ ហ្នឹងហើយ ។

បូលី ៖ វាមាន៣លេខ?

សែ ៖ (ស្តាប់មិនបាន) ។

បូលី ៖ ២២១ ២២២ និង ២២៣ ចឹងតូ?

សែ ៖ បាទ! ដាន់ក្បាលលេខពីលើ ។

បូលី ៖ ចឹងវរសេនាតូចលេខ២២១ មាន៣អនុសេនាធំ មាន១១ ១២ ១៣ ណាតូ?

សែ ៖ បាទ!

បូលី ៖ ដល់ពេលវរសេនាតូច២២២វិញ ២១ ២២ ២៣ចឹងទៅតូនេះ?

សែ ៖ បាទ!

បូលី ៖ ហើយវរសេនាតូច២២៣ មាន៣អនុសេនាធំដែរ ។

ភាព ៖ វរសេនាធំ ៨៣នឹងអ្នកណាគេប្រធានមុនគេ ។

បូលី ៖ ៨៣ ប៉ុន្មានទៅ?

សែ ៖ ៨៣ តា ស៊ុន នឹង ។

ភាព ៖ វារវល់តែដូរ ធី កាលនឹងនៅ៨៣ដែរ ដកមក៨២ៗ ដកមក៨១ ឡើងវង្វេង ។

បូលី ៖ វង្វេងអស់ហើយ?

ភាព ៖ ចា៎! រវល់តិចផ្លាស់ដកនេះមកដាក់នេះ ។

សែ ៖ អ៊ូ! ៨៣នឹង ដើមកំណើត តា ប្រ ។

បូលី ៖ វរសេនាធំ៨៣?

សែ ៖ អឺ! តា ប្រ ដើមកំណើត ។

បូលី ៖ ចុះ តា ម៉ូន?

សែ ៖ ប៉ុន តា ប្រ មកទៅ៩២០ ។

បូលី ៖ វរសេនាធំ៨៣ ឈរជើងនៅកន្ទុយនាគ ស្រុកតាវែង ខេត្តរតនគិរី?

ភាព ៖ ចាំ!

បូលី ៖ មាន ម៉ូត ជាលេខា?

ភាព ៖ ម៉ូត នឹងក្រោយទេ ដក តា ប្រ ទៅមណ្ឌលគិរីហើយបាន ម៉ូត នឹងឡើងនោះ។

បូលី ៖ មាន តាប្រ?

ភាព ៖ តា ប្រ ដឹបូងគេ។

សែ ៖ តា ប្រ ខ្មែរ ព្រះវិហារ យើងជ័យសែន។

បូលី ៖ អ៊ូ! គាត់នៅជ័យសែន?

សែ ៖ បាទ!

បូលី ៖ បន្ទាប់ពី ប្រ ដកទៅ៩២០?

ភាព ៖ ពូ ម៉ូត ណាណៃផ្លាស់ទៅឆ្ងាយគ្នាពេកមិនសូវដឹង បង ធី នឹងក៏ផ្លាស់ទៅ៨៣ដែរ។ តា ឡឺ ដូចដកមកពី៨៣ តា ឡឺ ប្ដីយាយ សៀង នោះ។

បូលី ៖ តា ឡឺ ៨៣ដែរ?

សែ ៖ ជនជាតិដែរ។

ភាព ៖ តា ឡឺ នឹងមកនៅសមាជិកកងពល ជំនាន់ តា សាន, តា វឿន នោះ។

បូលី ៖ សមាជិកកងពល៩២០?

ភាព ៖ អត់ទេ ៨០១នឹង គ្រាន់មកពីភ្នំពេញនឹងមក បាន តា ឡឺ នឹងបន្ទាប់ តា សាន។

បូលី ៖ ចឹង?

ភាព ៖ ចាំ! ៣នាក់ ប្ដី បង សៀង ហ៉ោះ។ វាចឹង ដកលិចដកកើតឡើងវង្វេងអស់។

បូលី ៖ សូ សាវឿន លេខា, យ៉ែម សាន អនុលេខា?

ភាព ៖ បន្ទាប់មក តា ឡឺៗ ដឹងមានប្រពន្ធអត់។

បូលី ៖ តា ឡឺ សមាជិកកងពល?

ភាព ៖ ចាំ!

បូលី ៖ ដឹបូងដែរ?

ភាព ៖ ចាំ! តា ឡឺ នឹងទើបរៀបចំ៧/៥ដែរនឹង ដល់ហើយបានដក តា ឡឺ ហើយ តា សាន ទៅមណ្ឌលគិរី បាន កែវ សាវឿន ហើយ តា ស៊ុន ឡើងនេះ។

បូលី ៖ អ៊ូ! ចឹង តា សាន ហើយនឹង តា សាន ត្រូវបានដកទៅមណ្ឌលគិរី?

ភាព ៖ ចា៎!

បូលី ៖ ហើយបាន តា ស៊ុន ហើយ តាអីគេឡើង?

ភាព ៖ កែវ សារឿន។ ដក។ បង ជុំ មិន១២ទេ?

សែ ៖ ជុំនែក!១៣។ ជុំ នៅត្រពាំងប្រាសាទនេះ។

ភាព ៖ វរសេនាតូច១១១។

បូលី ៖ វរសេនាតូច១១១ពីណាគេ?

ភាព ៖ បង ជុំ នេះ ជុំអភិបាលរងខេត្តរាល់ថ្ងៃនេះ។

បូលី ៖ ជាតិ ជុំ?

ភាព ៖ ចា៎!

បូលី ៖ អូ៎! គាត់នៅ៨០១ដែរ?

ភាព ៖ ៨០១តើ។

បូលី ៖ គាត់នៅវរសេនាធំ៨០ប៉ុន្មាន?

ភាព ៖ ៨១។

បូលី ៖ ចឹងតំណែងជាអី?

ភាព ៖ ជុំ កាលទៅដូចឡើង ប៉ុននៅអនុសេនាធំដឹង កាលនឹង។ វរសេនាតូចជាមួយ ម៉ៅ។

បូលី ៖ ចឹង?

ភាព ៖ ចា៎! វរសេនាតូចជាមួយ បង ម៉ៅ។

សែ ៖ ជាមួយ ម៉ៅ អី ជាមួយ១៣។

បូលី ៖ ១៣ពីណាចេះ?

សែ ៖ តា ហ៊ន ទេ នែក!១១។

ភាព ៖ អូ៎! មិនដឹងណាទេ ដូរលិចដូរកើតតែរហូតចង់វង្វេងហើយ អ្នកដឹង។ ហ៊ន ហុង ហៅ។ ហ៊ន ២, នឿន ក៏២ មិនដឹងណាណី ច្រើនពេក នឿន សុទ្ធតែអនុសេនាធំទៀត ទាំងពីរនឹង វង្វេងអស់ហើយ នឿន ១២, នឿន ១១។

បូលី ៖ ពូអនុសេនាធំលេខប៉ុន្មាន?

សែ ៖ នែក! ១១។

ភាព ៖ ភ្លេចអស់ហើយប្អូនអើយ វាច្រើនពេករវល់តែដូរ។

បូលី ៖ បាទ! ចឹង ជុំ ជាតិ គាត់វរសេនាតូចលេខប៉ុន្មាន អាចចាំទេមើលទៅ?

សែ ៖ ១១៣ ។

បូលី ៖ ១១៣?

សែ ៖ បាទ!

បូលី ៖ ជាអនុរបស់ លេខ១៣អត់ទាន់មានអ្នកណាធ្វើប្រធានទេ?

សែ ៖ ពីមុន កែវ សារឿន នៅដឹកនាំ ។

បូលី ៖ តែ កែវ សារឿន គាត់វរសេនាធំទេ?

សែ ៖ បាទ! គាត់វរសេនាធំ តែចូលមុនគាត់វរសេនាតូច ។

បូលី ៖ តូចលេខប៉ុន្មាន?

សែ ៖ លេខ១៣យើង ។

បូលី ៖ ១១៣?

សែ ៖ បាទ!

បូលី ៖ ប្រធាន ឬក៏អនុ?

សែ ៖ ប្រធាន ។

បូលី ៖ ខ្ញុំថាប៉ុននឹងសិនហើយ កុំឲ្យច្រើនពេក វាអាចវិលវល់វិញ ។

ភាព ៖ វាគិតអត់ឃើញ យើងវាមិនបានកត់ប្រវត្តិទុកទេ តាមការចងចាំឆ្លើយខុសខ្លះត្រូវខ្លះ ព្រោះចេះ អ្នកដឹកនាំនឹងវវល់លើកផ្លាស់ប្ដូរ ឧបមាដូច ធី ចឹងគាត់ធ្លាប់នៅវរសេនាធំ១១៣ក៏គាត់ធ្លាប់ ១១២ក៏គាត់ធ្លាប់ ១១១ក៏គាត់ធ្លាប់ វវល់តែលើកគាត់ដាក់ដុបបន្តចេះចុះឡើងសុត១២ដែរ ។ វវល់តែផ្លាស់ប្ដូរចឹង បានថា ។

បូលី ៖ ចឹងពូមីងខ្ញុំចង់សុំរំខានស្អែកតិចទៀត ព្រឹកក៏បាន ថ្ងៃក៏បានឲ្យតែមីងផ្ដល់ពេលឲ្យ ។

ភាព ៖ ពេលព្រឹកក៏បាន ។

បូលី ៖ ប្រហែលជាម៉ោង៨កន្លះ ម៉ោង៩អី ខ្ញុំនៅជួបមីងនៅផ្ទះមីងម៉ង អត់អញ្ជើញទៅណា?

ភាព ៖ ខ្ញុំទៅណា ត្រូវការធ្វើការសាលាឃុំ ចុះអគ្រានុកូលដ្ឋានឲ្យក្មេង ប៉ុនអត់អីទេ បើណាត់ជួបក៏បាន ។

បូលី ៖ ខ្ញុំសុំរំខានតិច ព្រោះខ្ញុំចង់ជួបមីងមែនទែន ហើយពូក៏ចឹងដែរ បើសិនពូអាចមានពេល ។

សែ ៖ មិនអីទេ ការងារខ្ញុំធ្វើតែធ្វើការងារជុំវិញផ្ទះទេ ។

០២:៤២:៣៧

បូលី ៖ ចឹងយើងតសាច់រឿងពីម្សិលទៀត។ ចឹងខ្ញុំតសម្ភាសន៍ជាមួយអ្នកមីង អន សុភាព ត្រូវជាសមាជិកក្រុមប្រឹក្សាឃុំទង។ ម្សិលមិញយើងដល់កងពល៨០១ ហើយមីងបានរៀបរាប់ថានៅក្នុងកងពល៨០១នឹង វាមានវរសេនាតូចដូចជាឯករាជ្យចឹង ៨០២, ៣, ៤, ៥, ៦, មីងអាចចាំទេ អ្នកណាគេជាប្រធានវរសេនាតូច៨០២?

ភាព ៖ ៨០២ ក៏វាផ្លាស់ប្ដូរដែរ មុនដំបូង គឺ ឡូញ នឹង។

បូលី ៖ ពូ ឡូញ?

ភាព ៖ ចា៎!

បូលី ៖ ពូ ឡូញ ក្រែងគាត់។

ភាព ៖ ៨០២ សួរខាងបង ដាន់ណា អន្តភាពចាស់គាត់។

បូលី ៖ ពូ ឡូញ គាត់វរៈត-៧ កាលនឹង?

ភាព ៖ អត់ទេ នេះមកកងពលផ្សេង។

សែ ៖ តា ឡោច។

បូលី ៖ អ៊ូ! តា ឡោច មិនមែន ឡូញទេ?

ភាព ៖ ឡូញ ហើយ ឡោច។

បូលី ៖ នេះ ឡូញ ឡាំ ផ្សេងទេ?

ភាព ៖ ហ្នឹងផ្សេងទេ នៅកន្លែងតំបន់ នោះភាគគេ។

សែ ៖ តា ឡោច។

បូលី ៖ តា ឡោច?

សែ ៖ បាទ!

បូលី ៖ កងពល៨០២?

សែ ៖ បន្ទាប់ពី តា ឡោច មួយ តា ឆន។

បូលី ៖ តា ឡោច ប្រធាន។ កង៨០២ របស់ពូ ដាន់ណា?

ភាព ៖ ចា៎!

បូលី ៖ ចឹង យឹម ដាន់ណា ពីមុនគាត់នៅ៨០១ដែរ?

ភាព ៖ ចា៎!

បូលី ៖ គាត់ធ្វើអី កាលនៅ៨០២?

ភាព ៖ ធម្មតា ធ្វើអីទេ កាលនោះ ខ្ញុំអត់សូវចេះស៊ើបប្រវត្តិគេទេ ខ្ញុំ។

បូលី ៖ ប្រហែលជាគាត់កូនចៅគេទេ កាលនឹង មិនទាន់ជាប្រធាន។ ចុះពូថាបន្ទាប់ពី តា ឡោច មកពីណាគេ?

សែ ៖ ឆន។

បូលី ៖ តា ឆន ៨០២ដែរ។ តា ឆន គាត់ធ្លាប់ធ្វើជា គាត់មានធ្វើវរៈអីទេ ជំនាន់នឹង តា ឆន?

សែ ៖ ឆន វាមាន២ មាន៣នោះ ប៉ុន្តែខ្ញុំអត់ចាំត្រកូល។

បូលី ៖ បន្ទាប់ពី ឆន មកមានទៀតទេ មើលទៅ?

សែ ៖ តា ជឿន គាត់កាន់៨០៥ហើយ តា ជឿន អនុដែរ។

បូលី ៖ តា ណា តា ជឿន?

សែ ៖ បាទ!

បូលី ៖ តា ជឿន គាត់នៅខាង៨០៥?

ភាព ៖ កាលមុននៅ៨០២ដែរ។ ៨០៥ គាត់ទើបមកនៅឆ្នាំ៧៧។ ៨០២ពីមុនជាមួយ តា ឆន ជាមួយ តា ឡោច។

បូលី ៖ នៅ៨០២នឹង គាត់ជាគណៈដែរ?

សែ ៖ បាទ! គណៈដែរ មិនក្រោម។

ភាព ៖ ៣រូបនឹង ប៉ុន្តែមិនដឹងសមាជិកអ្នកណាគេ។

បូលី ៖ ឲ្យតែបានឈ្មោះក៏បានដែរ ថ្ងៃក្រោយយើងអាចរកបានថែមទៀត បានឈ្មោះនឹងជាជំណាក់កាលទី១ដែលយើងអាចរកឃើញច្បាស់លាស់មែនទែន។ ចុះវរៈ៨០៣?

ភាព ៖ តា កែម។

សែ ៖ តា ហាន។

ភាព ៖ មុនដំបូង តា ហាន ប្រធាន។ តា កែម អនុ ប៉ុន្តែសមាជិកគេមិនដឹងណា។

បូលី ៖ សមាជិកអាចដឹងទេពូ?

ភាព ៖ តា ថន ដឹងវរសេនាតូច ហើយវរសេនាធំកាលនឹង។

បូលី ៖ ថន ពូ? ថន ៨០៣ ខ្ញុំដាក់សិន។ ចុះ៨០៤?

ភាព ៖ ៨០៤ បង រី។

បូលី ៖ រី ឬក៏ រុំ?

សែ ៖ រ៉ន។

ភាព ៖ រី, តា ខេង ក្រោយមកបាន បង រឿន។ រី, រឿន នឹង បងប្អូនគាត់ដូចគ្នា។

បូលី ៖ រី, រឿង បងប្អូនបង្កើត?

ភាព ៖ ជីដូនមួយ។

បូលី ៖ រី ប្រធាន?

ភាព ៖ ចាំ!

បូលី ៖ ហើយ រី ទៅណា បាន រឿន នឹងឡើង?

ភាព ៖ រី នឹងបានគ្រួសារ គាត់ផ្លាស់ទៅនៅ កាលដើម៧៧នឹងគាត់បានប្ដីនៅនោះ។ មុនដំបូង បង វ៉ន មកនៅភ្លេច អស់ពី សុខា ទៅ បង វ៉ន។

បូលី ៖ មុនដំបូង ខា?

ភាព ៖ បង ខា ដែលនៅភ្នំពេញ ខ្ញុំថាបានប្ដីរថក្រោះទៅ គាត់អត់បានមករតនគិរីជាមួយពួកខ្ញុំទេ ចឹងហើយបានមកដល់នេះ បង វ៉ន គាត់អ្នកគ្រប់គ្រង។

បូលី ៖ គ្រប់គ្រង៨០៨នឹង?

ភាព ៖ ចាំ!

សែ ៖ វ៉ន ហើយមួយខ្ពស់។

ភាព ៖ បង សឿង ក្រោយទេ។

បូលី ៖ ចឹង រី ទីប៉ុន្មាន?

ភាព ៖ បង រី គាត់អនុ បង វ៉ន។ ហើយ រឿន នឹងសមាជិក។ ដល់ក្រោយមកផ្លាស់ប្ដូរបង វ៉ន គាត់ទៅតាម បង សំអ៊ុន ទៅ បង រី គាត់ឡើងប្រធាន។

បូលី ៖ បង សំអ៊ុន នឹងប្ដីគាត់?

ភាព ៖ ចាំ! បង សំអ៊ុន នឹងប្ដីគាត់។ បង សំអ៊ុន នឹងផ្លាស់មកពី១១ នៅ៨១ដឹង។

បូលី ៖ រី ឡើងជាប្រធាន?

ភាព ៖ ចាំ! ដល់ រី ទៅតាម បង ខេង ទៅ។ បង រឿន នោះគាត់ឡើងប្រធាន បានបង សឿន ឡើងមកបន្តទៀត។

បូលី ៖ រី ទៅតាម ខេង?

ភាព ៖ ចាំ! ខេង នឹងប្ដីគាត់។ ដល់បង រឿង នឹង អ៊ូ! ៨០៣ មិនមែន ថន ទេ បងនេះប្ដីបង រឿន នោះ ឈ្មោះស្អីទេ រៀងស្ដើង។

បូលី ៖ ៨០៣មីង?

ភាព ៖ ចាំ!

បូលី ៖ អា នេះ ៨០៨?

ភាព ៖ ៨០៨ ប៉ុនសមាជិកវរសេនាធំមិនមែន ថន ទេ ថនទៅអនុសេនាធំទេ នៅ បង តេង នៅកន្លែងយន្តហោះ គេដកទៅកន្លែងព្រលានយន្តហោះកំពង់ឆ្នាំងនេះ តា តេង

បូលី ៖ តា តេង?

ភាព ៖ ចា៎!

បូលី ៖ តា តេង នឹងកាន់ខាងអី?

ភាព ៖ តា តេង នឹងវរសេនាធំជាមួយ បង កែវ ហើយ បង ហាន នឹងឯង ថន នឹងមិនមានទេ ថន អនុសេនាធំទេ ។

បូលី ៖ ចឹង តេង សមាជិក ជាមួយ តា ហាន, តា កែវ?

ភាព ៖ ចា៎ៗ ។

បូលី ៖ គាត់កាន់រហូត ហាន, កែវ នឹង អត់មានដោះដូរជាមួយ?

ភាព ៖ ទេ! បង តេង នឹងគាត់ ដល់ហើយគេដក គេឲ្យទៅនៅកន្លែងព្រលានយន្តហោះកំពង់ឆ្នាំងទៅ បាន បង រឿន នឹងគាត់ឡើងទៅតាមប្ដីទៀតទៅ បានឡើងបង សឿន មកម្ដងទៀត ៨០៨ នោះ ។

បូលី ៖ រឿន ទៅតាមប្ដី?

ភាព ៖ ហ្នឹងហើយ ។

បូលី ៖ តេង នឹងប្ដីរបស់ រឿន?

ភាព ៖ ចា៎! ចេញអស់ហើយ ។

បូលី ៖ មេទាំងពីរ?

ភាព ៖ ចា៎! សុទ្ធតែប្រពន្ធមេៗ ហើយគ្រប់គ្រងខាង ។

បូលី ៖ ហើយគេដកគាត់ទៅកំពង់ឆ្នាំងធ្វើអី តេង?

ភាព ៖ ថាកាលនឹងគេរៀបចំព្រលានយន្តហោះនៅកំពង់ឆ្នាំងថ្មីនឹង ។

បូលី ៖ អូ៎! គេទៅគ្រប់គ្រង?

ភាព ៖ ចា៎!

បូលី ៖ ទៅគ្រប់គ្រងចឹង?

ភាព ៖ ចា៎! ទៅរៀបចំកសាងព្រលានដំបូង ប៉ុនគេថាឲ្យទៅនៅកន្លែងគ្រប់គ្រងព្រលានយន្តហោះនឹង ប៉ុនមិនដឹងគាត់ទៅធ្វើអី បើគាត់ទៅនៅឆ្ងាយកំពង់ឆ្នាំង យើងមើលមិនឃើញរតនគិរីកំពង់

ឆ្នាំង អត់ដឹងដែរនឹងណា ។ ហើយបានបង សឿង នៅរហូតមកដល់យើង៧៩ បង សឿង ប្រពន្ធ បង សុត នោះ ។

បូលី : អ៊ូ! សឿង ស្រីទេ?

ភាព : ស្រី ។

បូលី : ប្រពន្ធរបស់ សុត?

ភាព : ចាំ! ប្ដីឈ្មោះ សុត ។

បូលី : សុត នឹងធ្វើអី?

ភាព : សុត វរសេនាតូច ។

បូលី : វរសេនាតូចលេខប៉ុន្មាន សុត?

ភាព : សុត ៨២ ។

បូលី : សុត ដឹងធំៗ

ភាព : ចាំ! ដឹងវរសេនាតូចលេខប៉ុន្មានអត់ដឹងដែរ ។

បូលី : ចឹង សឿង នេះចុងក្រោយគេបន្ទស់ហើយ?

ភាព : ចាំ! ចុងក្រោយ ។

បូលី : រហូតដល់៧៩បែកនឹង?

ភាព : ចាំ!

បូលី : គេង ជាសមាជិក៨០៣?

ភាព : ចាំ!

បូលី : សុត មិនដឹងជាមួយណា?

ភាព : សុត នៅ៨២នោះនឹង ។

បូលី : វរសេនាធំ៨២?

ភាព : ចាំ! ៨០២ អឺ! ៨២ ។

សៃ : ៨២ កម្លាំងនៅកន្ទុយនាគ ។

បូលី : ៨២នៅ សៀមប៉ាង?

សៃ : អឺ! នែកនៅសៀមប៉ាង សៀមបូកនេះ ។

បូលី : ចុះ សុត នឹងគាត់ធ្វើអី មឹងចាំទេមើលទៅ?

ភាព : សុត នឹងវរសេនាតូច ។

បូលី ៖ វរសេនាតូចលេខប៉ុន្មានដែ?

ភាព ៖ មិនដឹងលេខប៉ុន្មាន បើខ្ញុំមិនបាននេះដែរ ។

បូលី ៖ វរសេនាធំ វរសេនាតូចមាន៣ មាន២២១ ២២២ ២២៣?

សែ ៖ ២២១ ។

ភាព ៖ នៅឆ្ងាយៗពីគ្នាមិនងាយស្គាល់គ្នាអស់ទេ បើនៅខាងសៀមប៉ាង ស្គាល់តែពេលចូលទៅរៀន ជួបគ្នាដឹងថាអានេះនៅកងនេះ ដឹងតែវរសេនាធំ វរសេនាតូចវាមិនដឹងមិនអស់ទៀតជួបគ្នា នឹង ។ ពេលមកសន្និបាតអីជួបគ្នានឹងចេះមកស្គាល់គ្នា ។

បូលី ៖ អាចថាមានមីង ឬក៏ពូណានៅក្នុងវរៈ២២១, ២២ ២១ម៉ង បានគាត់អាចដឹងអានឹង ព្រោះ គាត់នៅផ្ទាល់?

ភាព ៖ បែកគ្នាអស់ហើយប្អូន បើមានច្រើន មានតែត្រពាំងប្រាសាទ ។ មកខាងនេះមកតិចណាស់ ។

សែ ៖ ខ្ញុំមកនេះ មកកសាងអន្លក់ភាពនេះទេ ពីមុនឬសកែវរបស់វានៅត្រពាំងប្រាសាទទាំងអស់ ។

បូលី ៖ ៨០១នឹង?

សែ ៖ ហ្នឹងហើយ ។

បូលី ៖ បាទ! ចឹងបានខ្ញុំចង់ទៅត្រពាំងប្រាសាទដែរ ។

សែ ៖ លោក កែវ នឹងនៅត្រពាំងប្រាសាទដែរ ។

បូលី ៖ រាល់ថ្ងៃ?

ភាព ៖ ចា៎! ប្រពន្ធគេឈ្មោះ វ៉ាន នៅ៨០៤ដែរ ។

សែ ៖ នៅខាងជើងផ្សារ ។ មិនបាន ត្រកូល វាភ្លេចត្រកូលអស់ ។

ភាព ៖ កែវ ឥឡូវគេកងពលហើយ ។

សែ ៖ ចូលនិវត្តន៍ ឧត្តមសេនីយ៍៨មុខព្រួញគេត្រូវចូលនិវត្តន៍ ។

ភាព ៖ ក្រោយពីគេចាប់ បង ហាន ទៅ បង កែវ គេឡើងប្រធាន ។

បូលី ៖ ចឹង?

ភាព ៖ ចា៎! បង ហាន គេថាជាប់សមាសភាពម៉េចទេ ដកពីកងពល១១មក ។

បូលី ៖ ដកទៅណាវិញ?

ភាព ៖ ដឹងដកទៅណា ខ្ញុំអត់ដឹងដែរ ។ ដកហូត លើកដាក់ មួយឆ្នាំៗផ្លាស់ប្តូរលិចកើត ។

បូលី ៖ ខ្ញុំមើលចម្លើយសារភាព នៅគុកទួលស្លែង មន្ទីរស២១ សមាជិកកងពល៨០១ ប្រហែល ជាជិត៨០០នាក់ ដែលត្រូវបានគេចាប់សម្លាប់ ។

ភាព ៖ ដែលជាប់និន្នាការនយោបាយ ។

បូលី ៖ ៩២០ក៏ចឹងដែរ របស់ តា សាន រាប់រយនាក់ ២០០-៣០០នាក់ ដែលត្រូវបានគេចាប់ និងសម្លាប់នៅមន្ទីរស-២១ទួលស្លែង ។

ភាព ៖ មុននឹងឲ្យទៅនឹងរន្ទោះរន្ទើរដែរ មិនមែនថាទេ បង រឿន គាត់មិនឆាយឲ្យទៅ រឿន ក៏ត្រូវគេចាប់ដែរ ។

បូលី ៖ ចឹង?

ភាព ៖ ចា៎! នេះ កែវ សារឿន ចាប់ កែវ សារឿន ដែលថា រឿន អត់ទៅនេះ ពេលហៅសន្និបាត បង រឿន ឲ្យទៅ កែវ សារឿន ទៅគេចាប់ ហើយបង រឿន គាត់ដឹងខ្លួនគាត់មកនៅស៊ឹងត្រែងនេះ គាត់មករៀនចំកន្លែងមួយនៅស៊ឹងត្រែងទៀត ។

បូលី ៖ ចឹង កែវ សារឿន អត់ស្លាប់ទេ មុន៧៩?

ភាព ៖ អត់ទេ គេចាប់យកទៅ ប៉ុនមិនដឹងជាស្លាប់នៅណា បើបាត់ វាអត់ដឹងដែរ ។

បូលី ៖ គេចាប់ទៅបាត់ម៉ង?

ភាព ៖ ចាប់តាំងពី៧៨នោះ ។

សែ ៖ ចូលទៅកន្លែងនឹងឯង ។

បូលី ៖ កែវ សារឿន ដូចតាមខ្ញុំចាំ ទៅទួលស្លែង កែវ សារឿន ។

សែ ៖ បាទៗ ចុះគាត់កំណើតកើតជាគាត់នៅភ្នំពេញដែរ ។

បូលី ៖ ត្រូវហើយ កែវ សារឿន ចាប់ខ្លួននៅខែ៥ឆ្នាំ៧៧ ។

ភាព ៖ ៧៧?

បូលី ៖ បាទ! បញ្ជូនទៅមន្ទីរស-២១ ។

សែ ៖ ហ្នឹងហើយ ចាប់ពីរតនគិរីមក ។

បូលី ៖ កែវ សារឿន អនុលេខារបស់ តា សូ សារឿន នឹង?

ភាព ៖ ចា៎!

បូលី ៖ តា ឡឹ សមាជិកនឹង អឺ! សុំទោស តា ឡឹ ខាង តា សាន នោះទេ?

ភាព ៖ តា ឡឹ ខាង សាន ទេ កាលមុននៅក្នុងកងពលនោះមុន កែវ សារឿន ប៉ុនដល់ផ្លាស់ទៅមណ្ឌលគិរីជាមួយ បង សាន ទៅ គេទៅចាប់នៅនោះ ។ គេសុទ្ធថានិន្នាការនយោបាយមិនដឹងរបៀបម៉េច ធ្វើប៉ុននឹងដែរ វាពិបាកណាស់ សម័យនោះ ។

សែ ៖ ជនជាតិ តា ឡឹ ។

បូលី ៖ តា ឡឺ ជនជាតិ?

សែ ៖ បាទ! ជនជាតិចារ៉ាយ ។

ភាព ៖ ពិបាកណាស់ប្អូនអើយសម័យនោះអ្នកណាមិនខ្វាច ជីវិត ខ្ញុំអីសុទ្ធជាប់សមាសភាពដែរ តែដកខ្ញុំចេញអត់រួច ។ ខ្ញុំដូចថា ទ្រឹស្តីខ្ញុំរៀនឡើងដែរ មេៗអត់ធ្វើអី ព្រោះគេទុកប្រើ ព្រោះរបាយការណ៍ក្នុងកង អត់មានអ្នកណាធ្វើ មានតែខ្ញុំ បើខ្ញុំអត់ធ្វើឲ្យ បង វឿន ដេរមកតាមទូរស័ព្ទនៅ រេវីមករឹង អ្នកឯងនៅស្រែក៏ត្រូវហៅមកដែរ ប្រធានកងវរៈ អនុសេនាធំអីមកដល់ម៉េចរបាយការណ៍ដល់ខែ ម៉េចមិនរាយការណ៍ ។

សែ ៖ ដូចក្នុងសៀវភៅ កាលជំរើសគេរើសដែលកសិករ ពិសេសអ្នកល្ងង់ខ្លៅ អ្នកបានតែប្រាប់ធ្វើបានតិចតួច វាមិនសូវមានសមាសភាព បញ្ញាជន បញ្ញាវ័ន្តអីទេ ។

ភាព ៖ ៧៧ គេសរិតសំរាំងមាគ៌ានយោបាយគេណាស់ បែងប្រភេទវណ្ណៈ ប្រភេទ១ប្រភេទ២ ប្រភេទ៣ ខាងមាគ៌ានយោបាយគេ ។ ខ្ញុំនៅក្នុងប្រភេទ៣ៗនឹងអ្នកជាប់និន្នាការនយោបាយ ចង់និយាយថា មានឪពុកម្តាយប្រឆាំងជាមួយសហករណ៍ មានបងប្អូនធ្វើទាហាន ធ្វើមន្ត្រីរាជការពីមុន ។ ខ្ញុំនិន្នាការនយោបាយ បងថ្លៃ ខ្ញុំគាត់ធ្វើទាហាន បងបង្កើតគាត់ធ្វើទាហាន ។

បូលី ៖ ទាហាន លន់ នល់?

ភាព ៖ ចា៎! សម័យលន់ នល់ ។ ដល់ចឹងទៅខ្ញុំអត់មានពាក់ព័ន្ធអីទេ បើថាម៉ែឪខ្ញុំនោះគេយកបំបែកគ្នាអស់ហើយ ម៉ែទៅនៅខាងត្បាញ ពុកនៅខាងសិប្បកម្ម បងប្រុសនៅចិញ្ចឹមមាន់ បងស្រីនៅកន្ទែងបាយ គេបំបែកខ្ទេចអត់មាន ។

បូលី ៖ នៅណា?

ភាព ៖ នៅកំពតនឹង ។

បូលី ៖ អូ៎! នៅអង្គរជ័យនឹង?

ភាព ៖ ចា៎! អត់មានបាននៅជុំគ្នាទេ ។

បូលី ៖ ចឹងមីងអត់មានលទ្ធភាពអីមកការពារពួកគាត់?

ភាព ៖ យើងនៅរតនគិរីនោះ មានសិទ្ធិអី ។

បូលី ៖ ថានៅក្បែរ ប្រធានកងពលដែរ អាច?

ភាព ៖ ហ្អឹង! នៅក្បែរក៏ដោយ អត់មានពាក់ព័ន្ធបានទេ គេសុទ្ធសំរាំងតាមដានយើងទៀត គេទៅយកប្រវត្តិនឹង ហើយគេតាមដានយើង ។ យើងចង់និយាយថា យើងទៅមើលសកម្មភាពយើងពីមុនដែលគេទៅពិនិត្យ ហើយដល់ក្រោយគេពិនិត្យបានមកសកម្មភាពយើងនៅរបៀប

ម៉េចទៀត ។ អានឹងនៅលើជំហររបស់ខ្ញុំ សកម្មភាពរបស់ខ្ញុំ អត់ធ្វើអ្វីដែលប៉ះពាល់ទេ បើសិនជាដូចអស់គេៗដកចេញដូចគ្នា នារីៗនៅកន្លែងខ្ញុំដកចេញអស់ម៉ាអនុសេនាធំ មួយវរសេនាតូច ។ គេយកទៅរៀបចំនៅផ្សេង កន្លែងដាំបន្លែដាំអី ។ ហើយខ្ញុំពេលប្រមូលឯកសារនឹងមិនដឹងម៉េច គេនៅតែរៀងទុកចិត្តខ្ញុំ ដែលខ្ញុំដូចថាខ្ញុំនៅមាននិន្នាការនយោបាយ ។ នៅក្នុងវរៈនឹងគេប្រមូលបានឯកសារមក ហើយគេយកមកប្រគល់ឲ្យខ្ញុំអ្នកបូកសរុបស្រង់ ។

បូលី ៖ ឯកសារអីគេ?

ភាព ៖ ឯកសារប្រវត្តិរូបនឹង អ្នកណានិន្នាការនយោបាយស្អីៗ យើងស្រង់ដាក់ដោយឡែកៗ ។ ឧបមាថាប្អូនឯងឪពុកធ្វើទាហានចិនទៅ យកបញ្ជីអ្នកឪពុកម្តាយធ្វើទាហានមន្ត្រីរាជការមុននោះផ្សេងចិនទៅ អ្នកចំនុះជាមួយសហករណ៍ដាក់ផ្សេងចិនទៅវាមានបែងភេទវាចឹង ។ ហ្នឹងហើយដល់ចឹងខ្ញុំគ្រប់គ្រង អាបញ្ជីស្នាមនឹងក្នុងអង្គភាពនោះ ។

បូលី ៖ ៨០១នឹង?

ភាព ៖ ចា៎! អត់ទេ ៨០៤ ។

បូលី ៖ ខាងកងនារីតែមួយ មិនមែន៨០១ទាំងមូលទេ?

ភាព ៖ ចា៎!អត់ទេ ។ ដល់ចឹងទៅខ្ញុំដឹងៗប្រវត្តិ ហើយខ្ញុំមិនដែលហ៊ាននិយាយប្រាប់នារីគ្នាឯង ព្រោះគិតសម្រាប់ខ្លួនឯង នឹកឃើញថា ខ្លួនឯងក៏មានប្រវត្តិចឹង ហើយមិត្តភ័ក្តក៏មានចឹង មិនដឹងគិតយ៉ាងម៉េច ខ្លួនឯងក៏ត្រូវគេដក មិត្តភ័ក្តក៏គេដក ម្ល៉ះហើយក៏អត់និយាយទេ សុខចិត្តនៅស្ងៀមបំពេញគ្រប់ពេល ។ គេនៅស្រែស្វាត់ៗ ខ្ញុំគេឲ្យយកមកបំពេញនៅក្នុងផ្ទះ តែថ្ងៃមួយនោះ ខ្ញុំហេវបាយពេកខ្ញុំអត់បានរៀបចំឯកសារទុកដាក់លើតុចឹង ខ្ញុំគ្រាប់បិទទ្វារមុខទ្វារក្រោយតែអត់បានខ្ទាស់ មានអីពួកនឹងគេមកពីស្រែ បាយហើយគេមកផ្ទះសិន ថាមកដល់ធ្លាប់ចូលមកផ្ទះខ្ញុំមានចំណីហូបអីចឹងថ្ងៃ មានចេកមានអីចឹងទៅ ចូលមកអត់ឃើញខ្ញុំ ឃើញឯកសារគរៗពួកខ្ញុំដឹងថា ខ្ញុំគូសឈ្មោះៗ ហើយបញ្ជីរាយនៅនឹង ។ ខ្ញុំគ្រាន់គ្របទុក ខ្ញុំទៅហូបបាយ មកវិញយំទ្រហឹងពេញទាំងអស់ ។ ខ្ញុំភ្ញាក់ខ្លួនព្រើត ដល់ហើយគេខឹងខ្ញុំថាខ្ញុំចិត្តអាក្រក់ បានហើយប្រាប់ម៉ាមាត់ ។ ការពិតខ្ញុំអត់មានចង់ធ្វើចឹង និយាយរួមគេហៅខ្ញុំទៅស្តីបន្ទោសច្រើនដែរនឹង យើងវាខ្វះការប្រុងប្រយ័ត្ន ។

បូលី ៖ ពីណាអ្នកឲ្យមីងទទួលខុសត្រូវខាងនឹង មេ៨០៤នឹង?

ភាព ៖ ចា៎!

បូលី ៖ តា តេង?

ភាព ៖ អត់ទេ ៨០៨នឹង ៧៧ រី ។

បូលី ៖ មីង រី អ្នកប្រាប់ឲ្យមីងរៀបចំឯកសារនឹង?

ភាព ៖ ចាំ!

បូលី ៖ រី ៧៧ ហើយឡើងជាប្រធាន ។ ហើយនៅក្នុងចំណោមឯកសារទាំងអស់នឹង យើងចែកចេញជាប៉ុន្មានប្រភេទទៅ?

ភាព ៖ ៣ ។

បូលី ៖ ប្រភេទទី១ ?

ភាព ៖ ទី១ ទី២ ទី៣ ។

បូលី ៖ ទី១ អ្នកអីគេ?

សែ ៖ ទី១ដែលគៀកជាប់នឹងគ្រួសារទ័ពនឹង ។

បូលី ៖ ចង់និយាយថា អ្នកដែលស្អាតស្អំជាងគេ?

ភាព ៖ អត់ទេ ។

សែ ៖ គៀកជាងគេដែលជាប់ពាក់ព័ន្ធនឹងបងបង្កើតចេញទៅ ។

បូលី ៖ គៀក ជាងគេ?

ភាព ៖ ហ្នឹងហើយ អានឹងវាជាប់នយោបាយធ្ងន់ធ្ងរជាងគេ ។

សែ ៖ មិនទាន់ចូលខក្រិដ្ឋទេ គ្រាន់កិច្ចការងារផ្ទៃក្នុងទំនាស់ផ្ទៃក្នុងជួរបក្សជួរអី ។

បូលី ៖ ចុះទី២ ?

ភាព ៖ ទី២ បន្ទាប់មក ហើយអាទី៣អ្នកស្រាល ។

បូលី ៖ អ្នកស្រាលជាងគេ?

ភាព ៖ ចាំ!

បូលី ៖ នៅក្នុងចំណោម៣ប្រភេទនឹង ប្រភេទមួយណាដែលឯកសារគរខ្ពស់ជាងគេ?

ភាព ៖ ទី៣ ។

បូលី ៖ ចឹងអ្នកជាប់សមាសភាពដែលខ្លាំងៗនឹងមិនសូវជាមានច្រើនទេចឹង?

ភាព ៖ មិនសូវមានច្រើនទេ រៀបទៅបានជាងមួយអនុសេនាតូចទេ ។

បូលី ៖ ប៉ុន្មាននាក់មួយអនុសេនាតូចរបស់មីង ៨០៨?

ភាព ៖ ម៉ាអនុសេនាតូច៣២ ៣៣នឹង ។

សែ ៖ ៣៦ វាពេញលក្ខណៈរបស់វា ។

ភាព ៖ មួយក្រុម១២នាក់ ។

សែ ៖ បាទ! ៣ក្រុម ។

បូលី ៖ ចឹងតិចដែរ មិនជាច្រើនប៉ុន្មានដែរ ។

ភាព ៖ ប៉ុនគ្រាន់គ្នាវាសោកស្តាយ គាត់ខំលះបង់គ្រប់បែបយ៉ាង ព្រោះកាលនោះយើងគិតថាក្បាលណាសក់អ្នកនឹង ដល់ចុងបញ្ចប់វាមិនចឹងណា វាពាក់ព័ន្ធដល់ ។ ទោះបីជាប់និន្នាការនយោបាយយ៉ាងណា តែយើងអត់មានគិតទេ រឿងឪពុកផ្សេង រឿងម្តាយផ្សេង រឿងបងប្អូនផ្សេង ក្បាលណាសក់នឹងទទួលខុសត្រូវដោយឡែក ។ ដល់ចេញចឹងទៅ ម្នាក់ៗវាធ្លាក់ថ្លើមកន្លែងនឹង វាយ៉ាប់ ។

បូលី ៖ នៅក្នុងវរសេនាតូចនីមួយៗ សមាជិកពេញអង្គ ៣៦នាក់?

ភាព ៖ ចាំ! ៣៦ មួយក្រុម១២ៗ អនុសេនាតូច ។

បូលី ៖ ចុះវរសេនាតូច?

សែ ៖ វរសេនាតូចវាមាន៣០០ជាង ។

ភាព ៖ ៣អនុសេនាធំ ។

សែ ៖ មួយអនុសេនាធំវាមាន១២០នាក់ ។

បូលី ៖ ចឹងវា៣៦០នាក់?

សែ ៖ បាទ! ៣៦០នាក់ ។

បូលី ៖ គ្រប់ទេ ៨០៤របស់មីង គ្រប់?

ភាព ៖ គ្រប់ ។

បូលី ៖ ៣៦០នាក់ ។

ភាព ៖ វាមាន៣អនុសេនាធំៗ៤១ ៤២ ៤៣ ។

បូលី ៖ ស្គាល់ប្រធានមួយៗទេ ពីណាគេ?

ភាព ៖ ៤១ រឿន ក្មេងជីតាអស់ហើយនៅចាំតែឈ្មោះៗទេ អានោះហើយ យាយ ឈាន ។

បូលី ៖ ឈាន?

ភាព ៖ ចាំ!

បូលី ៖ អនុប្រធាន?

ភាព ៖ អនុប្រធាន សមាជិក លី ។

បូលី ៖ ចុះ៤២?

ភាព ៖ ៤២ យ៉ន ប្រធាន។ អនុណាទេ ជ្រឿន សមាជិត ហេង។

បូលី ៖ ជ្រឿន?

ភាព ៖ ចាំ! ជ្រឿន ប្រពន្ធ តា ម៉ៅ។

បូលី ៖ តា ម៉ៅ ពីណាគេ?

ភាព ៖ តា ម៉ៅ ដែលថាស្លាប់នោះ។

បូលី ៖ តា ម៉ៅ ដែលថាវរៈធំ?

ភាព ៖ ហ្នឹងហើយ។

បូលី ៖ វរៈធំលេខប៉ុន្មាន?

សែ ៖ ៨១។

ភាព ៖ អូ! ជ្រឿន មុន យ៉ន។

បូលី ៖ ៤២ យ៉ន, ជ្រឿន អនុប្រធាន ហើយអីគេសមាជិក ថាមិញ?

ភាព ៖ ហេង។

បូលី ៖ ចុះ៤៣?

ភាព ៖ ៤៣ មុនបង សឿង មុនឡើងវរសេនាតូចនឹង បង សឿង ៤៣ សឿង, មិត្ត វ៉ាន១។

បូលី ៖ វ៉ាន អនុ?

ភាព ៖ វ៉ាន អនុ។

សែ ៖ ប្រពន្ធ តា កែវ នេះ។

បូលី ៖ អូ៎! វ៉ាន ប្រពន្ធ តា កែវ?

សែ ៖ ហ្នឹងហើយ នៅត្រពាំងប្រាសាទ ណាម្នាក់ទៀត។

ភាព ៖ ណា ហឿន ដឹង ដូច ហឿន។ មានតែ ហឿន ទេ។

សែ ៖ ហឿន នៅ៨០៦ ហឿន កាលនឹង។

បូលី ៖ ចឹង តា កែវ នៅរស់នៅឡើយ?

ភាព ៖ នៅ។

បូលី ៖ ចុះអ្នកផ្សេងៗទៀត ដូចជា រឿន, វ៉ន, រី?

ភាព ៖ បង រី, រឿន, ទៅស្រុកអស់ហើយ។

បូលី ៖ ឈាន, លី?

ភាព ៈ ប៉ុនសុទ្ធតែបែកប្ដីទាំងអស់នឹង ។ ឈាន នៅត្រពាំងប្រាសាទ បង លី គាត់ទៅលិច ទៅនៅមុំណាទេ ទៅនៅម៉ាឡៃ ហើយក៏នៅណាទេ បែកគ្នាអស់ យ៉ន អីទៅនៅលិច ។ អ៊ូ! ៨៣ មួយទៀត មិនមែន ហឿន ទេ បងឪ ។

បូលី ៈ ឪ ពុក?

ភាព ៈ ចា៎! ស្រីហើយ តែឈ្មោះ ឪ ។

សែ ៈ អានឹងសមាជិកកងធំ ។

ភាព ៈ អនុសេនាធំ៨៣ ភ្លួច បង ឪ, ហឿន អនុសេនាតូចដែរ ។

បូលី ៈ (ស្ដាប់មិនបានវែ្គព្រួសខ្លាំង) ។ នៅរស់ទេ ឪ?

ភាព ៈ នៅ ប្ដីស្លាប់ហើយ វ៉ាន ។

បូលី ៈ នៅណា?

ភាព ៈ ឥឡូវគេនៅខ្មែរ ។ បានជុំគ្នាវិញច្រើនដែរ ពួកមិត្តភ័ក្តខ្ញុំគេតេស្ដមករក ។

សែ ៈ កងទ័ពចំរុះ ។

បូលី ៈ ៨០១នឹង?

ភាព ៈ បាទ! ទូទាំងប្រទេសមានទាំងអស់ ។

បូលី ៈ ៨០១ មីងស្គាល់ច្រើន ដោយសារមីងនៅក្នុងនឹងដែរ?

ភាព ៈ នៅនឹង ព្រោះខ្ញុំដើរចុះ ដើរឡើងតែក្នុងកង ។

បូលី ៈ ចុះនៅក្នុងចំណោមសមាសភាពអ្នកទី១នឹង មានប្រហែលប៉ុន្មាននាក់មើលទៅ?

ភាព ៈ អត់មានពាក់ព័ន្ធ មិនសូវមានពាក់ព័ន្ធ អ្នកដឹកនាំប៉ុន្មាន ច្រើនជាសុទ្ធសមាជិក ឬក្រុម ។ សរុបទៅយកទៅបូកសរុប រើសទាំង៣ប្រភេទទៅវាបានតែ គេចង់និយាយថា គេមិនថាឯកសារចឹងហើយ គេមើលនេះទាំងអស់ទេ គេពិនិត្យលើសកម្មភាពអនុវត្តន៍របស់យើងទៀត ចង់និយាយចឹង មនុស្សនឹងប្រព្រឹត្តិអីខ្លះខុសពីការណែនាំចឹង គេមានដកហូតតាមនឹងដែរ គេមានលើកលែងខ្លះដែរ ។ មើលទៅវាអត់មានអ្វីគួរឲ្យចាប់អារម្មណ៍ គួរឲ្យអស្ចារ្យក៏គេអត់ដែរ ។ ហើយយកទៅនឹងគេមិនយកទៅដាក់គុក ដាក់អីទេ គេយករៀបជាអង្គភាពមួយចឹង គេធ្វើការអប់រំចឹងទៅ ប៉ុនគេចែកមុខរបរឲ្យធ្វើ ឧបមាថាទៅជាអ្នកដាំដុះសេដ្ឋកិច្ចសម្រាប់ផ្គត់ផ្គង់កន្លែងអង្គភាពចឹង អត់មានយកទៅធ្វើបាបវ៉ៃអីទេ ។

បូលី ៈ កាលនឹងមន្ទីររបស់ គ៤៥ នៅសៀមប៉ាងនឹង?

ភាព ៈ ណា មន្ទីរអប់រំ?

បូលី ៖ អត់ទេ មន្ទីរធ្វើការរបស់តា០៥?

ភាព ៖ អឺ! នៅវើនសៃ។

បូលី ៖ នៅវើនសៃ?

ភាព ៖ ចា៎!

សៃ ៖ ពីដើមគេហៅស្រុកវីរៈជ័យ។

បូលី ៖ មិនមែនវើនសៃទេចឹង?

សៃ ៖ បាទ!

បូលី ៖ មន្ទីរកងពលនៅវីរៈជ័យ?

ភាព ៖ ចា៎! ទៅដំបូងនៅបានលុង តែផ្លាស់កន្លែង។

បូលី ៖ ប៉ុនដំបូងនៅបានលុងទេ?

ភាព ៖ ទៅដំបូងមួយឆ្នាំនៅបានលុង ជិតមួយឆ្នាំ គ្រាន់សំចត។

សៃ ៖ ព្រោះកន្លែងនឹងគេប្រជុំជន។

បូលី ៖ ពី៧៥ ៧៦?

សៃ ៖ ហ្នឹងហើយ។

ភាព ៖ អត់ដល់៧៦ផង ចុង៧៥ យើងមកនៅវើនសៃហើយ យើងគ្រាន់ដាក់សំចត ហើយយើងមករៀបទីតាំងនៅនេះម៉ង។ បានកន្លះឆ្នាំ គ្រាន់យើងសំចតនោះសិន។ អ្នកនៅនោះនៅទៅអ្នករៀបផ្ទះសម្បែងនៅនេះរៀបរយទៅ ហើយយើង។

បូលី ៖ បាទ! ជិតទឹក។

ភាព ៖ ចា៎! វាជិតទឹក។

បូលី ៖ បើមន្ទីររបស់ តា សាន មីងអាចដឹងទេ ៩២០?

ភាព ៖ អត់ដែលដឹងទេ ព្រោះនៅឆ្ងាយណាស់។

បូលី ៖ ស្ទឹងត្រែងនៅម្តុំណា?

សៃ ៖ តា សាន មាននៅស្ទឹងត្រែងឯណា។

បូលី ៖ អ៊ូ! សុំទោសនៅមណ្ឌលគិរី?

ភាព ៖ មណ្ឌលគិរីតើ។

សៃ ៖ អូរច្បារ កោះញែក។

បូលី ៖ យើងបានដល់៨០២ ៨០៣ ៨០៤។

ភាព ៖ នេះគាត់ទៅសម្ភាសន៍ពីម្សិល អ្នក៩៧០ហើយ ។

បូលី ៖ ពីណាគេ?

ភាព ៖ បូ ភា ។

បូលី ៖ បូ ភា នឹងធ្វើជាអីឥឡូវ?

ភាព ៖ នៅជំទុក១ ។

បូលី ៖ អូ! បងដាវ៉ាសម្ភាសន៍ម្សិលមិញ?

ភាព ៖ ចាំ! ហ្នឹង៩៧០ ។

បូលី ៖ សង្ឃឹមថាអាចគាត់សួរនេះច្រើនតាមមើលដឹងច្រើន ។ ចុះ៨០៥ ពីណាខ្លះប្រធាន អនុប្រធាន សមាជិក?

ភាព ៖ ពីមុននោះ ឡាយ សារឹម ដែលយើងចេញពីភ្នំពេញមក ។

បូលី ៖ ហ្នឹងពី៧៥?

ភាព ៖ ចាំ!

បូលី ៖ ពី៧៥ ឡាយ សារឹម ជាប្រធាន?

ភាព ៖ ចាំ! បន្ទាប់មក ពូ សិដ្ឋ អនុ ។

បូលី ៖ ប្រសិដ្ឋ អនុ?

ភាព ៖ ដល់សមាជិកពូ ព្រិល ។

បូលី ៖ ពូ ព្រិល?

ភាព ៖ ឈ្មោះ ព្រិល ។

បូលី ៖ ចឹងបន្ទាប់មក?

ភាព ៖ បន្ទាប់មកគេចាប់ពានាក់នឹងដុតអស់ទៅ បាន ។

បូលី ៖ ចាប់ពេលជាមួយគ្នាម៉ង?

ភាព ៖ អត់ទេ មុនក្រោយ ។

សែ ៖ តាមចម្លើយពីភ្នំពេញមក ។

ភាព៖ តាមចម្លើយពីភ្នំពេញមកគេយកម្តងមួយៗ យកទាល់តែអស់ ។

បូលី ៖ ឆ្នាំប៉ុន្មានគេចាប់ពួកគាត់នឹង?

ភាព :	ចាប់នឹង ចុង៧៦ហើយ មិនទេទើបមកដល់ដំបូង ឡាយ សារឹម គេចាប់តាំងនៅបានលុង នោះ ឡាយ សារឹម ហើយ ពិសិដ្ឋ។ ហ្នឹងហើយ ឡាយ សារឹម ចាប់តាំងបានលុង មក ពិសិដ្ឋ ហើយ ព្រិល ចាប់នៅវើនសៃ។

បូលី :	ចឹងប្រហែលចុង៧៥ និងចុង៧៦?

ភាព :	ចា៎! ចុង៧៥ម្នាក់។ ហេ៎! ចុង៧៥អី ដាក់៧៦ទាំង៣ទៅ។

បូលី :	៧៦?

ភាព :	ចា៎! ៧៦ ប៉ុនដើមឆ្នាំ ហើយនឹងចុងឆ្នាំទេ។

បូលី :	ពីណាគេឡើង?

ភាព :	ក្រោយមក មន្ទីរពេទ្យនឹងដែលគេចាប់អស់ទៅបណ្តោះអាសន្ននោះបាននៅមិត្ត ថែប អ្នក គ្រប់គ្រង។

បូលី :	ថែប ប្រធាន?

ភាព :	ចា៎! គ្រប់គ្រងជំនួសបណ្តោះអាសន្ន។

បូលី :	អនុរបស់ ថែប?

ភាព :	ដឹងគេរៀបចំណាហើយទេ កាលនឹង។ ដល់គេប្តូរមន្ទីរពេទ្យមកនៅត្រើយម្ខាងវិញ បានគេ យក តា ជឿន ៨០២នេះមកគ្រប់គ្រង វាច្រើនណាស់ផ្លាស់ប្តូរពេក។

បូលី :	ជឿន សមាជិក៨០២ មកគ្រប់គ្រងវិញ?

ភាព :	ចា៎! នៅប្រធាន ហើយជាមួយ ថែប។

បូលី :	ថែប ទៅណាវិញ?

ភាព :	ទេ! ថែប នឹងដូចបែកគ្នា៧៩នឹង ដឹងទៅណាណើអស់។

បូលី :	ប៉ុនពេល ជឿន មកគ្រប់គ្រង ថែប?

ភាព :	នៅតើ។

បូលី :	ម៉េច ថែប ធ្វើប្រធាន?

ភាព :	អ៊ូ! ថែប ឡើងទៅរៀននៅភ្នំពេញ រៀនបច្ចេកទេសបន្ថែម គេមានបានវិលត្រឡប់មកណា អត់ ព្រឹត្តិការណ៍ ដល រៀនចប់ទៅ ថែប ឡើងទៅម្តង។

បូលី :	អ៊ូ! ពេលនឹង ថែប ឡើងទៅរៀននៅភ្នំពេញ។ រៀនខាងអីកាលនឹង?

ភាព :	រៀនបច្ចេកទេស។

បូលី :	ដូចជាបាញ់?

ភាព ៖ អត់ពេទ្យ កន្លែងមន្ទីរ០៥នឹង មន្ទីរពេទ្យ ៨០៥ ។

បូលី ៖ បាទ! ត្រូវហើយមន្ទីរពេទ្យសម្រាប់សមរភូមិ មុខនិងក្រោយ ។ ចឹង តា ជឿន នឹងគាត់ប្រធានរហូតដល់បែក?

ភាព ៖ តា នេះ អស់ពីពួកនឹងទៅ មាន តា ថែប ហើយ តាសាន យើង តាដីហ៊ុយនោះ ។

បូលី ៖ តាដីហ៊ុយម៉េចទៅ?

ភាព ៖ គាត់ដើរ និយាយពីថានេះជើងខោបោសដីឡើងសំពោង ។

បូលី ៖ អូ! ហៅតាដីហ៊ុយទៅ?

ភាព ៖ ខ្ញុំទេ! ដាក់ឆារគាត់ រវល់តែខឹង ។ ប៉ុន តានឹងប៉ុនមើលអ្នកជម្ងឺណាស់ ។

បូលី ៖ អ៊ូ! គាត់ពេទ្យដែរ?

ភាព ៖ រហ័សដៃរហ័សជើង មើលខ្ញុំទៅដេកពេទ្យខ្ញុំនៅ ថាលេងគាត់ខឹង នយោបាយ ពូ សិដ្ឋ អនុប្រធាន ប៉ុនពិនិត្យពូព្រិល។ គាត់ចុះជាប់តាមរោងអ្នកជម្ងឺចឹង ខ្ញិល ឡាយសារីម ប្រធានមិនដែលដើរអើតអ្នកជម្ងឺ ខ្ញុំអង្គុយប្រាជ្ញលេងជាមួយពេទ្យនឹង ។ ប៉ុនខ្ញិល ឡាយ សារីម ប៉ុនញញឹមមិត្តថែប បើប៉ុនស្ទាបពូសាន ។ អឺ! ប៉ុនឆ្ងល់មិត្តថែប ប៉ុនញញឹមមិត្ត ថែប ប៉ុនឆ្ងល់មិត្តថែប ប៉ុនស្ទាបពូសាន ។ ពួកនឹងទៅប្រាប់ ។ បង១ ភាព ថាបងឯងប៉ុន ស្ទាបគេ ។ មកដីដាច់ៗ ឯងថាម៉េច ថាអញប៉ុនស្ទាបណា មើល ។ ខ្ញុំថា ដើរស្ទាបអ្នកជម្ងឺ ក្តៅមិនទាន់ក្តៅត្រជាក់ៗ លូកដៃគេដ្ឋិប តែម្តងមិនទាន់ដាក់អង្រឹងផង ក្តៅត្រជាក់ៗ មើល ក្តៅត្រជាក់ ស្ទាបមុខស្ទាប់មាត់ គេក្ញាម ។ អឺ! ថាចឹង ថាអញស្ទាបលូកអីគេ ។ ថាសើច អើយសើច ។

សែ ៖ សាន អ្នកក្រចេះដែរ ។

បូលី ៖ សាង តំណែងជាអី មីង?

ភាព ៖ ពេទ្យ ។

បូលី ៖ ពេទ្យ ប៉ុន្តែមិនមែនជាប្រធាន ឬក៏អនុប្រធានអីទេនោះ?

ភាព ៖ កាលនោះគាត់មិនមែនទេ ដល់ក្រោយអស់ពីពានាក់នោះទៅ បានមាន សាន ហើយនឹង ថែប នឹងឯង ។

បូលី ៖ មើលឥឡូវ ឡាយ សារីម ប្រធាន, តា ប្រសិដ្ឋ អនុប្រធាន, ព្រិល សមាជិក?

ភាព ៖ ចា៎!

បូលី ៖ ដល់ពេលគេចាប់ទៅ ថែប ប្រធាន?

ភាព ៖ ចាំ!

បូលី ៖ ជឿន?

ភាព ៖ អត់ទេ ថៃប ហើយ ពូ សាន នឹងគេរៀបចំបណ្តោះអាសន្នគ្រប់គ្រងមិនទាន់តែងតាំងជាប្រធានជាអីទេ គ្រប់គ្រងបណ្តោះអាសន្ន។ ដល់ក្រោយមកបានគេយក តា ជឿន នឹងធ្វើប្រធាន។

បូលី ៖ ក្រោយមកប្រហែលជាឆ្នាំប៉ុន្មាន ជឿន ឡើងជាប្រធាន?

ភាព ៖ ខុសត្រូវគ្នាឆ្នាំ៧៧ហ្នឹងឯង ខុសត្រូវគ្នា មិនស្រួល ជឿន តាំងពីចុង៧៦ដែលដឹងខ្ញុំមិនដែលបានគិតស្មានគាត់ផង។ ហើយដឹងតែគេផ្លាស់ប្តូរ។

បូលី ៖ ពេល ថៃប ឡើងទៅរៀនចេញពីភ្នំពេញ?

ភាព ៖ ចាំ!

បូលី ៖ មីងសុំអានកំណាព្យមិញម្តងទៀតមើល។

ភាព ៖ ខ្ញុំនិយាយលេងសោះនឹង តែខ្ញុំនៅចាំ។

បូលី ៖ មីងតែងជំបូងថាអីគេ?

ភាព ៖ ខ្ញុំថា នយោបាយពិសិដ្ឋ ប៉ុនពិនិត្យពូព្រិល ខ្ជិលឡាយសារិម ប៉ុនញញឹមមិត្តផល ប៉ុនឆ្ងល់មិត្តថៃប ប៉ុនស្ទាបពូសាន។ ដល់នេះគាត់អន់ចិត្ត។

បូលី ៖ ពូផល ពីណាគេ ពេទ្យដែរ?

ភាព ៖ ពូផល ស្លាប់បាត់ហើយ ពេទ្យដែរ សុទ្ធតែមិត្តភ័ក្តខ្ញុំរាប់អានគ្នានឹង។

បូលី ៖ អត់មានដំណែងជាអីទេ ផល?

ភាព ៖ ផលគេខាងបច្ចេកទេស។ គេសុទ្ធតែមានជំនាញ ពួកនឹង។ តែខ្ញុំទៅដេកពេទ្យទៅ ពួកនឹងគេមកលេងខ្ញុំរហូតនោះមិត្តភ័ក្តនោះ។ ដល់នេះហួសពេលគេព្យាបាលគេមកអង្គុយប្រាជ្ញ។

បូលី ៖ (រែក្ត្រព្រួសខ្លាំងណាស់)

ភាព ៖ ថៃប ក៏គេសួរដែរ ហេតុម៉េចបានដាក់ងារគ្នាថា ប៉ុនឆ្ងល់គ្នាទៅវិញ។ ថាលើកនិយាយអីបញ្ឆោក់ស្អី១ គេឲ្យច្បាស់គិតមើលឲ្យបញ្ឆោក់តែរហូត ប៉ុនឆ្ងល់។ បើផលគ្នាតែមកហើយញញឹមតាំងពីចំងាយ។

បូលី ៖ ហើយ ឡាយ សារិម ប្រធានក៏មិនសូវធ្វើអី គាត់ខ្ជិលជាងគេ?

ភាព ៖ អត់សូវដែលចុះជាប់អ្នកជម្ងឺ អ្នកអីទេ នៅតែកន្លែង អត់ដែលចេះដើរអើតទេ បើថាពូព្រិលនោះប៉ុនណាស់ គាត់ចុះជាប់ជាមួយអ្នកព្យាបាលរហូត ជួយពិនិត្យជួយអី។

សែ ៖ ឡាយ សារឹម ធ្លាប់បួស អ្នកស្រុកយើងកៀនស្វាយ ។

ភាព ៖ បើពិសិដ្ឋ នឹងអ្នកកំពង់ចាម មិនដឹងនៅម្តុំណា ដឹងនៅកំពង់ចាម ។

បូលី ៖ ហើយ តា សិដ្ឋ ហើយនឹង ព្រិល នឹងអ្នកកំពង់ចាម?

ភាព ៖ ចា៎!

បូលី ៖ អស់ត្រឹមពួកគាត់ហើយ មិនមានអ្នកណាឡើងបន្ទាប់ពីនឹងទៀតទេ?

ភាព ៖ អត់ទេ ជឿន គាត់គ្រប់គ្រងរហូត ។

បូលី ៖ ៨០៦ ខាងដឹកជញ្ជូន សេដ្ឋកិច្ច?

ភាព ៖ អ្នកដឹកជញ្ជូន ឈ្មោះ តា ស្មៀន ។

បូលី ៖ ពីណាគេអនុរបស់គាត់?

ភាព ៖ អនុ ពូ ម៉ុន ។

បូលី ៖ សមាជិក?

ភាព ៖ សមាជិក តា អួយ(ស្តាប់មិនបានក្លែព្រូស) ។

បូលី ៖ អួយ សមាជិក?

សែ ៖ តាកួយ ។

ភាព ៖ អឺ! តា កួយ មិនមែន តា អួយទេ ។

សែ ៖ កសិករសុទ្ធ ។

បូលី ៖ ហើយមានការផ្លាស់ប្តូរទេ ៨០៦នឹង?

ភាព ៖ ផ្លាស់ប្តូរ ។

បូលី ៖ បន្ទាប់មកផ្លាស់អ្នកណាគេវិញ?

ភាព ៖ ផ្លាស់២នាក់ អឺ! ម្នាក់ ស្មៀន កងពល១១ដែរ សុទ្ធតែចម្លើយចេញមកពី(ស្តាប់មិនបានក្លែព្រូសខ្លាំង) ។

សែ ៖ ឡាយ សារឹម មកពីកងពល១១ដែរ ។

ភាព ៖ ១១ភាគច្រើន មកហើយគេចាប់ ទៅច្រើន ។

(ស្តាប់មិនបាន ក្លែ និងមាន់ ស្រែកខ្លាំងណាស់) ។

បូលី ៖ ចឹង ស្មៀន គេចាប់?

ភាព ៖ ចា៎!

បូលី ៖ ម៉ុន, គួយ អីគេចាប់?

ភាព ៖ ម៉ុន អត់ទេ។

បូលី ៖ ចុះគួយ?

ភាព ៖ អត់ទេ។

បូលី ៖ ចឹងបន្ទាប់ពីចាប់ ស្មៀន មក ពីណាគេឡើង?

ភាព ៖ ម៉ុន។

បូលី ៖ ហើយពីណាឡើងអនុរបស់ ម៉ុន?

ភាព ៖ តា កួយ។

បូលី ៖ មានសមាជិកថ្មីទេ មើលទៅ?

ភាព ៖ សមាជិកថ្មី ចូលមកមិនបានប៉ុន្មាន តា ឆេង ទៅមណ្ឌលគិរីទៅ។ អ៊ូ! បាន តា បុល។

បូលី ៖ បុល សមាជិក?

ភាព ៖ នែក! បុល អនុហ៎! តា កួយ នៅសមាជិកដដែល។

បូលី ៖ មានដូរទៀតទេ បន្ទាប់ពីនឹងមក?

ភាព ៖ អត់ដូរទេ ដូរដល់សភាពការណ៍៧៩ហើយបានគេដោះដូរ ដក តា បុល ទៅនៅទាហានវិញ។

បូលី ៖ បាទ! អានឹងក្រោយទេ?

ភាព ៖ ចា៎! ក្រោយ។

បូលី ៖ ចឹងអស់ត្រឹមប៉ុននឹង។ អស់ហើយ៨០៦ ចប់ត្រឹមនឹង?

ភាព ៖ ចា៎!

បូលី ៖ ចុះ៨០៣ តា ហាន ប្រធាន តា កែវ អនុប្រធាន តេង សមាជិក?

ភាព ៖ ចា៎!

បូលី ៖ ចា តេង នឹងជាប្តីរបស់ មីង រឿង?

ភាព ៖ ចា៎!

បូលី ៖ ក្រោយពី តា ហាន ចាប់ខ្លួនទៅ កែវ ឡើងជាប្រធាន?

ភាព ៖ ចា៎!

បូលី ៖ ពីណាគេអនុរបស់ កែវ?

ភាព ៖ អនុ តា តេង នឹងហើយ ឡើងបន្ត។

បូលី ៖ តេង ឡើងអនុ?

ភាព ៖ ចា៎! ដល់សមាជិកបន្ថែមដឹងគេដាក់អ្នកណា បើ ពូ ថន គេចាប់ដែរ ។

បូលី ៖ សមាជិកមិនដឹងមីង?

ភាព ៖ អត់ដឹងៗដាក់ណា ដឹង តា សយ ឡើងដឹងកាលនោះ តា សយ ។

សែ ៖ តា សយ នៅ(ស្តាប់មិនបាន) ប៉ុនពិការ ។

ភាព ៖ ពូ សយ គាត់អនុសេនាធំ ។

បូលី ៖ សយ សមាជិក ។ អស់ត្រឹមនឹង ឬមានអ្នកមកពីក្រោយគាត់?

ភាព ៖ អស់ត្រឹមនឹង ។

បូលី ៖ តា ហាន គេចាប់ប្រហែលឆ្នាំប៉ុន្មាន?

ភាព ៖ តា ហាន ដូច៧៧ ព្រោះប្រពន្ធកូនខ្ទីហើយក៏គេចាប់ ។

បូលី ៖ ហើយប្រពន្ធគេអត់ចាប់ទេ?

ភាព ៖ អត់ទេ ។

បូលី ៖ ៨០៣នឹង គេចែកចេញជា៣អនុសេនាធំទៀត?

ភាព ៖ ចា៎!

បូលី ៖ មានអីខ្លះ?

ភាព ៖ មាន៨០៣នឹង គេហៅ៣១ ៣២ ៣៣ដែរនឹង ។

បូលី ៖ មីងអាចចាំទេ ប្រធានមួយៗ?

ភាព ៖ ចាំអត់អស់ទេ ពីមុនដឹងតែពីរកងនឹង ដឹងតែមួយៗ ។

បូលី ៖ ៣១ ពីណាប្រធាន?

ភាព ៖ ៣១ តា សយ ។

បូលី ៖ សយ សមាជិកនឹង?

ភាព ៖ សយ សមាជិកនឹង ។ វាភ្លេច យូរ ។

បូលី ៖ ចុះ៣២?

ភាព ៖ ៣២នែក! ឈ្មោះ ហែម ។

បូលី ៖ ឈ្មោះ ហែម?

ភាព ៖ ចា៎!

បូលី ៖ ហែម ប្រធាន៣២?

ភាព ៖ ៣៣មិនដឹងណា អត់ដឹង ភ្លេចយូរពេក ។

បូលី ៖ ៨០២ មាន តា ឡូញ ប្រធាន, តា ឆន ប្រធានបន្ទាប់, តា ជឿន សមាជិក។ តា ឡូញ ទៅណា បាន តា ឆន ឡើងប្រធាន?

ភាព ៖ តា ឡូញ កាលនឹងក៏គេផ្លាស់ ហើយក៏គេដកទេ ដូចផ្លាស់ទៅមណ្ឌលគិរី ក៏គេដកទេ មិនបាន ចាប់អារម្មណ៍ផង។ សរិតសំរាំងណាស់៨០១នឹង ទៅសុទ្ធដល់ សូ សារឿន នោះ ចង់ រលាយ ៨០១គេរំលាយតើ។ កុំសភាពការណ៍យួនចូលមកដល់ ខ្ទេចអត់មានសល់ទេ។

បូលី ៖ មូលហេតុអីបានជាអាចត្រូវគេរំលាយ?

ភាព ៖ មិនដឹងគោលការណ៍ខាងលើម៉េច ព្រោះអីគាត់ចង់និយាយថា រកវិធីសាស្ត្រមុនដំបូងចាប់ រឿន ដល់គាត់មិនបានទៅ គាត់ទៅរៀន គាត់ដឹងដែរ គេចាប់ សោ ភឹម ចាប់អីមួយ គគោក បេះតែនេះ ចង់និយាយថាអ្វីតិចតួចៗយកមកគួបផ្សំដែរ គាត់បេះគិតពិចារណា ដល់ហើយ គាត់ឲ្យ កែវ សារឿន ទៅហើយក្រោយមកគេថាត្រូវផ្លាស់គាត់ឲ្យទៅនៅខាង ស្វាយរៀង កាលនោះ។

បូលី ៖ សូ សារឿន នឹង?

ភាព ៖ ចា៎! ដល់គាត់អត់ទៅទេ គាត់ថាបើទៅគាត់ទៅយកទាហានគាត់ទៅទាំងអស់ គាត់អត់ទៅតែ ឯងទេ គាត់ផ្លាស់ជាអន្តភាព បានគាត់ទៅ។ ដល់ក្រោយមកអត់បានទៅទៀត នេះ៧៩មុន យើងកើតព្រឹត្តិការណ៍នឹង គេយកទៅការពារនៅភ្នំពេញ យកទៅនៅផ្ទាល់នៅភ្នំពេញ។

បូលី ៖ ៨០១នឹង?

ភាព ៖ ចា៎!

សែ ៖ សភាពការណ៍ភ្នំពេញអត់ល្អ។

ភាព ៖ គេថា យកទៅដាក់នៅភ្នំពេញ គេដូរកង តា ញ៉ាន់ នេះមក ពួក១៤ ខាងក្របេះឡើងមក វិញ ពួក១៧។

បូលី ៖ ពួក១៧ កងពលប៉ុន្មាន?

សែ ៖ កងពល១១៧។

បូលី ៖ ១១៧?

សែ ៖ ហ្នឹងហើយ មកពីក្របេះ។

ភាព ៖ ចា៎! គេឲ្យពួកនឹងឡើងមក។

សែ ៖ តា យី នៅ តា យី គណៈតំបន់ក្របេះ។

បូលី ៖ យី, គួន?

សែ ៖	បាទ!

បូលី ៖	៨០២ បែកចេញជា៣អនុសេនាធំចឹងមីង?

ភាព ៖	ចាំ!

បូលី ៖	មានអីខ្លះមីង?

ភាព ៖	មិនដឹងអនុសេនាធំគេលេខប៉ុន្មានទៀត ខ្ញុំមិនដឹង ។

សែ ៖	២១ ២២ ២៣ ។

បូលី ៖	ប៉ុនប្រធានអាចចាំ?

ភាព ៖	អត់ស្គាល់ ។

សែ ៖	ប្រធានអនុសេនាធំ?

បូលី ៖	អនុសេនាធំ២១ ២២ ២៣ ។

សែ ៖	តា អឿន ប្ដីយាយ យ៉េ នោះ ។

បូលី ៖	សំអឿន?

សែ ៖	បាទ! តែអនុប្រធានសមាជិកគេនៅណា ។

ភាព ៖	បង ដាន់ណា កាលនឹងអាចអនុសេនាធំអីហើយ ប៉ុនមិនដឹងគាត់នៅអនុសេនាធំណា ។ បង ដាន់ណា មិនស្រួលនៅ២២ ព្រោះស្គាល់តែមុខៗគ្នាអត់ដឹង ។

បូលី ៖	កាលនឹងជិតជិតជាមួយគាត់ទេ?

ភាព ៖	វានៅត្រើយម្ខាងម្នាក់ ។ ជួបគ្នាបានតិច ។

បូលី ៖	ចឹងមីងនៅត្រើយខាងនេះ ពូដាន់ណានៅត្រើយខាងនោះ?

ភាព ៖	ចាំ! ម្ខាងត្រើយ ។

សែ ៖	តា ឃី នៅកង២១ដែរ ។

បូលី ៖	ឃី?

ភាព ៖	ឃី ប្ដី យាយ លី អនុសេនាធំដែរ ។

សែ ៖	យាយ លី ដែលនៅកង៤១ ដែលនេះនឹង មិញសមាជិក ។

ភាព ៖	សមាជិកអនុសេនាធំ៤១ ។

បូលី ៖	សមាជិកអត់ដឹង?

សែ ៖	បាទ! ដល់គិតយូរបាននឹកឃើញ ។

ភាព ៖	ច្រើនដែរនឹង គ្រប់គ្រងវាមិនដឹងអស់ ។

សែ ៖ (ស្តាប់មិនបាន) ។

បូលី ៖ ចុះ២៣?

ភាព ៖ តា លៀង អនុសេនាធំដែរ តា លៀង នៅត្រពាំងប្រាសាទរាល់ថ្ងៃ ។

បូលី ៖ ប៉ុនមិនដឹងថា នៅក្នុងអនុសេនាធំមួយណា?

សែ ៖ អាច២២ ។

បូលី ៖ ប៉ុនមានតំណែងជាប្រធានសមាជិកអីទេ ឬគ្រាន់ជាកូនចៅ?

ភាព ៖ អត់ទេ បើប្រធានគគេនឹង ប្រធានអនុសេនាធំនៅ ។

បូលី ៖ អនុសេនាធំលេខប៉ុន្មាន ប្រធាន?

ភាព ៖ ២២ ។

បូលី ៖ មិនមែន លៀង អ្ហុ! លៀង នឹងអនុសេនាធំ២២?

សែ ៖ បាទ!

បូលី ៖ អីលៀង?

ភាព ៖ អ៊ីង លៀង ។

បូលី ៖ មានអនុគាត់ទេ?

សែ ៖ ប៉ុនមិនដឹងឈ្មោះអីៗ វាភ្លេច ។

បូលី ៖ ចុះ២៣?

សែ ៖ កង២៣ ឆន ឡើងវរៈហើយ ។

បូលី ៖ ពីមុន តា ឆន?

សែ ៖ បាទ! ឡើងវរៈ៨០២ ហើយ ។

បូលី ៖ ពេលតា ឆន ឡើងជាវរៈ មិនដឹងពីណាឡើងជំនួសគាត់ទេ?

សែ ៖ បាទ!

ភាព ៖ ឆ្ងាយៗពីគ្នាពេក ។ តែការរៀបចំរចនាសម្ព័ន្ធ យើងអត់ដឹង ។

បូលី ៖ គេមានជាគំនូស បែងចែករចនាសម្ព័ន្ធទេ កាលនឹង?

សែ ៖ មានតើ ។

បូលី ៖ មានជាតារាងមួយពីណាប្រធានចុះមកក្រោមមក?

សែ ៖ ហ្នឹងហើយមានថ្នាក់គេរហូត ប៉ុនមិនរក្សាបានណា ។

ភាព ៖ មានៗតែគេប្រចាំវរៈរបស់គេ យើងមិនដែលទៅបានវរៈគេទៅដើរយកណា ។

បូលី ៖ អានឹងទាល់តែតា០៥បាន គាត់មានទាំងអស់?

សែ ៖ បាទ! ទាល់មេទទួលបន្ទុក ។

ភាព ៖ មេៗចំសាលារៀន ចូលទៅដល់ចង់បើកទ្វារចូលសួរមកធ្វើស្អី រកស្អី ការងាររងង ។ សួរចឹង ឥឡូវ ។

បូលី ៖ ត្រូវហើយ ព្រោះការងាររបស់អ្នកណា អ្នកនឹងទទួលខុសត្រូវ?

ភាព ៖ កងពល មិនងាយណាហ៊ានចូលទេ មានតែខ្ញុំទេ ទូរស័ព្ទហើយបានចូលទៅ ។

បូលី ៖ មានទូរស័ព្ទប្រើដែរកាលនឹង?

ភាព ៖ មាន តែទូរស័ព្ទរួមលើកតុ ។

បូលី ៖ របស់កងពលធំ?

ភាព ៖ ជុំវិញកងពល ។

សែ ៖ យើងប្រើតែគេអូ សំខាន់ជាង ព្រោះគេអូគាត់មានផ្សាយចេញក្រៅ ។

បូលី ៖ ចុះ៨០៥របស់មីងនេះ មាន៣អនុសេនាធំដែរ?

ភាព ៖ ៨០៥ មិនដឹងគេរៀបម៉េច ខ្ញុំមិនសូវដឹងដែរ ។

បូលី ៖ មីងអត់ចាំទេ?

ភាព ៖ ចា៎! មន្ទីរពេទ្យដឹងគេរៀប មិនសូវដឹងទេ គេមានដូចគ្នា ប៉ុនយើងអត់បានដឹង ។

បូលី ៖ ចុះ៨០៦?

ភាព ៖ ៨០៦ក៏គេមានវរសេនាធំ ។

សែ ៖ ៨០៦ ៦១ ៦២ ៦៣ មិនដឹងអ្នកណា តា ឆេង នេះ តា ឆេង នៅបានដឹង ។

ភាព ៖ បើ អ៊ំ ឆេង គាត់ទៅនោះហើយ ដឹងតិចណាស់ គាត់ចូលមកនៅបានតិច ។ បង រឿន មិន ដឹងវាគេនៅអនុសេនាធំណា ។ វ៉ាត ដឹងគេនៅអនុសេនាធំណា ។ យាយ វ៉ុន ៦១ដឹង យា វ៉ុន នោះ ។

សែ ៖ អឺ! យាយ វ៉ុន ៦១ (ស្តាប់មិនបាន)ជាងគេ, អា វ៉ាត ៦២, រឿន ខស្សរាប់ចេញចូល ក្របេះនោះឈ្មោះអី ។

ភាព ៖ មាន រឿន មាន ភាព មាន ខន សុទ្ធតែគ្នាគេ ប៉ុនមិនដឹងណាក្រោមណា អ្នកណាលើអ្នក ណា ។

បូលី ៖ ពីណា៦២?

ភាព ៖ ៦២ វ៉ាត នឹង ។

បូលី ៖ អាច៦៣?

ភាព ៖ ៦៣ រឿន ព្រោះយើងក្តាប់វាអត់ច្បាស់ដែរនឹង ដឹងតែគេកងធំៗ ប៉ុនមិនដឹងនៅក្នុងកងធំទីប៉ុន្មាន បើយាយ វ៉ុន ដឹងហើយ ។

បូលី ៖ យាយ វ៉ុន ច្បាស់ម៉ង មីង ៦១?

ភាព ៖ គេហៅតែ យាយៗ ។

សែ ៖ មនុស្សប្រុស ប៉ុនមារយាទគំនិតនឹងវាស្រីម៉ង ។

ភាព ៖ របៀបរបបធ្វើដូចស្រី ហៅតែយាយ ។

បូលី ៖ គាត់ពេដេតាមមើល?

សែ ៖ និយាយផ្ទាយៗ ។

ភាព ៖ រៀបចំទុកដាក់អីរបៀបមនុស្សស្រី លំអិត ។

បូលី ៖ គាត់ខឹងទេ ហៅគាត់ចឹង?

ភាព ៖ អត់ទេ មិនចេះខឹងទេ ។

បូលី ៖ ខឹង តែ ពូ សាន ប៉ុន ស្មាប?

ភាព ៖ (សើច) គាត់កាន់តែខឹងមកសួរដឹងរឿង អត់ខឹងទេ ។

បូលី ៖ និយាយទៅ ខាង៨០១នេះ ភាគច្រើននៅទំនប់ដាច់ ព្រះប្រឡាយនឹង?

ភាព ៖ ចា៎!

សែ ៖ បាទ! ដោយឡែកតែខ្ញុំទេ ចេញមកឆ្ងាយៗប៉ុន្មាននាក់នេះ ។

ភាព ៖ ទៅម៉ាឡៃក៏ច្រើនដែរ ។

បូលី ៖ មាននៅម៉ាឡៃដែរ?

ភាព ៖ ចា៎!

សែ ៖ នៅកោះកុងក៏មាន ពួកកងពលរបស់ តា ទិ នៅខាង(ស្តាប់មិនបាន) ។

ភាព ៖ អ្នកខ្មែម ផ្តាំឲ្យទៅលេង មិនបានទៅ សួរមកចំណាស់ណាហើយ របៀបរបបគេនៅតែដូចមុនដែរ ។ អ្នកនេះជាមនុស្សនឹងមួយជីវិតហើយ របៀបរបបគេមិនដែលគគ្រេចទេ ។ បានចេះស្គាល់គ្នាមក គេរៀបខ្លួនគេតែរហូតហើយ កែប្រែមិនបានទេ អត្តចរិត ។

បូលី ៖ ចុង៧៥ មន្ទីរ៨០១ដូរមកវើនសៃ ហើយនៅនឹងរហូតដល់៧៩ម៉ង?

ភាព ៖ ចា៎!

បូលី ៖ អត់មានដោះដូរទេ?

ភាព ៖ អត់ទេ ។

បូលី ៖ បន្ទាប់ពី តា សាន, តា ឡឺ ទៅមណ្ឌលគិរី តា កែវ សារឿន និង តា ស៊ុន ឡើងមកជំនួសគាត់ ជាមួយ តា០៥?

ភាព ៖ ចា៎!

បូលី ៖ ជំនួសរហូត ឬក៏មានការដោះដូរទៀត ប៉ុន តា កែវ សារឿន គេចាប់ឆ្នាំ៧៧?

ភាព ៖ ចា៎!

បូលី ៖ ពីណាឡើងជំនួសគាត់កាលនឹង?

ភាព ៖ នៅតែ២នាក់ តា ស៊ុន មិនឃើញប្ដូរណាបញ្ចូលផង ។

បូលី ៖ តា០៥ និង តា ស៊ុន នឹងម៉ង?

ភាព ៖ ចា៎!

បូលី ៖ អត់មានអ្នកថ្មីណាឡើងជំនួសតា កែវ សារឿន?

ភាព ៖ អត់ ពីព្រោះកំពុងច្របូលច្របល់ អត់មានការផ្លាស់ប្ដូរអីតំឡើងបន្ថែម ព្រោះកម្លាំងត្រូវជម្រុញសមរភូមិ ដឹកនាំត្រូវចុះទៅសមរភូមិ ដល់ហើយអត់មានដកម៉ង ។

បូលី ៖ កាលនឹង មិនយើងធ្វើសង្គ្រាមជាមួយវៀតណាមនៅតាមព្រំដែន?

ភាព ៖ ចា៎!

បូលី ៖ សង្គ្រាមចាប់ផ្ដើមផ្ទុះខ្លាំងនៅឆ្នាំណា?

ភាព ៖ និយាយរួម វាចូលមកតាំងពីចុង៧៦នោះ ។ វាគ្រាន់ចូលមកស៊ើប គិញវាបញ្ចូលមក ។

សែ ៖ វាយកខ្សែតាមព្រំដែននឹង វាយកសិទ្ធិទន្លេនឹង វាចង់ឲ្យត្រើយខាងនេះ វាអត់ឲ្យត្រើយខាងនេះទេ ។ ហើយអាអូរគ្រេសនឹង វាមានកូនកោះមួយនឹង អាជិតអូរយ៉ាដាវនោះនឹង នឹងវាឲ្យយើងយកមកត្រើយខាងនេះដែរ កន្លែងកាច់ ទន្លេសេសានកាច់បុកមកនេះ ។ ដល់ចឹងមកឧត្តមសេនីយ៍ផ្កាយ២មក។ជួបនៅអូរយ៉ាដាវ ។

បូលី ៖ ខាងវៀតណាម?

សែ ៖ បាទ! មើលទៅដូចជាមិនគោរពសិទ្ធិច្រើនពេក វៀតណាមយើងដឹង(ស្ដាប់មិនបាន) ។ ខ្ញុំមិនចង់និយាយទេ រឿងវៀតណាម ។

បូលី ៖ កាលនឹងគេចរចាយ៉ាងម៉េច របៀបចរចាសុំឲ្យយើងដកចេញ?

សែ ៖ ចរចាអី យើងយកដែនទី៥៤អី យើងគិត៥៤ យើងវានៅក្មេង មិនចង់និយាយទេ ចង់យកតែ៦២ ។ ដល់យក៦២ បេះតែរុញប្រានព្រំដែននឹង មកតែបន្ទប់ទន្លេនឹង វាចង់យកទាំងអស់ម៉ង ទន្លេសេសានក្បាលលើ ។

បូលី ៖ ក្បាលលើ ក្បែរព្រំដែននឹង?

សែ ៖ បាទ! ប៉ុនយើងមើលអា៦២ភ្លាម យើងយកខ្សែជញ្ជាំង១នេះ ត្រើយខាងនេះ អ្នកឯងលើនោះក្បាលអូរសេដ្ឋី ។

បូលី ៖ អូរសេដ្ឋី?

សែ ៖ អាជិតផុតពីនេះមាន មានអូរសេដ្ឋីមួយចាស់ឡើងទៅលើ យកទៅតាមដូរនឹងទាំងអស់សុទ្ធតែទន្លេរបស់យើងទាំងអស់ មិនទន្លេរបស់យួនទេ ។

បូលី ៖ ហើយពេលនឹងយើងមានការចរចាគ្នាទេ?

សែ ៖ ចរចារ១បានវា២-៣ថ្ងៃ បានវាចុះកិច្ចព្រមព្រៀងឲ្យ ។ កិច្ចព្រមព្រៀងឲ្យនឹងក្នុងខ្សែបន្ទាត់នឹង ពុះពាក់កណ្តាលទៀតទន្លេនឹង វាមិនទាន់ព្រមព្រៀងផ្តាច់ឲ្យមកយើង ។ ប៉ុនត្រឹមអូរគ្រេសបានមកយើង ។

បូលី ៖ អ្នកណាគេដឹកនាំចរចានឹង កាលនឹង?

ភាព ៖ ចរចារ កាលនឹង០៥គាត់នៅនឹង ។

បូលី ៖ ប៉ុនយើងចរចារហើយ ម៉េចបាននៅតែផ្ទុះអាវុធដាក់គ្នា?

ភាព ៖ វាអត់ព្រម វាគំនិតទាក់ទាញឲ្យធ្វើប៉ះបោរ ឲ្យធ្វើចលនាសង្គម ។ ចឹងគេយកភ្នាក់ងារគេនៅខាងក្នុង ។

ភាព ៖ វាចូលខ្សែបក្កប់វាមកតាំង ។

សែ ៖ ពិសេស វៀតណាមដែលចូលបាននេះ ដោយសារតាមជនជាតិចារ៉ាយ ព្រោះចារ៉ាយវាប្រទេសចំប៉ាសាក់ ដល់ចឹងវាទាបនៅខាងនយោបាយទាក់ទងពួកចារ៉ាយច្រើន ។ ដូចច្នេះសកម្មភាពវាចូលមកនឹង វាសុទ្ធបាញ់ភ្លើងសញ្ញេឲ្យម៉ូ ឲ្យអីប៉ះគ្នារហូត ចឹងមានការប្រយុទ្ធគឹងតែងដែរ ដល់បុកចូលមកនឹងយើងទប់បាន រហូតដល់ភ្នំពេញខាងកើត យកបានមុន ខាងនេះទើបទៅដល់ត្រឹមក្រចេះទេ ។ (ស្តាប់មិនបាន) ខាងនេះវាគានគឹងជាង វ៉ៃខ្ទប់បាន ។

បូលី ៖ មិនមីងថា គេចង់ចាប់តា០៥ទៀត គេឲ្យផ្លាស់ប្តូរទៅខាងណាស្វាយរៀង?

ភាព ៖ មុនដំបូងទៅស្វាយរៀង ដល់ក្រោយមកបានគេបញ្ជូលភ្នំពេញ ។

សែ ៖ គេចង់រំលាយអង្គភាព ។

ភាព ៖ គេចង់រំលាយអង្គភាពនឹងតែម្តងការពិត ។

បូលី ៖ ហេតុផលអី តា០៥ គាត់អ្នកស្មោះស្ម័គ្រណាស់ដែរ?

ភាព ៖ ស្មោះស្ម័គ្រប៉ុនផ្ទៃក្នុង ។

សែ ៖ ខ្លួនមួយ ពាក់អាវតែមួយ ប៉ុនអំវែក៣ម្នាក់ៗ ។

បូលី ៖ យ៉ាងម៉េចអំវែក៣?

សែ ៖ អំវែក៣នឹង ចង់និយាយថា ខួរក្បាលគេម្នាក់ៗនឹងចង់ដើរតួ៣ ចឹងវាពុះជ្រែកកម្លាំងណា ដែលខ្លាំងជាងគេ ជាគ្រឹះរបស់ជាតិ គេត្រូវបំបែកអានឹងម៉ង ។ គេកាច់ចឹង ហើយសុទ្ធថ្នាក់មជ្ឈិមដូចគ្នា លេងកាច់គ្នា ។

បូលី ៖ ខាងណាដឹង ដែលចង់បំបែក តា០៥?

សែ ៖ យើងមិនសូវដឹងជាក់ស្តែងប៉ុន្មាន ប៉ុនតែខាងមជ្ឈិមបក្សនឹង គេច្រើនយកពីយើងកំពូលនេះទៅពីក្រុងទៅ ។

បូលី ៖ ប៉ុល ពត?

ភាព ៖ មិនទេ មិនមែនទេ ។

សែ ៖ ប៉ុល ពត ត្រូវកាន់ជើងខាងនេះទេ ។

ភាព ៖ ប៉ុល ពត ត្រូវកាន់ជើងខាងនេះចំណាប់ណាស់ ។

សែ ៖ ស្លាប់រស់អីលើខាងនេះ ។

បូលី ៖ អាច នួន ជា?

សែ ៖ នួន ជា អត់ទេ ។

បូលី ៖ អៀង សារី?

សែ ៖ នេះដែលធូន់ជាងគេ សោ ភឹម ។

បូលី ៖ សោ ភឹម?

សែ ៖ បាទ! សោ ភឹម មជ្ឈិមបក្សទី៦ ។

បូលី ៖ បាទ! សោ ភឹម ធំណាស់ ។

សែ ៖ ហ្នឹងហើយ បាទ! ភូមិភាគបូព៌ាទាំងមូល ហើយនឹង កុយ ធួន ខាងឧត្តរមានជ័យនេះ អឺ! ខាងភូមិភាគឧត្តរនេះ កុយ ធួន ។

បូលី ៖ ២នឹង ចង់បំបែក តា០៥?

ភាព ៖ ២នាក់នឹងជាមួយ វ៉ន វ៉េត។ នៅក្រុងភ្នំពេញ។ វ៉ន វ៉េត ហើយពាក់ព័ន្ធដល់ ជ័យ សួន ទន្លេក្រោម ហើយ ចេង អន នៅខស្សរាហកម្ម។ គេគប់គ្នារហូត។

ភាព ៖ ទេ! ឃើញថា ព្រោះអីក្រោយពីជ័យជំនះមក ប៉ុល ពត ទុកចិត្តតា សាន នេះព្រោះកាល ដែលទៅធ្វើសន្និបាតទូទាំងប្រទេសដែលប៉ុល ពត ចូលមកនៅកម្ពុជាដំបូងចូលភ្នំពេញដំបូង នៅនឹងស្ថានតែម្តង កងពលនឹងតែម្តង កងពលគ្រប់គ្រងការពារនៅស្ថានរៀបរយកំប្លេទាំងអស់។

សែ ៖ របនាសម្ព័ន្ធអីរាជវាំងអីគ្រប់គ្រង អានឹងរឿងពិត។

ភាព ៖ ១៨នឹង កន្លែងវាំង កន្លែងអីនឹងគឺ១៨ទៅកាន់កាប់ទាំងអស់ ហើយគាត់មានទំនុកទុកចិត្ត ណាស់ ការពារសន្តិសុខ ឲ្យគាត់មានសុវត្ថិភាព គឺកងពលនេះម៉ង។ នោះខាង សោ ភឹម ខាងអីនឹងប្រហែលកំទេច ប៉ុល ពត តាំងពីជ័យជំនះភ្នំពេញដំបូង តែធ្វើមុនបានជាមួយ តា សាន តា រឿន។

បូលី ៖ តា ២នឹង?

ភាព ៖ ចា៎!

សែ ៖ សោ ភឹម គាត់ពាក់អាវបក្សពលករ ធ្ងន់ជាង។

ភាព ៖ លេងគ្នា(ស្តាប់មិនបាន) តាំងពីជ័យជំនះហើយ។

បូលី ៖ ៧៥មក?

ភាព ៖ ចា៎! តាំងពី៧៥។

សែ ៖ អានេះខ្ញុំនិយាយរឿងពិតហើយ ព្រោះខ្ញុំដែលពួកខ្ញុំតស៊ូរហូតដល់ចប់ចុងចប់ដើម មិនងាកទៅ ខាងណាខាងណីអី ព្រោះចង់ធ្វើចលនាខ្លួនឯងបើខុសឲ្យដឹងខុស ត្រូវឲ្យដឹងត្រូវ ព្រោះយើង មានខួរក្បាលគិតដែរ។

ភាព ៖ អង្គភាពបុរស។ ការពារប្រដាប់អាវុធ នៃនទាំងអស់ ទាំងក្នុងនិងក្រៅ តែដោយឡែកតែខ្ញុំ មួយវរសេនាតូច ដើរតួជាកងទ័ពផង ដើរតួជាអ្នកសេដ្ឋកិច្ចផង ក្នុងកម្មវិធី។ ពេលមុននឹង ប៉ុល ពត ចូលទៅរៀបចំឯកសណ្ឋានប្រដាប់អាវុធ ឈរតំរង់ជួរគោរព ធ្វើជាយោធាដែរ។ ពេលគាត់ឡើងចូលស្ថានដុត ពួកខ្ញុំទៅកន្លែងផ្ទះបាយរៀបចំម្ហូបអាហារផ្នែកនឹងទាំងអស់អត់ មានឲ្យអង្គភាពផ្សេងមកបៀតបៀន។

បូលី ៖ គិតទៅ៨០១នឹង ខ្លាំង?

ភាព ៖ ចា៎! ពេលរៀបចំនឹង បង០៥នឹង គាត់ត្រូវតែពិនិត្យមើលហើយ បានឲ្យភ្ញៀវចូលហូប។

បូលី ៖ ខ្លាចមានពុលមានអី?

ភាព ៖ ចា៎! ពេលយើងជញ្ជូនឆ្លងកាត់ សុទ្ធតែកម្លាំងយើងទាំងអស់ ទាំងចេញទាំងចូលទាំងកន្លែងបន្ទន់កន្លែងអីយើងទាំងអស់ ។

បូលី ៖ និយាយរួមមួយកម្មវិធីនឹង គឺ៨០១ម៉ង?

ភាព ៖ ៨០១តែម្ដង ។

បូលី ៖ មិនអាចមានកងពលណា ទៅចូលមកទេ?

ភាព ៖ កងពលចូលជាភ្ញៀវទេ ។

បូលី ៖ ហើយអ្នករៀបចំ?

ភាព ៖ រៀបចំ៨០១ ។ ពួកខ្ញុំពូជាម្នាក់ៗចង់ខ្យល់ រៀបចំទម្រាំភ្ញៀវហូបបាយហើយ រៀបតុកន្លែងប៉ុល ពត អីគាត់ហូបហើយ ។ បង០៥ អត់មានហ៊ានហូបជាមួយ ប៉ុល ពត ទេគាត់មកហូបតុជាមួយពួកខ្ញុំ ។

សែ ៖ ហើយសមាសភាពដែលសំរិតសំរាំង ។

ភាព ៖ តុនឹង តុក្រោយគេសល់ពី ប៉ុល ពត ហូបមុនតែម្ដង អត់មានរបស់ថ្មី ទេ ។

សែ ៖ ព្រោះគាត់ គេធ្វើយាដកម្មគាត់ជាប់រាល់យប់ អត់បានសំរាកទេ ខ្ញុំនៅការពារជុំវិញនឹង ម្ដុំសារថ្មីនឹង គាត់មួយយប់នឹង គាត់ដើរចល័តរហូត ។ ថ្ងៃបានមានពេលសម្រាក ។

ភាព ៖ យប់នេះគាត់ទៅនៅ ម៉ោងនេះចេញនេះ ម៉ោងនោះចេញនោះ ។

សែ ៖ ទៅនៅតាមអគ្គភាព ទៅប្រាជ្ញប្រាក ។

បូលី ៖ ពេលចេញទៅម្ដងៗ ពីណាអ្នកការពារគាត់?

សែ ៖ ដែលសេនារបស់គាត់នឹង ជុំវិញរបស់គាត់នឹងតែ៤-៥នាក់ ។

ភាព ៖ អង្គរក្សគាត់នឹង ហើយនឹងកន្លែងកងពលយើងនឹង ។

សែ ៖ មកតែជុំវិញកងពលនឹងទេ មិនហ៊ានទៅក្រៅទេ ព្រោះអត់ទុកចិត្តគេ ។

បូលី ៖ មានសញ្ញាមួយ ដែលបង្ហាញថាគេចង់សម្លាប់គាត់ទេ?

សែ ៖ ចុះយើងមានផ្ទុះ២-៣សារហើយ ប៉ុន្តែមិនត្រូវ ។ លើកក្រោយប៉ះនិរសា ពួកនឹងការពារបាន ។

បូលី ៖ ផ្ទុះនៅពេលណា ពូអាចចាំ?

សែ ៖ នៅម្ដុំក្រុងភ្នំពេញនឹង ។

បូលី ៖ ផ្ទុះគ្រាប់បែក ឬផ្ទុះអាវុធ?

សែ : អាវុធ ។

បូលី : អាវុធ បាញ់គ្នាម៉ង?

សែ : បាទ! លើកទី២ លើកទី៣ នៅស្ពាតអូឡាំពិច ប៉ុនបាញ់អត់ចេញទាន់ កងការពារវា ប្រយ័ត្នដែរ អានឹងមកពីអា ភឹម ដែរ ។

បូលី : ម៉េចបានដឹងថា?

សែ : ចុះអានឹងវាកម្លាំងកងពលពីបូព៌ាមក ។

ភាព : ជុំវិញគាត់សុទ្ធតែការពារគេខ្លាំងណាស់ ល្មមៗចូលអត់ចុះដែលនឹង អាវុធក៏អត់ទាន់ដើងហើយ នឹងដៃដែរ ។

សែ : សុទ្ធពួកជើងឯក នឹងខ្ញុំឃើញព្រឹត្តិការណ៍ច្រើនដែរ នៅក្រុងភ្នំពេញ ។

បូលី : ការពិតយើងដឹងថាម៉េចពួកបូព៌ានឹង ជាអ្នកធ្វើបាតុភូតទាំងអស់នឹងឲ្យកើតមានឡើង?

ភាព : ចុះសួរចម្លើយអាអ្នកចាប់បាននឹង មិនឆ្លើយអ្នកណាអ្នកធ្វើ ។

សែ : អានឹងជើងឯកអ្នកបាញ់ ស្រឡាញ់ត្រង់ណា ដាក់ត្រង់នឹង គាំភ្លើងខ្លីរបស់វាប៉ុនវាធ្វើមិនបាន សកម្មភាពពេលនឹង ដែលប៉ុល ពត ឡើងប្រកាសបក្សកុម្មុយនីសកម្ពុជា ។

ភាព : សូម្បីតែពេលផ្តល់ថ្នាំឲ្យកម្លាំងដែលចូលរួមក្នុងកម្លាំងនឹង ក៏កម្លាំងពេទ្យយើងដែរ ហើយពេទ្យ អត់យកពេទ្យរួមទេ ពេទ្យអង្គភាព យកស្រ្តីពេទ្យក្នុងអង្គភាព ខ្ញុំ២នាក់អាពៅ មកវិញរកកៅ អីវិញមិនចង់ឃើញ ។ ចុះស្ពាតមនុស្សមិនចេះតិច ដល់ពេលចូលចំណោមទៅមើលទៅ ដើរ ចង់ខុសកៅអី ។ ហើយគាត់ពាក់មួកអត់ដូចយើងទេ ដាក់ក្លីប មួកគាត់បញ្ឈិតទៅចេះ ។

បូលី : បញ្ឈិតក្បាលទៅចេះ?

ភាព : ចា៎!

បូលី : ហេតុអីបានគាត់ពាក់ចឹង?

ភាព : ដឹង ។

បូលី : តា ប៉ុល ពត?

ភាព : ចា៎!

សែ : អត់ទេ អារម្មណ៍ខួរក្បាលរបស់គាត់ដូចកុំព្យូទ័រ ។

ភាព : អត់ឲ្យបាំងភ្នែកម៉េច គាត់ខបមាពាក់ចឹង ខ្លាចដូចថាបាំងអីនេះ ឲ្យគាត់ពាក់ជិតទៅវាច្បាស់ ធម្មតា ។

សែ : គាត់រវាស មើលម៉ង នៅគាត់មានកម្លាំង ។

បូលី ៖ អ៊ូ! ខ្លាំងកាលនឹង ។

ភាព ៖ យី! ពេលសាច់ៗ ដើរមកចាប់ដៃខ្ញុំ ។

សែ ៖ ១ម៉ែត្រ៨០នោះ ។

ភាព ៖ ឃើញអង្គភាពនារីមុនគេ ចេញមកចឹង គាត់ដូវចូលចឹង ពួកខ្ញុំឈរចេះដូវទៅប៉ុនគាត់ដើរចាប់ដៃ ហើយគាត់ឡើង ។ ហើយនៅក្មេងៗណាស់ គាត់ កូនៗតូចៗ ។

បូលី ៖ មិនបានចាប់ដៃគាត់ទេ?

ភាព ៖ ចា៎! ខ្ញុំដូរមុខ ព្រោះកងទ័ពកាលនោះគេមានរបៀបណាស់ណា អ្នកតូច អ្នកខ្ពស់ អ្នកទាប គេដាក់ឈរតាមលេខរៀងរបស់គេដើរទៅ ។

បូលី ៖ កាលនឹងគេហៅខួបកងទ័ពបដិវត្តន៍ ដែលតា ប៉ុល ពត គាត់ឡើងទៅធ្វើអធិបតី?

សែ ៖ ខួបកំណើត ។

បូលី ៖ ឆ្នាំ៧៥?

ភាព ៖ ៧៥ ប៉ុនខ្ញុំភ្លេចខែ មិនដឹងខែប៉ុន្មានទេ ។

សែ ៖ ចោលបាត់ទៅហើយ ។

បូលី ៖ ខែប៉ុន្មានទេនេះ?

សែ ៖ ប្អូនឯងតាមដានអីទៀតចេះបានដឹងរឿងច្រើន ប៉ុនយកកិច្ចការងារក្នុង៨០១នេះ វាពាក់ព័ន្ធវែងឆ្ងាយណាស់ ព្រោះទ័ពនេះវាសម្រាប់ទូទាំងប្រទេស សិក្សាដឹងរឿងរ៉ាវច្រើនណាស់ ។

ភាព ៖ សូម្បីតែគាត់មកនៅខ្មែរក្រហម ក៏គាត់ទុកចិត្តអង្គភាពបង ។

បូលី ៖ ៨០១ដែរ?

ភាព ៖ ចា៎! គាត់ទៅនោះយប់ គ្មានអ្នកណាដឹងទេ គាត់នៅនេះ តែគាត់ទៅទំនប់ដាច់ អត់មានអ្នកណារលឹង ទៅដល់ម៉ោង៨យប់ហើយ ពួកខ្ញុំគេទៅហៅខ្ញុំអីមកជួយរៀបកន្លែងឲ្យគាត់សម្រាក ហើយម្ចាស់ផ្ទះអត់នៅទៀត តា០៥ក៏អត់នៅ ប្រពន្ធគាត់អត់នៅទៀត នៅតែ ។

សែ ៖ គាត់ឡើងទៅមើលពួកខ្ញុំធ្វើស្រែ ជុំទៅវិញ ហៅគ្នាពូៗអីមកយាមយប់ឡើង ស្អែកឡើងគាត់ឲ្យជូនដើរមើលស្រែ គាត់ចុះដល់ស្រែស្រូវ គាត់ថាស្រូវខាងនេះល្អ គាត់ថាសប្បាយចិត្ត គាត់ចង់មកសុំឲ្យ សារឿន ធ្វើផ្ទះឲ្យមួយហើយ នៅនេះសប្បាយណាស់ ភ្នាមៗ ។ ចុះទំនប់ដាច់សម័យនោះគួរសម មិនដូចអន្លង់វែងៗអន់ជាងទំនប់ដាច់ ។ ទំនប់ដាច់គេមានផ្ទះរបបធ្វើឲ្យនៅ ។

សែ ៖ ខ្ញុំជាអ្នកជួយសាងសង់គ្រប់កន្លែង ។

ភាព ៖ មួយគ្រួសារដឹងតែមេគោមួយ ហើយស្រូវអង្ករអត់ដែលខ្វះហូបទេ តា ខាងខ្ញុំធ្វើបានច្រើន តា ដូរអង្ករដូរស្រូវ គាត់ទិញ អត់ដែលយ៉ាប់ទេ ។ តា នោះចូលចិត្តណាស់ តា រឿន ដឹក នាំគាត់ចូលចិត្តរឿងអ្នកបង្កបង្កើនផលដូច តា ម៉ុក គាត់ចូលចិត្តណាស់ អ្នកប៉ិនធ្វើជួយរហូត សូម្បីតែឡានដឹកដីអាធំៗនឹងទៅជួយដឹកស្រូវខ្ញុំមកពីស្រែយកមកបោកដល់ផ្ទះ តែឡានទៅ ដល់កន្លែងដេញហើយ ឯងទៅមើលស្រែម្តុំនេះ ម្តុំនោះ ពុមិត្តភាព គាត់ច្រូតហើយគាត់អត់ មានអីដឹកទេ ឡានមកដល់ស្រែខ្ញុំម៉ង ដាក់២ឡានធំៗដឹកមកទាំងកណ្តាប់លើកបោះៗ ខ្ញុំដើរ ចាប់ ស្អែកឡើងគោយន្តម៉ាស៊ីនគាត់បោកឲ្យ ។

បូលី ៖ តា សារឿន នេះជួយ?

ភាព ៖ ចា៎! គាត់ជួយ ។

បូលី ៖ កាលពីនៅប្រជុំស្តាតអូរឡាំពិច ស្តាតនឹង ស្តាតចាស់ ឬស្តាតថ្មី?

សែ ៖ អូរឡាំពិចនឹង អាស្តាតថ្មី ។

បូលី ៖ អាថ្មីនៅក្បែរផ្សារអូរឡាំពិចនឹង?

សែ ៖ បាទ! ដែលជាប់វត្តព្រះពុទ្ធយើង ។

បូលី ៖ មិនមែនអាចាស់គល់ស្ពានជ្រោយចង្វារទេ?

សែ ៖ អានឹងស្តាតចាស់ទេ ។

បូលី ៖ កាលនឹងគឺយើងបែកភ្នំពេញប្រហែលជាប៉ុន្មានខែ គេចាប់ផ្តើមប្រជុំ?

សែ ៖ ៣ខែ ។

បូលី ៖ ៣ខែ?

សែ ៖ បាទ! សន្តិសុខមានស្ថេរភាពហើយ ។

បូលី ៖ ពេលនឹងអ្នកណាខ្លះធ្វើជាអធិបតីនៅក្នុងពិធីប្រជុំនឹង?

ភាព ៖ អ៊ូ! ច្រើនណាស់ រាប់មិនអស់ ។

បូលី ៖ ប៉ុនមាន តា ប៉ុល ពត ដែរ?

ភាព ៖ ចា៎! មានគាត់ប្រធាន ក្រៅពីនឹងអមគាត់ខ្ញុំមិនស្គាល់ទេ ។

សែ ៖ ហ៊ោ! គណៈចាត់តាំង ណាទេ ។

បូលី ៖ តា នួន ជា អីចូលទេ កាលនឹង?

សែ ៖ ចូលទាំងអស់ ។

បូលី ៖ តា ម៉ុក អី?

សែ ៖ ២១រូបនោះ មិនមែនតិចណា ។

បូលី ៖ អ៊ូ! មជ្ឈឹម?

សែ បាទ! តាំងពី ចាន់ ស៊ី ក៏មក ។

បូលី ៖ អ៊ូ! ចាន់ ស៊ី មកដែរ?

សែ ៖ មក ចាន់ ស៊ី នៅភូមិភាគពាយ័ព្យនឹង ចាន់ ស៊ី, វ៉ន វ៉េត, ចេង អន, សុទ្ធមជ្ឈឹមហើយ ទៅកើត សោ ភឹម, មកលិចនេះ កុយ ធួន, រស់ ញឹម, នែក!មើលនៅភូមិភាគឥសាន នេះ យ៉ា ។

បូលី ៖ ណៃ សារ៉ាន់?

សែ ៖ ណៃ សារ៉ាន់?

បូលី ៖ ណៃ សារ៉ាន់ ហៅ យ៉ា ។

សែ ៖ ហ្នឹងហើយ ហៅយ៉ា ។ តា យ៉ា នឹងក៏(ស្តាប់មិនបាន)ដែរ ភូមិភាគនិរតី តា ម៉ុក នេះ ក៏ មក វ៉ន វ៉េត អឺ!នែក! ជ័យ សួនៗ ត្រកូលគាត់ពីរ ។

បូលី ៖ គេហៅ តា ជ័យ?

សែ ៖ ហ្នឹង តា ជ័យ ។ ខ្ញុំទៅដេកពេទ្យនឹងដែរ កាលត្រូវរបួសធ្ងន់នឹង ។

បូលី ៖ ដួន ជឿន ឃើញទេ?

សែ ៖ ក៏មក នឹងមកដែរ ហើយនែក! ។

បូលី ៖ ខៀវ សំផន មានទេ?

សែ ៖ មកៗដែរ មកតំណាងឲ្យរដ្ឋ ។

បូលី ៖ អៀង ធីរិទ្ធ អីមានទេ ប្រពន្ធ អៀង សារី?

សែ ៖ ដូចអត់ទាន់ជាប់មជ្ឈឹមទេ កាលនោះ ។

បូលី ៖ អត់ទាន់ទេ?

សែ ៖ អត់មកទេ អត់មានមជ្ឈឹម ។

បូលី ៖ សុន សេន?

សែ ៖ សុន សេន មកៗ (ស្តាប់មិនបាន) ២១រូប ។ នែក! កង ចាប កាលនឹងចូលខាងតុលាការ ពីមុនការងារតុលាការ ។

បូលី ៖ ចុះ កែ ពក?

សែ ៖ កែ ពក មកដែរ ទៅចូលមជ្ឈឹមទាំងអស់ ខ្ញុំរាប់ទៅឃើញ២១ ។

បូលី ៖ ហើយអ្នកដែលចូលក្នុងស្តាតអូរឡាំពិចនឹង កងពលណាខ្លះដែលទៅនឹង?

សែ ៖ កងពលប្រចាំប្រទេស មកទាំងអស់ ហើយមេបញ្ជាការតាមភូមិភាគក៏មកដែរ មេបញ្ជាការកងពល ។

បូលី ៖ មេបញ្ជាការកងពល?

សែ ៖ បាទ! ក្នុងឋានៈកងពល សមាជិកកងពលទាំងអស់មេបញ្ជាការក្រុមខណ្ឌកងពលមកទាំងអស់ចំរុះ ។

បូលី ៖ និយាយរួមទូទាំងប្រទេសម៉ង?

សែ ៖ បាទ! ទូទាំងប្រទេស ។

បូលី ៖ ទាំងកងពលមជ្ឈិម ទាំងកងពលភូមិភាគ?

សែ ៖ ២១ កងពល ។

បូលី ៖ ទាំងអស់?

សែ ៖ បាទ!

បូលី ៖ មាន២១កងពល?

សែ ៖ មាន២១កងពល ដែលពេញលក្ខណៈ ។

បូលី ៖ ដែលកងពលពេញលក្ខណៈនឹង?

សែ ៖ បាទ!

បូលី ៖ ទូទាំងប្រទេស២១?

សែ ៖ តាំងពីខត្តរបូព៌ា និរតី បស្ចឹម ក៏ចូលដែរ បានថាមនុស្សរាវរត់ ។

ភាព ៖ ទូទាំងប្រទេស ប៉ុនគ្រាន់ថាកងពល១៨នឹង គេធ្វើជាម្ចាស់ផ្ទះ ។

សែ ៖ ម្ចាស់ផ្ទះ ប៉ុនយើងមានសិទ្ធិទៅតាំងពីអនុសេនាធំទៅ ចូលទៅមហាសន្និបាតនឹង ។

ភាព ៖ ទាំងយុទ្ធជនចូលទៅការពារដែរ គ្រប់អង្គភាពនៅក្នុងកងពលនឹង ។

បូលី ៖ ប៉ុននៅក្នុងចំណោមកងពលទាំង២១នឹង គឺកងពល១៨នេះ ជាម្ចាស់ផ្ទះ នៅក្នុងការរៀបចំពិធីទាំងមូល?

ភាព ៖ ចា៎!

សែ ៖ កងពល១៨, កងពល១១, កងពល១៣ អឺ! កងពល១២ នៅ៣នឹងនៅកងមជ្ឈិមផ្ទាល់ ។

បូលី ៖ ជាកងពលភូមិភាគពិសេស?

សែ ៖ ហ្នឹងហើយ ភូមិភាគពិសេស ។

បូលី ៖ ជាអ្នកការពារអន្តពិធីទាំងមូលតែម្តង?

ភាព ៖ ចាំ!

បូលី ៖ ហើយពិធីនឹងគេធ្វើរយៈពេលប៉ុន្មានថ្ងៃដែរ?

ភាព ៖ ធ្វើតែមួយថ្ងៃនឹង ។

បូលី ៖ មួយថ្ងៃ ចាប់ផ្តើមពីម៉ោងប៉ុន្មានទៅ?

សែ ៖ ហែលក្បួនទ័ព យប់ឡើងទៀត ។

ភាព ៖ ម៉ោង៨ យប់តែសិល្បៈតែនេះទេ ប៉ុន្តែគាត់ចូលរួមបានមួយព្រឹកនឹង ហូបបាយរួមគាត់ចេញដំណើរទៅ អត់មានបាននៅ សិល្បៈអីនឹងយើងសម្រាប់កំដរខាងក្រោយទេ ។

បូលី ៖ ចឹងបើសិនជាយើងគិតតែពិធីមេវិញ កុំគិតពីសិល្បៈវិញ?

ភាព ៖ គិតតែមួយព្រឹកនឹងឯង ។

បូលី ៖ តែមួយព្រឹកនឹង?

ភាព ៖ ចាំ!

បូលី ៖ ក្នុងរយៈពេលមួយព្រឹកនឹង មានប៉ុន្មាននាក់ឡើងចាប់អារម្មណ៍?

សែ ៖ គ្រប់កងពល ។

បូលី ៖ គ្រប់កងពល?

សែ ៖ បាទ! ឡើងចាប់អារម្មណ៍ទាំងអស់ ។

បូលី ៖ តា០៥ គាត់មានឡើងទេ?

សែ ៖ ឡើង ០៥ បូព៌ានេះ គេឡើង គឺ សូ មាន ហៅ ច័ន្ទ ចក្រី នេះ ។

បូលី ៖ ច័ន្ទ ចក្រី ឡើង?

សែ ៖ ឡើង ។

បូលី ៖ ច័ន្ទ ចក្រី ឈ្មោះគាត់ សូ មាន?

សែ ៖ បាទ!

បូលី ៖ ចុះខាងនិរតីពីណាគេ?

សែ ៖ និរតី តាអី តា ប៊ិត ។

បូលី ៖ សំ ប៊ិត នឹង?

សែ ៖ បាទ!

បូលី ៖ សំ ប៊ិត មេបញ្ជាការភូមិភាគនិរតី?

សែ ៖ បាទ! ភូមិភាគនិរតី។ ចង់ភ្លេចអស់វាច្រើន ចុះគេហៅប្រកាសគ្រប់កងពលទាំងអស់ ឡើង
ទាំងអស់ ឡើងឈរ តំណាងទាំងអស់។

បូលី ៖ ចុះ ខាងឥសាន ពីណាគេឡើង?

សែ ឥសាន កាលនឹងដូច តា ធិន គាត់កាន់បញ្ជាការដែរ គាត់ស្លាប់។

បូលី ៖ ខាងខត្តរពីណាគេ?

សែ ៖ ខត្តរ សំអឿន។

បូលី ៖ កុយ ធួន?

សែ ៖ ហ៉ើ! អានឹងភូមិភាគហើយ។

បូលី ៖ ភូមិភាគ?

សែ ៖ គណៈមជ្ឈឹមហើយ។

បូលី ៖ គណៈមជ្ឈឹម?

សែ ៖ បាទ! សំអឿន។

បូលី ៖ សំអឿន ខាងខត្តរ?

សែ ៖ បាទ! រៀងខ្ពស់ដូច០៥។

បូលី ៖ ខត្តរ និរតី បូព៌ា ចក្រី ពាយ័ព្យ?

សែ ៖ ពាយ័ព្យមិនដឹងអ្នកណាគេទេ ខ្ញុំអត់សូវស្គាល់ដែរ ពាយ័ព្យ។

បូលី ៖ បើភូមិភាគពិសេសនេះ គឺ តា០៥ហើយ?

សែ ៖ ០៥, តាណាត ១២, តាសោម ១១, តា សោម ឡើងដែរកាលនឹង។

បូលី ៖ តា សោម១១?

សែ ៖ បាទ! ជាមួយ តា ពៀច។

បូលី ៖ ១១ តា ពៀច, តា សោម?

សែ ៖ បាទ! តា សោម នឹងយកស្លាបកាបប៉ាវខ្ញុំមួយកាលនោះ គាត់ថាមើលអ្នកក្រុង ឲ្យគ្នាអញសុំ
មួយ យកៗទៅទះអាវ(ស្តាប់មិនបាន)របស់បារាំង ដូវទីន។

បូលី ៖ អ៊ូ! ចឹង តា ណាត, តា០៥, តា ពៀច, តា សោម ឡើងចាប់អារម្មណ៍ដែរ?

សែ ៖ បាទ! តា ឡាយ អនុបញ្ជា តា ណាត។

បូលី ៖ តា ឡាយ អនុរបស់ តា ណាត?

សែ ៖ អនុរបស់ តា ណាត។

បូលី ៖ អី ឡាយ ពូ?

សែ ៖ វាភ្លេចត្រកូលអស់នឹង វាយូរពេក ពីដើមចាំ ។

បូលី ៖ តា ឡាយ អនុរបស់ តា ណាត ហើយសមាជិករបស់ តា ណាត នឹងពីណាគេ មានពាទាក់នឹង?

សែ ៖ តា ពីន ។

បូលី ៖ អូ! ចឹង តា ពីន សមាជិក?

សែ ៖ ហ្នឹងហើយ ចេះចេញហើយរឿង រកនឹកឃើញ ។

បូលី ៖ ក្រោយមកបានពេលដែល តា ណាត?

សែ ៖ ទៅទូត ។

បូលី ៖ ទៅទូតនៅណា?

សែ ទៅទូតប្រទេសកូរ៉េ ក៏មិនដឹង តា ណាត កាលនឹង ។

បូលី ៖ កូរ៉េ ដូចតានេះទេ តា ស៊ឹម ស៊ុន ទេ តា ស៊ឹម ស៊ុន ដែល?

សែ ដូចប្ដូរ តា ណាត មកវិញ គាត់ថាគាត់មិនចេះធ្វើទេ ទូត ជាមនុស្សដែលចេះតែយោធា ចូលចិត្តតែយោធា ។

បូលី ៖ ក្រោយមក តា ណាត ដូចឡើងទៅគណៈសេនាធិការ ជាមួយ សុន សេន?

សែ ៖ ហ្នឹងហើយ ។

បូលី ៖ ហើយបាន តា ពីន ឡើងជំនួស?

សែ ៖ ឡើងរង ។

បូលី ៖ តា ឡាយ អត់ឃើញឡើងជាមេកងពលសោះ តា ឡាយ?

សែ ៖ តា ឡាយ មិនដឹងទៅណាកាលនឹង តា ឡាយ តាមពិតទៅជាប់និន្នាការពីភាគខាងជើងមកដែរ ។

បូលី ៖ អ៊ូ! ជាប់វៀតណាមដែរ?

សែ ៖ ហ្នឹងប្រវត្តិគាត់ តាមខ្ញុំដឹង ។

ភាព ៖ ការពិត ខ្លះជាប់ចោទខ្លួនឯងអត់ដឹងខ្លួនផង មិនដឹងជាប់អីផង និយាយតែជិតស្និត។ គេថាជាប់ទៅ ការពិតអត់ដឹងសោះ ។

បូលី ៖ អានេះយើងមានខាងបូព៌, និរតី, ឦសាន, ឧត្តរ, ពាយ័ព្យពីណាគេ?

សែ ៖ ពាយ័ព្យអត់បានស្គាល់ទេ ទៅតែនេះទេ ភូមិភាគនេះទៅពាយ័ព្យ ។

បូលី ៖ ទៅតែ រស់ ញឹម?

សែ ៖ បាទ! នៅបស្ទឹមមួយទៀត ពាយ័ព្យកម្លាំងកងទ័ពអត់បានទៅចូលក្រុងទេ ដូចជាកាច់ញោច ជាងគេពេក ចូលបានតែបស្ទឹម ។

បូលី ៖ តា ជូ ជេត?

សែ ៖ ហ្នឹងហើយ ។

បូលី ៖ ពីណាគេតំណាងកងទ័ព?

សែ ៖ មិនដឹងអ្នកណាដូចជាភ្លេចបាត់ហើយ គេសុទ្ធតែប្រកាស វាយូរឆ្នាំពេក ។

បូលី ៖ ហើយឡើងចាប់អារម្មណ៍មុនគេបំផុតពីណាគេកាលនឹង?

ភាព ៖ ខ្ញុំអត់បានដឹងទេ ខ្ញុំទៅនៅខាងសេដ្ឋកិច្ចហើយ ។

បូលី ៖ អ៊ូ! មីងទៅរៀបចំម្ហូបអាហារ?

ភាព ៖ ចា៎!

បូលី ៖ ពូនៅនឹង?

សែ ៖ នៅនឹង ប៉ុនរកនឹកគណៈចាត់តាំងមិនដឹងអ្នកណាកាលនឹងរដ្ឋមន្ត្រីប្រកាសដូច បូពាំមុន ។

បូលី ៖ បូពាំមុនគេ?

សែ ៖ បាទ!

បូលី ៖ ចឹងមីងគ្រាន់តែ តា ប៉ុល ពត ដើរចូលមកហើយ ចាប់ដៃ មីងទៅរៀបចំម្ហូបបណ្តោយ?

ភាព ៖ ចា៎!អន្តភាពនឹង គាត់ដើរផុតហើយ អន្តភាពនឹងចេញរ៉ូតែម្តង ដោះប្រដាប់អាវុធទៅ ស្លៀក ពាក់ស៊ីវិលធម្មតា រៀបបាយទឹកវិញម្តង ។

បូលី ៖ កន្លែងណាធ្វើម្ហូប នៅកន្លែងណា?

ភាព ៖ នៅជាប់គ្នា ។

សែ ៖ ខាងត្បូងវត្តព្រះពុទ្ធនឹង ។

ភាព ៖ ជាប់ម្ហូបអាហារយកទៅដាក់ជាប់នឹងស្តាត យើងមានរោងមួយយកមកធ្វើដាក់នៅតំកល់ទុក ប៉ុនម្ហូបសំខាន់ៗដែលក្លាសេសដូចគ្រឿងកំប៉ុង គ្រឿងអីនឹង យើងនៅកន្លែង៨០៣ អានឹង គេអ្នកគ្រប់គ្រង ។

បូលី ៖ អីគេ៨០៣?

ភាព ៖ វរសេនាតូច ព្រោះវាមាននៅក្នុងជំនាញឲ្យធ្វើត្រៀមស្រេច ។

បូលី ៖ កងកាំភ្លើងធំ៨០៣?

ភាព ៖ ចា៎! ពួកកាំភ្លើងធំនឹង គេយកសាច់ជ្រូកគេសាច់អីនៅគេទាំងអស់ ដល់ត្រូវការគេយកមកឲ្យយើងៗត្រូវការអីគេដឹកមកៗតែម្តង ព្រោះយើងបានរាប់រៀបចំ ហើយនឹងទទួលទេ រឿងធ្វើគេខាងនោះធ្វើហើយស្រេចៗ

បូលី ៖ កាលនឹងមានម្ហូបប៉ុន្មានមុខ មីងចាំទេ?

ភាព ៖ ច្រើនមុខដែរ ព្រោះកាលនោះគេត្រូវការហូបបាយផង ហូបនំប័ុងផង មាន២-៣មុខចឹងទៅម្ហូប៣-៤មុខដែរនឹងៗ

បូលី ៖ ហូបប៉ុន្មានពេល តែថ្ងៃត្រង់មួយពេលទេ ឬក៏ពេលព្រឹកមានហូបដែរ?

ភាព ៖ ពេលព្រឹកអត់ទេ តែថ្ងៃត្រង់ទេៗ

បូលី ៖ ពេលព្រឹកហូបរៀងខ្លួនចឹង?

ភាព ៖ ចា៎! ពេលព្រឹកមុនទៅហូបហើយៗ ស្រស់ស្រូបខ្លួនឯងៗ

បូលី ៖ ពីកន្លែងទៅហើយ ទៅដល់នោះ គឺថាចាំទទួលភ្ញៀវតែម្តង?

ភាព ៖ ទទួលតែមួយពេលនឹងទេៗ

សែ ៖ វាអត់មានសេដ្ឋកិច្ចពាណិជ្ជកម្មឯកជនណា សុទ្ធតែប្រមូលដាក់ការរបស់គេទាំងអស់ៗ

ភាព ៖ ចុះបើទទួលមិនចេះតិចណា ២ជាន់ស្តាតនឹងដាក់ម្ហូបរៀបណែនទាំងអស់ៗ

សែ ៖ អ៊ូ! កាលនឹងដូចក្រសួង ហូ នឹម ចូលដែរ ខាងក្រសួងឃោសនាការចូលដែរៗ

បូលី ៖ ត្រូវហើយ ហូ នឹម មិនទាន់ស្លាប់ណាកាលនឹងៗ

ភាព ៖ នៅៗ

សែ ៖ នៅ ហើយ ទីវ អុល ពីរនាក់នឹងៗ ខ្ញុំទៅនៅប៉ុស្តិ៍នឹងវា៦ខែ ៧ខែដែរនឹងៗ

បូលី ៖ ប៉ុស្តិ៍?

សែ ៖ ការពារកន្លែងប៉ុស្តិ៍នឹងៗ

បូលី ៖ ស្តាតនឹង?

សែ ៖ អត់ទេ កន្លែងប៉ុស្តិ៍ កន្លែង ហូ នឹម នឹងៗ

បូលី ៖ ប៉ុស្តិ៍វិទ្យុ ហូ នឹម?

សែ ៖ បាទ! ព្រោះសន្តិសុខវាអត់នេះ អត់ធានា យប់ព្រលប់អីយើងខ្លាចៗ

បូលី ៖ បកមកម្ហូបវិញ គេរៀបចំជាតុ ឬក៏អង្គុយនឹងដី?

ភាព ៖ តុៗ

បូលី ៖ ទាំងអស់គ្នា ឬតុសម្រាប់មេៗទេ?

ភាព ៈ អត់ទេ តុទាំងអស់គ្នា ។

បូលី ៈ ទាំងកងទ័ព ទាំងអីទាំងអស់?

ភាព ៈ ចា៎! តុស្មើគ្នាម៉ង ។

បូលី ៈ កាលនឹងមីងចាំទេ មានម្ហូបអីខ្លះ?

ភាព ៈ ភ្លេចហើយ ។

បូលី ៈ ឆា ស្ងោរ ឆាមាន់?

ភាព ៈ វាច្រើន ម្ហូបច្រើនមុខ ប៉ុនគ្រាន់ថាយើងភ្លេច មានតាំងផ្លែឈើ មានអីសម្រាប់ហូបមួយចប់នឹង ។

បូលី ៈ ប៉ុនមីងអត់ចាំមុខម្ហូប?

ភាព ៈ ចា៎! អត់ចាំទេ វាយូរពេកហើយបានអីចាំមុខ ដឹងច្រើនមុខ ដឹងមុខស្អីខ្លះ ដឹងតែមានបាយផង មាននំប៉័ងសាច់ប៉ាតេ មានអីមួយចប់ ។

សែ ៈ បើយូរអត្ថុយមួយកន្លែងចេះនឹកឃើញ ប៉ុនវាដើរកាត់ទូទាំងប្រទេស ហើយវាផ្លាស់ប្តូរហូត ។

បូលី ៈ ហើយចុះទឹកវិញមានអី?

ភាព ៈ ទឹកនឹងយើងសុទ្ធតែទឹកក្លាសេសដូចគ្នានឹង ទឹកកកក៏មានអីក៏មានព្រោះកាលនោះមានទូសម្រាប់សាច់ប៉ាតេផង ឡើងរីងសុទ្ធតែទឹកកក ។ អាទឹកក្រូចទឹកអីនេះក្លាសេសយូរពេក រីង ទឹកក្រូចនៅក្នុងដបអត់មានចេញទេ អ្នកក្លាសេសអត់បានមើល ពេលដែលដឹកមកនៅរីងចេសនឹង ។

បូលី ៈ មានកូកាកូឡាអីទេ?

ភាព ៈ មានអាទឹកក្រូចរបស់យើងនៅសល់ពីមុនដែលនៅតាមហាងមួយៗ គេប្រមូលយកមកនោះមានទាំងអស់ និយាយរួមហូបនំប៉័ងមានអ្នកត្រូវហូបជាមួយសាច់ប៉ាតេហូប មានអ្នកហូបជាមួយបឺរផ្អែមនោះ គេជ្រលក់ជាមួយបឺរនឹងជ្រលក់ទៅ ។ វាមានកាលនោះ វាសំបូរនោះភ្នំពេញដំបូងសំបូរណាស់ ល្មមតែគេថាសុទ្ធតែពួកស្តេស្វាទៅនៅទីក្រុង ។

បូលី ៈ ចង់និយាយថាម៉េចទៅ?

ភាព ៈ ស្តេចស្វាគេចង់និយាយថា ពួកព្រៃដែលមិនដែលស្គាល់ក្រុងឃើញស្អីក៏ប្រមូលទុកប្រមូលដាក់ដែរ វាមិនដែលឃើញ ប្រមូលទុកប្រមូលគំកល់រៀបចំទាំងអស់ ។

បូលី ៈ កាលនឹងមីងស្នាក់នៅម្តុំណាដែរ?

ភាព ៈ ខ្ញុំនៅខាងលិចស្តាតនឹងម៉ង ។

បូលី ៖ អូ! នៅជិតស្តាតនឹង?

ភាព ៖ ចា៎! ផ្លូវទ្វារចូលស្តាតតែម្តង ។

បូលី ៖ ហើយយើងនៅក្នុងផ្ទះល្វែង ឬក៏នៅណា?

ភាព ៖ នៅនឹងនឹងផ្ទះល្វែងនឹង ផ្ទះធំៗនឹង ។

បូលី ៖ ហើយមានទឹកមានអីប្រើទេ មីងកាលនឹង?

ភាព ៖ មានតើ ។

បូលី ៖ អាទឹកក្បាលរ៉ូមីនេគេនឹង?

ភាព ៖ ចា៎!

បូលី ៖ នៅដើរនៅឡើយ?

ភាព ៖ នៅដើរតើ កន្ត្តារអីនៅដើរនៅអី ។

បូលី ៖ មានភ្លើងមានអីដែរ?

ភាព ៖ មានតើ ម៉ាស៊ីនទឹកកន្លែងស្តាតនឹង ដល់មកវាចូលអាម៉ាស៊ីនធំ ម៉ាស៊ីនធំនៅស្តាតរាល់ថ្ងៃនឹង ប៉ុន្តែក្រែងគេរើម៉េច ។ ហើយអាកន្លែងអាងនៅស្តាតអីនឹងយើងបូមចេញ ហើយយើងបើកបន្ទូរចូលវិញស្អាតចេះ ។ យើងលាងជុំវិញស្អាតនឹង បាញ់លាងឲ្យស្អាតទាំងអស់ តាមបន្ទប់ស្តាតកន្លែងកំសាន្តមន្ទីរខាងកើតនឹង យើងលាងឲ្យស្អាតអស់រលីងពីលើអាង បាញ់ត្រយោងដាក់សាប៊ូ បែកសាប៊ូពេញៗបន្ទប់ យើងបាញ់រៀបចំស្អាតទាំងអស់ ។ អាងទឹកនឹងយើងលាងប្រចាំ យើងបូមចោល ដុះលាងវាស្អាតបានយើងបន្ទូរទឹកចូល រៀបចំស្អាត ឡានបរឡើងលើស្តាតនឹង ។

បូលី ៖ ហើយមីងមានបានទៅចូលមើលវាំងទេកាលនឹង ដើរលេងដើរអី?

ភាព ៖ បានតើ ចូលតើ ។

បូលី ៖ បិទដែរ?

ភាព ៖ ចា៎! វាមានបិទអី បើអង្គភាពយើងនៅនឹង ។

បូលី ៖ យ៉ាងម៉េចដែរ ក្នុងវាំង ដូចគ្រឿងអី?

ភាព ៖ កាលនឹងគ្រឿងគ្រាប់របស់របរដូចនៅទាំងអស់ ប៉ុន្តែដូចឥឡូវដូចរៀងក្ងៗម៉េច ដូចមិនសុទ្ធ ។

សែ ៖ បាត់នេះ បាត់ព្រះខ័ន្ធរាជ ។

បូលី ៖ ព្រះខ័ន្ធរាជមែនទែន មិនដឹងជានៅណា?

សែ ៖ ព្រះវ័ន្ទរាជមែនទែន បាត់តាំងពីសម័យលន់ នល់ អានឹងព្រះវ័ន្ទនឹងដូចបរមី វាដូចដែលនេះ សុទ្ធម៉ង ដាវសិរិទ្ធ ។

ភាព ៖ ចុះយើងប្រគល់ដាវអាជ្ញាសឹកឲ្យទៅលន់ នល់ ហើយទៅរកឃើញទៀត ។

បូលី ៖ បាទ!

ភាព ៖ ព្រះវ័ន្ទនឹងដាវអាជ្ញា គេមានសិទ្ធិគេមានអំណាចហើយ បើដាវអាជ្ញាសឹកលើគេហើយ មិនប្រកាសកាលមុនរដ្ឋប្រហារ ។

សែ ៖ តាំងពីចន្រ្ទានោះ លន់ នល់ បានដាវអាជ្ញាសឹក ។

បូលី ៖ ហើយចប់ពីនឹងមក បានមីងមកត្បសាន?

ភាព ៖ ចាំ!

បូលី ៖ ត្បសាន យើងនិយាយអស់ហើយ ។ ឥឡូវចូលមកដល់កន្លែងដែលមីងថា តា០៥ គេឲ្យមកវៃជួយទប់ភ្នំពេញដែលវៀតណាមវៃចូលនេះ យ៉ាងម៉េច?

ភាព ៖ គេនិយាយរួម គេមិនមែនថាចូលទប់ទេ គេយកមកការពារកន្លែងមជ្ឈិម ។

បូលី ៖ កន្លែងមជ្ឈិមចង់សំដៅកន្លែង តា ប៉ុល ពត ស្នាក់នៅ?

ភាព ៖ ចាំ!

បូលី ៖ កន្លែងណាមីងចាំទេ?

ភាព ៖ អត់ដឹងទេ កន្លែងភ្នំពេញ ដឹងគាត់នៅកន្លែងណា បើខ្ញុំចេញមកដុតហើយ ចេញតាំងចុង៧៥ ព្រោះខ្ញុំចេញខែ១២ ខែកត្តិក ។

បូលី ៖ ប៉ុនពិបាកថាដែរ ព្រោះ តា ប៉ុល ពត គាត់ចល័តរហូត?

ភាព ៖ គាត់អត់ដែលនៅក្នុងនឹងដង ។

បូលី ៖ គាត់អត់ដែលនៅមួយកន្លែងទេ ។

ភាព ៖ អត់ដែលនៅទេ ហើយក្រោយពីអស់កងពលនឹងទៅ គាត់ចេញទៅក្រៅដងអីដង គាត់អត់ដែលសូវនៅក្នុងទេ ។

បូលី ៖ ហើយគាត់មកទេ តា០៥?

ភាព ៖ គាត់អត់ព្រមមកទេ គាត់រៀបចំកន្លែងប្រុងប្តូរទៅនៅស៊ឹងត្រែង ព្រោះកាលនោះគាត់ ។

សែ ៖ តា វ៉ឹង ភូមិភាគជិនួសតាយ៉ា ។

បូលី ៖ បាទ! តា វ៉ឹង ។

សែ ៖ ហ្នឹង តា វ៉ឹង មិននៅស៊ឹងត្រែង ។

បូលី ៖ បាទ! តា វ៉ង់ នៅស៊ីងត្រែង ។

សែ ៖ ហ្នឹងហើយដល់០៥នេះឲ្យទៅបូព៌ាមិនទៅ បានយកមកឲ្យគ្រប់គ្រងភូមិភាគវិញ ។

បូលី ៖ ពេលដក តា វ៉ង់ ទៅ?

សែ ៖ ហ្នឹងហើយ សភាពការណ៍ស៊ីងត្រែងវាអត់ល្អដែរ ។

ភាព ៖ ឲ្យភូមិភាគវិញ ប៉ុនដល់៧៩នឹង គេថាឲ្យទៅការពារនៅមជ្ឈិម គេត្រូវប្តូរកងពល តា ញ៉ាន់ នេះ៤១៧នេះ មកឈរ ។

សែ ៖ គេចង់រំលាយ ។

ភាព ៖ ការពិតគេចង់រំលាយ ហ្នឹងគាត់ប្រជុំប្រកាសទូទៅក្នុងកងពល ឲ្យដឹងទាំងអស់ទាំងយុទ្ធជនទាំងអស់ ឲ្យយើងត្រៀមមានការប្រុងប្រយ័ត្ន ហើយគេឲ្យយើងទៅតាមផ្លូវជើងទឹកតែម៉ាផ្លូវទេកងពលនឹង ។ អត់ឲ្យជើងគោកទេ តែគាត់អត់ឯកភាពទេ គាត់ថាគាត់សុខចិត្តរត់ជើងគោកទោះអស់ប្រេងអស់សាំងប៉ុណ្ណាក៏ដោយ ឡានគាត់ដឹកជញ្ជូនតាមជើងគោក ជើងទឹកតែគេបាញ់ភ្លឹប ឆាប់អស់គ្នាចេះហែលទេ គាត់និយាយចឹង ។ គាត់ប្រកាសប្រាប់ថាយើងគេយកទៅសម្លាប់ហើយ អត់មានត្រូវយកទៅរស់ទេ ភ្នំពេញ ។ គាត់និយាយប្រាប់ចឹងម៉ង ។

បូលី ៖ ប៉ុន តា ប៉ុល ពត នៅភ្នំពេញ ម៉េចក៏បណ្តោយឲ្យសម្លាប់បាន?

ភាព ៖ តាអត់នៅផង តាមាននៅណា សភាពការណ៍អត់ល្អហើយ ។

សែ ៖ គាត់ដឹងសភាពការណ៍ចឹងអត់ល្អ ហើយកាត់ដកកម្លាំងដែលស្រួចគាត់ធានារ៉ាប់រងគាត់ទុកចិត្តគេចេញមកក្រៅអស់ហើយ គាត់អត់នៅទេ ប្រគល់អំណាចឲ្យគេ ។

បូលី ៖ ឲ្យពីណាគេ?

សែ ៖ ឲ្យណា ឲ្យពួក ចេង អន, ពួក វ៉ន វ៉េត ពួកអីនឹង ។

ភាព ៖ គាត់ទៅនៅចិននោះ ទៅនៅស៊ីសនោះ តា គ្មានបាននៅណាទេ ។

សែ ៖ គាត់ច្រើនទៅស៊ីស គាត់មាននៅក្នុងគណៈកម្មការកាកបាទក្រហមផង តា នឹងផ្ទៃក្នុងរបស់គាត់ ។

បូលី ៖ មានកាកបាទក្រហមហើយកាលនឹង?

សែ ៖ បាទ! គាត់ជាសមាជិករបស់អង្គការផ្នែកកាកបាទក្រហម គាត់ដើរតួខាងនោះផង ។

បូលី ៖ អន្តរជាតិ?

សែ ៖ បាទ! អានឹងនិយាយរឿងជម្រៅ ។

បូលី ៖ ហើយចឹងតា០៥ គាត់ព្រមមកទេ ភ្នំពេញនឹង?

សែ ៖ ចុះដឹង ។

បូលី ៖ គាត់បន្តនៅស៊ីនត្រែងវិញ?

សែ ៖ ឲ្យតា ធី ទៅជំនួសប្រជុំអីផ្សេងៗ ។

បូលី ៖ តា ធី?

សែ ៖ តា ធី ខស្សាហ៍ចេញចូល ។

ភាព ៖ ធី កងពល ។

បូលី ៖ កងវរសេនាធំ?

ភាព ៖ វរសេនាធំមុន ។

សែ ៖ ប៉ុនយកមកនេះ ដូចប្រើគាត់ជាសេនាធិការ សម្រាប់កងពល ។

ភាព ៖ ក្រោយពីយកកែវ សារឿន ចេញផុតអស់ទៅ ដែលថាគាត់នៅតែគាត់នឹង គាត់ច្រើនប្រើ ធី ជាជំនួយការរបស់គាត់ ។

បូលី ៖ ធី នឹងដំណែងជាអី ប្រធានវរសេនាធំ?

ភាព ៖ ប្រធានវរសេនាធំ ។

បូលី ៖ លេខប៉ុន្មាន ៨២?

សែ ៖ ៨២ក៏ទៅ ៨១ក៏ទៅ ។

ភាព ៖ អ៊ូ! ខ្ញុំពិបាកថា គាត់៣ ឮខ្ញុំថាម្ដង៨៣ ៨២ ៨១ គាត់យកទៅដាក់នោះមួយចប់ ។

បូលី ៖ យក ធី ធ្វើជាជំនួយការគាត់?

ភាព ៖ ចា៎!

បូលី ៖ ចឹងគាត់តែងតែប្រើអីទៅប្រជុំនៅភ្នំពេញ?

ភាព ៖ ចា៎! គាត់ឈប់ទៅប្រជុំហើយ តាំងពីចាប់ កែវ សារឿន មកគាត់មិនដែលទៅទេ គ្រាន់ឡើងទៅប្រជុំប្រើតែបង ធី គាត់អត់ទៅ ។ តែទៅដឹងតែគេឆ្កោកយកហើយ គាត់ថាអាណិត កងទ័ព ។

បូលី ៖ ប៉ុន ធី គេចាប់?

ភាព ៖ អត់ ។

សែ ៖ បាទ!កងទ័ពអត់មានសិទ្ធិអីចុះឈ្មោះពាក់ព័ន្ធ អ្នកដឹកនាំលំដាប់ក្រោម អត់សួរចាប់អារម្មណ៍ ។

ភាព ៖ តា នោះចង់ចាប់ល្មមៗ គាត់មិនសួរចេះខ្វាចអាណាទេ ។

បូលី ៖ តា០៥?

ភាព ៖ ចា៎! គាត់អត់ចេះខ្លាចគេទេ ឃើញម៉េចថាចឹង ។

ខែ ៖ មនុស្សខ្លាំងខាងយោធា ចក្រី គាម សូ សារឿន នេះមិនទាន់ទេ រឿងប្រយុទ្ធដាក់ស្តែងប្តូរស្លាប់ប្តូររស់គាត់ខ្លាំងជាងគេ ។

បូលី ៖ ព្រោះកាលមុនល្បីចក្រី?

សែ ៖ បាទ! ចក្រីសាហាវណាស់ ។

បូលី ៖ ថាពូកែ ជាកងទ័ពពូកែច្បាំងមិនដែលចាញ់សមរភូមិណាទេ ។

សែ ៖ ហ្នឹងហើយប៉ុនមកដល់ជាន់សមរភូមិដីឥដ្ឋនេះ វេទនាជាងគេ ថ្នាក់រហូតយកទ័ពមកផ្ញើខាងភូមិភាគពិសេសនេះ ជួយមើលរបួសគ្រោះថ្នាក់អីនឹង ។ ខ្ញុំដេកពេទ្យនៅនឹងដែរ ។

បូលី ៖ មកផ្ញើខ្លួនផ្ញើប្រាណជាមួយ តា០៥ដែរ ។

សែ ៖ យើងម្តុំស្អាងកោះធំនេះ ម្តុំពេទ្យយើងនេះយើងជំនាញៗដែរកាលនោះ យកមកផ្ញើខាងនេះវិញ ។

បូលី ៖ ហើយដល់ពេលវៃបែក៧៩នេះ យើងចាញ់វៀតណាមហើយ?

សែ ៖ បាទ!

បូលី ៖ ពេលនឹងយ៉ាងម៉េច តា គាត់ទៅណា?

សែ ៖ ចូលព្រៃ ច្រៀងចំរៀងផ្ញើលាដីរំលាផ្ទះលាសម្បែងម៉ង ប្រកាសកងទ័ពចូលព្រៃ ។

បូលី ៖ ច្រៀងយ៉ាងម៉េច?

សែ ៖ គាត់អ្នកនិពន្ធចំរៀងផង ទេពកោសល្យរបស់គាត់ ។ គាត់តែងចំរៀងនឹងហើយ រំសាយបណ្តោយ ។

បូលី ៖ ពូចាំចំរៀងរបស់គាត់?

សែ ៖ អត់ចាំទេ ចាំតែមួយម៉ាត់ៗ ។

បូលី ៖ មួយម៉ាត់ក៏បាន?

សែ ៖ ស្អីគេទេ ពីមុនចាំច្រើនដែរនឹង លែងសូវដឹងហើយ ដូចគាត់វាលចូលព្រៃម៉េចទេ គាត់រៀបរាប់ ចុះគាត់ធ្លាប់ល្មោនបាសាក់ ហើយគាត់ធ្លាប់លេង ធ្លាប់សាកល្បងគ្រប់កន្លែងនឹង ។

បូលី ៖ តា០៥?

សែ ៖ ប៉ុស្តិ៍អីនេះ ប៉ុស្តិ៍ផ្សាយមុននេះ សុទ្ធតែគាត់អ្នកនិពន្ធចំរៀងតើ ។

ភាព ៖ ទៅស្នាក់ភូមិណា ប្រជាជនសំណូមពរឡើងច្រៀងឲ្យប្រជាជនស្តាប់ហើយ ។

សែ ៖ ច្រៀងឲ្យប្រជាជនស្តាប់ តាំងពីនៅវរសេនាតូចនោះ ។

បូលី ៖ តាំងនៅវរសេនាតូច?

សែ ៖ បាទ! ខ្ញុំរស់នៅជាប់ជាមួយគាត់រហូតមក ។

បូលី ៖ ក្រែងគាត់ប្រធានកងពលរហូត?

សែ ៖ អត់ទេ ពីដើមមកតាំងពីវរសេនាតូចកកើតកងទ័ពដំបូង យើងមិនទាន់មានកងពលណា ។

បូលី ៖ បាទ! ដំបូង ។

ភាព ៖ ប្រវត្តិចូលទ័ព ។

បូលី ៖ ដំបូងនៅវរសេនាតូចលេខប៉ុន្មាន ពូដឹងទេ?

សែ ៖ ខ្ញុំនៅវរៈ៦ ឡើង១៦០ នៅទ័ពនិរតី ។

បូលី ៖ ចឹង តា០៥នឹងកំណើតកើតជាពីនិរតីទេចឹង?

ភាព ៖ និរតីតើ ស្រុកគាត់នៅខេត្តកំពត ។

បូលី ៖ ប៉ុនដែលវរៈដំបូង និរតីក្រែងមានវរៈគ-៣ គ-៤?

សែ ៖ អត់ទេ មុននឹងបដិវត្តន៍ប្រជាជាតិនឹង មានវរៈ១ វរៈ២ អត់វរៈ៣ វរៈ៤ ។ វរៈ៦ វរៈ៥ ៧, ៩, ។

បូលី ៖ អានឹងហ្នឹងហើយ មីងប្រាប់ខ្ញុំម្សិលមិញនឹង?

សែ ៖ អានឹងត កងតំបន់ទេ ។

បូលី ៖ អូ! អានឹងវរៈភូមិភាគ?

សែ ៖ បាទ! ភូមិភាគ កាល តា ម៉ុក គាត់នៅលេខាភូមិភាគនោះ ។

បូលី ៖ វរសេនាតូចពូ?

សែ ៖ បាទ!

បូលី ៖ វរសេនាតូចភូមិភាគនិរតីតាំងពីឆ្នាំ១៩៧០មក?

សែ ៖ បាទ! ៧០មក៧១ យើងកកើតកងទ័ពហើយ ។ ថា៧១ចុះព្រោះនៅដកកងទ័ព ។

បូលី ៖ កងទ័ពដំបូង

សែ ៖ បាទ! ។

បូលី ៖ មានវរៈ?

សែ ៖ វរៈ១ ។

បូលី ៖ វរៈ?

សែ ៖ ២ ។ ហ្នឹងសុទ្ធតែថែមហើយណា ដល់វរៈមួយនឹងវាឡើងទៅ១១០ ។

បូលី ៖ កងពល?

សែ ៖ ហ្អឹងហើយ ។ វរៈ២នេះវាឡើងទៅ១២០ អានឹងសុទ្ធតែនៅវរៈដែរ មិនទាន់ឡើងកងពលទេ គេមន្ទីរ ។

បូលី ៖ ពូរៀបឲ្យអស់សិន ១ ២ បន្ទាប់មកប៉ុន្មានទៀត?

សែ ៖ មវរៈ៣ខ្ញុំអត់ដឹងទេ ដឹងតែវរៈ៥ ។

បូលី ៖ ៤អត់មានទេ?

សែ ៖ ៤អត់មានដែរ ។

បូលី ៖ ៤អត់មានទេ មានតែ៥?

សែ ៖ បាទ! ឡើង១៥០ ។

បូលី ៖ ហើយវរៈប៉ុន្មានទៀត?

សែ ៖ វរៈ០៥នេះ វរៈ៦ ទៅ១៦០ វរៈ៧ វរៈ៩ ។

បូលី ៖ ៨ អត់មាន?

សែ ៖ ៨អត់ទេ ។

ភាព ៖ នោះវរ១៨ វរៈ១៨០គេនោះ ។

សែ ៖ អ៊ូ! វរៈ១៨០មួយទៀត ហ្អឹងកង តា ណាត ទើបនឹកឃើញ ១៨០-១៦០ជាប់គ្នា ។

បូលី ៖ វរសេនាតូចលេខ១នេះ ក្លាយទៅជាវរសេនាតូចលេខ?

សែ ៖ ១១០ ។ ១០១ផង បានឡើងទៅ១១០ទៀត វាមាន២-៣គន្លាក់ទៀតគេប្រើនោះ ។

បូលី ៖ មុនដំបូង១០១?

សែ ៖ បាទ! ១០១ ។

បូលី ៖ ក្រោយមកបាន១១០?

សែ ៖ ហ្អឹងហើយ១១០ ។

បូលី ៖ ១០១ មកវរសេនាតូចដដែលទេ?

សែ ៖ បាទ!

បូលី ៖ បន្ទាប់មកវរសេនាតូចទី២នេះ?

សែ ៖ ១០២ទៅ១២០ ។

បូលី ៖ ចុះវរសេនាតូចទី៣?

សែ ៖ អត់មានតែទី៤ ។

បូលី ៖ ទី៤?

សែ ៖ ១០៤ ឡើងទៅ១៤០ ។

បូលី ៖ វរសេនាតូចទី៥?

សែ ៖ ទី៥ ១៥០ ។

បូលី ៖ ទី៦?

សែ ៖ ១៦០នឹង សូ សារឿន នឹង។ ១៤០ តា ណាត ។

បូលី ៖ ១២០?

សែ ៖ ១២០ តា សឿង ។

បូលី ៖ ១១០?

សែ ៖ ១១០នេះ តា សឿង ហើយ តា ស្រស់ ។

បូលី ៖ ១១០ពីពូមិញ?

សែ ៖ តា ស្រស់ ។

បូលី ៖ ១៥០?

សែ ៖ ១៥០ អាច សំប៊ិត ។

បូលី ៖ សំប៊ិត?

សែ ៖ បាទ! ព្រោះឡើង២-៣ដំណាក់ បានតា ប៊ិត ទៅគ្រប់គ្រង១៥០វិញ ។

បូលី ៖ ចុះ វ-៧ ១៧០?

សែ ៖ ១៧០នេះ ដូចក្មេច១៧០នេះហើយ មេ អត់ចាំទេ ១៩០ក៏ភ្លេច អាអីក្បត់នឹង មិនដឹង អាណាក្រោយគេ ។

បូលី ៖ វ-៩ ក្លាយជា១៩០?

សែ ៖ បាទ! មានតែប៉ុននឹងទេ ភូមិភាគនិរតី ។

បូលី ៖ ១៩០ពីណាគ្រប់គ្រង?

សែ ៖ ១៩០នឹង ផ្លាស់ប្តូរច្រើន វាគេប្រែមេច្រើនពេក ព្រោះសកម្មភាពវារបើ្បកមុនគេរឿងផ្ទៃក្នុង។ ប៉ុនអាចដើរទៅមុខទៀត អាចដឹងហើយ ជីវប្រវត្តិពួកនឹង។ ហ៎! តា ហឿន នៅត្រពាំងប្រាសាទនឹងដឹងបាត់ ។

បូលី ៖ តា ហឿន?

សែ ៖ ហ្នឹងហើយ នៅកងពលនឹង។ ហ៏!៥០២ណា ភូមិភាគនិរតី តា ហឿន ។

បូលី ៖ បន្ទាប់មកវរសេនាតូចទាំងអស់នឹង ក្លាយជាកងពល?

សែ ៖ កងពល ។

បូលី ៖ មួយណាក្លាយជាកងពលណា ពូចាំទេមើលទៅ?

សែ ៖ កងពលទី១ វា៣វរសេនាធំ អត់ចាំអស់ទេ ។

បូលី ៖ ឥឡូវវរសេនាតូចទាំងអស់នឹង ក្លាយជាវរៗសេនាធំក្រោយមក?

សែ ៖ ក្លាយ ។

បូលី ៖ វរសេនាធំលេខប៉ុន្មានខ្លះ?

សែ ៖ វាថាវាចាំមិនអស់ទេ វា៣ៗលេខពួកគេនោះ ។

បូលី ៖ ចឹងអានេះវាមាន៩វរសេនាតូច?

សែ ៖ បាទ! កកើតកំណើតពី៧១ ៧២មក ។

បូលី ៖ ៣វរសេនាតូច គេបញ្ជូនទៅ១វរសេនាធំ?

សែ ៖ បាទ!

បូលី ៖ មានណាខ្លះដែរគេចូលទៅ វ ប៉ុន្មានខ្លះ?

សែ ៖ មើលវ-១៦០ មកភូមិភាគពិសេសពាក់កណ្ដាល ទៅពាក់កណ្ដាល ។

បូលី ៖ ១៦០?

សែ ៖ បាទ! ១៦០បូក១៨០ៗ បូក១៥០ ហ៎! ៣កងពល ។

បូលី ៖ ភូមិភាគនិរតីមាន៣កងពល?

សែ ៖ បាទ! ៣កងពល ។

បូលី ៖ មានកងពលទី១ ទី២ ទី៣?

សែ ៖ ទី១ ទី២ ទី៣ មាន៣ខាងលិចដល់សមុទ្រម៉ង ។

បូលី ៖ មាន៣នឹង ក្រោយមកក្លាយជាកងពល១៦៤?

សែ ៖ បាទ! ហ្នឹងហើយ ។

បូលី ៖ ប៉ុនខ្ញុំចង់ដឹងថា តើវរសេនាតូចអស់នេះ មួយណាខ្លះដែលវាក្លាយជាកងពលទី១ អាណាក្លាយទៅជាកងពលទី២?

សែ ៖ ថាមិនត្រូវ ដូច តា ប៊ិត គ្រប់គ្រងកងពលដែរ ។

បូលី ៖ សំប៊ិត កងពលលេខប៉ុន្មាន?

ភាព ៖ កងពលលេខ១ ។

បូលី ៖ លេខ១ក្រែង តា សឿង?

ភាព ៖ តា សឿង លេខ២ ។

បូលី ៖ មួយ សឿង មួយ សឿន លេខ២ ពីម្សិលមិញនេះ?

ភាព ៖ ហ្នឹងហើយ សឿន នេះ នៅកងពលលេ២ជាមួយ តា សឿង ដែលដឹង សឿន នោះ ។

បូលី ៖ មួយ ប៉ែន សឿង?

សែ ៖ តា សឿង នឹងហើយដែលមេចាស់ ដែលត្រូវកាន់កងពលទី១ ។

បូលី ៖ បាទៗ ប៉ែន សឿន កងពលទី១ ។

សែ ៖ តាអី ដែលនៅភ្នំវល្លិ៍នេះ ។

បូលី ៖ សំបិត, ឈូក រិន?

សែ ៖ ហ៊ែ! ភ្នំវល្លិ៍ តាអីទេ ខ្ញុំវាដាច់ចលនានឹងពីនឹងមកយូរហើយ អត់ហ៊ានថា ។ ចង់ដឹងច្បាស់ទៅត្រពាំងប្រាសាទ ជួបលោក ហឿន ជិតតាកែវនឹងដែរ ជួបទៅសួរគាត់ៗដឹង ព្រោះគាត់ឋានៈធំដែរ ចេញពីកងពលលេខ២តាមមើល ។

បូលី ៖ ប៉ុនពូអត់ចាំវរៈតូចណា ទៅជាកងពលណាទេ?

សែ ៖ អត់ទេ បើខ្ញុំចេញមកបាត់ហើយចូលភូមិភាគពិសេស ។

បូលី ៖ គ្រាន់ដឹងថា ក្រោយមកទាំងអស់នេះគឺថារៀបចំទៅជាកងពល១-២-៣ចឹងទៅ?

សែ ៖ បាទ! ត្រឹម៣កងពលធំនឹង ។

បូលី ៖ ចឹងពេលដែលវៀតណាមវ៉ៃចូល តា០៥ គាត់រត់ទៅខាងណាវិញមីង?

ភាព ៖ គាត់នៅរតនគិរីនឹងឯង នៅក្នុងព្រៃ នាំចលនាគស្ទូ កងទ័ពរបស់គាត់នៅក្នុងដៃទាំងអស់ វ៉ៃខ្ទបតាំងពីអូរយ៉ាដាវមករហូត ។

បូលី ៖ ហើយពេលណាបានគាត់រត់មកខាងលើភ្នំ?

ភាព ៖ មកដល់ភ្នំឆ្នាំ៨០ ។

សែ ៖ គាត់មកក្រោយ ខ្ញុំមកមុន ។

បូលី ៖ មកមុន?

សែ ៖ ហ្នឹង មករករយៈរដ្ឋាភិបាលមុន ។

ភាព ៖ ឆ្នាំ៨០គាត់ឡើងមកដល់ ។

បូលី ៖ ចុះមីង?

ភាព ៖ ខ្ញុំនិយាយរួម ខ្ញុំចេញរតនគិរីតាំងពី៧៨ ខែ១២ ។

បូលី ៖ ទៅណា?

ភាព ៖ ខ្ញុំឮថាខ្ញុំចេញដំណើរពីនោះមកសម្រាលកូននៅកុងប៉ីញ ។

សែ ៖ រត់ទាំងពោះធំ ។

ភាព ៖ ចេញពីវើនសៃមក ដេកសៀមប៉ាង ចេញពីសៀមប៉ាងមកដេកយើងបៀតស្ទឹងត្រែងនេះ ដេកនៅឆែប ចេញពីឆែបមករវៀង មកកន្ទួត មក ។

បូលី ៖ ម៉េចក៏មិនសម្រាលនៅរតនគិរី ស្ទឹងត្រែងនេះទៅ មកនេះធ្វើអី?

ភាព ៖ បើកំពុងសភាពការណ៍ចឹង អត់ហ៊ានទុកចិត្ត គេព្រោះកាលនោះសភាពការណ៍ប្រជាជនក៏វាមិនសូវខ្លាច ។ មិត្តភ័ក្តខ្ញុំមកដល់កន្ទួតហើយ ទៅវិញគេចាប់បានដាក់គុកនៅកោះកន្ធុយគោឡើងយូរ ។ ឥឡូវបានប្តីនៅម្តុំនឹងហើយ ។

បូលី ៖ កោះកន្ធុយគោនឹង?

ភាព ៖ ចា៎! គេធានាដោះយកមក តែប្តីនៅធ្វើទាហាននៅស្ទឹងត្រែង គេឥឡូវគេនៅតន្ត្រីកិរម្យយោធាគេនៅស្ទឹងត្រែងនោះឯង ។

បូលី ៖ មិញនឹង មីងនិយាយអំពីកងពល១១៧ កាល?

ភាព ៖ អ្ហូ! ហ្នឹងហើយ កង តា ញ៉ាន់ នឹង ។

បូលី ៖ កង?

ភាព ៖ កងនឹងមកពីខេត្តគេហៅពួកខេត្តកណ្តាល អឺ! គេហៅពួកក្រចេះ កំពង់ចាម ។

បូលី ៖ ១១៧?

ភាព ៖ ចា៎! ខាងក្រចេះ គេឡើងមកដូរ៨០១ ។

បូលី ៖ កងពល១១៧នឹង ដូរ៨០១?

ភាព ៖ ចា៎!

បូលី ៖ កងពលនឹងទើបបង្កើតទេ?

ភាព ៖ ទើបបង្កើតទេ ទើបរៀបចំក្រោយទេ ។

បូលី ៖ ៧៧ ដើម្បីរៀបចំច្បាំងជាមួយវៀតណាម?

ភាព ៖ ចា៎!

បូលី ៖ ហើយកងពលនឹងឈរជើងនៅស្រុកស្នួលខេត្តក្រចេះ?

ភាព ៖ ចា៎! គេដូរយកកងពលនឹងមក។ កងពលនឹងការពិតទៅប្របល់គ្រប់ខេត្តនឹង ព្រោះតា ញ៉ាន់ អ្នកកំពត។ តា ញ៉ាន់ ធ្លាប់ស្គាល់គ្នាជាមួយពួកខ្ញុំ វៃ៧២នៅតាកែវជាមួយគ្នា វៃនៅកំពង់ជ្រៃ។

សែ ៖ យកពីកងតំបន់មកខ្លះចូល។

ភាព ៖ តែតំបន់គេឡើងមកពីភូមិភាគដែរនឹង។

សែ ៖ គ្រាន់វាខ្ចី១ គ្នាខ្សោយ គ្នាមិនចង់ហ៊ានមក។

បូលី ៖ កាលនឹងដឹបួនបំផុតមាន រុំ ហើយនឹង លាង គណៈកងពល ដែលពុ?

ភាព ៖ ១៧ហ្នឹង?

បូលី ៖ បាទ! ១១៧នឹង ដែលពុទេ? តា ញ៉ាន់ក្រោយទេ។

សែ ៖ ក្រោយ១ តា ញ៉ាន់។

បូលី ៖ បន្ទាប់ពីចាប់ខ្លួន រុំ ហើយនឹង លាង បាន តា ញ៉ាន់ ឡើង?

ភាព ៖ អត់ដឹងទេ ដឹងតែ តា ញ៉ាន់។ ហើយអ្នកមកជាមួយ តា ញ៉ាន់ នឹងឈ្មោះស្អីទេ ជួបគ្នាពួកនឹងឡើងមកហើយ ពេលដែលសភាពការណ៍ខ្ញុំរត់ហើយនេះ មកជួបគ្នាម៉្ងនេះ រត់ទៅតាមផ្លូវជាមួយគ្នាម៉្ងនេះ ហួសពីគោករមៀតអីទៅជាមួយគ្នា វៃជាមួយខ្មែរសេរីអីទៅជាមួយគ្នានឹងឯង។ កងពលនឹងគ្នាច្រើន ពួកខ្ញុំទៅខាងបារាំងធ្លាក់ អូរល្ហុង អូរអន្ទក់ ទៅតាមកងពលនឹងឯង តាមរយៈកងពលនឹងអ្នកនាំទៅ ព្រោះគេកម្លាំងគេធំ គេអ្នកត្រួសត្រាយផ្លូវមុខឲ្យយើងដើរទៅណាតាមផ្លូវក្រោយគេ។

បូលី ៖ ប៉ុនដូរ៨០១ម៉េច អត់យល់?

ភាព ៖ គេចង់និយាយថា គេពេលដក៨០១ទៅនៅការពារមជ្ឈិមទៅ គេយកកងពលនឹងមកនៅឈរនៅរតនគិរីម្តង។

បូលី ៖ ព្រោះតា០៩ នឹងអត់ព្រម?

ភាព ៖ ចិត្តសាស្ត្រគេ ចិត្តសាស្ត្រអី ការរៀបរយគេត្រូវចឹងហើយ តែគេឲ្យយើងខាងកងពលនឹងរៀបចំកម្លាំងចេញដំណើរទៅ តែយើងអត់ទាន់បានចេញទេ គាត់រង់ចាំមើលថាតើគេមកដូរពិតប្រាកដហើយរបៀបម៉េច។ ប៉ុនគ្រាន់គាត់ប្រជុំប្រាប់សភាពការណ៍ ការយកទៅនឹងអីរបៀបម៉េច ប្រវត្តិដែលគេត្រូវចង់រំលាយនឹងវាមូលហេតុមកពីគេចង់ចាប់គាត់អីចឹង អត់ចាប់បានចឹង គាត់នៅគ្រប់គ្រងទៅជាមួយទ័ពដដែល។ ហើយម៉្យាងគេចោទប្រកាន់របៀបថា

គាត់ដាប់និន្នាការនយោបាយអីនឹងកងពលដាប់និន្នាការនយោបាយអីចឹងៗ ។ ប៉ុនការពិតកងពលនឹងតាំងមកឈរនៅនឹងវែរជាមួយឃួនរហូតនឹង តាំងក្នុង៧៦ ។

បូលី : កងពល តា ញ៉ាន់?

ភាព : អត់ទេ ៨០១ ។

បូលី : ក្រោយមក តា ញ៉ាន់ ពេលមកនៅខាងអន្លង់វែងនេះ គាត់កាន់កងពលលេខប៉ុន្មាន?

ភាព : អឺ! ខ្ញុំនៅទំនប់ដាច់ តា ញ៉ាន់ នៅអន្លង់វែងនេះដែរ ខ្ញុំមិនដឹងដែរនឹង ។

បូលី : កងពលនឹងវាចែកចេញជាពវរសេនាធំ មានវរសេនាធំ១៥ មាន ភាព លេខា, ពូអាចដឹងទេ មីងមើលទៅ?

ភាព : អត់ដឹងទេ ។

សែ : អត់ដឹង ។

បូលី : អត់ដឹងរឿងខាងនឹង?

សែ : បាទ!

ភាព : តា ញ៉ាន់ ការពិតឡើងមកក្រោយទេ អ្នកគេឡើងមកមុននោះ ហួសទៅពាយ័ព្យបាត់ហើយ ហួសទៅម៉ុំឡែម ភ្នំតាង៉ុក បារាំងធ្លាក់ អីជាមួយខ្ញុំនោះ ទៅនេះបៀតក្នុងយៃនោះ ហៅស្លឹទេ ភ្លេចបាត់ហើយ ពួកនឹងហួសទៅនោះអស់ហើយ ។ ហើយ តា ញ៉ាន់ គេឡើងមកសារក្រោយ គេឡើងម៉ាសារៗ ដូចថាតាមកងពលតូចនីមួយៗ អឺ! តាមវរសេនាធំនីមួយៗ គេត្រូវឡើងមកចឹង គាត់ឲ្យចេញដំណើរក្រោយទេ ។ បានគាត់ឡើងមកនៅ១០០១នេះ ។

បូលី : ១០០១យើង?

ភាព : ចា៎! កន្លែងមុំពនឹង តា ញ៉ាន់ មកនៅនឹងដែរ កម្លាំងគាត់ប៉ុន្មានទេ តា ញ៉ាន់ តា ដេរចង់ងាប់ឡើងមកដល់ដំបូង ។

បូលី : ម៉េចចឹងមីង?

ភាព : ចុះគាត់ប៉ិនស្រីនោះ ឲ្យតែពួកខាងពេទ្យ ពួកខ្ញុំនេះទៅបើកអង្ករ តា សួរពួកមីស្រីល្អៗនេះមកពីណា នៅណា? នៅមន្ទីរអ៊ំញ៉ាន់ៗ អូ! ពួកមីសំដឹង អាញ៉ាន់នេះ តាដែលប្រដាក់មាត់ង៉ែងខ្លួនវិញឲ្យក្មេងៗយកខ្លួនទៅដូរជាមួយអាញ៉ាន់ បានប៉ុន្មានមួយយប់ៗ ។

បូលី : គាត់ដឹងម៉ង?

ភាព : ដឹង ។

បូលី : គាត់ដឹង តាមណា ឬមានអ្នករាយការណ៍ប្រាប់គាត់?

ភាព ៖ មានអ្នករាយការណ៍ ឲ្យមានផ្ទៃក្នុង មិនអត់ទេ ផ្ទៃក្នុងតាមអង្គភាពរាយការណ៍ឲ្យគាត់ មេណាធ្វើម៉េចៗ គាត់ព័ត៌មានគាត់យកបានរហូត ប៉ុន្តែគ្រាន់កែមនុស្សមិនផាយកែ ឲ្យគាត់ចោល ។

បូលី ៖ ចុះ តា០៥ គាត់មកដល់ទន្លេល្អៅនេះឆ្នាំ៨០ ?

ភាព ៖ ឆ្នាំ៨០ ហើយ ។

សែ ៖ ខ្ញុំមកអង្គភាពផ្សេងទៀតហើយ ។

បូលី ៖ ពូមកអង្គភាពណា?

សែ ៖ ខ្ញុំមក៦១២ ។

ភាព ៖ មកឆ្នាំ៨០ ឡើងឆ្នាំ៨០ ។

បូលី ៖ ពូមក៦១២?

សែ ៖ បាទ!

បូលី ៖ ៦១២នឹង អង្គភាពរបស់ តា ហឿន?

សែ ៖ បាទ!

បូលី ៖ សុខ ហឿន ត្រកូលគាត់ ។

សែ ៖ ប្រហែល សុខ ហឿន ។

ភាព ៖ កាលនេះ តា ឈាន ទេ ។

សែ ៖ តា ឈាន មុន តា ហឿន ទើបមកក្រោយគេទេ ។ នេះ តា ហឿន ហើយ តា ញ៉ាន់ ចង់ជាប់គ្នាផង ការងារនៅក្រចេះនឹង ។

បូលី ៖ កងពល៦១២នឹង បង្កើតនៅឆ្នាំ៨១ ?

សែ ៖ បាទ!

បូលី ៖ ចេញពីកងពលណាមក?

សែ ៖ ចំរុះ ៨០១ក៏មក ។ ៨០១ មកពាវរៈ ។

បូលី ៖ ពាវរៈសេនាតូច?

សែ ៖ ហ៊ើ! ពាវរៈសេនាតូចអី ។ ឈប់ តា ទិត យកមកម៉ាវរៈ, ខ្មោច អ៊ីវ ហើយ យិន ម៉ាវរៈ ហើយខ្ញុំម៉ាវរៈដែរ ។ ខ្ញុំនៅវរៈ១៤នោះ កងពិសេស ។

បូលី ៖ ១៤របស់ពីណា?

សែ ៖ របស់៨១នោះ ចេញមកគេសភាពការណ៍នឹងគេរៀប៤វរៈទាំងអស់ ។

បូលី ៖ ចឹងបានខ្ញុំថា វាយកវរសេនាតូច៣មកពី៨០១?

សែ ៖ បាទ! មកពី៨០១ ប្អូនវរៈនោះ មិនមែន៣ទេ ប្អូនទាំងវរៈខ្ញុំ ។

បូលី ៖ មានពីកងពលណាខ្លះឥឡូវមកពី៨០១ មាន៤វរសេនាតូចហើយ?

សែ ៖ បាទ!

បូលី ៖ មកពីណាទៀត ដើម្បីបញ្ចូលឲ្យបានទៅជាកងពល៦១២នេះ?

សែ ៖ មើលនែក! ឈប់ ម៉េចខ្ញុំនឹកមិនឃើញចឹង តា ឈាន មកអត់កម្លាំងទេ តា ហឿន ក៏អត់កម្លាំងដែរ សុទ្ធតែមកមួយក្រុមៗទេ ។

បូលី ៖ គ្រាន់ តា ឈាន មេកងពលដំបូងគេបំផុត?

សែ ៖ បាទ! ចុះខ្ញុំមកនេះមិននេះ កាលសម្រេចឲ្យមកមើល ខ្ញុំចេញពី៨១មក មាន១១ ហើយនឹង១៤ ។

បូលី ៖ ពូលេខប៉ុន្មាន?

សែ ៖ ខ្ញុំ១៨វិញ ឡើងមក១៨នេះ ។

បូលី ៖ ពូមេ១៨?

សែ ៖ បាទ! បញ្ជាការ មិត្ត ម៉ុន គេស្នងការ១៨នឹង ។

បូលី ៖ វរសេនាតូច១៨របស់កងពល៨០១នឹង?

សែ ៖ ៨១ ។

បូលី ៖ វរសេនាធំ៨១?

សែ ៖ បាទ!

បូលី ៖ ហ្នឹងគឺថា កងពលហ្នឹងពូចេញពី៨១នឹងមក មានពូមាន ម៉ុន ប្រធាន?

សែ ៖ បាទ!

បូលី ៖ ពូ អនុប្រធាន?

សែ ៖ ហ្នឹងហើយ ។ យិន នោះ(ស្តាប់មិនបាន) ។

បូលី ៖ យិន មកពីណា?

សែ ៖ ៨១ ។

បូលី ៖ កាលនឹង៨០១ដូចគ្នា?

សែ ៖ បាទ!

បូលី ៖ ហ្នឹងកាលចូល៦១២ដែរ?

សែ ៖ បាទ!

បូលី ៖ បន្ទាប់មក មានពីណាទៀត?

សែ ៖ មាន៧២ កងអាអ៊ីម ហើយនឹង តា គីប នោះ ។

បូលី ៖ មួយវរសេនាតូចដែរ?

សែ ៖ មួយវរសេនាតូច ។

បូលី ៖ វរសេនាតូច៧២ របស់វរសេនាធំលេខប៉ុន្មាន?

សែ ៨២ ។

បូលី ៖ ហ្នឹងពីណាគេ?

សែ ៖ អ៊ីម ។

បូលី ៖ អ៊ីម ប្រធាន?

សែ ៖ បាទ!

បូលី ៖ ហើយពូណា អនុគាត់?

សែ ៖ តា ទីប ។

បូលី ៖ ហ្នឹងគាត់ចូល៦១២ដែរ?

សែ ៖ ៦១២ ។

បូលី ៖ មានអីទៀត ដែលចូល៦១២?

សែ ៖ ទៀត មិនដឹងពីណាពីណែមកភ្លេចអស់ បើបញ្ចូលទៅឡើងវា៣វរសេនាធំ៦១ ៦២ ៦៣ ។

បូលី ៖ បាទ! ឥឡូវខ្ញុំសុំសួរកងពលមុនៗ កងពលដំបូងគឺ តា ញ៉ិន តា ឈាន ជាប្រធាន មេកងពល?

សែ ៖ បាទ!

បូលី ៖ អនុរបស់គាត់ពីណាគេ?

សែ ៖ តា ហឿន ។

បូលី ៖ សុខ ហឿន ត្រកូលអីគេ?

សែ ៖ ខ្ញុំមិនដឹងឈ្មោះ ។

បូលី ៖ តា ហឿន អនុប្រធាន សមាជិក?

សែ ៖ ហ៎! ដូចឃើញតែពីរ ។

បូលី ៖ បន្ទាប់មក តាទាំងពីរនឹងគាត់កាន់កងពល៦១២ ចាប់ពី៨១រហូត៩៨ ឬក៏មានការដោះដូរ?

សែ ៖ អត់ទេ ដោះដូរ ។

ភាព ៖ ឈាន គេដក ។

បូលី ៖ ដកទៅណា?

សែ ៖ ទៅកោះកុង ។

បូលី ៖ ឆ្នាំប៉ុន្មាន?

សែ ៖ ដឹង៨០ប៉ុន្មានទេ ៨៣មិនដឹង ។

បូលី ៖ ទៅកាន់កងពល ហើយទៅកាន់អី?

សែ ៖ កាន់កងពលដែរ ។

បូលី ៖ កាន់កងពលដែរ?

សែ ៖ បាទ! កាន់កងពលទី១ហ្នឹងឯង កាន់កង តា ប៊ិត នឹង ។

ភាព ៖ ៨៣អី តា ឈាន ដក៨១ ទើបទំនង់ ដល ។

បូលី ៖ ៨១នេះ?

ភាព ៖ ចា៎!

បូលី ៖ ពេលនោះពីណាគេឡើង?

ភាព ៖ តា ហឿន នឹងប្រធាន ។

បូលី ៖ ចឹងពី៨១មក តា ហឿន ឡើងប្រធាន ។

សែ ៖ ចង់ភ្លេចអស់ទៀត ដូច តា សាន ដែរកងពល អត់ទេ ។

ភាព ៖ វរសេនាធំ តា សាន ។

បូលី ៖ ហើយអនុរបស់ តា ហឿន ពីណាគេ?

ភាព ៖ អត់ដឹងពីណាទៀតខ្ញុំ ។

បូលី ៖ មានឈ្មោះ សន់ ឈ្មោះអីទេ?

ភាព ៖ មាន សន់, សាន់ ហ្នឹងឯង ឈ្មោះគាត់ពីរ ។

បូលី ៖ ចឹង?

ភាព ៖ ចា៎! ឈ្មោះគាត់ពីរ ។

បូលី ៖ សន់ ហៅ សាម សរសេរម៉េច?

សែ ៖ ស-ា-ន- ់ ។

បូលី ៖ សាន់ចឹង?

ភាព ៖ សន់ ។

សែ ៖ ដល់អានេះ សាន់ ។

បូលី ៖ សន់ នឹងអនុរបស់ តា ហឿន នឹង?

ភាព ៖ ចា៎!

សែ ៖ សមាជិក តា មឿន ។

បូលី ៖ ហើយសមាជិកពីណា?

សែ ៖ សមាជិក តា មឿន ។

បូលី ៖ មឿន?

សែ ៖ បាទ!

បូលី ៖ ដែលពូឈ្មោះ សូ ញាន អីទេ តា ញាន?

សែ ៖ ញាន នេះក្រោយ ។

បូលី ៖ មឿន សមាជិក?

ភាព ៖ តា ញាន នឹង ឡើងមកពី១១នឹង ។

សែ ៖ ក្រោមខ្ញុំទៀត ពីដើម ។

បូលី ៖ បន្ទាប់មកមានការដោះដូរម៉េចទៀត តា ហឿន កាន់ពី៨១ ដល់៨០ប៉ុន្មាន?

សែ ៖ ៨០ប៉ុន្មានទេ ខ្ញុំចេញពីនឹងមកទៀត ។

បូលី ៖ ពូចេញហើយ?

សែ ៖ បាទ! ខ្ញុំមកនៅ៩១២នេះ ។

បូលី ៖ ពូនៅ៩១២?

សែ ៖ បាទ!

ភាព ៖ កងពល តា ហឿន គាត់នៅគ្រប់គ្រងរហូត ។

បូលី ៖ រហូតដល់៩៨ម៉ង?

ភាព ៖ ចា៎!

សែ ៖ ចប់ទាល់សមាហរណកម្ម ។

បូលី ៖ តា ហឿន គ្រប់គ្រង?

ភាព ៖ រហូតទាល់សមាហរណកម្ម តា ហឿន គាត់គ្រប់គ្រងរហូត២នាក់ សន់ ។

សែ ៖ ៣ តា មឿន នឹងនៅជាប់គ្នាទាំងអស់នឹង ។

ភាព ៖ ហ៊ឺ! សន់ កាលនេះគេដកមកគ្រប់គ្រងមូលដ្ឋាន ។

សែ ៖ មិនដឹងអ្នកណាគេដក ៣នាក់នឹងដដែល ប៉ុន សន់ នឹងដដែល សន់ ចេញមកនៅតែ តា មឿន ហើយ តា ហឿន នឹង ។

បូលី ៖ កងពលនឹងចែកចេញជា៣វរៈសេនាធំ មាន៦១ ៦២ ៦៣?

សែ ៖ បាទ!

បូលី ៖ ពីណាគេប្រធាន៦១?

សែ ៖ ៦១ ស្អី អា រិន បន្ទាប់មក តា ជូត ។

បូលី ៖ ដែលឮឈ្មោះ តា ញ៉ា?

សែ ៖ អត់មានទេ ។

បូលី ៖ ញ៉ែម ញ៉ា?

ភាព ៖ ដូចមិនដែលឮ ។

បូលី ៖ឃុន ម៉េង?

សែ ៖ អត់ទេ ។

បូលី ៖ ឈ្មោះនេះនៅក្នុងក្រដាស ប៉ុន្តែអត់ច្បាស់ទេ កាលនឹង ។

ភាព ៖ ៦១ ដឹងតែបង យិន ហើយនឹងនេះពីមុន ។

បូលី ៖ ៦១ ពីណាគេ?

ភាព ៖ ៦១ មិនដឹងណាគេគ្រប់គ្រង អត់ដឹង ។

សែ ៖ យី! វាបាត់អស់ហើយ អាជំនាន់នោះ ខ្ញុំនៅ៦៣ ។

បូលី ៖ ៦៣ ពីណាគេ?

សែ ៖ មិត្ត ម៉ុន នេះគេឡើងប្រធាន៦៣ ។

បូលី ៖ ហើយអនុរបស់គាត់?

សែ ៖ អនុរបស់គាត់ តា គង់ នេះ ។

ភាព ៖ តា គង់ សាំង គង់ ។

បូលី ៖ សាំង គង់?

ភាព ៖ ចា៎!

បូលី ៖ ក្រោយមក តា គង់ ឡើងជាលេខាកងពលទីប៉ុន្មាន?

សែ ៖ កងពល៩១២ ។

បូលី ៖ ចុះសមាជិកពីណាគេទី៣?

សែ ៖ សមាជិកមានតែពីរទេ ។

បូលី ៖ អត់មាន តា មាន តា អី?

សែ ៖ ហ៉េ! តា មាន ហើយ ត្រូវហើយទើបនឹកឃើញ តា មាន វរសេនាធំដែរ ។

បូលី ៖ តា មាន សមាជិកកងពល?

សែ ៖ ហ្នឹង ។

បូលី ៖ ចុះពូ?

ភាព ៖ ៦២ ក្រែង តា អ៊ីម ។

សែ ៖ ៦២ អា អ៊ីម ក្រោយមក អាណាគេ ។

ភាព ៖ ៦១ ដូចគេរៀប តា យិន ។

សែ ៖ អត់ទេ អាយិន នៅ៦៣ ។

បូលី ៖ ខ្ញុំសុំ៦៣តិច ដូចថា ៦៣នឹង គឺថា តា ម៉ុន, តា គង់, តា មាន គាត់កាន់រហូតដល់៩៨ ម៉េង ឬក៏មានការផ្លាស់ប្ដូរ?

សែ ៖ ផ្លាស់ប្តូរ ។

ភាព ៖ ផ្លាស់ប្តូរ តា ម៉ុន ដក ។

សែ ៖ ម៉ុន ទៅលិច ។

ភាព ៖ ដកចូលកងអន្តរាគមន៍ អត់ទាន់ទៅលិចទេ ។

សែ ៖ អឺ! កងអន្តរាគមន៍នៅ៩៨០នឹង យកកម្លាំងខ្ញុំទៅខ្លះដែរ ។

បូលី ៖ តា ម៉ុន ឆ្នាំប៉ុន្មាន គេដកគាត់?

ភាព ៖ ដកឆ្នាំ៨២ ។

បូលី ៖ អន្តរាគមន៍៩៨០?

ភាព ៖ យី! ដក៨២ណា ដកតាំងនៅ១០០២ ។

សែ ៖ ខ្ញុំត្រូវរបួស ។

បូលី ៖ នៅប្រហែលជាកងអន្តរាគមន៍៩៨០?

សែ ៖ បាទ! (ស្តាប់មិនបាន)

ភាព ៖ ចា៎! ដល់ កើត៨១ គេដកតាំងពី៨១នោះ ។

បូលី ៖ ៨១?

ភាព ៖ មើលខ្ញុំគិតមើលសិន វរៗភ្លេច ។

បូលី ៖ ជិតចូលដល់កន្លែងសំខាន់ ជិតដល់អនុងវែងយើង ។

ភាព ៖ គិតមើលសិន ព្រោះអន្តរាគមន៍នេះ តាំងពីខ្ញុំនៅព្រៃឫស្សី តាំងកូននៅក្នុងពោះមិនទាន់សម្រាលផងនឹង ៨១ ។

បូលី ៖ កូនទី១នឹង?

ភាព ៖ ចា៎! កូនខ្ញុំសម្រាល ។

សែ ៖ ទី២ ។

ភាព ៖ ទី២ៗនឹងកើត៨១ ខែ៣នឹង ។

បូលី ៖ ខែ៣ មីងមិនទាន់សម្រាលទេ?

ភាព ៖ ចា៎!

បូលី ៖ ចឹងបែប តា ម៉ុន គេដកតាំងពីដើម៨១?

សែ ៖ ហ៎! ជិតគ្រប់ខែហើយ ព្រោះខ្ញុំរបួស ម៉ែគេទៅថៃខ្ញុំ ។

ភាព ៖ (ស្តាប់មិនបាន) កាលអាចរៀបចំចុង៨០ ដល់៨១ ក៏ខែ១ ឬខែ២អីដែរ ។

បូលី ៖ ៩៨០នេះ គឺរៀនចំនៅខែកញ្ញា ឆ្នាំ១៩៨០ ។

ភាព ៖ ខ្ញុំថាដឹងតែ៨០ហើយ ព្រោះខ្ញុំទៅលេងអ៊ំ អួច នៅ១០០២ហ្នឹងឯង កងអន្តរាគមន៍គេចាប់រៀបចំ ។

សែ ៖ ចុង៨០ ។

បូលី ៖ ចឹង តា ម៉ុន គេដកទៅកងអន្តរាគមន៍៩៨០ នៅចុងឆ្នាំ៨០?

ភាព ៖ ចា៎!

បូលី ៖ ហើយគេដកគាត់នឹង គាត់ទៅធ្វើជាប្រធានកងពល៩៨០ ឬទៅធ្វើអី?

សែ ៖ ទៅ ។

បូលី ៖ ព្រោះប្រធាន៩៨០ ដំបូងគេ មាស មុត?

សែ ៖ ហ៎! តា មុត ណា តា មុត គាត់កងពលហើយ កងពល៩៨០ ។

បូលី ៖ បាទ! ហ្នឹង៩៨០នឹង កងពល ។

សែ ៖ តា ម៉ុន ទៅ ហ៎!មិនទាន់បង្កើតកងពលទេ ។

ភាព ៖ ក្នុងវរសេនាធំ ។

សែ ៖ វរសេនាធំ ប្រធានវរសេនាធំដដែលនឹង ប៉ុននៅ៩២ ។

បូលី ៖ មាស មុត?

សែ ៖ ហ៎! និយាយ តា ម៉ុន ។

បូលី ៖ នេះខ្ញុំនិយាយ មាស មុត គាត់ប្រធានកងពល៩៨០?

ភាព ៖ ប្រធានកងពល តា មុត ប្រធាន ។

បូលី ៖ តា មុត ប្រធាន ហើយ តា ថិន អនុប្រធាន?

សែ ៖ តា ថិន អនុប្រធាន ។

បូលី ៖ តា បាវ សមាជិក?

សែ ៖ ទេ! តា បាវ ឡើងក្រោយតានេះទេ តា ពឹម ទេ ។

បូលី ៖ យឹម ពឹម?

សែ ៖ បាទ!

បូលី ៖ យឹម ពឹម មួយស៊េរីក្រោយ ស៊េរីយឹម ផាន់ណា, ដុំ ឈុនទី?

ភាព ៖ តា ពឹម ស្រករក្រោយទេ ក្រោយនេះហើយទេ ។ ដល់មកនៅក្នុងអន្លង់វែងនេះហើយទេ បើរៀបនោះ ។

បូលី ៖ ឥឡូវគេដក តា ម៉ុន មក៩៨០?

សែ ៖ បាទ! ដូចមិនទាន់បានកងពលផង ។

ភាព ៖ វរសេនាធំទេ កងអន្តរាគមន៍ ។

បូលី ៖ គាត់មកវរសេនាធំ៩២?

សែ ៖ បាទ!

បូលី ៖ ឈរជើងនៅសំឡូត?

សែ ៖ អត់ទេ ។

ភាព ៖ ហ្នឹងក្រោយ ។

សែ ៖ ឈរជើងនៅភ្នំគូលេននេះ មុខបន្ទាយស្រី ។

បូលី ៖ ឥឡូវយើងបកទៅ៦១២តិច ឲ្យច្បាស់កន្លែងនឹងតិច ។ ពេលគេដក តា ម៉ុន ពីណាឡើង?

សែ ៖ តា គង់ៗ ម្នាក់ឯង ។

ភាព ៖ នៅ តា គង់ ម្នាក់ឯង ពីរនាក់តា មាន ។

បូលី ៖ សាន់ គង់ ឡើងជាប្រធានវរសេនាធំ៦២?

ភាព ៖ ចា៎! ៦៣ ។

បូលី ៖ ហើយ តា មាន ជាអនុប្រធាន?

ភាព ៖ ចា៎!

បូលី ៖ ពីរនាក់នឹង គាត់កាន់នឹងរហូត មានការផ្លាស់ប្តូរទៀត?

សែ ៖ ខ្ញុំត្រូវចេញមកជាមួយ តា គង់ មក៩១២នេះ ។

បូលី ៖ ឆ្នាំប៉ុន្មាន ពូចេញមកជាមួយ តា គង់?

សែ ៖ ៨២ មកអង្គភាពផ្សេងទៀត អង្គភាពថ្មីទៀត ។

បូលី ៖ ចឹង តា គង់ ចេញពី៦៣?

ភាព ៖ ការពិតចេញពី៨១ មិនមែន៨២ទេ ព្រោះកូនខ្ញុំទើបសម្រាលបាន២ខែទេ ធ្វើដំណើរមកនៅនេះទៅចូលកងពលតាភាពនេះ ៩១២នេះ ទៅនៅថ្កូវ ខ្ញុំដឹង ខ្ញុំចាំ ។

បូលី ៖ ចឹង តា គង់ ចេញឆ្នាំ៨១?

ភាព ៖ ចា៎! ៨១ កាលនោះដូចចូលឆ្នាំរួច ។

បូលី ៖ កងពល៩១២?

ភាព ៖ អាចចេញខែ៥ តាមមើល ។

បូលី ៖ ប្រហែលជាខែ៥ ។

ភាព ៖ ព្រោះចូលឆ្នាំ ខ្ញុំសម្រាលរួច គេចូលឆ្នាំនៅ៤០នៅឡើយនឹង ខ្ញុំចាំ ទៅអាចខែ៥ ព្រោះកូនខ្ញុំបាន២ខែ ខ្ញុំសម្រាលខែ៣ ខែ៥ចេញដំណើរ ផ្លាស់ទៅនៅថ្កូវ ទៅចូលកងពលគេនោះ ។

បូលី ៖ ពេលតា គង់ ចេញពីណាគេឡើង?

ភាព ៖ ពេលក្នុងកងពល១២នឹង យើងលែងដឹង កងតា ឈាន នឹងយើងលែងដឹងហើយ យើងទៅចូលនៅ៩១២ហើយ លែងក្តាប់ លែងដឹងប្រវត្តិ ។ ខ្ញុំចាំខែ៥នឹងឯង ចូលឆ្នាំរួចហើយបានប្រហែលមួយខែ ក៏ចេញទៅនៅ ។

បូលី ៖ ចុះ ប៉ាំង កុសល ដែលពូ?

ភាព ៖ បង កុសស?

បូលី ៖ បាទ!

ភាព ៖ បង កុសល់ គាត់ទៅនៅជាមួយ កង តា ហឿន នោះ ។

សែ ៖ ៦១២ ។

បូលី ៖ ប៉ុនដំណែងជាអី?

ភាព ៖ វរសេនាធំ ។

បូលី ៖ មិនមែនអនុរបស់ តា ហឿន?

ភាព ៖ អត់ទេ ទើបមកនេះទេ គាត់នៅវរសេនាធំ ។

បូលី ៖ វរសេនាធំលេខប៉ុន្មាន ៦១ ឬ៦២?

ភាព ៖ អត់ដឹង១តែវរសេនាធំ ប៉ុនដឹងវរសេនាធំលេខប៉ុន្មាន នៅជិតគ្នាតែខ្ញុំអត់ដឹង ។

បូលី ៖ អត់ដឹងវរៈសេនាធំលេខប៉ុន្មាន?

សែ ៖ បានជួបគ្នាវិញ គាត់ឡើងកងពលដែរ ជាមួយ តា ហឿន ។

ភាព ៖ កង តា ហឿន នឹងនៅមានកងពួក តា ឆាន់ ពួក តា ភុត នោះម៉ាកងទៀត ខ្ញុំអត់ដឹងដែរ តែពួកនឹងផ្លាស់ទៅលិចដែរ ។

សែ ៖ ពួកនឹង៥៣ ។

បូលី ៖ មិញ មីងថា ពូ កុសល នេះឡើងជាអនុរបស់ តា ហឿន ក្រោយទេ?

ភាព ៖ មិនបានឡើងផង ដកមកនេះ ។ មិនបានឡើងកងពលណា បងកុសល នៅវរសេនាធំដកមក នៅសភាពការណ៍ប្រែប្រួលចឹងទៅគេផ្លាស់មកខាងអន្លង់វែងនេះ ។ ដល់សមាហរណកម្មរួច បានគាត់ចូលទៅវិញ ។

បូលី ៖ វរសេនាធំ ប៉ុនអត់ដឹងវរសេនាធំលេខប៉ុន្មាន?

ភាព ៖ ចាំ! អត់ដឹង ។

បូលី ៖ ពុំអាចចាំទេ៦១ ៦២ ប្រធាន?

សែ ៖ ភ្លេចអស់ហើយ ។

ភាព ៖ ព្រោះវាពិបាកអា៩១២នឹង ២ដើង មិនមែនចូលនៅតែម៉ាសារទេ ខ្ញុំ ។ អឺ!នែក កងពល នៅជាមួយ តា ហឿន នឹង២សារ ។ ចេញមកនៅ៩១២នេះ ផ្លាស់ទៅនោកង តា ហឿន វិញទៀត វាដូរចុះដូរឡើងចឹង ។

បូលី ៖ ពីណាផ្លាស់ទៅកង តា ហឿន វិញ?

ភាព ៖ ខ្ញុំហ្នឹង ។

បូលី ៖ មីងផ្លាស់ទៅកង តា ហឿន ធ្វើជាអី?

ភាព ៖ កាលទៅនៅជាមួយតាហឿននឹង ។

សែ ៖ កាន់វរសេនាធំ ។

បូលី ៖ មីងកាន់វរសេនាធំដែរ?

ភាព ៖ អត់ទេ ខ្ញុំនៅមូលដ្ឋាន ។

បូលី ៖ ពូវរសេនាធំលេខប៉ុន្មាន?

សែ ៖ ទៅនឹងដូច៦១វិញ ។

បូលី ៖ ប៉ុនពូកាន់បានមួយភ្លែតដែរទេ ព្រោះពូត្រូវដូរទៅ៩១២?

សែ ៖ ហេ៎! ទៅ៩១២នេះហើយ បើរយៈយូរ៩១២នេះហើយ បានត្រឡប់ទៅ៦១២វិញ ។ ៦១២មួយរយៈ ។

ភាព ៖ ៦១២ ទៅឆ្នាំ៨៧ ។

សែ ៖ មួយរយៈ០៥ យកមកនៅមន្ទីរ០៥វិញ ថាចឹងចុះកិច្ចការងាររខាងរដ្ឋបាលម៉ារយៈខ្ញុំ៩១២ នេះ គេទៅសុំសំណើរយកមកវិញ ។

បូលី ៖ ពីតា០៥មកវិញ?

ភាព ៖ មកវិញ មកកាន់នៅកងពលនេះវិញ ចឹង ។

បូលី ៖ ចឹងពូធ្វើប្រធានវរសេនាធំ៦១ពីឆ្នាំណាដល់ឆ្នាំណា មីងថា៨៧?

ភាព ៖ ៨៧ ចេញទៅនៅ៩១២ ការពិតវាចេញតាំងពីដើម៨៧ ។

សែ ៖ មក៩១២នេះ វាដល់វរសេនាធំហើយ វរសេនាតូច វរសេនាធំឡើងជាប់ ។

បូលី ៖ ឥឡូវខ្ញុំចូលមកកងពល៩១២ចុះ កងពល៩១២នេះ គឺថាត្រូវ ។

ភាព ៖ ឈប់ខ្ញុំគិតសិន មិនមែន៨៧ទេ ៨៦ៗចុង៨៦ចូលទៅនៅកង តា ហឿន វិញហើយ ព្រោះនៅធ្វើការម្តុំ៨០នេះបានយូរ បានផ្លាស់ទៅនៅជាំក្សាន្ត ។

បូលី ៖ មេដឹបូងបំផុតរបស់៩១២នេះ ពីណាគេ?

សែ ៖ តា ភាព អោម ភាព ។

បូលី ៖ អ-េ ា-ម?

សែ ៖ ឱ-ម ។

បូលី ៖ ឱម ភាព លេខាកងពល ។

ភាព ៖ ចូលទៅនៅ៩១២នឹង ខែ៥ ។

បូលី ៖ ពីណាគេអនុកងពលរបស់៩១២?

ភាព ៖ កាលមុន មានតែបងភាពម្នាក់ឯងកាលចូលទៅនៅដំបូង ។

បូលី ៖ ប៉ុន តា ភាព គាត់ស្លាប់ឆ្នាំ៩២?

ភាព ៖ ចាំ! ច្រើម ។

បូលី ៖ គាត់ឈឺរោគច្រើម?

ភាព ៖ ចាំ!

បូលី ៖ ដល់គាត់ស្លាប់ឆ្នាំ៩២នឹង បាន តា គង់ ឡើងប្រធានកងពលម្តង?

សែ ៖ បាទ! បានតា គង់ ឡើងកងពល ។

បូលី ៖ កងពល ៩១២ នឹង បង្កើតឆ្នាំប៉ុន្មាន ពូដឹងទេ?

សែ ៖ ដូច៨៣ ១៩៨៣ ។

ភាព ៖ ៨៣ស្អី បើទៅនៅ៨២ ទៅចូលកងពលតាភាព ខែ៥ ។ អឺ! ៨១ និយាយរួមជួបបងភាព តាំងពីនៅជាំនោះ កងពលនឹងដឹងគេរៀបចំពីអង្កាល់យើងអត់ដឹងដែរ ព្រោះខ្ញុំជួបគាត់តាំងពីខ្ញុំមិនទាន់ចូលទៅកងនឹងម៉េះ ។ និយាយរួមចេញពី តា ហឿន ទៅកងពលនឹង នែក! យើងចេញទៅ៨១នឹងឯង ។

បូលី ៖ ឆ្នាំប៉ុន្មាន?

ភាព ៖ ចេញពី មើលខ្ញុំគិតសិន ចេញបានប៉ុន្មានខែ ។

បូលី ៖ ពូអត់ដឹងឆ្នាំ?

សែ ៖ ភ្លេចឆ្នាំ រង្វង់៨១ ។

ភាព ៖ ៨១ចេញទៅ ។

បូលី ៖ បឹងបង្កើតនៅឆ្នាំ៨១?

សែ ៖ បាទ!

បូលី ៖ ដែលមាន តា ភាព ជាប្រធាន ឪម ភាព?

ភាព ៖ ចាំ! ជួបគាត់នៅជាំនេះហើយ ។

បូលី ៖ ហើយ ឪម ភាព នឹងប្រធានតាំងពី៨១ រហូតដល់៩២ ពេញគាត់ស្លាប់នឹងម៉ង ប៉ុយ៉ាងម៉េច?

សែ ៖ បាទ!

បូលី ៖ បន្ទាប់ពី តា ភាព ស្លាប់បាន តា គង់ ឡើងជាប្រធាន?

សែ ៖ តា គង់ ផង តាស្អី ។

បូលី ៖ តា រ៉េត?

សែ ៖ ឃឺ! រ៉េត មិនទាន់បានកងពលទេ កាលខ្ញុំនៅ ។ តា អីស្លាប់ នយោបាយ ។

ភាព ៖ តា ភាន់?

សែ ៖ មួយទៀត តា ហេង ។

បូលី ៖ ពីណាឡើងមុន តា ហេង ឬ តា គង់?

ភាព ៖ តា ហេង មុន ។

បូលី ៖ អី ហេងទៅ មីងដឹង?

សែ ៖ អត់ចាំឈ្មោះ អឺ! អត់ចាំត្រកូលទេ ។

ភាព ៖ មិនដឹងស្អីហេងទេ ។

បូលី ៖ ពេលណាបានតាគង់ ឡើងធ្វើមេកងពល?

ភាព ៖ ទាល់ភាពស្លាប់ បាន តា គង់ឡើង បើខ្ញុំបែកគាត់យូរណាស់ហើយ ។

បូលី ៖ ហេង១ជាអីគេ?

ភាព ៖ ហេង នឹងដូចអនុបងភាព ។

សែ ៖ កាន់ការងារប្រជាជន ។

បូលី ៖ អនុរបស់ តា ភាព?

សែ ៖ បាទ!

ភាព ៖ មានតែពីរនឹងកាលនោះ ។

បូលី ៖ សាំង គង់ ឡើងជាប្រធានពេល ភាព ស្លាប់?

ភាព ៖ ចាំ!

បូលី ៖ ចឹង ហេង ជាអនុលេខាកងពលរបស់ ភាព កាន់ការងារប្រជាជន ។ ចុះ រ៉េន ជាអី?

ភាព ៖ រ៉េត កាលនោះនៅវរសេនាធំ ។

សែ ៖ នៅវរសេនាធំ នៅស្មើខ្ញុំដែរនឹង ។

បូលី ៖ នៅវរសេនាធំទេ?

សែ ៖ បាទ!

ភាព ៖ ទើបមកកើតកងពលក្រោយហើយ វរសេនាធំ៥២ ។

សែ ៖ ទេ! រ៉េត មាន៥២ណា យើង៥២តើ ៥១ តា គង់ ឡើងកងពល ។

បូលី ៖ គេថាមានឈ្មោះ ទុយ ប៊ុនរ៉េត អនុកងពល?

ភាព ៖ ហ្នឹងហើយ ទុយ ប៊ុនរ៉េតនឹង ។

សែ ៖ គេឡើងក្រោយ មុនចេញទៅ ។

បូលី ៖ មុនដំបូងកាលពី៨១ ភាព ប្រធាន?
សែ ៖ ៨១ ៨២ ៨៣ ។
បូលី ៖ ភាព ប្រធាន ហេង អនុប្រធាន?
សែ ៖ បាទ!
បូលី ៖ បន្ទាប់ពី ភាព ស្លាប់ឆ្នាំ៩២ តា គង់ ឡើងជាប្រធាន ហេង នៅតែអនុដដែល?
សែ ៖ បើ តា គង់ ខាងយោធា មិនប្រធាន តា ហេង គាត់កាន់ការងារខាងនយោបាយ ។
បូលី ៖ តា ហេង នៅនយោបាយ?
សែ ៖ បាទ!(ស្តាប់មិនបាន)
បូលី ៖ តា ហេង ខាងនយោបាយ?
សែ ៖ បាទ! (ស្តាប់មិនបាន) ។
បូលី ៖ ហេង ខាងនយោបាយរបស់ តា គង់?
សែ ៖ បាទ!
បូលី ៖ តា គង់ៗ ប្រធានខាងយោធា?
សែ ៖ យោធា ។
បូលី ៖ ពីណាធំជាងមើលទៅ?
សែ ៖ គេគោរពគ្នាទៅវិញទៅមក សមរភូមិដែលប្រធានយោធា សមរភូមិក្រោយប្រធាននយោបាយ មិនចឹង ដើរដូរពីរមួយម្តងធ្វើអនុ ម្តងធ្វើប្រធានៗ ។
បូលី ៖ មីងអាចសុំមួយពេលទៀតបានទេមើលទៅ ព្រោះជិតចប់សល់ចុងក្រោយតិចទៀត?
ភាព ៖ នៅដល់ក្រោយសមាហរណកម្ម ។
បូលី ៖ ខ្ញុំចង់និយាយលេងបន្តទៀត ប៉ុន្តែបើសិនជាអត់មានគោលៗនឹងទេ យើងពិបាក តាមដានព្រឹត្តិការណ៍វា ទាល់តែមើលគោលៗនេះ តែកាលណាយើងនិយាយចោល វាបាននិយាយទៅ វាលែងរៀបចំព្រឹត្តិការណ៍នឹងបានត្រឹមត្រូវ ។
សែ ៖ ព្រោះស្ថាន ជីវិតមនុស្សម្នាក់ៗមានការផ្លាស់ប្តូរ ដល់ចឹងវាមិនអាចនឹងថ្កល់នៅមួយកន្លែងនឹងទេ ហើយរយៈកាលវាយូរមកហើយ តាមដំណាក់កាល ដូច្នេះវាអាចទៅប្រាស្រ័យខ្សែណាឲ្យប្រព័ន្ធខ្សែនឹង ប៉ុន្តែខ្សែណាដែលយើងមិនដឹងពិតប្រាកដនឹង អានឹងយើងដកល់ទុកនឹងស្រាវជ្រាវរកខាងស្ថាននឹងតទៅទៀតទៅ ។
បូលី ៖ ទេ! ត្រូវ អានេះវាមានពីម៉ាគន្ទាក់មកមួយគន្ទាក់ចឹង ។

សែ ៖ កុំឲ្យវាបាត់អត់ស្រមោល ។

បូលី ៖ បាទ! ពីព្រោះតាមតែពូ ហើយនឹងមីងជម្រាបមក ឃើញថាវាមានការបត់បែនសម្បើម ណាស់ ពីម៉ាដំណាក់កាលមកដំណាក់កាល វិលក្រញ៉ាំងដូចខ្សែចាក់ឫសចឹង ទម្រាំស្រាយវា ចេញមួយម្ដងៗគឺ ។

សែ ៖ តាំងពីទូទាំងប្រទេសមក វាមកជាចំណែក ។

ភាព ៖ មើលពី៨០១មក មក៦១២ ចេញពី៦១២ទៅ៩១២ ចេញពី៩១២ចូល៦១២ ចេញ ៦១២ទៅ៨០១វិញ បានមក៩១២វិញ ។

សែ ៖ នេះមកចប់ត្រឹម៩១២នេះ ។

បូលី ៖ មកចប់ត្រឹម៩១២នឹងម៉ង ទាំងពូទាំងមីង?

ភាព ៖ ចាំ!

សែ ៖ បាទ! ព្រោះសមាហរណកម្ម ។

បូលី ៖ សមាហរណកម្ម?

សែ ៖ កាលខ្ញុំនៅ៩១២នេះ ក្នុងឋានៈបញ្ញោការរងរបស់កងពល ។

បូលី ៖ រងកងពល?

សែ ៖ បាទ! ដល់ចឹងចូលនិវត្តន៍ សមាហរណកម្មនេះ ចូលខេមរៈភូមិន្ទ ។

បូលី ៖ ឥឡូវនឹង ពូនៅតែជាខេមរៈភូមិន្ទ?

សែ ៖ អត់ទេ ខេមរៈភូមិន្ទនឹង ក៏ចូលនិវត្តន៍កាត់ហើយ ។

បូលី ៖ ចឹងបច្ចុប្បន្ននេះ ពូសម្រាកហើយ?

សែ ៖ សម្រាកប៉ុនគេជាប់ការជម្រើសបោះឆ្នោតនេះ ទៅជាប្រធានសមាគមន៍អតីតយុទ្ធជន ប្រចាំ ក្នុងស្រុកអន្លង់វែងនេះ ។

បូលី ៖ ខមាទោស ពូពិការនៅឆ្នាំណាដែរ?

សែ ៖ អានេះ១៩៧២ ។

បូលី ៖ តាំងពី៧២មក?

សែ ៖ គ្រាប់ផ្ទុះនេះ គ្រាប់ចូលនេះដាច់នេះ បាក់ខ្ទេច ។ ក្រោយមកបន្ទាប់អានឹង អានេះរោងចក្រ ចក្រទីងកំពត លលាក់ក្បាលពីលើនេះពាក់កណ្ដាលខេត្តតាកែវមកអង្គតាសោម ប្រេះលលាក់ ដល់បន្ទាប់ពីអានឹងមក ក្រញ៉ុមជើងនេះ ត្រូវគ្រាប់បែកនៅអន្លង់រមៀតយើងនេះ ។ បន្ទាប់

មកទៀត មើលទៅមកដល់ត្រូវអានេះមកសៀមរាបទេ បែកចិញ្ចើមទៀត មួយសារទៀត អានេះមកព្រះវិហារនេះ នេះគ្រាប់អាការមួយនៅទាំងមូលនេះ ។

បូលី ៖ ទាំងសោះពេញខ្លួនហើយ?

សែ ៖ បាទ! ទៅរតនគិរីអត់អីទេ ។

បូលី ៖ ហើយចុះភ្នែកពូ?

សែ ៖ ភ្នែកនឹងដែលត្រូវពីរសារនឹង បាក់ឆ្អឹងត្រូវភ្នែកផង វាស្រុត ។

បូលី ៖ តាំងពីឆ្នាំ៧២?

សែ ៖ តែនៅប្រើបានៗនឹងប៉ុនវាអត់ប្រក្រតីទេ វាអត់ដូចភ្នែកនេះទេ ។ ដល់ក្រោយមកវាត្រូវមួយសារទៀត បែកអាចិញ្ចើមនេះវាស្រអាប់ អាកូនក្រមុំក្នុងទៀត ប្រើបាន៣ឆ្នាំទៀត សកម្មភាពវាអត់ស្រួល ។

បូលី ៖ ដល់ពេលណាបានយកចេញតែម្តង?

សែ ៖ យកចេញនៅ៨៦ ។ អានឹងទទួលមេបញ្ជាការវរសេនាធំហើយ ។

បូលី ៖ ហើយកាលដែលមីងរត់ទៅខាងទន្លេល្ពៅ មុំ៣នឹង យើងរស់នៅកន្លែងនឹងរហូតដល់ឆ្នាំប៉ុន្មានដែរ?

ភាព ៖ ខ្ញុំៗនៅទន្លេល្ពៅ បានតែមួយឆ្នាំ ខ្ញុំចេញទៅនៅ៦១២ ។

សែ ៖ ចុះបើខ្ញុំមក មុន ។

បូលី ៖ ពូមកមុន?

សែ ៖ បាទ!

ភាព ៖ ចេញមកនៅ៦១២នៅបានប៉ុន្មានខែ បានមក៩១២នេះរហូត ។

បូលី ៖ កាលនឹង៦១២ ឈរជើងនៅម្តុំណា?

ភាព ៖ នៅក្រោមព្រះវិហារនេះ ម្តុំប្រាសាទអ្នកបួស ជាំក្សាន្ត ។

សែ ៖ ៦១២ ចាប់ពីប្រាសាទអ្នកបួស ជាំក្សាន្តមកទល់គ្នានឹងខេត្តព្រះវិហារនេះ នេះប្រាសាទព្រះវិហារនេះ ។

បូលី ៖ ហ្នឹងកន្លែងឈរជើងដំបូង?

ភាព ៖ បាទ!

បូលី ៖ ខ្ញុំអត់ទាន់ចង់និយាយចូលដល់នឹង ព្រោះកាលណានិយាយទៅវាភ្លេចវិញ ចង់ពេលដែលមានថ្មយើងប្រូបាច់បញ្ចូលគ្នាម៉ង ។

សែ ៖ រឿងនេះ តាមដានវាវែង សាច់រឿង បន្ទ្រញឲ្យខ្ញីអាចយើងស្តាប់បាន ។

ភាព ៖ ប្រវត្តិបើសរសេរសៀវភៅ ។

បូលី ៖ នេះខ្ញុំយករឿងរបស់មីង-ពូសរសេរសៀវភៅ បានទេ?

សែ ៖ ខ្ញុំយក៣០០សន្លឹកសរសេរបានសាច់រឿងច្រើន ជីវិតខ្លួនឯងនឹង វាខូចខាតបាត់បង់ទៅ វារើរុះតាំងពីខ្ញុំនៅទំនប់ដាច់នោះ ។

បូលី ៖ ពូធ្លាប់សរសេរដែរ?

សែ ៖ បាទ!

បូលី ៖ ៣០០សន្លឹក?

សែ ៖ បាទ!

បូលី ៖ ឥឡូវនៅទេ?

សែ ៖ ថាវាឆេះខ្ទេចខ្ទី អស់កាលផ្លាស់ប្តូរទីកន្លែង អានេះដកស្រង់សង្ខេបៗបន្តមក ។

បូលី ៖ ពូអាចចែករំលែកបានទេ ឬក៏រឿងផ្ទាល់ខ្លួនខ្លាំងពេកនៅក្នុងសៀវភៅនឹង ឬក៏ជាប្រវត្តិដំណើរសាច់រឿងរបស់ពូទេ?

សែ ៖ វាសាច់រឿងក្នុងសង្គមគ្រួសារ ក្នុងចលនាតស៊ូ សង្ខេបៗទេ ឲ្យដឹងដំណើរជីវិត មិនបានទុកឲ្យកូនឲ្យចៅទេ នេះនោះ ។ ប៉ុនដល់រយៈកាល៨០មកដល់សមាហរណកម្មនេះមក ខ្ញុំបិទវគ្គវាអត់មានពេលឱកាសសរសេរបន្ត ។

បូលី ៖ ខ្ញុំអាចសុំកុំពីបានទេមើលទៅ?

សែ ៖ មិនបានទេ មើលទៅ ។

បូលី ៖ ដូចគេហៅអីកំណត់ហេតុផ្ទាល់ខ្លួន ។

សែ ៖ ចង់ដំណើរជីវិត សង្ខារខ្លួនឯងទៅចុះ ។

បូលី ៖ មីងមានសរសេរដែរ?

ភាព ៖ ខ្ញុំអត់សរសេរទេខ្ញុំចាំខួរក្បាលខ្ញុំម៉ង បើនិយាយចឹងប្រវត្តិឃើញដើរនៅណា ខ្ញុំស្រមៃឃើញខ្ញុំធ្វើអីខ្ញុំដឹង ។

បូលី ៖ ពេលនិយាយចឹង ស្រមៃឃើញទេ ។

ភាព ៖ ចា៎! ស្រមៃឃើញ ព្រោះខ្ញុំធ្លាប់នៅណា ធ្លាប់លំបាកម៉េច ។

បូលី ៖ ហើយក្រៅពីរូបថត ដែលខ្ញុំខ្ចីមីងថត មីងនៅសល់រូបថតអីខ្លះផ្ទាល់ពីដើមមក?

ភាព ៖ អត់មានផងមានមួយសន្ទឹកបងខ្ញុំយកទៅបាត់ហើយ ហើយមួយសន្ទឹកនឹងកាត់ដោយឡែកពីគេទៀត នៅដល់មួយកំណាត់ខ្លួននឹង ថតជុំជាមួយប្រធានកងវរៈនឹង ជាមួយ យាយ វ៉ន នោះ ប៉ុនដល់ហើយ ។

សែ ៖ ចង់បានរូបថតយ៉ាងម៉េច?

បូលី ៖ ខ្ញុំចង់បានរូបចាស់ៗនឹងទៅ ក្រែងលរអាចប្រើប្រាស់ក្នុងការបោះពុម្ពសៀវភៅ ។ ព្រោះសៀវភៅកាលណាមានរូបថតវាជួយឲ្យការអាននឹងវាត្រជាក់ភ្នែកដែរ ។ បើសិនជាសៀវភៅមួយដែលមានអក្សរសុទ្ធជួនកាលលែងចង់អានវិញ ។

សែ ៖ ខ្ញុំមានខ្លះៗដែរ តាមមើល ។

បូលី ៖ បើសិនជាពូអាចឲ្យខ្ញុំខ្ចីថតបាន កាន់តែល្អ ។ រូបថតដូចជាឧទាហរណ៍ថាសម័យអន្តរប្រជាជនគាត់ស្លៀកម៉េច គាត់រស់នៅយ៉ាងម៉េចជីវភាពរបស់គាត់ ។ ចឹងបានកាន់តែល្អ ។

ភាព ៖ អត់មានទេរូបថតនឹង មានតែរូបផ្ទាល់ៗខ្លួន មានរូបថត០៦ តា ភាព ។

បូលី ៖ អ៊ូ! មានជាមួយ តា ភាព?

សែ ៖ ខ្ញុំមាន ។

បូលី ៖ អាចឲ្យខ្ញុំសុំថតចម្លងបានទេ?

សែ ៖ ខ្ញុំឈរនឹង៩១២នេះក៏មាន នៅណាៗនោះ វាមានច្រើន ប៉ុនមិនដឹងស្រាវជ្រាវទៅណាអស់

បូលី ៖ ខ្ញុំបិទត្រឹមនឹងចុះ អរគុណមីងពូ ។

០២:២៦:៥១

បូលី ៖ សម្ភាសន៍វគ្គទី៣ ជាមួយអ្នកមីង អន សុភាព និងលោកពូ នោម សែ ។

ភាព ៖ សែ ។

បូលី ៖ ព្រឹកមិញយើងដល់ត្រឹមកងពល៩១២ ដែលប្រធានកងពល ឌិម ភាព លេខាកងពល ៩១២ ហើយ ហេង អនុលេខា ។ ប៉ុន ភាព នេះគាត់ស្លាប់នៅឆ្នាំ៩២ ដោយរោគ ។

សែ ៖ អស់ប្រើលេខា រយៈកាលនឹង ។

ភាព ៖ ដល់ប្រធាន, នយោបាយ, និងយោធា ។

បូលី ៖ លែងជាលេខាហើយ?

សែ ៖ បាទ! របបប្រធាន១ប្រើលេខា អានេះយើងប្រើរបបប្រធានពីរវិញ ។

បូលី ៖ របបប្រធានពីរ?

សែ ៖ បាទ!

បូលី ៖ ចឹងគេប្រើអីគេ ប្រធាន?

សែ ៖ បាទ! ប្រធាននយោបាយ និង ប្រធានយោធា ។

បូលី ៖ ពីរនឹងមួយណាអាចមានឥទ្ធិពលជាង ឬក៏យ៉ាងម៉េច?

សែ ៖ មួយមានឥទ្ធិពល ស្មើគ្នា ។

បូលី ៖ ចឹង ឌិម ភាព ប្រធាននយោបាយកងពល៩១២?

សែ ៖ បាទ!

បូលី ៖ ហេង ប្រធានយោធា៩១២?

សែ ៖ ការងារដោយឡែកៗពីគ្នា ។

បូលី ៖ ប្រធានយោធាកងពល ។

សែ ៖ មានអនុប្រធានទី១ ទី២ ។

បូលី ៖ មានអនុទី១ ទី២ទៀតចឹង?

សែ ៖ បាទ! ប៉ុនកងពលនឹងនៅខ្វះខាតច្រើនដែរ កម្លាំង អត់ទាន់ជម្រើសបានទេ ។

បូលី ៖ ឌិម ភាព គាត់ស្លាប់នៅឆ្នាំ៩២ ដោយសាររោគថ្លើម ខ្លះគេថាទាចទឹក វាហើមធំពោះ?

ភាព ៖ ចា៎!

បូលី ៖ បន្ទាប់ពី ភាព ស្លាប់មក អាចថា ហេង គាត់ ។ ប៉ុន ហេង ឮសួរថាស្លាប់មុនភាពទៀត?

ភាព ៖ មុន បង ភាព ទៀត ហេង ។

បូលី ៖ គាត់ស្លាប់?

ភាព ៖ គាត់ស្លាប់មុន ហេង គាត់ឈឺតាំងពីមើលឈឺតាំងឆ្នាំ យើងរត់នៅចំការត្រប់នោះ ។ ស្លាប់មុន ហេង អាចស្លាប់នៅ៨៨អីនោះ ។

បូលី ៖ គាត់ឈឺយ៉ាងម៉េច?

ភាព ៖ គាត់ឈឺ ព្រោះគាត់ឈឺតាំងពី៨៤នោះ ឈឺធ្ងន់ ព្រោះ៨៧ខ្ញុំនៅនឹងបានដឹ ។

បូលី ៖ ចឹង ហេង គាត់ស្លាប់ប្រហែលជាខ្ទង់៨៧?

ភាព ៖ ៨៧ហើយ អាច៨៨ ព្រោះ៨៧ខែ១២ខ្ញុំទើបចេញពីកងនឹង ចេញពីនៅជុំគ្នានឹងទៅនៅជាំស្លា ។

បូលី ៖ ដោយសារជម្ងឺ?

ភាព ៖ ចា៎! ជម្ងឺគាត់ឈឺតាំងពី៨៤នោះ ។

បូលី ៖ ជម្ងឺអីមីងដឹងទេ តាមមើល?

ភាព ៖ ដឹងគាត់ជម្ងឺអីទេ ផ្ទះជិតគ្នាដែរនឹង កាលនៅ៤០ ប៉ុនគ្រាន់ថា គាត់មានជម្ងឺមួយ គាត់អ្នករបួសផង គាត់មានជម្ងឺផ្សេងៗផង ។

បូលី ៖ ចឹងបន្ទាប់ពីស្លាប់ទៅនឹង សាំង គង់ ឡើងជាប្រធានយោធាជំនួសគាត់ ឬយ៉ាងម៉េច?

សែ ៖ បាទ!

ភាព ៖ ឡើងពី ភាព ស្លាប់ ព្រោះ ហេង ស្លាប់មុន ភាពៗ ៩២បានស្លាប់ ។

បូលី ៖ ហេង ស្លាប់ ភាពនៅជាប្រធានដដែលទេ ប្រធាននយោបាយ ហើយ គង់ ឡើងជាប្រធានយោធា អាចចឹងទេមីង មើលទៅ?

ភាព ៖ បែបអាចចឹងដឹង ព្រោះខ្ញុំចេញជុតហើយ ចេញពីនឹងជុត ព្រោះឆ្នាំ៨៨ ខែ១២នឹង ខ្ញុំចេញពីនឹងហើយ ។

បូលី ៖ ចេញពីនឹងទៅណាវិញ?

ភាព ៖ ខ្ញុំទៅនៅជាំក្សាន្តជាមួយ៦១២នោះ កាលមុននៅ៦១២ តាំង៨៦ ប៉ុនគ្រាន់ថាវានៅផ្ទះជិតគ្នាចឹង ។ ដល់ពេលផ្លាស់ទៅជាំក្សាន្តទៅ ខ្ញុំទៅខាងជាំក្សាន្តនោះវិញ ។ ដល់ចឹងឆ្ងាយពីគ្នាក្តាប់អត់បាន ។

បូលី ៖ បន្ទាប់ពី តា ភាព ស្លាប់ទៅ តា គង់ ឡើងជាប្រធាននយោបាយកងពលម្តង?

សែ ៖ បាទ!

បូលី ៖ ហើយពីណាគេឡើងប្រធានយោធាកងពល?

សែ ៖ ដួច រ៉េត ។

ភាព ៖ ទុយ ប៊ុនរ៉េត ។

បូលី ៖ ទុយ ប៊ុនរ៉េត?

សែ ៖ តា ទ័ព ឡើងមុន តា ទ័ព ស្លាប់ទៅឡើង ទុយ ប៊ុនរ៉េត នេះ ។

បូលី ៖ ហើយពីណាឡើងជាប្រធាន ពេល គង់ ឡើងពីណាគេឡើង?

ភាព ៖ ទុយ ប៊ុនរ៉េត ។

បូលី ៖ ពូថាពីណាមុនមិញ?

សែ ៖ ទ័ព រ៉ុល វានៅស្រុករជាមួយ តា ហេង អីនឹងស្លាប់នៅសមរភូមិដូចតែគ្នា អត់ទាន់ឥទ្ធិពលដឹកនាំខ្ពស់ផង ។

ភាព ៖ មិនទាន់បានប៉ុន្មានផង គ្រាន់យកទៅជំនួយការសិន ។

បូលី ៖ បានមួយភ្លែត?

សែ ៖ វាពីដើមនៅក្រោមខ្ញុំអានោះ ដល់មានបញ្ហាយើងចង់ផ្គត់ផ្គង់សមរភូមិសៀមរាបនឹង ឲ្យម្ចាស់ទឹកម្ចាស់ដីគេមានឥទ្ធិពល យើងអ្នកចំណាយ ដល់ចឹងចៀសផ្លូវឲ្យគេឡើងទៅ ដល់ទៅវាគ្រោះថ្នាក់នោះទៅវាធ្វេសប្រហែស ។

ភាព ៖ គ្រាន់ឡើងនឹង ឡើងដកហើយចុះទៅក្នុងនឹងស្លាប់បណ្ដោយ គ្មានទាន់បានធ្វើអី ។

បូលី ៖ គាត់ស្លាប់ដោយសារអី?

ភាព ៖ ត្រូវគ្រាប់ ។

សែ ៖ គេបាញ់ផ្ទុះនៅនឹង ។

ភាព ៖ មានបានធ្វើអី មិនទាន់បានធ្វើអី ។

បូលី ៖ បានមួយភ្លែត?

ភាព ៖ បានមួយភ្លែត កាលនឹងមកពីសមរភូមិមកលើគេ ។

សែ ៖ មនុស្សវាជំនោរផង វាភ្លឹតភ្លឺន ចុះបើឡើងតាំងពីវរសេនាតូចធ្វើសមាជិកកងពលហើយវា ។ ពីមុនខ្ញុំនៅក្នុងគណៈកម្មការកងពលដែរ ដល់ចឹងយើងចង់ជួយផ្គត់ផ្គង់ក្នុងស្រុកកំណើតនេះឲ្យវាម្ចាស់ការឲ្យវាមាននាទីតំណែងអីវាកាន់តែជ្រាលជ្រៅ ផ្សារសាច់ ផ្សារឈាម តែយើងមិនមានអារម្មណ៍អីទេ ដើម្បីឲ្យតែជាតិវារីកចំរើន ។

បូលី ៖ ចឹងពីឆ្នាំ៩២មកគឺថា តា គង់ គាត់ជាប្រធាននយោបាយកងពល?

សែ ៖ បាទ!

បូលី ៖ ទុយ ប៊ុនរ៉េត នេះជាប្រធានយោធាកងពលពី៩២មក?

ភាព ៖ ចា៎!

បូលី ៖ មានការផ្លាស់ប្ដូរទៀតទេ?

សែ ៖ មើល៩២ ៩៣ ៩៤ ។ យើងទៅ៩៤ មកកើតវិញ ។

ភាព ៖ ផ្លាស់ប្ដូរព្រោះយើងចេញផុតតាំងពី៨៧ យើងចេញផុតអត់មានដឹងសាច់រឿងប៉ុន្មានទេ ខ្ញុំទើបមកដល់ឆ្នាំ៩៦បានមកនៅកងនេះវិញ ។

បូលី ៖ ៩៦ មកនៅ៩១២វិញ?

ភាព ៖ ចា៎!

សែ ៖ បាទ! មកទទួលបញ្ជាការកងពលនេះ ។

បូលី ៖ ចឹងពេលដែលមីងមកនៅ៩៦ អ្នកណាគេប្រធានកងពល?

ភាព ៖ នៅបង គង់ ដដែល ។

បូលី ៖ គង់ ដដែលទេ?

ភាព ៖ ចាំ!

សែ ៖ ទៅសុំយកពួកខ្ញុំមកវិញ ។

បូលី ៖ គង់ នឹងគាត់ជាប្រធានកងពលរហូតដល់៩៨មែន ហើយយ៉ាងម៉េច?

ភាព ៖ ចាំ!

សែ ៖ ចប់សមាហរណកម្ម ។

បូលី ៖ ចឹងច្បាស់មួយ ។ ចុះ ទុយ ប៊ុនរ៉េត គាត់នៅជាប្រធានយោធាកងពល?

សែ ៖ យោធាកងពល ប៉ុនគាត់ចូលនិវត្តន៍ទៅរដ្ឋាភិបាល បែកបាក់ត្រឹមនឹងទៅ ។

បូលី ៖ ឆ្នាំប៉ុន្មានដែលគាត់បែកទៅ?

សែ ៖ ដូច៩៧ ៩៦៩៧ជីង ។

ភាព ៖ ទៅ៩៦នឹងឯង គាត់មានបានឡើងណា គាត់ចុះទៅធ្វើការក្នុងគាត់នៅនោះម៉ង ។

បូលី ៖ អូ! គាត់ផ្លាច់ខ្លួនទៅមុនចឹង?

ភាព ៖ ចាំ!

សែ ៖ អ្នកស្រុកកំណើតនោះ ។

បូលី ៖ គាត់នៅស្រុកកំណើតណា?

ភាព ៖ សៀមរាប ។

បូលី ៖ ចឹងបានគាត់ស្រួលផ្តាច់ខ្លួន ។

ភាព ៖ គាត់ចុះទៅធ្វើការនៅនោះ គាត់មាន ។ គាត់មកគាត់នាំកម្លាំងរដ្ឋាភិបាលមកម៉ងនឹង ។

សែ ៖ គាត់យកប្រពន្ធគាត់ទៅមុន ចាប់មានការរង្គោះរង្គើលគ្នា ។

បូលី ៖ ដោយសារតែគាត់ឃើញខាង ប៉ៃលិន ខាងអីគេចុះចូល?

សែ ៖ អត់ទេកន្លែងនេះក៏មានបញ្ហាដែរ មើលជីវប្រវត្តិខ្ញុំម៉ង បានវាដឹង ខ្ញុំលំបាកស្រួលយ៉ាងម៉េច

បូលី ៖ ហើយពេលដែលគាត់ផ្តាច់ខ្លួនទៅ ឥឡូវនឹងគាត់នៅរស់ទេ ទុយ ប៊ុនរ៉េត?

ភាព ៖ ស្លាប់បាត់ហើយ ស្លាប់ឆ្នាំទៅ ២០១១ ។ គាត់កើតពោះធំដែរ ។

បូលី ៖ ថ្លើម?

ភាព ៖ គាត់ដុះសាច់ក្នុងពោះផង ដុះសាច់ឡើងវៀចមួយចំហៀងអានឹងគេថាគីស មុនដំបូងតាំងពីតូច តែពេទ្យអត់វះ គាត់មានជម្ងឺគ្រាប់ឈាមសស៊ីគ្រាប់ឈាមផង ចឹងអត់ ។

បូលី ៖ មហារីក អានឹងអត់បាច់រស់ទេយូរទៅហើយ ។

ភាព ៖ ទៅពេទ្យឃួនផង វះផងអីផង ។

សែ ៖ វាចេះតែស៊ីដល់យើងអស់គោលិការមេរោគចិញ្ចឹមជីវិតទៅ អាទេសខុមទស្សន៍ទៅវាបំផ្លាញដោយគ្រប់វិធីមើលមិនត្រូវទេ ជម្ងឺវារីបរួបខ្ទេចខ្ទីអស់ ទៅដល់ស្រុកឃួនទៅទៀត ។

បូលី ៖ ប៉ុនពេលដែលគាត់ផ្តាច់ខ្លួនទៅនឹង គាត់មានបានទទួលតំណែងអីធំដុំដែរ?

សែ ៖ បានតើ ។

ភាព ៖ គាត់កងពលដែរ ។

បូលី ៖ របស់ខាងរដ្ឋាភិបាល?

ភាព ៖ រដ្ឋាភិបាល នៅកងពល៤១ ឈរជើងនៅក្នុងឃុំលំទងនេះឯង គាត់មកដល់នេះហើយបានគាត់ឈឺ នៅកងពលតូច ។

បូលី ៖ ចឹងគាត់គេឲ្យដំណែងគាត់ដែរ?

ភាព ៖ ចា៎!

សែ ៖ ចុះមានប្រធាន វ៉ៃរយៈមានកម្លាំង ។

ភាព ៖ ការពិតកងពលនឹង ភាគច្រើនសុទ្ធអ្នកសៀមរាប ហើយតួនាទីគេអត់ចោលគាត់ទេ នៅរបស់គាត់ដដែល ។

បូលី ៖ តា គង់ គាត់អត់ទេ?

ភាព ៖ តា គង់ អ្នកកំពង់ស្ពឺ ។

បូលី ៖ ទាល់ឆ្នាំ៩៨ បានគាត់ទៅ?

ភាព ៖ តា គង់ នៅរហូតទាល់សមាហរណកម្ម៉ង ។

បូលី ៖ ចុះពេលដែលគាត់ផ្តាច់ខ្លួនទៅ អ្នកណាគេឡើងជំនួសគាត់?

ភាព ៖ អត់មានទេ ។

សែ ៖ អត់មានទេ មេជំនាន់ក្រោយៗគ្មានទេ មានតែមករៀបចំក្រោយយកខ្ញុំមកនេះ វាមានបន្ទាប់មក ឌី ។

បូលី ៖ ដំណែងជាអី យោធា?

សែ ៖ ឌី វាអាចយោធា ។

បូលី ៖ បន្ទាប់ពី គង់?

សែ ៖ បាទ! ហើយបន្ទាប់មក នាមៗមកមានខ្ញុំ, ជន នេះ, អ៊ូ! គឺ មួយទៀត ៥-៦រូបនោះ ។

បូលី ៖ ចឹងពេល ទុយ ប៊ុនរ៉េត ផ្តាច់ខ្លួនក្រោយមកមាន ឌី?

ភាព ៖ បាទ!

បូលី ៖ ឱ គាត់ឡើងជំនួសជាប្រធានយោធាកងពល?

ភាព ៖ បាទ!

ភាព ៖ សុខ ឌី ។

បូលី ៖ សុខ ឌី មីង?

ភាព ៖ ចាំ!

បូលី ៖ ឡើងជាប្រធានកងពល ហើយពូថាមិញមានប៉ុន្មាននាក់ទៀតនេះ?

ភាព ៖ រស់ នាម ។

បូលី ៖ រស់ នាម?

សែ ៖ តា គី, ស្មី គី ។

ភាព ៖ ហ៊ុន គី ។

សែ ៖ ហើយខ្ញុំ ។ ដន ស្មី ដន ។

ភាព ៖ ស៊ិន ដន ។

សែ ៖ តាំងពីមុនមកនឹង ប្រធាននៅក្រោយ តែគាត់ទាំងអស់ គ្រួសារយុទ្ធជនទាំងប៉ុន្មាននៅគ្រប់គ្រងទាំងអស់ ។

បូលី ៖ ចឹងមីងដែរ?

ភាព ៖ ខ្ញុំនៅគ្រប់គ្រងគ្រួសារយោធាទាំងស្រុង ។

សែ ៖ គ្រប់គ្រងគ្រួសារនៅខាងក្រោយ ខាងរដ្ឋបាល ។ ចឹងបានគេយកមកវិញ ទាំងប្តីប្រពន្ធគេយកមកវិញ កំណើតកងពលនេះ កើតពីកម្លាំងខ្ញុំទេដែលច្រើនជាងគេ យកមកវិញ ។

បូលី ៖ ត្រូវហើយពូ ពី៨០១មក?

សែ ៖ បាទ!

បូលី ៖ ដែល មីង, ពូ, ដន, គី, នាម នឹងគាត់ហៅជាសមាជិកកងពល?

សែ ៖ បាទ! គណៈកងពល ។ ប៉ុននិយាយតែប្រុសៗទេ ស្រីៗការងារខាងក្រោយ ។

បូលី ៖ មានច្រើនដែរតើចឹង គឺអ្នកទាំងអស់នេះនៅរហូតដល់សមាហរណកម្ម៩៨ម៉ង?

សែ ៖ បាទ!

បូលី ៖ ដន មិនមែន ដង?

ភាព ៖ ដន ។ ឥឡូវគាត់គេដកប៉ុន្មានឆ្នាំហើយ ។

សែ ៖ ដកសិទ្ធិគ្នាចេញ ។

ភាព ៖ ដន ដូចតាំងអាណត្តិទី១ប៉ុន្មានឆ្នាំហើយទេ ។ ដាប់និន្នាការនយោបាយអី ។

បូលី ៖ ចឹងយើងដូចជាគ្រប់គ្រាន់ហើយអំពីសមាសភាពគណៈកងពល ដូចជាអត់មានខ្វះចន្លោះទេ តាំងពីបង្កើតឆ្នាំ៨១ រហូតសមាហរណកម្មឆ្នាំ៩៨នេះគឺគ្រប់គ្រាន់តែម្តង យើងដឹងពីដើមដល់ចប់ ។ កងពលចែកចេញជា ៣វរសេនាធំ?

សែ ៖ បាទ!

បូលី ៖ ទី១មានវរសេនាធំ៥១?

សែ ៖ ៥១ ។

បូលី ៖ វីរៈចឹង មិនមែនវិរទេ?

សែ ៖ មើល វទទេរ វរៈ ។ សុទ្ធពួកវរៈសេនីយ៍ហើយ អាវរៈនឹង ឋានន្តរសក្តិវាសិទ្ធិវរៈសេនីយ៍ហើយ ។

បូលី ៖ មានឋានន្តរសក្តិនឹង គឺស្មើនឹងវរៈសេនីយ៍ហើយ?

សែ ៖ បាទ! វរៈសេនីយ៍ ។

បូលី ៖ ដល់កងពល?

សែ ៖ កងពលវឿង ឧត្តមសេនីយ៍ ។

បូលី ៖ ត្រូតផ្កាយហើយ?

សែ ៖ ចឹងបានថាឈោងយកផ្កាយអត់ដល់ ។ ប៉ុនគេគោរពឋានន្តរសក្តិតាមនាទីយើង សូម្បីតែខ្ញុំទៅព្រំដែន៥ច្រកនេះ ខាងលើនេះ៣-៤ក្រវ៉ាត់នេះ គេគោរពម៉ង ដឹងថាសក្តិយើងធំ យើងអត់មានសញ្ញាអីសំគាល់ទេ ព្រោះសមរភូមិ ។

បូលី ៖ មានប៉ុន្មានវរសេនាធំទាំងអស់?

សែ ៖ ឯណា?

បូលី ៖ កងពល៩១២នឹង?

សែៈ វរសេនាធំ វាមាន៣វរសេនាធំ ។

បូលី ៖ មានលេខប៉ុន្មានខ្លះ?

សែ ៖ ៩១២?

បូលី ៖ បាទ! ៩១២ ។

ភាព ៖ ៥១ ៥២ ៥៣ ។

ភាព ៖ មានដល់៥៤ កង តា ឡេង ។

សែ ៖ ៥៤ ដឹកជញ្ជូន ។

បូលី ៖ មាន៥៥ ៥៦ ៥៧?

ភាព ៖ ក្រោយមកគេរៀបមែន ប៉ុនយើងចេញផុត យើងអត់ដឹងរឿង ។

សែ ៖ មាន៧៥៥ កង ដន នឹង៥៥ ។

បូលី ៖ ៥៥ ដន មេគេ?

សែ ៖ ហ្នឹងហើយត្រូវហើយ ។

បូលី ៖ មាន៥៧ មាន តា ហេង មេគេ?

សែ ៖ អត់ទេ ។

បូលី ៖ និយាយរួមមេវរៈនឹង អាចថាជាសមាជិកកងពលទេ ឬក៏ខុសគ្នាទាំងស្រុកគណៈកងពលមិនអាចជាមេវរៈទេ?

សែ ៖ អត់ទេ អត់មានពាក់ព័ន្ធទេ ។ ប៉ុនអានឹងមួយជំនាន់ៗ ។

ភាព ៖ ព្រោះឡើងតាមលំដាប់ ។

បូលី ៖ វាអាចឡើងពីមេវរៈទៅកងពល?

ភាព ៖ ចាំ!

បូលី ៖ ឥឡូវយើងវរៈ៥១មុន ពីណាគេ មេវរៈ៥១?

សែ ៖ វរៈ៥១ អា យ៉ា ក្រោយមកអាយ៉ា អត់ដឹងទេ ។

បូលី ៖ ពីមុនអាចដឹងទេ?

សែ ៖ ពីមុន មានសតែ តា គង់ នឹងហើយ ។

បូលី ៖ មុនគេដែលគាត់ឡើងជាមេកងពល?

សែ ៖ បាទ!

ភាព ៖ ៥១ណា បើ តា ដន នេះដកដាក់កងពិសេសអស់ តា គង់ ដកអស់ ។

បូលី ៖ តា គង់ ប្រធាន ចុះអនុប្រធាន តា គង់?

សែ ៖ ប្រធានមិនដឹងអ្នកណាទេ ដូច តា រ៉េត ដឹង ។

បូលី ៖ រ៉េត អត់ទាន់ច្បាស់ដាក់ គង់ មួយសិន តា គង់ ប្រធាន?

សែ ៖ វរៈនឹងមានតែ រ៉េត នឹងហើយដាក់លំដាប់បន្តគ្នា ។

បូលី ៖ រ៉េត?

សែ :	បាទ! ទុយ ប៊ុនរ៉េត នឹង។ ហើយ ៥២ កាលនោះមាន តា ភាន់, ខ្ញុំ, ប៊ុន មិត្ត ណន ស្លាប់ហើយ កាលមុន ណន។

បូលី :	អនុវរះ៥២?

សែ :	បាទ!

បូលី :	ពីមុនពីណាគេ?

សែ :	មិត្ត ណន។

បូលី :	ន និង ន?

សែ :	ណ និង ន។

បូលី :	ណន ជាប្រធាន ពេល ណន ស្លាប់បានៗ?

សែ :	ឡើង តា ភាន់។ ហើយបន្ទាប់មកខ្ញុំ។ តា ភាន់ ស្លាប់ទៀត។

ភាព :	ស្លាប់ឆ្នាំ៨៥ គានឹង។

សែ :	ជម្ងឺ។

បូលី :	ពេល ភាន់ ស្លាប់ឆ្នាំ១៩៨៥ បានពូឡើង?

សែ :	ឡើងបន្តគ្នានឹងឯង ខ្ញុំឡើងវរសេនាធំមើលឆ្នាំ៨២ ៨៣នឹង កាន់វរសេនាធំ។

បូលី :	ចឹងឡើងមុនពេល ភាន់ ស្លាប់ទៀត?

ភាព :	ឡើងមុន ទៅនៅជាមួយគ្នាមួយឆ្នាំ ២ឆ្នាំ។

សែ :	២ឆ្នាំ។

បូលី :	ឡើងម៉េចទៅ បើ ភាន់ គាត់នៅប្រធានចឹង?

សែ :	ចុះយើងមិនប្រធាននយោបាយ ប្រធានយោធា។ ៥៣ កាលនឹង តា ឆាន់។

បូលី :	៥៣?

សែ :	បាទ!

បូលី :	៥៨?

ភាព :	ឆាំ យុត។

បូលី :	ភាន់ នេះស្លាប់ឆ្នាំ៨៥។

ភាព :	ថាមើល ពួកតា ឡើង ពួកអី។

សែ :	ឡើងនៅវរៈកាលនឹង។

បូលី :	ពូឡើងធ្វើជាប្រធានឆ្នាំ១៩៨០ប៉ុន្មាន?

សែ ៖ មិនដឹងជានៅ៨៤ ៨៣ ហៅខ្ញុំពីទន្លេសាបមក កាលនឹងខ្ញុំនៅ៥១ ។

បូលី ៖ កាលនឹងពូនៅ៥១?

សែ បាទ! ប្រធានវរៈ ។

បូលី ៖ សេនាតូច?

សែ ៖ បាទ!

បូលី ៖ លេខប៉ុន្មានដែរពូ?

សែ ៖ ២១០ ។

បូលី ៖ ចឹងមានប៉ុន្មាន៣វរសេនាតូច?

សែ ៖ ៣វរសេនាតូច ។

បូលី ៖ ចឹងមានអីខ្លះ៥១នឹង?

សែ ៖ ៥១ ។ ២០១ ២០២ ២១០ ។

បូលី ៖ ម៉េចក៏មិន២០៣ ម៉េច ២១០វិញ?

សែ ៖ ហ្នឹងគេមិនឲ្យលេខ ។

បូលី ៖ កាលនឹងពីណាប្រធាន២០១?

សែ ៖ ២០១ដូច អាអ៊ុន, ២០២ អាធឿន, ។

បូលី ៖ ចឹង អ៊ុន ប្រធាន២០១?

ភាព ៖ អ៊ុន ជាមួយ តា ឡើង ។

បូលី ៖ ធឿន ២០២?

សែ ៖ អាអ៊ុល អនុប្រធាន ។ មើល២០១សិន ។

បូលី ៖ ២០១?

សែ ធឿន ប្រធាន ។

បូលី ៖ ២០១ ពីណាប្រធាន?

សែ៖ ធឿន ។

បូលី ៖ មិនមែន អុន ទេ?

ភាព ៖ អ៊ុន មិនមែន អុន ។

បូលី ៖ ធឿន ប្រធាន?

សែ ៖ ហ៎! អ៊ុន ប្រធាន២០១ ។

ភាព ៖  ២០១ទេ អ៊ុន នោះ ឡើង អនុ។

សែ ៖  ដូច អា ចាម មួយទៀត អាចាម សមាជិក។

បូលី ៖  មានសមាជិកមួយទៀត?

ភាព ៖  ចាមមាន ឈ្មោះ ចាម។

បូលី ៖  ចាម សមាជិក។

ភាព ៖  ដល់២០២ ពូ ធឿន, អ៊ុល អនុ។

សែ ៖  ដឹងតែ២នឹងទេ។

បូលី ៖  ហើយ២១០?

ភាព ៖  ២១០ ៣នាក់ គាត់ប្រធាន ហើយបង ចន្ថា អនុ, វ៉ាន់ សមាជិក។

បូលី ៖  ២១០ ពូប្រធាន?

សែ ៖  បាទ!

បូលី ៖  អនុរបស់ពូ?

ភាព ៖  ចន្ថា។

បូលី ៖  ត្រកូល ចាន់ ឈ្មោះ ថា?

ភាព ៖  គាត់ឈ្មោះ ចន្ថា ម៉ង អត់ស្គាល់ត្រកូលគាត់ទេ ភ្លេច។ សមាជិកឈ្មោះ វ៉ាន់ ដឹងអីវ៉ាន់ទេ នៅតែគេសួរកន្លា នៅកំពង់ស្ពឺ។

បូលី ៖  ប៉ុនអានឹងគ្រាន់ថានៅតែមានការដោះដូរទៀត?

សែ ៖  ដោះដូរ។ ខ្ញុំឡើងទៅវរសេនាធំទៅ វាចេះតែដូរទៀត។

ភាព ៖  ដោះ ដូរនឹងវាបែកគ្នាអស់ ហើយវរៈនឹងត្រូវបែកគ្នាអស់ មួយទៅនៅជាមួយវរសេនាធំ ៥២ទៅ មួយឈ្មោះ វ៉ាន់ គាត់ឡើងទៅជាមួយ តា ម៉ុន ទៅលិចទៅ។

សែ ៖  ទៅ លាច។

ភាព ៖  ទៅលិច ហើយ ចន្ថា នោះគាត់ស្លាប់ទៅចប់ គេរៀបចំក្រោយមិនដឹងណា។

សែ ៖  ចន្ថា ពេលស្លាប់គេនៅ៥៣។ គេជាសមាជិករបស់វ-៥៣។

បូលី ៖  ចឹងដើម្បីឲ្យស្រួលស្តាប់ យើងដាច់ដាក់ថា មានការដោះដូរនៅក្នុងរយៈពេលពីឆ្នាំ៨១ ដល់ ៩៣។

សែ ៖  ២ឆ្នាំ ៣ឆ្នាំ ផ្លាស់ប្តូរៗមេបញ្ជាការ ឬក៏ឡើងឋានៈ។

បូលី ៖  ៥១នេះ ឈរជើងនៅម៉ុណា?

ភាព ៖ ៥១នៅស្រុកពួក ។

បូលី ៖ មានតែមួយនឹងទេ ឬក៏ចល័តទៅស្រុកណាទៀត?

ភាព ៖ ទៅទៀតនោះទៅដល់កំពង់ប្រហុក ទៅដល់ដងស្ទឹងសង្កែនឹងទៅ ។

បូលី ៖ ទៅដល់កំពង់ធំនោះនឹង?

សែ ៖ អត់ទេ វាចូលទៅភាគខាងត្បូងម៉ង ។

ភាព ៖ អត់ទេ បាត់ដំបង ស្ទឹងសង្កែក្រោម កំពង់ប្រហុក ។

សែ ៖ ចុះខ្ញុំចុះទៅដល់ព្រែកទាល់ទន្លេសាប ។

បូលី ៖ រហូតដល់ស្ទឹងសង្កែ?

សែ ៖ បាទ! ក្បាលស្ទឹងសង្កែ ។

ភាព ៖ ស្រេចតែគាប្រើ ដកក្រវាត់ទៅនេះតិច ដកក្រវាត់ទៅនោះតិច ។

សែ ៖ ស្រេចតែគាត់ប្រើ ខ្ញុំអីទៅដល់មង្គលបូរី ។

បូលី ៖ អ៊ូ! ចល័តច្រើនណាស់ និយាយទៅ?

ភាព ៖ ចា៎! ដើររហូត អត់សូវទំនេរទេ ។

បូលី ៖ មិនមែននៅឈរជើងធ្វើការតែម្ដុំ ។

សែ ៖ អារឿងការងារផ្លាស់ប្ដូរ ប៉ុនរឿងអង្គភាពជាខ្សែបណ្ដាញវាត្រូវទៅ ។

បូលី ៖ អាចថាវរសេនាតូចនេះទៅនេះទៅ វរសេនាតូចនោះទៅនោះទៅ អត់នៅម្ដុំទេ?

ភាព ៖ ចា៎! អត់នៅជុំគ្នាទេ ។

សែ ៖ ដល់៥២ មកស្រុកក្រឡាញ់ ។

បូលី ៖ ៥២ចែកជាប៉ុន្មានវរតូច ៣ដែរ?

សែ ៖ ៣វរៈ ។

បូលី ៖ មានប៉ុន្មានដែរ?

សែ ៖ ២០៤ ២០៥ ២០៦ ។

បូលី ៖ ពូអាចចាំទេ ប្រធានមួយៗ?

សែ ៖ ២០៤នឹង ជាប់ជាងគេ អាដន នេះឯង ។ អេ៎! អាហាក់ មើលឈប់ អាហាក់ ។

បូលី ៖ ហាក់?

សែ ៖ បាទ! ២០៤ ។

បូលី ៖ ពីណាទៀត?

សែ ៖ អាហាក់ហើយ អា ដន នឹងឯង៧នាក់នឹង ។

បូលី ៖ អនុប្រធាន?

សែ ៖ បាទ!

បូលី ៖ ដន អនុប្រធាន២០៤ ចុះ២០៥?

សែ ៖ ២០៥ ប៉ូ ។

បូលី ៖ ប៉ូ ប្រធាន អនុគាត់?

សែ ៖ អនុគាត់មិនដឹងអាណាទេ ភ្លេចទៀត ។

បូលី ៖ អត់អីទេ ចាំតែមួយក៏បាន អត់អី អត់ចាំមួយទៀត ។ ២០៦?

សែ ៖ ២០៦ អាពួកនោះឡើងក្រោយ ម៉ាដំណាក់ៗវា ។ អ៊ូ! គេឡើងផុតទៅហើយ វានៅ២០៦ មាន ញឹម ។

ភាព ៖ ញឹម, រ៉ូ ។

បូលី ៖ ញឹម, រ៉ូ?

សែ ៖ កាលនឹង អាកប ។

បូលី ៖ ញឹម ប្រធាន?

សែ ៖ អាកបវាឡើងវរសេនាធំដែរ ។

បូលី ៖ លេខប៉ុន្មានកប?

សែ ៖ ២០៦ វាប្រធាន ។

បូលី ៖ កបៗប្រធាន?

សែ ៖ បាទ!

បូលី ៖ ចុះ ញឹម?

សែ ៖ អាញឹម នឹងវាអនុប្រធាន ។

បូលី ៖ កប ប្រធាន ញឹម អនុប្រធាន២០៦?

សែ ៖ បាទ!

បូលី ៖ ក្រោយមក កន ហើយ កប?

សែ ៖ កប ។

ភាព ៖ ស្លាប់ហើយ ។

បូលី ៖ កប នឹងធ្លាប់ឡើងជាវរសេនាធំ៥៧ដែរ?

សែ ៖ បាទ! ឡើង៥២ដែរ ។

បូលី ៖ ឡើងពីអន្លង់?

សែ ៖ តា កប ឡើង ក្រោយខ្ញុំចេញនឹង តាមមើល ។

ភាព ៖ ជិនាន់ឆ្នាំ៨៦ ។ ៨៦អី កបអាចឡើង៨៨ហើយ ទ័ព ងាប់ហើយនោះ ។ ទ័ព ឡើងទៅវរសេនាធំហើយស្លាប់ ។ ឡើងវរសេនាតូចបន្តពី តាប៊ុ ទ័ព ឡើង៨៦ ។

បូលី ៖ ឆ្នាំ៨៦?

ភាព ៖ អត់ទេ នៅវរសេនាតូចដដែលឡើយ ។

សែ ៖ តា ទ័ព នឹង នៅវរសេនាតូច ។

បូលី ៖ អត់ឡើង?

ភាព ៖ តែមិនដឹងគេឡើងឆ្នាំណាយើងចេញផុតវាពិបាក បាំងមួយឆ្នាំយើងចេញ ព្រោះយើងចេញតាំងក្នុងឆ្នាំ៨៦នោះ គ្រាន់យើងនៅអន្លកភាពជុំគ្នា ច្រើនកងពលចំរុះនឹងណា ដល់គេលើកដោយឡែកទៅបានយើងចេញដាច់ពីគ្នា ក្តាប់អត់បាន ។

បូលី ៖ ហើយ៥២នេះ ចល័តទៅនៅណាខ្លះ?

សែ ៖ ចល័តមាន ស្រុកក្រឡាញ់ ស្រុកស្រីស្នំ ។

បូលី ៖ ពីរនឹងទេ?

សែ ៖ បាទ! តែពីរ ។ ដល់៥៣ ។

បូលី ៖ វរៈ៥៣?

សែ ៖ ៥៣ក្រោយ ឆាន់ ទៅលិចទៅ នៅណាគេទេ ប្រធាន រកនឹកប្រធាន៥៣លែងឃើញ ។ មេស្លាប់អស់២-៣នាក់ហើយ មិនទាន់ដឹងអ្នកណាឈរកាន់កាប់៥៣ កាលនឹង ។

បូលី ៖ មេមុនពីណាគេ ដែលស្លាប់នឹង?

សែ ៖ មេមុនវា មើល ចន្ថា ផង អា ធុន ៥៤ទេ វងមិនចេញភ្លេចហើយ វងមេប្រចាំទិសនឹងដំបូង មិនដឹងជាអ្នកណាគេ បាត់៥៣ ៥៤ នឹងវកនឹកមិនឃើញ ។

បូលី ៖ ៥៤ក៏រកមិនឃើញ? ចុះវរសេនាធំច្រើនម៉េច៩១២?

សែ ៖ វាឡើង៤ ។

បូលី ៖ ៤វរសេនាធំ?

សែ ៖ បាទ! យកកងដឹកជញ្ជូននេះទៅជាកងនេះផង ទៅជាអន្លកភាព ។

បូលី ៖ ចុះវរៈ៥៥នោះ?

សែ ៖ វរៈ៥៥ ។

ភាព ៖ ៥៥គេរៀបក្រោយទេ យើងដឹងត្រឹម៥៤ ដឹកជញ្ជូន កង តា ឡេង ដឹកជញ្ជូន៥៤ ។ ដល់៥៥ដឹងណា អត់ដឹង ។

បូលី ៖ ចឹង៥៤ជាកងវរៈដឹកជញ្ជូន?

សែ ៖ បាទ!

បូលី ៖ ពីណាគេប្រធាន ឡេង?

ភាព ៖ ចា៎!

បូលី ៖ ចុះអនុរបស់ឡេង ពីណាគេ?

ភាព ៖ មិនដឹងពីណាអីកាលនឹង ដក តា ធុន ដកអីទៅ ប៉ុនមិនដឹងគេដកយកទៅដាក់ខាងតួនាទីអីមិនបានជាតាមដានដែរ ។

បូលី ៖ មាន៥៥ មាន៥៦ទេ?

ភាព ៖ អត់ដឹងទេ ។

បូលី ៖ ៥៥ ៥៧?

ភាព ៖ ៥៥អាដឹងល្អៀងៗ ប៉ុនមិនដឹងអ្នកណាគេ ។

សែ ៖ ៥៧អត់ទេ ។

បូលី ៖ ៥៧អត់ទេ?

សែ ៖ បាទ! ៥៥នឹងដូចពួកអា ជន ក្រោយឡើង២០៤នឹង ។

បូលី ៖ ៥៥ ជន ប្រធាន?

សែ ៖ បាទ!

ភាព ៖ មានទៅណាៗ នៅតែជុំវិញកងពល ។

បូលី ៖ នៅជុំវិញកងពល?

ភាព ៖ ចា៎!

បូលី ៖ ត្រូវហើយនៅជាប់នឹងមន្ទីរកងពល?

ភាព ៖ ចុះ ជន នៅមន្ទីរកងពល អាខា, អាជន, អាចន្ថា, អាជុំ អីនឹង ឆយ, រិន, ហៀប, សុទ្ធជុំវិញកងពលឥឡូវ ។

បូលី ៖ ចុះ ម៉ៅ ហម ដែលឮ?

សែ ៖ ហម ឈ្មោះ ហម មកជិនួសខ្ញុំ ។

បូលី ៖ ជំនួសពូវិញ?

សែ ៖ បាទ! ពេលដកខ្ញុំ មិត្ត ហម ទៅជំនួស ។

បូលី ៖ ជំនួសពូតាំងពីនៅវរៈប៉ុន្មាន?

សែ ៖ ៥២ ។ អាភាព មួយទៀតអនុប្រធាន ។

បូលី ៖ ក្នុងនេះអត់មានឈ្មោះពូ?

សែ ៖ បាទ?

បូលី ៖ អ៊ូ! នេះពូឡើង៨៣ ។ ពេលពូទៅណាបាន ហម ឡើងជំនួសពូ?

សែ ៖ ខ្ញុំទៅព្រំដែន មកព្រំដែនហើយទៅភ្ជាប់ជាមួយ៦១២នោះ ដាច់គ្នាត្រឹមវយៈនឹង ។

បូលី ៖ ម៉ោ ហម ឡើងជំនួសពូ?

សែ ៖ បាទ! ហម វាមានពីរ ។ ហម វរសេនាធំមួយ ហម វរសេនាតូចមួយ តែអាវរសេនា តូចស្លាប់ ។ អាហម វរសេនាធំ ទៅជំនួសខ្ញុំនេះក៏បែកបាក់គ្នាដែរ ។

បូលី ៖ ហម វរសេនាធំត្រកូលអី?

សែ ៖ ដឹងស្អី ត្រកូលអី ។

បូលី ៖ ចឹង ដាក់ ហម ទទេរចឹង?

សែ ៖ បាទ! អាចជួបពួកនឹងបន្តៗទៀតសួរដឹង ។

បូលី ៖ ចឹង៥៥នេះ គឺនៅជុំវិញមន្ទីរកងពល មាន ជន ប្រធាន ។ វ៉ាន់ សមាជិក?

ភាព ៖ មិត្ត វ៉ាត់ ។

សែ ៖ ត្រូវហើយ ។

ភាព ៖ វ៉ាត់ មេភូមិទ្រលទ្រាសនេះ ។

សែ ៖ ប៉ុនវាមិនទាន់ពិការ ពីដើមវានៅជាមួយខ្ញុំ ។

ភាព ៖ កាលមុនអនុសេនាធំនៅជាមួយគ្នា ។

សែ ៖ ខ្ញុំបែកចេញទៅឡើងវរៈៗតូចវរធំទៅ ។

ភាព ៖ គេរៀបចំក្រោយ ព្រោះយើងចេញដាច់ហើយ គាត់នៅអនុសេនាធំនឹងជាមួយគ្នាតាំងពីឆ្នាំ ៨០ ។

សែ ៖ ខ្ញុំចេញពីអង្គភាពនឹងទៅ៣-៤ឆ្នាំ ។

ភាព ៖ វ៉ាត់ នោះ កាលនេះ(សែ)ប្រធាន សាវ៉ាត់ នេះ(សែ)នយោបាយ សាវ៉ាត់ យោធា ។ ប្ដីរឹម នយោបាយ ឆ្នាំ៨០ មកជាមួយគ្នា ។ សុទ្ធតែពួកខ្ញុំការឲ្យ ។

បូលី ៖ ៥៧នេះ មានតា ហេង ។

សែ ៖ ហេង ណា?

បូលី ៖ មិនដឹង ជា តា ហេង ណា ពូសួរតែ ហេង?

ភាព ៖ ហេង ៣២ដឹង មិនស្រួល ។

បូលី ៖ អានឹងនៅក៏នៅជាប់នៅមន្ទីរកងពលដែរ ស្លាប់ដោយបរទេះបះមីន ។

ភាព ៖ ហេង ៣២ ហេង មេក្រុម ។

សែ ៖ ហេង នឹងក៏នៅជាមួយខ្ញុំដែរ ពីដើម ។

ភាព ៖ ហេងអនុសេនាតូច៣២ ពីមុនមេក្រុម កាលឆ្នាំ៨១ ៨២ ពួកនឹងមេក្រុម នៅកងអនុសេនាធំ តា ដន ។

សែ ៖ កម្លាំងនឹង សុទ្ធតែកម្លាំងខ្ញុំទេ ខ្ញុំបង្កើតមក ។

ភាព ៖ កម្លាំង៣១០ យូរៗអស់រលីង បំបែកវាទៅដាក់ធ្វើមេនោះមួយ នេះមួយ ។

បូលី ៖ ចឹង៥៧ មានពូ?

សែ ៖ មាន គេរៀបក្រោយរចនាសម្ព័ន្ធក្រោយ ។

ភាព ៖ អានឹងនៅសួរគេអ្នកនៅចាស់ ដូបដូច តា រ៉ាត់ ដូចអីបានគេដឹង ។

សែ ៖ អា ជូ វាជាប់ការងារនឹងដែរ ។

ភាព ៖ ពួក ជូ ពួកអា តៀង អីសុទ្ធតែនៅជុំវិញនឹង កងគេនឹងរៀបចំក្រោយ ។

បូលី ៖ វរសេនាធំ៥៧នឹង មាន ហឺ ជាប្រធាន ពូមិនដែលឮទេ?

ភាព ៖ អត់ដែលដឹង ។

បូលី ៖ គេប្រាប់ថាស្លាប់ដោយបរទេះកិនមីននៅឆ្នាំ៩០ជាង?

សែ ៖ ៩០ជាង ខ្ញុំទៅបាត់ហើយ ។

ភាព ៖ ៩០ជាង យើងនៅ៨០១វិញហើយ លែងដឹងហើយ នៅឆ្ងាយពីគ្នាណាស់ ។ មានពួកប្រុសគល់គេមិនប្រែប្រួលទេ បានដឹង ។

សែ ៖ តា អ៊ុម!

ភាព ៖ តា អ៊ុម នៅ៥២ដែរ ពីមុន តា អ៊ុម នៅតាំងពី ។

សែ ៖ ប៉ុនគាត់ធ្លាប់ជាប់គុកម្តង ដល់មកវិញ យើងមិនបានទទួលនាទីកងពលទេ នៅទទួលវរសេនាធំនេះវិញ ។

ភាព ៖ មិនដឹងវរសេនាធំលេខប៉ុន្មាន តា អ៊ុម ។

សែ ៖ តា អ៊ឹម នៅ៥២ ។

បូលី ៖ ៥៣ យើងអត់ដឹង ដាច់៥៣?

ភាព ៖ ៥៣ ដាច់ពី ពូ ឆាន់ ហើយ ពូ ឃុត ទៅអត់ដឹងអ្នកណា ។

បូលី ៖ អូ៎! ឆាន់ ឃុត?

សែ ៖ យកទៅលាចទៅ ។

ភាព ៖ យកទៅលាចបាត់ហើយ ឆ្នាំ៨៥ ។

បូលី ៖ លាចនឹងស្អីគេ?

សែ ៖ លាចសមរភូមិស្រុកលិច ។

បូលី ៖ នៅកំពង់ឆ្នាំងមែន?

សែ ៖ បាទ! លាច កំពង់ឆ្នាំង ។

បូលី ៖ ចឹង ឆាន់ នឹងប្រធាន?

សែ ៖ បាទ!

បូលី ៖ ហើយ ឃុត នឹងអនុប្រធាន?

សែ ៖ តា ឃុត កាលនឹងសិទ្ធិដំណាលនឹងខ្ញុំដែរ ។

បូលី ៖ ហើយដល់ពេលយកទៅលាចនឹង បាត់រហូតឈឹងចឹងទៅ?

សែ ៖ ទៅសមរភូមិគេនឹងទៅ ។

បូលី ៖ ស្លាប់ ឬក៏ចុះចូលជាមួយរដ្ឋាភិបាល?

សែ ៖ អត់ទេ តា ឆាន់ គេនៅកងពល នៅរាល់ថ្ងៃ ។

បូលី ៖ ប៉ុន ឆាន់ នឹងប្រធានធំ៥៣?

សែ ៖ បាទ!

បូលី ៖ ហើយឡើងកងពលក្រោយទៀត?

សែ ៖ ទៅកងពលលិចនោះ ។

បូលី ៖ កងពលអីគេ?

ភាព ៖ កាលនឹងគេរើសទៅចំរុះកងអន្តរាគមន៍ទៅអី ។

សែ ៖ គេសុំពីកងនឹងទៅយកទៅពង្រឹកនោះ ។

ភាព ៖ យកទៅពង្រឹកបន្ថែម ។

សែ ៖ ប៉ៃលិននេះក៏មានពួកពីនេះទៅ ខ្លះគេទៅមកវិញ កោះកុងក៏មានពួកពីនេះទៅ ។

ភាព ៖ ខ្លះក៏ទៅសារភាពក្នុងទៅ ខ្លះក៏រត់មកនេះមក ខ្លះក៏ស្លាប់ ពិបាក ។

សែ ៖ ខ្ញុំអីក៏ត្រូវទៅដែរ ប៉ុនវាប្រកែកជាមួយតាទេ ថាកុំប្រើបានតែអានឹងប្រើតែអានឹងតា ។

ភាព ៖ បានដូរកម្លាំងទៅ ។

សែ ៖ ចុះឯងថាចិន (ស្តាប់មិនបាន) មិនប្រើចាំនៅនេះប្រើតែអានេះទៀត ខ្ញុំអ្នកនិយាយគជាមួយគាត់បាន ។

បូលី ៖ ហ៊ាន តជាមួយតា?

សែ ៖ អីមិនហ៊ាន ។

ភាព ៖ បើកូនខ្ញុំមកពីព្រឹក ឈ្លោះជាមួយ តា ។ កូនខ្ញុំខ្ចីស្រូវពូជខ្ញុំ យកមកឲ្យគេដាំនៅអន្ទង់វែង កូនខ្ញុំទារសងអង្ករខ្ញុំលោកតា ។ សងអង្ករអី? តាឯងដឹកស្រូវពូជម៉ែខ្ញុំមក ។ កូនណា? ចុះអត់ស្គាល់ម៉ែខ្ញុំឈ្មោះ ភាព ។ អ៊ូ! កូនខ្វាក់នឹង សាហាវកាចម៉េច ។ តាមិនសង ក៏ខ្ញុំយកកើបអង្ករវាស់យកហើយ ។ វានៅតូចៗ តាចូលចិត្តក្មេងៗណាស់ ។

បូលី ៖ ហ៊ានតវ៉ាជាមួយតាផង?

សែ ៖ ចុះគាត់សាមញ្ញដែរ គាត់មិនដែលជាមេហ្វូងហែងណា គាត់អត់មានដូចពួកឥស្សរៈជន ពួកកសិករម្តង ។

ភាព ៖ ថា តាឯងចេញ ចាស់អន្ធុយយូរ ឲ្យក្មេងចង់និយាយម្តង ។

សែ ៖ ធ្វើអីចង់ឲ្យចៅស៊ី ហៅពួកទឹកកក ការ៉េមតីធ្វើអីនៅណាមក អន្ធុយចែកនៅនឹងមើលក្មេងៗស៊ី ។

បូលី ៖ គាត់ដូចសាមញ្ញ តា?

ភាព ៖ សាមញ្ញ បានអាជញ្ជាត់កំពីស ត្រីក្អិត បានយកមកដូរត្រីខ បានមួយកេស ចំណីឆ្ងាញ់គាត់ ។

សែ ៖ ចុះគាត់ព្រឹទ្ធាចារ្យហើយ ខាងអក្សរសិល្បន៍ សិស្សលោកតា ជួន ណាត ដែលនឹង ។

ភាព ៖ ថារឿងរបៀបរបបអ្នកស្រែមិនចោលទេ ។

សែ ៖ ប៉ុនរឿងស្តេចមិនចូលចិត្តទេ ចឹងបានគេហៅ អា តា ម៉ុក នឹង វារឹកពេក ។

ភាព ៖ បើផ្លាស់ភូមិៗទៅនៅថ្មី ភូមិណាមានត្រីងត្រឡាច ត្រីងនទេងត្រីងឃ្មោកមានគល់ស្មឹកគ្រែឲ្យគ្រាប់ពូជបន្ថែម ថែមត្រីខ ថែមអង្ករឲ្យស៊ីទៀត ។

បូលី ៖ ចូលចិត្តអ្នកដែលធ្វើការដាំដុះ?

ភាព ៖ ចា៎! បើអ្នកណាអត់ធ្វើ ស្តាប់មាត់ផ្ទៃងអត់មាត់ អត់ភ្នែកអីណាទៀត មិនចេះមើលគេមើល ឯង ។

សែ ៖ គាត់មិនចង់ ចូលចិត្តអាកំសត់សែងតែង អណ្តែតអណ្តូង គ្មានរឹប គ្មានគល់ គាត់មិនចូលចិត្ត ទេ អ៊ីដែលខ្វះ គាត់ទិញឲ្យ ។

បូលី ៖ ចង់៦១២តិច ពូវិលមកពី៩១២មក ចូល៦១២?

សែ ៖ បាទ!

បូលី ៖ ៦១២នេះ ខ្ញុំអានឲ្យពូមីងស្តាប់ ពីដំបូងគេ តា ឈាន ហើយនឹង តា ហឿន ។ បន្ទាប់មក តា ឈាន ត្រូវបានដកទៅនៅកោះកុងនៅប្រហែលឆ្នាំ៨១ ។ ចឹង តា ហឿន ជំនួស តា ឈាន ហើយមាន តា សន់ ហើយ តា មឿន ឡើងមកទៀត ។ តា ហឿន គ្រប់គ្រងកង ពល ។

ភាព ៖ តា ឈាន នឹងមិនមែនទៅ៨១ ទៅពាក់កណ្តាល៨០គត់ ព្រោះគ្រប់គ្រងបានតិចណា ព្រោះខ្ញុំមកនៅផ្លូវដារនេះ គាត់ចេញហើយ ជិតព្រះវិហារនឹង គាត់ចេញហើយ ។

បូលី ៖ កងពលនឹងបង្កើតឆ្នាំប៉ុន្មាន?

សែ ៖ ឆ្នាំ៨០នឹងដែរ ។

បូលី ៖ មិនមែន៨១?

ភាព ៖ មិនមែនទេ ៨១ខ្ញុំមកកន្លែងកងពល តា ភាព ហើយនឹង ៩១២ហើយនឹង ។ មើលខ្ញុំចេញ មកចុងឆ្នាំ៨០ ខែ១២ ។

បូលី ៖ ប្រហែលជាចុងៗឆ្នាំ៨០?

ភាព ៖ ហ្នឹងហើយ អាចខែ១១ ខែអី ។

បូលី ៖ ខែកត្តិកហើយ ត្រជាក់ៗហើយ?

ភាព ៖ ចា៎!

បូលី ៖ ចឹង តា ឈាន ចេញទៅ, តា ហឿន ហើយនឹង តា សន់ នេះ លេខ?

ភាព ៖ ហ្នឹង ។

បូលី ៖ ហើយគាត់ទាំងពនាក់នេះ នៅគ្រប់គ្រង៦១២នេះរហូតដល់៩៨តែម្តង អត់មានដោះដូរ ទៀតទេ?

ភាព ៖ អត់ទេ តា ហឿន នៅគ្រប់គ្រង រហូត ។

បូលី ៖ នៅរហូត?

ភាព ៖ ចាំ!

បូលី ៖ ហើយកងពលនេះចែកចេញជាពាវរសេនាធំ មាន៦១ ៦២ ៦៣?

ភាព ៖ ចាំ!

បូលី ៖ ៦១ ៦២ អត់ទាន់ដឹងទេ ប៉ុន ៦៣ មាន តា ម៉ុន ជាប្រធាន?

ភាព ៖ ចាំ!

បូលី ៖ ហើយ តា សារ៉ំង គង់ នេះអនុ តា មាន នេះសមាជិក ។ តា ម៉ុន ត្រូវបានដកទៅកងអគ្គភាគមន៍ឆ្នាំ?

ភាព ៖ ៨០ ។

បូលី ៖ ៩៨០ នៅឆ្នាំ៨០?

ភាព ៖ ចាំ!

បូលី ៖ ចឹង តា គង់ ឡើងប្រធាន តា ម៉ុន អនុប្រធាន?

ភាព ៖ កាល មាន ។

បូលី ៖ អូ! មាន១ អនុប្រធាន?

ភាព ៖ ចាំ!

បូលី ៖ ហើយ សារ៉ំង គង់ ចេញទៅកងពល៩១២ ប្រហែលខែ៥ឆ្នាំ៨១ទៀត?

ភាព ៖ ការពិតមិនមែនចេញនៅក្នុងនេះទេ ព្រោះចេញពីតា ហឿន ទៅ តាំងពីខែ១២ ។ ខែ១ ខែ២ ព្រោះខែ៣ខ្ញុំសម្រាល ខែ៤នៅចូលឆ្នាំនៅ៨០ អាចខែ១ ។

បូលី ៖ ចឹងគាត់ចេញទៅប្រហែលជាខែប៉ុន្មាន?

ភាព ៖ ប្រហែលខែ១ ខែអីនឹងឯង ។

បូលី ៖ ខែ១ ៨១?

ភាព ៖ ចាំ! ខែ១ ៨០ ។

បូលី ៖ ហេ៎! ខែ១ ៨០ណា បើ?

ភាព ៖ តា ឈាន ចេញហើយ ពួកខ្ញុំក៏ត្រូវផ្លាស់ទៅនៅជាមួយ តា ភាព នឹងម៉ង ។

បូលី ៖ ចុះ តា គង់ គាត់ចេញទៅពេលណា?

ភាព ៖ ចេញជាមួយគ្នា ជាមួយខ្ញុំនឹង ។ ត្រង់ តា មាន តាអីនឹងខ្ញុំពោះធំ តា មាន ដើរតាមខ្ញុំរហូតនឹង ។ តា ឈាន ចេញហើយ ខ្ញុំចេញដែរ ។

បូលី ៖ ប៉ុន តា ឈាន នឹងគាត់ចេញចុង៨០ ឬក៏ដើម៨០?

ភាព ៖ ចុង ។

ប៊ូលី ៖ ចុង?

ភាព ៖ ចា៎! មុនក្រោយគ្នាម៉ាខែ ឬពីរខែមិនដឹងទេ ។

ប៊ូលី ៖ មុនមីង ឬក្រោយមីង?

ភាព ៖ មុនខ្ញុំ ។

ប៊ូលី ៖ តា គង់ ជំនាន់មីង?

ភាព ៖ ចា៎! បង គង់ មកជាមួយគ្នា ខ្ញុំជាមួយ បង មាន ជាមួយអីទាំងអស់ ដើរជាមួយគ្នាទាំងអស់ ដើរជុំគ្នា ។

ប៊ូលី ៖ ចឹងទាល់តែដើម៨១?

ភាព ៖ ដើម៨១ ។

ប៊ូលី ៖ ដើម៨១?

ភាព ៖ ចា៎! ដើម៨១មកនៅ៩១២នេះ ។

ប៊ូលី ៖ ចឹងមាននៅសល់ តា មាន ប្រធាន វរៈ៦៣នេះ?

ភាព ៖ បង គង់ ហើយ មាន នឹងមកនៅវរសេនាធំជាមួយគ្នារហូត ។

សែ ៖ មកទាំង៦៣នឹង មកទាំងអស់ ។

ប៊ូលី ៖ មកទាំងប្រធានទៀត?

សែ ៖ បាទ! ៦៣នឹងមកទាំងអស់មួយវរសេនាធំនឹង ។

ប៊ូលី ៖ ចឹង៦១២ នៅសល់តែ២?

សែ ៖ ២ ប៉ុន្តែគេរៀបក្រោយទៀត ។

ប៊ូលី ៖ ចឹងយើងដាក់ថា វរសេនាធំ៦៣ត្រូវបានប្តូរទៅកងពល៦១២ នៅដើមឆ្នាំ៨១?

ភាព ៖ ចា៎! ដើមឆ្នាំ៨១ ព្រោះខ្ញុំដឹងថា យកខ្ញុំទៅនៅ ។

ប៊ូលី ៖ ចឹងមានន័យថា៩១២ បង្កើតក្រោយ៦១២?

សែ ៖ ៦១២កើតមុន ។

ភាព ៖ កាលនោះ បង ភាព ពូថាឡើងមកភូមិភាគកណ្តាល រៀបចំដីបូង យកមកបំពេញកងពល ។ ខ្ញុំមកនៅជាំនឹង គេចុះទៅក្នុងបានជាងមួយខែ បានខ្ញុំសម្រាល បានខ្ញុំដឹងថាមកដើមឆ្នាំ បើកូនខ្ញុំកើតខែ៣នោះ ។ មកដល់ហើយគេ(សែ)ចុះបានមួយខែជាង ។

ប៊ូលី ៖ ចឹងមាន តែ តា ម៉ុន មួយទេ ដែលចេញពី៦៣?

ភាព ៖ ចាំ!

បូលី ៖ តា គង់ តា មាន អត់ចេញទេ គ្រាន់តែគេដូរទាំងអស់មក?

ភាព ៖ អត់ចេញទេ ដូរមកជាមួយ តា ភាព ទាំងអស់ វរសេនាធំនឹង។

បូលី ៖ ហើយអានឹងវាក្លាយទៅជាវរសេនាធំ៥១នឹងទៅ ឬយ៉ាងម៉េច ឬក៏អត់ទេ ៦៣ពីមុន៦១២នឹង?

សែ ៖ ៥១ ។

បូលី ៖ បញ្ចូលទៅ៥១?

ភាព ៖ ៥១ ។

បូលី ៖ ប៉ុននៅក្នុង៥១នេះ អត់មានឈ្មោះ តា មាន ទេ មានតែ តា គង់ តា ទុយ ប៉ុនរ៉េត?

ភាព ៖ មានតើ បង មាន នៅរហូតនឹង ។

សែ ៖ អត់ទេ អត់មាននៅទេ ដាច់ហើយ ។

ភាព ៖ ដាច់ណា បើនៅ ។

សែ ៖ ទៅតែម៉ាវរៈយើងនេះទេ យកទៅ ។

ភាព ៖ នៅចំការគ្រប់ បង មាន នៅទឹកធ្លាក់ ទឹកចេញ ។

សែ ៖ នៅជាមួយ ឆាន់ ទៅ៥៣វិញ ។

ភាព ៖ អត់ទៅនៅទឹកធ្លាក់នោះទេ នៅកន្លែងដឹកជញ្ជូន កាល ពួកអា ហ៊ូវ ឡៅ អីនេះ ទឹកចេញដូវចុះហួស៥២ទៀត មិនមែនទឹកធ្លាក់កន្លែងកងពលទេ បង មាន នៅទេ។ ដូចចេញមកនៅ៥២ហើយ បង មាន នៅឡើយនឹង ទើបដល់ក្រោយទេ មាន នៅ គង់ ដដែលនឹង ។

បូលី ៖ មាន នៅជាមួយ គង់ រហូតហើយចឹង?

ភាព ៖ ចាំ! មិនដឹងគាត់ ហើយក្រោយមក គាត់ទៅណានោះ យើងអត់ដឹងទេ ព្រោះយើងផ្លាស់ចេញ គេដូរគាត់ទៅណាទៀត ក្រោយមកអត់ដឹងទេ បើកាលនោះក្នុងឆ្នាំ ៨៣៧ យើងនៅដឹងនៅឡើយទេ ថាដឹងនៅជុំគ្នា ។

បូលី ៖ ចុះ វ៉ាន់ កុសល ដែលព្រុឈ្មោះនឹងទេ?

ភាព ៖ បង កុសល នៅអភិបាលស្រុកត្រពាំងប្រាសាទរាល់ថ្ងៃនឹង ។

បូលី ៖ បាទ! រាល់ថ្ងៃនឹង គាត់កាន់អីគេ?

ភាព ៖ បងកុសល គាត់វរសេនាតូចដែរ កាលនោះ ។

បូលី ៖ មិនមែនវរសេនាធំទេនេះ?

ភាព ៖ ទេ! វរសេនាធំក្រោយមក ។

សែ ៖ កាន់វរសេនាធំ ។

ភាព ៖ អ៊ូ! វរសេនាធំទៅនៅជាំស្វា ពួកនឹង ។

សែ ៖ ហ្នឹងហើយ ជាមួយពួក តា ណាត ពួកអីនេះ តា ណាត កាលនឹងវរសេនាតូច ។

បូលី ៖ វរសេនាធំលេខប៉ុន្មាន វ៉ាន់ កុសល?

ភាព ៖ អត់សូវដឹងលេខ ។

សែ ៖ ពួកនឹងវង៦៣នឹងម៉ង ។

បូលី ៖ វង ៦៣?

ភាព ៖ បាទ! ៦៣ដើរចេញមកដុតអស់ ។

បូលី ៖ ប៉ុន៦៣ ដកចេញមក បានកម្លាំងណាទៀត អស់កម្លាំងហើយ ដកចេញហើយ?

ភាព ៖ គេយកកម្លាំងមកបន្ថែមបគ្រប់ ។

បូលី ៖ បន្ថែមបញ្ចូលក្នុង៣នេះ?

ភាព ៖ ចា៎!

បូលី ៖ ចឹង វ៉ាន់ កុសល នេះ ពីណាអ្នក?

ភាព ៖ អាចឡើងៗកងពល ។

បូលី ៖ វរៈ?

ភាព ៖ វរសេនាធំ ។

បូលី ៖ វរសេនាធំ៦៣ តាមមើល?

ភាព ៖ ចា៎!

សែ ៖ ៦៣ ប៉ុនគាត់ឡើងកងពលក្រោយមក នៅ ហឿន ម្នាក់ឯង កាលនឹង ។

បូលី ៖ តា ហឿន ក្រែងមាន តា សន់, តា មឿន?

ភាព ៖ តា សន់ ជាមួយ នេះ បង កុសល នៅវរសេនាធំទេ ផ្លាស់មកនៅជាមួយខ្ញុំនេះ ក៏វរៈ សេនាធំដែរ ។

សែ ៖ ប៉ុននៅដោយឡែកកាលនឹងជាមួយ តា ផាត ។

ភាព ៖ បង កុសល ផ្លាស់មកនៅនេះមួយរយៈដែរនឹង ។

បូលី ៖ នៅណា?

ភាព ៖ នៅនឹង ។

បូលី ៖ ៦១៧ដែរ?

ភាព ៖ ចា៎!

សែ ៖ ប៉ុនមិនទាន់ភ្ជាប់អង្គភាពទេ ។

ភាព ៖ មិនទាន់ភ្ជាប់ជាអង្គភាពទេ ដល់សមាហរណកម្មរួច គាត់វិលទៅវិញ ។

បូលី ៖ ប៉ុនគាត់ជាអី?

ភាព ៖ វរសេនាធំ ។

បូលី ៖ លេខប៉ុន្មាន?

ភាព ៖ តែអត់ដឹងលេខប៉ុន្មានទេកាលនឹង ។

បូលី ៖ អត់ដឹងទេ?

សែ ៖ គេផ្លាស់ប្ដូរដាច់អាជីពមក វាអត់ដឹងការរៀបចំរបស់គេ រចនាសម្ព័ន្ធវាប្រែប្រួល វាអត់ច្បាស់ទេ ប៉ុនទៅត្រពាំងប្រាសាទ គាត់ច្បាស់ ។

ភាព ៖ តា ឆុន ផ្សេង បង កុសល ផ្សេង ។

សែ ៖ វា តា ឆន់ នៅជាមួយ កុសល ។

បូលី ៖ ៦៣នេះ បែកចេញជា៣វរសេនាតូចដែរ?

សែ ៖ បាទ!

បូលី ៖ មានប៉ុន្មានខ្លះ៦៣?

សែ ៖ ៦៣ក្រោយនេះ?

បូលី ៖ ៦៣ កាលនៅ៦១៧?

សែ ៖ វាមាន៧ជំនាន់ មើលកាលខ្ញុំនៅ៦៣នឹងវាមានវរសេនាតូចខ្ញុំ៣១០ ៣០៧ ។

ភាព ៖ ដូចអំពិលអំពែង ម្ដងចេញម្ដងចូល កាលផ្លាស់ប្ដូរយើងគ្រប់គ្រងអត់បានច្បាស់ទេ យើងរយៈពេលខ្លីៗទៀត តែទៅហើយអត់ដែលបានទៅជុំគ្នាណា ទៅសមរភូមិផ្សេងទៀត ។

បូលី ៖ ដើរចល័តចុះចល័តឡើង?

ភាព ៖ ចា៎! វរសេនាធំមួយគេទៅនៅផ្សេងទៅៗ អត់ស្គាល់គ្នាទៀត ដល់ចឹងពិបាកភ្ជាប់ប្រវត្តិនិយាយរួមយើងវាភ្ជាប់អត់បានអស់ម៉ង ។

បូលី ៖ ឥឡូវសុំតែលេខបានហើយ វរសេនាធំ៦៣មាន៣វរសេនាតូចមានប៉ុន្មានខ្លះ?

សែ ៖ លេខ មើល យិន នៅ ។

ភាព ៖ ៦១ ។

សែ ៖ ៦១ទេ កាលនឹង ។

ភាព ៖ ៦១ ៦២ អ៊ុម ។

បូលី ៖ យិន ប្រធាន៦១?

សែ ៖ អឺ!

បូលី ៖ ពីណាគេអនុរបស់ យិន?

សែ ៖ មិនដឹងណាៗទេ ក្រោយមក ផ្លាស់ប្តូរគ្នា ។

បូលី ៖ ចុះ៦២ ពីណាគេខ្លះ?

សែ ៖ ៦២ មាន តា អ៊ុម មាន តា សន់ ដែរនឹង ។

បូលី ៖ តា សន់ ដែរ?

សែ ៖ បាទ!

ភាព ៖ តា តឹក ។

សែ ៖ អា តឹក នេះនៅវរៈ ទេកាលនឹង ដំណាលខ្ញុំដែរនឹង ។

ភាព ៖ តានេះទៀត ចេញពី៨២ដែរ តាអី ភ្លេចឈ្មោះបាត់ ។

បូលី ៖ តា តឹក នឹង អនុ៨២?

សែ ៖ អត់ទេ តឹក នឹងវាក្រោយទេ ដំណាលខ្ញុំដែរនឹងកាលនៅប្រធានវរសេនាតូចដូចគ្នា ។

ភាព ៖ ភ្លេចគ្នាអស់ ថាចាំឈ្មោះជួបមុខក៏មិនស្គាល់ នៅតែខ្លួនមួយឥឡូវ ។

សែ ៖ ៦៣ អាផលវរៈ១ អាឃុត វរៈ២ អូ! អាអឿនៗវរៈ២ ។ ៣០២ អឿន ។

បូលី ៖ អឿន ៣០២?

សែ ៖ មើល ឈប់ៗ អាអឿន ៣០១ អាឃុត៣០២ ។

ភាព ៖ អឿនៗនឹង ស្លាប់ទេ ។

សែ ៖ អឿន ស្លាប់ សំអឿន ចូលជំរំ ។

បូលី ៖ សំអឿន?

សែ ៖ បាទ!

ភាព ៖ ខ្មោច តា ម៉ុន, ខ្មោច តា មាំុង អី ។

សែ ៖ ហ្នឹងហើយ អា ម៉ុន, អា ផល អីនឹង សុទ្ធតែនៅក្រោមអា ឃុត ។

បូលី ៖ ៣០២ មាន ឃុត ជាប្រធាន?

សែ ៖ បាទ!

ភាព ៖ មាន យុត មាន តា ម៉ុន ។

បូលី ៖ អីគេ ម៉ុន?

ភាព ៖ មុន មួយទៀត ម៉ុន នឹង ម៉ុន មាឌធំ ម៉ុន វរសេនាធំ ម៉ុន រៀងស្ដើង ។

សែ ៖ អានឹងកម្លាំង តា គង់ ហើយ ។

បូលី ៖ ម៉ុន មាឌធំ ហើយនឹងអីមួយទៀត?

សែ ៖ អាផល ។ អានឹងខ្ញុំនៅវរសេនាតូច៣១០ ៣០២ ៣០១ អានឹងមួយវរសេនាធំ៦៣ អានឹងដើមកំណើតវា ។

បូលី ៖ ហើយពូនៅ៣១០?

សែ ៖ ៣១០ ។

បូលី ៖ ពីណាគេកាន់៣១០ ពូ?

សែ ៖ បាទ! ប្រធាន ចន្ថា, អា រ៉ាន់ ។ បាន អឿន ហើយនឹងវាបាត់តែ អឿន សាខារបស់ អឿន ២នាក់ទៀត វាបាត់ឈ្មោះ ។

បូលី ៖ ចឹងអ្នកទាំងអស់នឹងទៅ៩១២ទាំងអស់?

សែ ៖ ទៅ៩១២ ទៅតែខ្ញុំទេ ។

បូលី ៖ ទៅតែពូ?

សែ ៖ ហ្នឹងមក៩១២ តែមួយវរៈខ្ញុំទេ ដែលពេញជាងគេ ។

បូលី ៖ មិនមែន៦៣ទាំងមូលទេ?

សែ ៖ ៦៣មកទាំងមូលនឹង ប៉ុន្តែវាបំបែកគ្នា ។

ភាព ៖ ៦០៣ក៏មក កង តា ឆាន់ មក វរសេនាធំផ្សេង ។

សែ ៖ ហ្នឹងហើយបែកគ្នាទៅ៥៣ ទៅនៅ៥៣ខ្លះ វរសេនាធំផ្សេង ។

ភាព ៖ មួយវរសេនាតូច យើងបែកគ្នាចូលទៅនៅវរសេនាធំមួយមិនចឹង ។

បូលី ៖ ៦១២នេះ ឈរជើងនៅម្ដុំណាខ្លះ?

សែ ៖ ៦១២ អាវគ្គទី២ អាវគ្គទី១ វាមាន៣-៤វគ្គរបស់វា ។

បូលី ៖ យ៉ាងម៉េចខ្ញុំអត់យល់?

សែ ៖ ប្ដូរសមរភូមិ ។

បូលី ៖ ចឹងវគ្គទី១នៅសមរភូមិណា?

សែ ៖ សមរភូមិស្រុកជាំក្សាន្ដ ។

ភាព ៖ កន្លែងកកើតដំបូង ។

បូលី ៖ ហ្នឹងកន្លែងកកើតកងពលដំបូង?

ភាព ៖ ចា៎!

បូលី ៖ ដល់ពេលវគ្គទី២?

ភាព ៖ វគ្គទី២មក វានៅនេះ ពីព្រះប្រឡាយមក៤០នេះ ។

បូលី ៖ ស្អីគេ៤០?

សែ ៖ ៤០កន្លែងជំរុំយើង ប៉ុនមកវាទល់គ្នាអូរស្វាយនេះ ។

ភាព ៖ ដាក់អូរស្វាយទៅ ៤០អត់យល់ ។

បូលី ៖ ៤០នឹង គេហៅជំរុំអូរស្វាយ?

ភាព ៖ វា៤០នៅពីលើ ។

សែ ៖ អូរស្វាយវានៅពីខាងក្រោម ៤០នៅពីលើចឹង ជំរំភ្នំដែន ។

ភាព ៖ វានៅលើចឹង ប៉ុនយើងមើលមកពីលើ ឃើញវាលល្វល្វេវ បានធ្លាក់មកដីខ្មែរយើង ។

សែ ៖ ជំរុំគេមានលេខ មុំ៣នេះគេ១០០១, មកដល់ជិតព្រះវិហារនេះគេ១០០៣ ខាងលិចព្រះវិហារនេះ ១០០៣ហើយបានឆ្លងមក៨០៨នេះ អានឹងជំរុំគេធំៗ ។

បូលី ៖ មាន៣នឹង?

សែ ៖ បាទ! ៣នឹង ។

បូលី ៖ ១០០២?

សែ ៖ ១០០២ដែរ ។

បូលី ៖ ១០០២ម្តុំណាវិញ?

សែ ៖ ១០០២ នៅប៉ោយព្រេច ដាំក្បាន្តនឹង ។ ១០០១មុំ៣ ។

ភាព ៖ ១០០២នៅកន្លែងដាំក្បាន្តហ្នឹងឯង កន្លែងកងពល៦១២កើតដំបូងនឹងឯង គេហៅចំការដំឡូងៗ ។

បូលី ៖ ១០០១នៅទន្លេល្ពៅ?

ភាព ៖ ចា៎!

បូលី ៖ ១០០២នៅដាំក្បាន្ត?

ភាព ៖ ដាំក្បាន្តគេហៅកន្លែងទីតាំងនឹង កន្លែងចំការដំឡូង ឃ្លាំងក្រោយនោះចំការដំឡូង ។

បូលី ៖ ហើយទៅ១០០៣?

សែ ៖ ១០០៣ចាប់ពីប្រាសាទព្រះវិហារមកនែក! នៅទន្លេ តា ងិន នេះ ។

បូលី ៖ ត្រពាំងប្រាសាទ?

សែ ៖ ឈប់១០០៣ ហ្នឹងហើយដាន់ត្រពាំងប្រាសាទ ក្បាលអូរល្ហុង១ ។

ភាព ៖ ក្បាលអូរល្ហុង កន្លែងគេហៅ៥០ ។

បូលី ៖ អត់ឡូយមកដល់យើងអន្ទង់វែងនេះទេចឹង?

សែ ៖ អត់ដល់ ។

ភាព ៖ អត់ទេ អានេះអន្ទង់វែង គេហៅ៨០៨វិញ ។

បូលី ៖ ចឹងពីប្រាសាទព្រះវិហារមកដល់?

ភាព ៖ ព្រះប្រឡាយ ក្បាលអូរល្ហុង ។

បូលី ៖ ក្បាលអូរល្ហុង ជាភូមិជាអី?

សែ ៖ អត់ទេ មិនមែនភូមិគេកាលនឹង ។

ភាព ៖ អានឹងអូរចាស់ ។

បូលី ៖ ព្រះប្រឡាយ?

សែ ៖ បាទ! នៅភូមិព្រះប្រឡាយអី វាមកឃុំអូរល្ហុងហើយ ជិតត្រពាំងប្រាសាទនឹង ។

បូលី ៖ ចឹងដាក់មកដល់ទីរួមស្រុកត្រពាំងប្រាសាទចឹងម៉ង អាចទេ តាមមើល?

សែ ៖ ហ្នឹងហើយដាក់ទីរួមស្រុកត្រពាំងប្រាសាទ ។

បូលី ៖ ក្បាលអូរល្ហុងឃុំ?

សែ ៖ បាទ! ឃុំអូរល្ហុង ។

បូលី ៖ តែបច្ចុប្បន្នអត់មានទេ ឃុំក្បាលអូរល្ហុង?

ភាព ៖ អត់ទេហៅតែពីមុនៗយើងហៅឃុំព្រះប្រឡាយ ជប់រ៉ុន ព្រះប្រឡាយ ។ អាក្បាលអូរល្ហុង គេហៅទួលឯលើផ្លូវកន្លែង៥០ ចំការម្ទេស ។

បូលី ៖ ស្អីគេ៥០ ស្អីគេ៨០?

ភាព ៖ គេចង់និយាយ គេនិយមហៅភាសាចឹង វាល៨០ វាល៥០ៗនឹងកន្លែងវាលសេរីកានៅពួក ប៉ាវ៉ាន់នៅ ។

សែ ៖ អ៊ូ! កុមារអូអី សុទ្ធយើងដាក់ឈ្មោះទេ ។ ប៉ុនអូរល្ហុងនេះ វាឈ្មោះអូរល្ហុង ពិត ។

ភាព ៖ អូរល្ហុងនឹង គេហៅអូរល្ហុង១នឹងឯង កន្លែង១០០៣ ។

បូលី ៖ ចុះ៨០៨?

ភាព ៖ ៨០៨នេះ ។

សែ ៖ អានឹងវាចំត្រពាំងតាវនេះ ។

បូលី ៖ ចេញពីត្រពាំងប្រាសាទមកចាក់មកខាងនេះ រហូតដល់ខាងអន្លង់វែងយើង?

សែ ៖ នេះ៨០៨ ចំណុចវា ។

ភាព ៖ ៨០៨នៅលើឃុំត្រពាំងតាវរាល់ថ្ងៃនេះ៨០៨ ។

សែ ៖ ហើយអានេះ ដាំកន្ទែង តា ពត នៅ ។

បូលី ៖ តា ពក?

សែ ៖ តា ពត ។

ភាព ៖ ប៉ុល ពត ។

បូលី ៖ ប៉ុល ពត?

ភាព ៖ ចា៎!

បូលី ៖ ប៉ុន្តែអន្លង់វែងនេះ គឺវៀតណាមកាន់កាប់ មុន៩០?

ភាព ៖ បាទ! ត្រូវហើយ ។

បូលី ៖ បើយើងនិយាយនេះ គឺយើងនិយាយ១០០១ ១០០២ ១០០៣នេះ គឺយើងនិយាយ មុនឆ្នាំ៩០ ពេលយើងវៃបានអន្លង់វែងមិនចឹង?

ភាព ៖ ចា៎!

បូលី ៖ ដល់ពេលយើងបានអន្លង់វែង វាលែងមាន១០០១,១០០៣ទៀតហើយ?

សែ ៖ ចុះមកបាត់ហើយ ។

បូលី ៖ ព្រោះយើងចុះមកក្រោម?

ភាព ៖ ចុះមកក្រោមហើយ ។

បូលី ៖ ១០០១យើងលែងនៅពេលនឹង?

សែ ៖ លែងហើយអស់ហើយ ។

បូលី ៖ ១០០៣នៅទៀតទេ?

សែ ៖ តាំងពីអ៊ុនតាក់មក គឺចុះមកអស់ហើយ ។

បូលី ៖ ១០០៣លែងមាន?

ភាព ៖ លែងមានហើយយើងចុះមកឆ្នាំ៩០នឹង ។

បូលី ៖ ចឹង៨០៨នឹងពីណាដល់ណាទៅបើយើងគិតមើលដែនទី?

សែ ៖ ដែនទីចាប់ពីយើងនេះទៅ ពីដើងភ្នំនេះទៅ ច្រកផ្លូវ ។

បូលី ៖ ជាំស្រងាំ?

សែ ៖ បាទ! ជាំស្រងាំនេះ ទៅទល់គ្នាប្រាច់ តាទុំនោះ ។

បូលី ៖ អីគេតាទុំ?

សែ ៖ ភូមិៗយើងតើពីមុន ។

បូលី ៖ ឃុំអីគេ?

ភាព ៖ ឃុំនែក! ភ្លេចបាត់ ។

បូលី ៖ ព្រះប្រឡាយ?

សែ ៖ ត្រពាំងតាវ ។

បូលី ៖ ត្រពាំងតាវ?

សែ ៖ បាទ!

ភាព ៖ អត់ទេ តាទុំមិនមែនត្រពាំងតាវទេ នៅឃុំកូនគ្រាល ។

បូលី ៖ ស្រុកអីគេ?

ភាព ៖ ស្រុកសំរោង ។

បូលី ៖ ខេត្តឧត្តរមានជ័យ?

ភាព ៖ ចាំ! អានឹងយើងហួស ឆ្លងស្ពានធំហួសអក្សរគេទៅនោះហើយ តាទុំ ។

បូលី ៖ ឲ្យវាច្បាស់ចឹងម៉ង វាសសៀវតាមព្រំដែនរហូតនិយាយទៅ ។ គេថាមាន៨០០ទៀត?

សែ ៖ អត់មានទេ ៨០០អន្លកភាព ។

បូលី ៖ កងពល?

សែ ៖ កងពល តា ជិន ពួកជនជាតិនេះ ។

បូលី ៖ ឥឡូវយើងចូលមកវគ្គវិញ ៦១២នេះ វគ្គទី១នៅជាំក្សាន្តសមរភូមិ?

ភាព ៖ បាទ!

បូលី ៖ កន្លែងដែលកកើតដំបូងមក?

ភាព ៖ បាទ!

បូលី ៖ កន្លែងដែលកកើតដំបូងមក ។ ហើយវគ្គទី២សមរភូមិនៅត្រង់ណា៦១២?

ភាព ៖ មកយើងព្រះប្រឡាយ ។

បូលី ៖ វគ្គទី៣?

ភាព ៖ ទី៣ទៅផ្ទះវិញ ។

សែ ៖ ទៅម្តុំនឹងវិញ ទៅនៅស្រុករាល់ថ្ងៃនឹង ។

បូលី ៖ វគ្គទី៣នៅក្នុងសម័យមុន៩៣ យ៉ាងម៉េច?

ភាព ៖ នែក! វគ្គទី៣នេះវានៅក្នុងមុន៩៣ ។

បូលី ៖ នៅណាវិញ?

ភាព ៖ ពីត្រឹមមើលខ្ញុំមកនឹងត្រឹម និយាយរួមចេញពីនឹងទៅឆ្នាំ៨៧ ។

សែ ៖ វគ្គទី២គេនៅលើទេ ពួកនឹងអត់ទាន់បានចុះទេ ។

បូលី ៖ បាទ! វគ្គទី២នៅលើទេ ។

សែ ៖ មិនទាន់បានចុះ អាវគ្គទី៣មកដល់នេះហើយ ចុះមកព្រះប្រឡាយនេះ ។

ភាព ៖ មកធ្វើនៅព្រះប្រឡាយ កាលមុននៅគេហៅដាំស្វា១ នៅចំការម្ទេស ។

បូលី ៖ វគ្គទី២អានឹង?

សែ ៖ បាទ! ទី២នៅជិតព្រះវិហារនោះ នៅជិតប្រាសាទព្រះវិហារ ។

បូលី ៖ ក្រែងថានៅព្រះប្រឡាយ?

ភាព ៖ ព្រះប្រឡាយ ចុះមកទី៣ហើយ ចុះមកនៅ៩១ ។

សែ ៖ យកឈ្មោះ ស្រុកទេសយើងដាក់ ។

បូលី ៖ ចឹងវគ្គទី៣ទេ សមរភូមិនៅព្រះប្រឡាយ ។ វគ្គទី២នៅខាងណាវិញ?

ភាព ៖ នៅអីជិតព្រះវិហារនោះជិតប្រាសាទ ឆ្លងពីកើតមក នៅស្នាក់មិនទាន់មានជំរុំរឹងប៉ឹងទេពួកនោះធ្វើការតាមព្រំដែននឹងពីមុន ។

បូលី ៖ ដាំ១ស្វា?

ភាព ៖ ចា៎! ប្រកដាំស្វា ជប់រ៉ុន នឹងឯង ចុះដាំស្វាមក១ជប់រ៉ុន ។

បូលី ៖ ខាងជប់រ៉ុន នឹង?

ភាព ៖ ចា៎! តែយើងនៅដីថៃគេហៅដាំស្វា ។

សែ ៖ អានឹង ឆងព្រះប្រឡាយ យើងហៅប្រកព្រះប្រឡាយ ព្រោះអូរនឹងអូរព្រះប្រឡាយ ។

ភាព ៖ កាត់អូរទឹកខៀវអានឹងនោះ ។

បូលី ៖ វគ្គទី៣បាន១មកខាងចុះមកភូមិព្រះប្រឡាយហើយ?

ភាព ៖ ចា៎!

បូលី ៖ យើងមករៀបចំឃុំភូមិនៅព្រះប្រឡាយនេះ?

ភាព ៖ ចាំ!

បូលី ៖ ត្រពាំងប្រាសាទ?

ភាព ៖ ៩១ ។

សែ ៖ អូ! អាភូមិអូរល្ហុងនឹង គេដាក់នៅឃុំបែកអន្លង់សព្វថ្ងៃ ។

ភាព ៖ និយាយរួមយើងចុះតាំងពីរៀបចំភូមិដ្ឋានតាំងពី៩០ ប៉ុនដល់ប្រជាពលរដ្ឋមកនៅ៩១ ។

បូលី ៖ អន្លង់វែងយើងក៏ចឹងដែរ វ៉ៃបាន៩០ ខែ១២ ឆ្នាំ៨៩ ហើយ៩០បានៗ?

សែ ៖ ៩១ ។

បូលី ៖ ៩១?

ភាព ៖ ៩១ បានចុះមកអស់ ៩០នឹងគ្រាន់អ្នកចុះមកធ្វើស្រែ ធ្វើផ្ទះធ្វើអីសិនទេ ធ្វើទ្រូសៗព្រោះ កន្លែងមូលដ្ឋានសម្រាប់ប្រពន្ធកូនសិន ។ ប្រពន្ធកូនចុះមក ចុង៩០គត់ ។

បូលី ៖ ពីណាគេប្រធានមន្ទីរតំបន់៦១២?

សែ ៖ ៦១២?

បូលី ៖ ប្រធានមន្ទីរកងពល?

ភាព ៖ ៦១២ កងពលមានតែ តា ហឿន កាន់កាប់ដដែលនឹងគ្មានអ្នកណាគេកាន់កាប់ ។

បូលី ៖ ប៉ុនប្រធានមន្ទីរចង់និយាយថា លេខា?

ភាព ៖ អូ! កន្លែងមន្ទីរកងពល អត់ ។

សែ ៖ អត់មានទេ ។

បូលី ៖ អត់មាននេះ?

ភាព ៖ មានដែរ ប៉ុនយើងអត់ដឹង ។

បូលី ៖ លោកមេឃុំនេះ បងមួយគាត់ប្រាប់ថា គាត់ប្រធានមន្ទីរកងពល?

ភាព ៖ មេឃុំលំទងនេះ?

បូលី ៖ បាទ!

សែ ៖ អត់ទេ នៅជាមួយខ្ញុំនឹង ។

ភាព ៖ ប្រធានគាត់ក្រោយពីគាត់ពិការ គាត់មកប្រធានកងពល៩១២នេះ នៅជាមួយ តា គង់ ។

សែ ៖ ប៉ុនពីមុននៅកង ឃុត ។

ភាព ៖ ចាំ! ពីមុននៅកង៩៣ ។

សែ ៖ អាសំអឿន ។

ភាព ៖ នៅជាមួយពូសំអឿន ។

បូលី ៖ ៥៣ជាមួយ ឆាន់, យុត?

សែ ៖ ហ្នឹងហើយ ឆាន់, អឿន ទេ ឆាន់ ទៅបាត់ហើយ នៅសំអឿន ។

បូលី ៖ ឆាន់ ទៅណា?

ភាព ៖ ឆាន់ ទៅ លាច ជាមួយពូ យុត ។

បូលី ៖ ក្រោយ ឆាន់ និង យុត ទៅបាត់?

សែ ៖ អឺ!

បូលី ៖ សំអឿន ឡើងជាប្រធាន?

ភាព ៖ ឆាន់ កងផ្សេង តា យុត កងផ្សេង វរៈផ្សេងៗគ្នា ។

បូលី ៖ មិនមែន យុត របស់ ឆាន់?

សែ ៖ អឺ! ឆាន់ គេវរសេនាធំ ។

ភាព ៖ យុត វរសេនាតូច ។

សែ ៖ ប៉ុន យុត ហើយនែក! សំអឿន នេះវានៅសាខាជាមួយពួកខ្ញុំទេ ពួក៦៣នេះ ។

បូលី ៖ ចឹងពេល ឆាន់ ទៅបាត់ សំអឿន ឡើងជាប្រធាន?

សែ ៖ អឿន ក៏ទៅដែរ ប៉ុនចូលនិវត្តន៍ អឿន ទៅនៅអូរគ្រាវ បាត់រូបបាត់រៀងគ្នាទៅបាត់ម៉ង ។

បូលី ៖ ចុះលោកមេឃុំនៅណា ៥២ដែរ?

ភាព ៖ នៅ៥៣ ជាមួយពូ សំអឿននឹងឯង ។

បូលី ៖ មានតំណែងជាអី?

ភាព ៖ អនុសេនាធំហើយកាលនឹង ពូ សំអឿន គាត់ឡើង ។

បូលី ៖ ៥៣ មានវរសេនាតូចអីខ្លះ?

សែ ៖ ៥៣ ។

ភាព ៖ កាលនឹងមិនដឹងឡើងសមាជិកវរសេនាតូចមិនដឹង កាលត្រូវរបួសនោះ ។

សែ ៖ អត់ទេ យើងមកដុតហើយ ។

ភាព ៖ វាចេញដុត ចេញមុនគេចឹងអត់ដឹង ។

បូលី ៖ ចេញមុនគេ អត់ដឹង?

ភាព ៖ ចា៎! ព្រោះពួកនឹងវាចេញមកពីនោះដំណាលគ្នាដែរ ប៉ុនយើងចែកមុខព្រួញខុសគ្នាៗ ពេលផ្លាស់ទៅនៅលិចនោះ ខ្ញុំចេញដំណើរមុន កងវរសេនាធំគេចេញក្រោយខ្ញុំទៀត វាចឹងវាមិនទៅទាំងស្រុងទេ ។

សែ ៖ ប៉ុននេះវាដែលភ្ជាប់មកជាមួយគ្នានេះ បានដឹងខ្ញុំនៅក្នុង គេនេះនៅធ្វើការនៅព្រំដែន ជាប់មួយវរសេនាតូចនឹង ។ ដល់ចឹងហើយមេឃុំនេះរបួស ប៉ុនខ្ញុំវាមិនដឹងថានេះអីនៅក្នុងកងពលវរសេនាធំដែរ ។

ភាព ៖ នេះ នៅខាងភូមិត្រពាំង ខាងនោះផ្សារចាស់នេះ គាត់ចុះមកធ្វើការនៅនឹង របួសនៅនឹង ។

សែ ៖ ពួកនេះគេនៅព្រំដែន ខ្ញុំដំណាក់ចុងបំផុត ចុះស្រួចមុនគេ វាចឹងឯង ។

ភាព ៖ របួសខែប៉ុន្មានទេ កាលនោះ ខ្ញុំភ្លេចខែគាត់របួស ។

សែ ៖ បើ៩២០ ចូលក្នុងដំបូងៗគេទៅនៅជាមួយ៩២០ដែរ ជាមួយពួក តា សាន ។

បូលី ៖ ៩២០ តា សាន គាត់មេ អនុ តា សាន មានទេ ពូអាចដឹង?

ភាព ៖ ដល់ទៅជួបជាមួយលោក ជិន សាវង្ស អភិបាលក្រុមប្រឹក្សាស្រុកអន្លង់វែងនេះដឹងហើយ ។

បូលី ៖ ជិន សាវង្ស?

សែ ៖ ចា៎! គាត់នៅនឹង ផ្ទះគាត់ទល់មុខនេះកន្លែងផ្ទះសំណាក់១៣តុលា ។

បូលី ៖ ហ្នឹងគាត់នៅផ្ទាល់នឹងម៉ង?

ភាព ៖ នៅ៩២០ កាលមុន៨០១ដែរ គាត់ផ្លាស់ទៅ៩២០ ជាមួយ បង សាន ។

សែ ៖ តាំងពីបដិវត្តន៍ប្រជាជាតិមក នៅជាមួយខ្ញុំ នៅគោរពបងៗខ្ញុំរហូតនឹង ដូចតាប្រធានស្រុកចឹង នៅតែហៅខ្ញុំបងដដែល ។

បូលី ៖ យឹម ដាន់ណា?

សែ ៖ បាទ!

បូលី ៖ ជិន សាវង្ស កាលនៅនឹង គាត់មានតំណែងជាអី?

សែ ៖ ប្រហែលជាកងពល នៅ៩២០ ។

បូលី ៖ គាត់នៅជាមួយ តា សាន តាំងពីមណ្ឌលគិរីនោះនឹង?

សែ ៖ បាទ! ជាមួយ អា ឆិល នេះ យកចេញពី៨០១ យកចេញពី៨១ទៅនឹង ។

ភាព ៖ បង សាន ទៅយកកម្លាំងទៅម៉ាគគោក ។

សែ ៖ យកតែកងនឹងទៅច្រើនៗ ប៉ុនបាត់ខ្លះជួបមុខ នួន, នឿន, នៅតែ អានួន អានឿន អត់ទេស្លាប់ ។

បូលី : ចង់ដឹង៩២០ ទៅជួបគាត់ ជិន សាវង្សនឹង?

សែ : បាទ! ខេមរា នេះ សុទ្ធ៩២០ ។

ភាព : គាត់គល់ឫស ទល់ដល់យើង៩០ ។

សែ : អត់មានបែកចល័តដូចខ្ញុំទេ ។ ខ្ញុំបាន តា គាត់រុញច្រើនជាងគេ ទទួកអ្នករងគ្រោះរហូត ។

ភាព : តា ប្រើអ្នកណាបាន ប្រើតែអានឹង ។

បូលី : ពូដែលដឹងរឿងរ៉ាវខ្លះៗពីកងពល៦១៦?

សែ : មិនសូវបានចុះជាប់ទេ ។

ភាព : កង តា ញ៉ិន អត់សូវនៅជាប់គ្នា ចង់ដឹងសួរ តា ជិន ។

បូលី : ជិន ណាចេះ?

ភាព : ជិន នៅកងពលសព្វថ្ងៃ គេនៅទាហាននោះ ។

បូលី : គាត់ឈ្មោះអី ជិន?

ភាព : ជិន ព្រោះអី ជិន ។

បូលី : ឥឡូវគាត់នៅណា?

សែ : នៅចុះនៅកងពលណា មិនសូវដឹង ខ្ញុំ១៦នឹងឆ្ងាយជាងគេបំផុត ។

បូលី : ឆ្ងាយ?

ភាព : បាទ! គ្រាន់ស្គាល់តាមមេៗ តាមរយៈទេតាំងពី អា ហ៊ិន អីនេះ អា ហ៊ិន នឹងកងពលដែរ តាញ៉ិន នេះ កងពលប្រធាន ។

ភាព : ១៦ ស្គាល់តិចណាស់ ព្រោះ១៦នៅជាមួយ កង តា វ៉ិន កូនប្រសារ តា ម៉ុក ច្រក ១០០៣នោះ ។

សែ : ប្រវត្តិកង អា ស៊ូ ពីដើម ។

បូលី : មីង ស្គាល់ តា ពេជ្រជាង?

ភាព : ស្គាល់ តើ ។

បូលី : គាត់ស្លាប់បាត់ហើយ?

ភាព : ស្លាប់បាត់ហើយ នៅតែប្រពន្ធ នៅតែ មឿន ។

បូលី : ប្រពន្ធរាល់ថ្ងៃធ្វើអី?

ភាព : ទេ! បង មឿន គាត់មានធ្វើអី មិនដឹងគាត់ធ្វើការងារអី ប៉ុនជួនគាត់មួងម្កាលដែរ ។

បូលី : គាត់នៅណា គាត់នៅផ្ទះកន្លែងលក់សាំងនឹងមែន?

ភាព ៖ ឥឡូវមិនដឹងនៅផ្ទះចាស់ មិនដឹងនៅកន្លែងលក់សាំងមុខ អត់ដឹងដែរ ។

សែ ៖ នៅផ្ទះចាស់ ។

ភាព ៖ ផ្ទះចាស់ដល់គេលើកផ្ទះធំៗចឹងរកផ្ទះ មឿន លែងឃើញហើយ ។

បូលី ៖ ព្រសួរថាគាត់នៅហាង មហាហេង?

ភាព ៖ មិនដឹងម៉េចអី ។

បូលី ៖ បើសិនជាទៅសួរកន្លែងហាងគាត់អាចដឹងទេ?

ភាព ៖ បើគាត់ធូរធារដែរ គាត់មាននេះអី គាត់អ្នកធូរធារដីផ្សាររាល់ថ្ងៃនេះ ដីគេដូរយាយ មឿន ធ្វើផ្សារតើ ។ ប៉ុនដឹងថាគាត់អាចលក់ប៉ុន្មាន ដូលប៉ុន្មានអីមិនដឹងទេ ប៉ុនថាដីបូងគេដូលដីគាត់ នឹងហើយ ។

សែ ៖ យាយនឹង ចិន ច្រើនជាងខ្មែរ ។

បូលី ៖ ចុះបើគាត់ទៅនេះ គាត់ទៅទូតនៅចិនរហូតតាំងពី៧៥មក?

ភាព ៖ ប៉ុនបើ តា ពេជ្រ ដាង សម្របណាស់ មិនងាយអ្នកណាដឹងប្រវត្តិគាត់ក្លាយជាមនុស្សអ្នកមានៗ មកនៅនឹងកន្លែង៩៩ថ្មី សាលាស្រុកអន្លង់វែងថ្មី សុខចិត្តធ្វើកូនខ្ទមតូចនៅតែឯង សុខចិត្តពេលចូលដាក់ជើងចូលទៅមុននោះ នៅតូចសម្រាប់ម៉ាខ្លួនទេ អត់មានចង់រកកន្លែងស្អឹមស្អែអីដូចអត់ទេ ។

សែ ៖ ដូចទៅទូតកូរ៉េ ដឹង?

បូលី ៖ ទូតចិន ។

ភាព ៖ គាត់លះបង់ គាត់សម្របៗយកហួស ។

បូលី ៖ គាត់នៅជាមួយ កែ ពក នៅឧត្តរ គាត់សមាជិកភូមិភាគ គាត់ខាងបញ្ញាជន ហើយឆ្នាំ៧៥ គេបញ្ជូនគាត់ទៅទូតនៅចិន រហូតដល់៨៦បានមកវិញ កាន់កងពល៤១៧យើង តា ពកៗ គាត់លាពីកងពលចឹង គាត់នៅតែមានឥទ្ធិពលចឹង ។

សែ ៖ មានឥទ្ធិពល ប៉ុនយក តា ជុំ ទៅធ្វើជាប្រធាន ។

បូលី ៖ យក ជុំ ជាតិ វិញ?

សែ ៖ ហ្នឹងហើយ ៤១៧ ។

បូលី ៖ មិនមែន ពេជ្រ ដាង ទេប្រធាន?

សែ ៖ អត់ទេ! តា ជុំ ខាងយោធា ។

បូលី ៖ តា ពេជ្រ ដាង ខាងអី ខាងនយោបាយ?

សែ :	ច្រើននយោបាយទេ គាត់ដើរជាក្រុមៗគាត់មិននៅស្ថិតស្ថេរនៅអន្តភាពប្រយុទ្ធទេ ជាអ្នកនយោបាយ ។

បូលី :	បើសិនជាសុំជួបគាត់ៗយ៉ាងម៉េចដែរ យាយ មឿន អាចគិតរឹង អាពិបាកតាមមើលមើល?

សែ :	រៀងពិបាកដែរ ខ្ញុំមើល ។

ភាព :	ខ្ញុំមិនហ៊ានថាទេ យាយ មឿន ចិត្តខុសជាមួយ បង ពេជ្រ ដាង ចិត្តខុសគ្នា មិនដែលដឹងជម្រៅចិត្តគាត់ទេ ពីមុនមានអី ថាកាលបង ពេជ្រ ដាង នៅ ខ្ញុំទៅចេញចូលម៉េច រាក់ទាក់តែឥឡូវបើយើងសួរគាត់មុន គាត់និយាយរៀងហាក់បីដូចអត់ស្គាល់យើង បានថាខ្វាចគាត់រើសអើងដែរនឹង គាត់រៀងថាដូចស្គាល់យើងស្រពេចស្រពិល ។

បូលី :	ពីព្រោះជាទូទៅកាលណាខ្ញុំចូលទៅ មិនចង់ឲ្យមានរង្គោសចិត្តពីដំបូងទី តែរង្គោសពីដំបូងទីចប់ហើយ ធ្វើអីលែងចេញហើយ ឲ្យដំបូងល្អតែម្តង ។ ចឹងដូចខ្ញុំមកជួបមីងពូចឹង ថាមកដល់ពូមីងយល់ម៉ង តែពេលយល់សាច់រឿងស្រួលនិយាយគ្នា បើមិនចឹងទេសួរមួយម៉ាត់ឆ្លើយម៉ាត់ចឹងអស់អីសួរបណ្តោយ ។

សែ :	គេមិនចង់ឲ្យយើងក្តាប់ជីវប្រវត្តិ ។

ភាព :	ខ្លះគេលាក់ជីវប្រវត្តិ គេមិនៗ ខ្ញុំខ្ជិលណាស់ មិនដឹងលាក់ទុកទៅណាទេ ។

សែ :	គេថា គេមិនចង់ឈឺចាប់ ប៉ុន្តែខ្ញុំថាតុលាការអីក៏ដោយ សំខាន់មនុស្សដែលមានវិបត្តិផ្លូវចិត្តឬមនុស្សដែលមានល្អក់កករក្នុងជីវប្រវត្តិរបស់ខ្លួនតែងតែប្តូរឈ្មោះហើយ ។ ពិតជាផ្លាស់ឈ្មោះម៉ង ហើយមនុស្សដែលគេធ្វើត្រង់ផ្លូវគេនឹងម៉ង គឺឈ្មោះគេពីដើមប៉ុនណា គឺប៉ុននឹងហើយ អានេះខាងចិត្តសាស្ត្រ ខ្ញុំរៀនក្បួននឹង ។ អានឹងទស្សនៈអាសម្ភារៈនិយម បដិច្ចៈសមូលបាត ដែលខ្ញុំយកមកវិភាគអានឹង ។

បូលី :	បដិច្ចៈសមូលបាតនឹង សម្ភារៈនិយម?

សែ :	បាទ! សម្ភារៈនិយម ។

បូលី :	ប៉ុនព្រឹកមិញ ពូថា?

សែ :	ប៉ុនសម្ភារៈនិយមនឹង វាបូកនឹងបដិច្ចៈសមូលបាត កត្តាទាំង៤ ។

ភាព :	គេថាអ្វីៗមានការប្រែប្រួល ។

បូលី :	អ្វីៗមានការប្រែប្រួល?

ភាព :	ចាំ!

សែ : អ៊ីៗតែមានការវិវត្តន៍ អ៊ីៗតែងមានការទំនាស់ ពីតូចទៅធំពីទាបទៅខ្ពស់ អានឹងទស្សនៈរបស់លោកវិទូៗ ប៉ុនវាក្មេងអា ១ មួយនោះ អត់ទាន់ច្បាស់ កូនសៀវភៅនេះវាចោលដល់សភាពការណ៍កសាង វិវឹកព្រឹត្តិការណ៍ខ្ញុំវាចេះជួប៤ឆ្នាំជួបម្តង ៨ឆ្នាំជួប២ដង ព្រឹត្តិការណ៍នឹងបើមើលជីវប្រវត្តិខ្ញុំៗអានមើលវាវេទនាវាច្រើនបែបពេកៗ

បូលី : ខ្ញុំរឿងកងពលរឿងអីដូចជាមិនជម្រាបសួរពូទៀតទេៗ

សែ : បាទ! យើងដឹងចង្កោមហើយៗ

បូលី : ៩៩០អីខ្ញុំដឹងខ្វះៗហើយ កងពលរបស់ តា គាន់ ៦០៣ កូនប្រសារ តា ម៉ុក នេះ ដែល តា ម៉ុក យកទៅសម្លាប់ចោលនឹងៗ ក្រោយមកពីណាគេឡើង តា ញ៉ន?

សែ : អា មិញចូលកង តា ញ៉ន នេះ ពួកនឹងចង្កោមវាហ្នឹង៦១៦ៗ

បូលី : ៦១៦ មួយទៀត?

សែ : ៦១៦នឹង របស់កង តា វ៉ិន នឹងៗ

បូលី : របស់ កង តា វ៉ិន?

សែ : បាទ! កម្លាំងនឹងឯងៗ

បូលី : ប៉ុន តា វ៉ិន នេះ៦០៣?

សែ : ៦០៣ ប៉ុនអត្តភាពនឹង នៅក្នុង៦១៦ចង្កោមរបស់វា ៦១៦ បច្ចុប្បន្ននេះៗ

បូលី : ៦១៦របស់រដ្ឋាភិបាលរាល់ថ្ងៃ?

សែ : អត់ទេ អតីតមុននេះ វាចង្កោមនឹងវានៅក្នុងនឹងទាំងអស់ៗ

បូលី : សុំទោស ខ្ញុំអត់សូវយល់តិចៗ ៦១៦ ៦០៣?

សែ : វាកើតចេញពីកង តា វ៉ិន នឹងៗ

បូលី : អ៊ូ! ៦១៦ វាចេញពី៦០៣នឹង?

សែ : បាទ! ប៉ុនអានឹងវា២កងៗពលបូកចូលៗ

បូលី : ៦១៦?

ភាព : ៦១៦ គ្រប់គ្រងដោយ តា ញ៉ន ពីមុនរួមគ្នាជាមួយ តា ញ៉ន, តា វ៉ិនៗ

បូលី : បាទ! តា ញ៉ន?

សែ : តា ញ៉ន ក្រោមលំដាប់ តា វ៉ិន គ្រប់គ្រងៗ

បូលី : តា ញ៉ន ក្រោម តា វ៉ិន ទេ?

សែ : បាទ! តា ញ៉ន តា សេង នេះៗ

បូលី ៖ ប៉ុនគ្រាន់ថា ពូមានប្រសាសន៍ថា ៦១៦នេះ បំបែកចេញពីកង តា រ៉ិន នឹងឯង?

សែ ៖ ចន្លោមវា គឺធ្លាក់មកកង តា រ៉ិន ទាំងអស់ បំបែកចេញតូចៗទេ។

បូលី ៖ នៅក្រោមការគ្រប់គ្រងរបស់ កង តា រ៉ិន ទេចឹង?

សែ ៖ ហ្នឹងហើយ ប្រវត្តិដើមរបស់វា។ ដល់ចឹងយើងចេះស្រាវជ្រាវរក ដូចរក៨០១ចឹង មកទល់គ្នានឹង៩១២នេះចឹង ជាខ្សែវាចឹង។

បូលី ៖ ៨០១, ៩១២?

សែ ៖ តាំងពី៦១២, ៩១២, មកសុទ្ធតែខ្សែ៨០១ចូលមក អានឹងវាចឹង។

បូលី ៖ វាមានចន្លោមវាចេះ ឧទាហរណ៍៦០៣ វាមេចន្លោមចឹងទៅ ហើយ៦០៣ វាក្តោបទាំង៦១៦នឹង។

សែ ៖ ៦១៦នឹង កម្លាំងរបស់ ៦០៣ វាធ្លាក់៦១៦នឹង ចន្លោមច្រើន។

បូលី ៖ មានអីខ្លះ?

សែ ៖ មានតាំងពីកងពលវរសេនាធំ វរសេនាតូចអីនឹង ចន្លោមអាដើមកំណើតរបស់វានឹង ធ្លាក់នៅនឹងហើយ ចឹងបានវាបែងចែកសាខាផ្សេងៗ អត់ដូចទេ អត់អស់ទេ។

បូលី ៖ បានន័យថាកម្លាំងរបស់៦០៣មួយចំនួន ត្រូវបានកាត់មកឲ្យ៦១៦?

សែ ៖ មួយចំនួនទៅប្រភពវាច្រើនៗ នៅនឹងទាំងអស់គល់ឫសរបស់វា។

បូលី ៖ ចុះពីថាមិញ ៩២០ អា៩១២នេះ ចន្លោមជាមួយគ្នាដែរ?

សែ ៖ ៩១២នេះ វាមកពី៨០១មក ជាខ្សែរបស់វាបន្តគ្នាមក វាមានកម្លាំងដែលច្រើនជាងគេមកពង្រីកៗ។

ភាព ៖ គេច្រើននិយាយកម្លាំពង្រីកទេ។

បូលី ៖ កម្លាំងពង្រីក?

ភាព ៖ ចា៎! បើថាពាក់ព័ន្ធកងពលដាច់ឡែកៗវាអត់មាននេះទេ វាអត់មានរយៈជាមួយគ្នាទៀតទេ ព្រោះអីយើងពង្រីកពី៨០១មក យកមកបញ្ចូល៦១២ យកមកចូល៩១២ចឹង អានឹងដើមកំណើតវា។ ទៅអនាគតមន៍ គេចង់ថាកម្លាំងនឹងវាត្រូវបំបែកយកទៅដាក់តាមកងពលចឹងៗ

បូលី ៖ ពីកំណើតចេញមក?

ភាព ៖ ចា៎!កំណើតចេញមកពី៨០១ អានឹងនិយាយចឹងទេ ហើយអា៦១៦នេះ ក៏វាចេញកំណើតពីនោះ។

បូលី ៖ ៦០៣នេះ?

ភាព ៖ ចាំ! ចង់និយាយចឹង ។

សែ ៖ បើចង់ដឹងរឿង៦០៣ សួរ៦១៦ វាចេញ ។

បូលី ៖ ដឹងហើយ?

សែ ៖ បាទ!

បូលី ៖ ដល់៩១២នេះ កំណើតចេញមកពី៩២០?

ភាព ៖ ៩២០ ។

បូលី ៖ ឬ៨០១ពូ?

សែ ៖ ពីណា?

បូលី ៖ ៩១២?

សែ ៖ ៩១២នេះវាចេញកំណើតពីខាងខុត្តរគេនេះ ខាងកងចាស់គេនេះ ប៉ុនយើងបូកពី៨០១ វាមកមួយស្ពានវា ។

បូលី ៖ ៨០១?

សែ ៖ បាទ! មានខ្ញុំមានអីមក ។

បូលី ៖ មានកងពលផ្សេងៗទៀត ប្រហែលពូមិនដែលឮតាមមើលពីព្រោះវានៅឆ្ងាយ ដូចជា៤១៥ ដែរឮទេ?

សែ ៖ ៤១៥ មិនដែលឮទេ ។

បូលី ៖ កងពល៨៦?

សែ ៖ អត់ទេ វាភូមិភាគឆ្ងាយគ្នា ។

បូលី ៖ ឆ្ងាយទៅខាងនោះវិញ?

សែ ៖ បាទ!

បូលី ៖ បើ៤៥០ពូឮ?

សែ ៖ ៤៥០ឮ ។

បូលី ៖ របស់ សុខ ភាព?

សែ ៖ ៤៥០នឹង កងលោក សួង ពីដើម ។

បូលី ៖ មិនមែន សុខ ភាព ទេ?

សែ ៖ អត់ទេ សុខ ភាព ទទួលបន្ទុកក្រោយ តា សួង ។

បូលី ៖ ពីមុន សួង?

សែ ៖ អឺ! ៤៥០ៗ នែក! ៦០៣ វាមាន៣១០ ៤៥០ កងលោក សំអឿន និង លោក សួង នេះ បូកចូលគ្នា លោក វ៉ិន គ្រប់គ្រងៗ

បូលី ៖ ចឹង៤៥០ក៏របស់ ៦០៣ដែរ?

សែ ៖ បាទ!

បូលី ៖ មាន៣១០ទៀតពូ?

សែ ៖ បាទ!

បូលី ៖ ៣១០ខ្ញុំដូចមិនប្រទះទេៗ

សែ ៖ កងលោក សំអឿនៗ

ភាព ៖ ៣១០មួយៗខាងៗ

សែ ៖ និរតីៗ

ភាព ៖ ៣១០មួយ នែកៗ៩១២ៗ

សែ ៖ ៣១០នេះ ៣១០កងពលៗ

បូលី ៖ ៣១០នេះ ពូចង់និយាយថា តាំងពីជំនាន់៧៥មកទេ?

សែ ៖ បាទ! ហ្នឹង កងលោក សំអឿនៗ លោក សួង ៤៥០ៗ

បូលី ៖ ៤៥០នេះ តាំងពីជំនាន់៧៥មកដែរ?

សែ ៖ ហ្នឹងកងទ័ពប្រកាសទូទាំងប្រទេសៗ

បូលី ៖ មុនទេ តាំងពី៧៥?

សែ ៖ បាទ! ប៉ុនចង្កោមវាៗធ្លាក់នៅក្នុង៦០៣ៗ

បូលី ៖ មានន័យថាពួក ក្រុម៣១០ ៤៥០នេះ វាចូលមក៦០៣នេះ?

សែ ៖ ហ្នឹងហើយ៦០៣នេះៗ

បូលី ៖ អានេះតាំងពីជំនាន់បដិវត្តន៍មកនោះ?

ភាព ៖ តែដល់ក្រោយមកគេបូកបញ្ចូលអានេះវិញ ៦០៣វិញនេះ រៀបរចនាសម្ព័ន្ធក្រោយៗ

បូលី ៖ ៨០០ពីណាគេប្រធានកងពល?

សែ ៖ ពីមុន តា ឋិន, តា ប្រ ពីរនាក់នឹង?

បូលី ៖ មិនមែន តា ភាព មាន ភាព មួយទៀតឈ្មោះ ភាព ដែរ អនុរបស់ តា ឋិន?

សែ ៖ មិនដឹងភាពណាៗ

បូលី ៖ ឌី ឋិន?

សែ	បាទ! ជនជាតិ ។

បូលី :	មកពីខាងរតនគិរី?

សែ	បាទ!

ភាព :	ស្លាប់បាត់ហើយ ជិះម៉ូតូដួល ។ នៅតែ វ៉ាន់ នៅនោះ ។

បូលី :	បាទ! គាត់ស្លាប់ឆ្នាំ៩៨ សមាហរណកម្មហើយ ។

សែ :	ខ្ញុំទៅពីឆ្នាំរកអត់ជួប ។

បូលី :	ឥឡូវខ្ញុំមានសំនួរចុងក្រោយខ្លះៗ ។ សម្ភាសន៍មីងដូចចង់២ម៉ោងហើយនេះ តាំងម៉ោង៣មក ឥឡូវម៉ោងជិត៥ សរុបទៅវា៨ម៉ោងហើយ មិនអាចមានពីណាលើសយើងទេ ។

ភាព :	អត់អីទេ ។

សែ :	ព្រោះយើងចង់ដឹងសាច់រឿងច្រើន ។

បូលី :	ពូអាចជួយរៀបរាប់អំពីរឿង បដិច្ចៈសមុប្បាតគិចបានទេ យ៉ាងម៉េច គោលការណ៍បដិច្ចៈសមុប្បាតនឹង ដែលពូនិយាយមិញមានកំណាព្យ?

សែ :	បើនិយាយពាក្យវាថា សម្ភារៈនិយម អានឹងដើមរបស់វា បូកនឹងបដិច្ចៈសមុប្បាត ។ ចឹងសម្ភារៈនិយមនឹងគឺ សម្បត្តិដែលកើតមកជាសម្បត្តិធម្មជាតិ សម្ភារៈនិយម ប៉ុន្តែបដិច្ចៈសមុប្បាតនឹង គឺចង់និយាយកត្តាទាំង៤ ។

បូលី :	ទី១?

សែ :	ទី១ គេមានអ៊ីៗទាំងអស់សុទ្ធតែមានការវិវត្តន៍ វាអត់មាននឹងថ្កល់ទេ ។

ភាព :	ប៉ុនអានឹងពាក្យបូកសរុប ចុងក្រោយធំជាងគេ អាពាក្យនឹងគេនិយាយចឹងម៉ង ។

បូលី :	ទី២?

សែ :	អ៊ីៗទាំងអស់សុទ្ធតែមានការប្រែប្រួល អានេះសុទ្ធដើមមេវា ។

បូលី :	ទី៣?

សែ :	អ៊ីៗទាំងអស់សុទ្ធតែមានការទំនាស់ អានឹងច្បាស់សម្ភារៈនិយម វាមកខុសអាក្រោមនេះទៀត វាភ្លេចអាមួយនឹង ភ្លេចនឹកមិនឃើញ ហើយបានគេបំបែកទៀត ។

បូលី :	សល់មួយទៀត?

សែ :	បាទ! សល់មួយទៀត យើងរកមិនចេញ ។ ចឹងបានគេបំបែក អាល្អិតៗនឹងទាំងអស់ ពីទាបទៅខ្ពស់ ពីតូចទៅធំ ពីល្អមកអាក្រក់ ពីអាក្រក់មកល្អ វាសុទ្ធតែមានការប្រែប្រួលវាអត់នៅនឹងថ្កល់ទេ ព្រោះសម្ភារៈនិយមនេះ ជាសម្បត្តិធម្មជាតិបង្កើតមក ។

ភាព ៖ គេយកពាក្យមួយជាសំខាន់ ពាក្យខាងលើ ។

បូលី ៖ ជាសម្ភារៈនិយម?

ភាព ៖ នេះពាក្យខាងលើ អ៊ីៗត្រូវតែមានការប្រែប្រួល ។

បូលី ៖ ចង់មានន័យថាម៉េច អ៊ីៗទាំងអស់?

ភាព ៖ វាអត់មានការងាយស្រួលទេ ចង់និយាយថា មនុស្សយើងកើតហើយត្រូវតែមានស្លាប់ត្រូវតែមានជម្ងឺមានអីចឹង អានឹងវាចឹង ។

បូលី ៖ និយាយទៅដូចសាសនាហើយ ស្តាប់មើលទៅ?

ភាព ៖ ចាំ!

បូលី ៖ ដូចជាសាសនាមួយចឹង?

ភាព ៖ ហ្នឹងហើយ ។ បើគេនិយាយពីមនុស្សក៏ចឹងដែរ គេចង់និយាយថា មនុស្សក៏មិនអាចចិត្តនឹងដែរវាមានថ្ងៃនេះ អារម្មណ៍ល្អ មានថ្ងៃនេះអារម្មណ៍អាក្រក់ មានថ្ងៃនេះមានជម្ងឺ មានថ្ងៃនេះមានកើតទុក្ខ មានសប្បាយចិត្ត មានអីចឹងថាវាប្រែប្រួលជារៀងរហូត វាអត់មាននឹងនរទេ ។ ចឹងបានគេថា អ៊ីៗសុទ្ធតែមានការប្រែប្រួល និងការផ្លាស់ប្តូរ ។

បូលី ៖ នឹងពាក្យបដិច្ចៈសមូលបាត?

ភាព ៖ ចាំ!

បូលី ៖ ខ្ញុំតែងតែឮ ខ្ញុំមើលឯកសារបោះពុម្ពខាង៧៥ ៧៦ ឃើញពាក្យបដិច្ចៈសមូលបាតនឹង ប៉ុន្តែមិនដឹងប្រែថាម៉េចពាក្យនឹងៗមានន័យជាភាសាបាលីចឹង ។

ភាព ៖ នេះៗ ស្អីខ្លះហើយមើលមិញ ។

បូលី ៖ អ៊ីៗទាំងអស់សុទ្ធតែមានការវិវត្តន៍ អ៊ីៗទាំងអស់សុទ្ធតែមានការប្រែប្រួល អ៊ីៗទាំងអស់សុទ្ធតែមានទំនាស់?

ភាព ៖ នៅមានការផ្លាស់ប្តូរ វាត្រូវតែមានការផ្លាស់ប្តូរ ។

បូលី ៖ ទាក់ទងអីនឹងសម្ភារៈនិយមបដិច្ចៈសមូលបាត?

សែ ៖ អានឹងគេចង់និយាយថា បដិច្ចៈសមូលបាត គេយកកត្តាគោលវាជាកត្តា៤ យកមកវិនិច្ឆ័យដូច្នេះសូម្បីតែទង្វើលអីផ្សេងៗមានការវិវត្តន៍ទាំងអស់ វាអត់មាននៅនឹងថ្កល់ ឯរឿងការទំនាស់ គេចង់និយាយថា រស់នៅសូម្បីតែក្រុមគ្រួសារក៏មានការទំនាស់ៗពីខាងមធ្យោបាយទំនាស់ខាងឋានៈ ទំនាស់ខាងអារម្មណ៍ ។

ភាព ៖ ការពិតទៅគេនិយាយពីរឿងបញ្ហាពាក់ព័ន្ធយើងធ្វើការងារនៅក្នុងសង្គមក៏ចឹងដែរ គេលើកថា អ្វីៗវាមិនអាចនឹងនរទេ ។ ហើយមិនមានកាន់អំណាចតែក្នុងម្នាក់ៗទេ វាត្រូវតែមានការផ្លាស់ប្ដូរ វាត្រូវតែមានការប្រែប្រួលនៅក្នុងសង្គម គេលើក ។ ដល់ហើយច្បាប់សម្ភារៈនិយម គេត្រូវតែធ្វើតាមច្បាប់សម្ភារៈនិយមនេះឯង ព្រោះគេត្រូវតែមានការប្រែប្រួលរហូត ។ ព្រោះប្រែប្រួលៗ គេចង់និយាយប្រែប្រួលទៅតាមសភាពការណ៍ បានគេលើកច្បាប់សម្ភារៈនិយមបដិច្ចៈសមូលបាតនឹង យកមកប្រើនឹង ឲ្យយើងគិតពិចារណាទៅលើនឹង ។ អានឹងដូចពាក្យកម្រិតយល់ដឹង ចេះឯងត្រូវក្រែងចេះគេអី ចេះគិត ។ គេឲ្យយកអានឹងមកគិត មកពិចារណា ។

បូលី ៖ ដូចជាធម៌មួយខ្ញុំស្ដាប់មើលទៅ ។

ភាព ៖ ចា៎! គាត់បង្រៀនជ្រៅៗ ។

សែ ៖ គាត់បង្រៀនទស្សនៈសកល ។

បូលី ៖ ទស្សនៈវិជ្ជានឹងជាទស្សនៈវិជ្ជារបស់ ប៉ុល ពត ឬរបស់អ្នកណា?

ភាព ៖ របស់ ប៉ុល ពត ។

បូលី ៖ ព្រោះពាក្យនេះកម្រ មិនដែលមិនដែលមិនថាមានគេប្រើទេ ។

សែ ៖ គាត់ថាកសិករយើង មិនយល់ទេ តែយើងធ្វើហើយ យើងយកអាទង្វើលរបស់យើង យកមកផ្ទុះបញ្ចាំងខ្លួនយើងៗនឹងអាចឃើញហើយ គង់តែដឹង គាត់ថាចឹង ។

បូលី ៖ មានន័យថា យល់តាមរយៈការអនុវត្តន៍?

សែ ៖ បាទ!

បូលី ៖ បើសូត្រទ្រឹស្ដីទៅ គាត់មិនយល់ទេ?

សែ ៖ ហ្នឹងមិនយល់ទេ ។

បូលី ៖ តែបើធ្វើអានឹងហើយ អាចគាត់យល់តាមក្រោយ?

សែ ៖ បាទ! បានជាគាត់យកកត្តាមួយថា តិទៀន និងស្វ័យតិទៀន ។

បូលី ៖ យ៉ាងម៉េចអានឹង?

ៃ ៖ មុននឹងតិទៀនគេ យើងស្វ័យពិនិត្យខ្លួនឯងសិន តើយើងបរិយាកាសយើងៗអាចលាតត្រដាងកំហុសរបស់យើងស្មោះត្រង់នៅក្នុងសមូហភាព ឬអត់ បើមិនស្មោះត្រង់ទេ គេធ្វើការ តិះទៀនមកយើងជួយបំពេញ ។

ភាព ៖ តែបើយើងឥឡូវគេនិយាយគុណសម្បត្តិ និងគុណវិបត្តិ ។

សែ : បាទ! គេនិយាយរឿង អាវុធ ស្មារតី ។

បូលី : ចំពោះការគិតទៀន ស៊ុយតិទៀននឹង?

ភាព : ចាំ!

បូលី : និយាយពីគុណសម្បត្តិ និងគុណវិបត្តិ?

ភាព : ចាំ! មុននឹងយើងលើកគុណសម្បត្តិខ្លួនយើងៗលើកការខ្វះខាតរបស់ខ្លួនយើងសិន ។

សែ : អានឹងគេចង់ស្ដាប់ទស្សនៈយើង ។

ភាព : យើងមាន ចំនុចអ្វីខ្វះខាត ។

សែ : បើយើងធ្វើជំនឿថាខ្លួនយើងធ្វើល្អ ហើយខ្លួនយើងត្រូវ ទង្វើលនេះអាចអំនួតខ្លួនឯងហើយមោទនភាពខ្លួនឯងពេក អានឹងគេយកកត្តាចឹង ។ ហើយចំនុចដែលយើងលើកពីការខ្វះខាតបើយើងត្រង់ លើកកត្តាខ្វះខាតបញ្ជាក់ឲ្យសមាហភាពគេដឹង គេដឹងថាមនុស្សនឹងអាចវិវត្តន៍ទៅល្អ មនុស្សវាស្មោះត្រង់ តែបើវាយមិនអស់ទេ នៅមានគំនួចនឹង គឺលាក់បំពួននឹង គឺដឹងវិនិច្ឆ័យថា លោកនេះនឹងមានការវិវត្តន៍ៗពីល្អទៅអាក្រក់ នេះការវិនិច្ឆ័យ ។ ចឹងបានគាត់បញ្ជាក់ រៀនសារចុះសារឡើង ចុះបើសុទ្ធតែអ្នកទាប ។

ភាព : យើងមកដល់យើងឥឡូវ យើងនិយាយចំនុចខ្លាំង និងចំនុចខ្សោយវិញ អត់មានគុណវិបត្តិគុណសម្បត្តិដូចមុន ។ គុណសម្បត្តិជាការធ្វើបាន គុណវិបត្តិ ជាចំនុចខ្វះខាត ដែលយើងធ្វើមិនទាន់បាន ។

សែ : ប៉ុនធ្វើទៅ ដូចប្អូនឯងខំចងក្រងឯកសារនេះ ធ្វើទៅយើងគ្រាន់វិនិច្ឆ័យថាចំនុចដែលល្អរបស់ប៉ុល ពត នេះវាច្រើនគណនាណាស់ រៀបរាប់មិនអស់ទេ ប៉ុនចំណុចដែលខ្វះខាតរបស់គាត់នេះ គាត់វាទាញទៅឆ្វេងខ្លាំងពេក ។ អាឆ្វេងនឹងទៅជាផ្ដាច់ការគណៈដែលវាលំអៀងនេះចឹងដល់មាគ៌ាដំណើរការវាត្រូវបរាជ័យ វាអត់បានបញ្ចប់ ។

បូលី : ពូអាចជួយរៀបរាប់បានទេ ខ្ញុំជួបសំនួរនេះច្រើនណាស់ គេសួរខ្ញុំថា តើអ្វីជាចំនុចល្អរបស់របបកម្ពុជាប្រជាធិបតេយ្យ គេសួរខ្ញុំ ទាំងតាមវិទ្យុក្ដី ទាំងតាមទូរទស្សន៍ក្ដី ទាំងខ្ញុំជួបជាមួយកូនសិស្ស គ្រូបង្រៀន ប្រជាជនក្ដី នៅក្នុងវេទិកាមួយៗគេសួរច្រើន ហើយខ្ញុំឆ្លើយមិនចេញសំនួរនឹង?

សែ : គេកន្លងមក យើងបានការរួមរស់ក្នុងចលនានេះវាជ្រៅដែរកន្លងទៅ ។ កត្តាទី១គឺជីហរស្មោះត្រង់រវាងប្រុស និងស្រី ភាគច្រើនដេករស់នៅជាមួយគ្នាជិតស្និតយ៉ាងម៉េចក៏ដោយ ក៏អត់មានទង្វើលមួយប៉ះពាល់រឿងសីលធម៌នឹងដែរ នឹងកត្តាមួយនឹងដែលវាលេចធ្លោរ គេហៅ

សីលធម៌ស្អាតស្អំ ហើយសីលធម៌រស់នៅនេះ មានសភាពរស់នៅដូចជាការរស់នៅប្រមូលផ្ដុំញាតិមិត្តផៅសណ្ដាន វាមានជំហរសាមគ្គីនេះវាជ្រាលជ្រៅណាស់ វាដូចសាច់ ដូចឈាមគ្នាចឹង ដូចបងដូចប្អូនបង្កើត ។

បូលី : មានអីទៀតមីង ដែលមីង ក្រែងលរពូអាចរកនឹកឃើញពីចំនុចល្អរបស់របបនឹង?

ភាព : វាមុនខុសប្លែកគ្នាទេ សំខាន់ទៅលើកចេះការសាមគ្គីគ្នា សង្គ្រោះគ្នា ជួយគ្នាទៅវិញទៅមក ដឹងទុក្ខធុរៈគ្នា ស្គាល់សុខទុក្ខគ្នានៅក្នុងអន្តភាព ។

សែ : កត្តាមួយទៀត យើងនិយាយភាពទូលំទូលាយ គឺកត្តាជាតិ ។ គាត់មានះទាំងខ្លួនគាត់ ហើយគាត់គិតក្នុងឋានៈជាតិ មិនដូចយើងស្គាល់ថា ប៉ុល ពត ជាមនុស្សកាប់សម្លាប់ទាំងស្រុងតែឯងទេ ព្រោះអ្វីគាត់គិតរឿងជាតិ ជាកត្តាធំណាស់ គាត់ស៊ីជម្រៅណាស់រឿងជាតិ ខ្ញុំមើលកត្តានឹងខ្ពស់ ប៉ុនអ្វីដែលយើងមើលទៅ យើងថ្កោលពីចំងាយមកឃើញថា ប៉ុល ពត ដឹកនាំជាប្រធាន ប៉ុន្តែ ប៉ុល ពត សម្លាប់ប្រជាជន២លាននាក់ អឺ! ២សែននាក់ ហើយយើងថា ២លាន ទៅលើទង្វើលផ្សេងៗគ្រប់បែបយ៉ាងនឹង វាជាឈ្មោន់រូបភាពនៃ ប៉ុល ពត ប៉ុន្តែសាខារបស់ ប៉ុល ពត នេះមិនមែនខួរក្បាល ប៉ុល ពត វាចេះធ្វើដោយបំពានគ្រប់សាខាទាំងអស់ ដែលពួកគេនៅក្លែងបន្លំខ្លួន ។

ភាព : គេយកមាគ៌ានឹង ទៅបំភ័យ ។

សែ : បាទ! ពាក់អាវរូបរាងអ្នកនឹង ប៉ុន្តែចិត្តគំនិតរបស់គេមាន២ផ្លូវ ពផ្លូវសម្រាប់ខ្លួនគេ នេះអារម្មណ៍របស់គេ ។

បូលី : ចឹងអ្នកនឹងឯង ដែលជាអ្នកសម្លាប់?

សែ : បាទ! ហ្នឹងហើយដែលខ្ញុំឈរជើងនៅរយៈកាលនឹងមួយជីវិត ខ្ញុំមិនលំអៀងទៅផ្សេងៗ ខ្ញុំមើលកត្តានឹង ហើយកត្តាទឹកដី មិនឲ្យបាត់បានទេ ។

បូលី : អ្វីជាសមិទ្ធផលរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលបានកសាងឡើងនៅក្នុងសម័យនឹង?

សែ : ពេលវេលាវាខ្លីពេក យើងរកស្ថាបនាការកសាងអីវាគ្រាន់ដោះស្រាយដំណើរខាងផ្លូវជីវិតខាងសេដ្ឋកិច្ច ។

ភាព : យើងយោធា មិនសូវដឹងដូចគេមូលដ្ឋានៗបានគេចុះជាប់ បានកសាងអីច្រើន យើងផ្នែកយោធា យើងដឹងតែការពារ ហើយបង្កបង្កើតផលខ្លួនឯង វាអត់លំនឹង ។

សែ : យើងអត់នៅនឹងកន្លែងផងនឹង ប៉ុនគ្រាន់ថាអ៊ីៗយើងយកជាទស្សនៈថាល្អនិងអាក្រក់យើងដឹង ប៉ុនខ្ញុំគ្រាន់ថាគាត់ធ្ងន់នៅលើឆ្វេងពេក ដំណើរការនឹងដើរវាឆ្វេងពេក ។

បូលី ៖ គាត់ឆេ្មងខ្លាំងពេក?

សែ ៖ បាទ!

បូលី ៖ ដែលធ្វើឲ្យអានឹងទៅជាបរាជ័យវិញ?

សែ ៖ បាទ! វាជម្រៅខាងលំអៀងឆេ្មងពេក ដូច្នេះយើងធ្វើអាប្រទេសជុំវិញគេអត់ទាន់ធ្វើដូចយើងផង យើងផ្ដាច់ការចាយរូបបិយប័ណ្ណនឹង ។

បូលី ៖ អត់មានលុយ អត់មានសាលារៀន?

សែ ៖ បាទ! អត់មានលុយ វ៉ៃកម្មសិទ្ធិបុគ្គលៗមិនត្រូវមានទេ ត្រូវមានសិទ្ធិ ។

បូលី ៖ រួម?

សែ ៖ រួមម៉ង វ៉ៃអានឹងវាធ្ងន់ពេក ។

បូលី ៖ ធ្ងន់?

សែ ៖ បាទ!

ភាព ៖ សាលារៀនឲ្យមានត្រឹមថ្នាក់ទី៣ ។

បូលី ៖ ឲ្យមានត្រឹមថ្នាក់ទី៣ទេ?

ភាព ៖ ទី៣ ទី៤ ទី៥ អត់បានរៀនទេ ទី៥មានមួយកន្លែង រៀនរបៀបចង់លួចលាក់ផង ។

បូលី ៖ យល់ឃើញយ៉ាងម៉េច បានជាមិនឲ្យមានសាលារៀន តាមពូដឹង?

ភាព ៖ សាលារៀនមាន មិនមានទេ សាលារៀនមានគ្រប់កន្លែងទាំងអស់ ទោះបីយើងផ្លាស់ទៅដល់ណា ត្រូវតែសាងសង់សាលាឲ្យកូនរៀន រើសគ្រូឲ្យកូនរៀនតែម្ដង ប៉ុន្តែកម្រិតថ្នាក់ខ្ពស់នឹងមានត្រឹមថ្នាក់ទី៥ប៉ុននឹងទៅលើនឹងអត់មាន ។ តែចប់ថ្នាក់ទី៥ចប់ ។

សែ ៖ វាអត់មានបញ្ញាជន គ្រូបង្រៀនជំនាន់មុនៗ វាខ្វះសមត្ថភាព ។

ភាព ៖ ខ្វះសមត្ថភាពគ្រូ ។

បូលី ៖ ចុះគ្រូដែលសល់ពីសម័យលន់ នល់ ទៅណាអស់?

សែ ៖ សុទ្ធតែពាក់ព័ន្ធនិន្នាការនយោបាយ ។

ភាព ៖ សល់នៅក្នុងនេះវាតិច ។

សែ ប៉ុន្តែគ្រូនមិនដែលសួរសម្ងាប់ទេ ។ វាច្រើនតែព្រាត់ប្រាសគ្នានិរាសអីផ្សេងៗ បែកចាកមែកចាកធាងទៅ វាអត់មានរឿងអីសត្រូវនយោបាយក្នុងជាតិ រឿងគ្រូ ។

ភាព ៖ ចូលចលនាតស៊ូ គ្រូអីគេមានចូលមកណា មកតែកសិករៗនឹងអ្នករៀនកម្រិតខ្ពស់ក៏គេមិនមកនៅដែរ បានត្រឹមថ្នាក់ទី៧អីមកនឹង អានឹងចេះតែស៊ូទៅ ច្រើនដែររៀនថ្នាក់ទី៥ខ្វះដែរ ។

សែ :	អ្នកចេះដឹងខ្ពស់វាអត់មានគ្រូបង្រៀនវាខ្វះសមត្ថភាពគ្រូ ។

ភាព :	ហើយនិយាយពីរៀនចេញពី ប៉ុល ពត មកសៀវភៅឯកសារវើចេញមកសុទ្ធតែកម្រិតខ្ពស់ ស្មៀនខ្ញុំថ្នាក់ទី៥ ប៉ុនស្អីក៏ទៅរួចដែរ អត់មានយ៉ាប់ទេ ប៉ុនគ្រាន់គ្នាខ្សោយអង់គ្លេសប៉ុននឹង ។ ឥឡូវកុំព្យូទ័រអីវើខ្លួនឯង ព្រីនឯកសារចេញខ្លួនឯង មិនបានទៅរៀនណាណែនាំផង ទៅលួចរៀនតិចៗពេលនេះនឹង ហើយទៅទិញកុំព្យូទ័រពីគេតមកយកមករៀនច្ចៃប្រឌិតធ្វើ ឥឡូវធ្វើបានអស់របស់វា ។

បូលី :	ចេះតែខំប្រឹង?

ភាព :	ចេះខំប្រឹងទៅ ចុះបើក្មេងកើត៧៧នឹង មានពិបាកអី បើគ្នាកើត៧៧បានរៀនអីប៉ុន្មានដែរ ហើយនៅព្រៃរហូតនឹង ។

បូលី :	ហេតុអ្វីបានជាគេមិនឲ្យមានវត្តអារាម ទាស់ខុសត្រង់ណាវត្តអារាម និងលោកសង្ឃនឹង?

ភាព :	ខាងក្នុងខ្ញុំមិនដឹងទេ បើថាខាងអ្នកក្រៅ មានវត្តពិបាកចិញ្ចឹមលោក ព្រោះមិនមានភូមិកំណត់ជាយុត្តិសាស្ត្រទេ ។

សែ :	វាអត់មានចលនានឹងថ្កល់ ។

ភាព :	វាអត់នឹងទេ លំនៅដ្ឋានផ្លាស់ជារៀងរាល់ខែរាល់ឆ្នាំ កម្របានដល់ឆ្នាំណាស់ ដាំចេកបានកាប់១ដង២ដងទៅទៀតហើយ ភូមិថ្មីទៀតមានគេមកគេនៅភូមិយើងទៅ ។ យើងទៅបង្កើតភូមិថ្មីទៀតក៏មានដែរ ។

សែ :	ក្នុងឋានៈជាអ្នកតស៊ូយើងមិនអាចនៅនឹងថ្កល់ទេ ។ ពេលវេលាខ្លះមានបរិយាកាសឲ្យយើងពេលវេលាខ្លះវាប្រថុចញូច ប្រថុចជនមែនទែន ។ ដូចខ្ញុំគ្រួសារខ្ញុំនៅលើដែលឈើធ្ងន់ ខ្ញុំនៅផ្លូវជាតិលេខ៦ដីមិនចេះតិចតីឡូទេ ។

បូលី :	ហេតុអីចាំបាច់វិលប្រជាជនចុះឡើងៗនៅក្នុងភូមិឃុំស្រុកខេត្តនឹង?

ភាព :	ចុះបើកងទ័ពដូរលិចដូរកើត ដូរទៅសមរភូមិនេះសមរភូមិនោះ គាត់មិនឲ្យដាច់គ្រួសារឆ្ងាយពីគ្នា ។

សែ :	វាលំបាកដឹងសុខទុក្ខ ។

បូលី :	មានអ្នកនៅមូលដ្ឋានទេ ឬដូរទាំងអស់គ្នា?

ភាព :	ដូរចល័តម៉ង អត់មាននៅនឹងនរម៉ាកន្លែងនឹងឲ្យបាន៣ឆ្នាំអីអត់ទេ អត់បានទេ ។

បូលី : នេះខ្ញុំសួរចង់ឆ្ងល់ ហេតុអីបានជាកងទ័ពចាំបាច់ដោះដូរចុះឡើងអីវិលចុះឡើងច្រើនម៉្លេះរឿងនឹង ម៉េចមិនកងទ័ពណានៅម្តុំការពារម្តុំនឹងទៅចាំបាច់ដូរចុះដូរឡើងវិលចុះវិលឡើងឲ្យពិបាកធ្វើអី?

សែ : សភាពការណ៍មិននឹងថ្កល់ សត្រូវក៏គេផ្លាស់ប្តូរទីតាំងកន្លែងខ្លះគេអត់មានលទ្ធភាពកម្លាំងមកគេត្រូវដកចេញ ទទួលការបរាជ័យ យើងក៏រុញទៅទៀត ចឹងណា៎ ។

បូលី : វាមានបញ្ហារឿងសត្រូវបង្កប់ខាងក្នុងនឹង?

សែ : បាទ!

ភាព : ហើយចុះបើខ្ញុំនៅទន្លេល្អៅនោះ ប្តីមកធ្វើការនៅថ្កាមរមាសនេះ គិតម៉េចឆ្លងប៉ុន្មានដើរតាមព្រំដែនមួយថ្ងៃទល់យប់ដើរមិនដល់ទេ ។

សែ : គិតទៅវា២០០គីឡូដាង ។

ភាព : គិតទៅដើរ២យប់២ថ្ងៃបានដល់ ។

សែ : ហើយខ្ញុំពីលើកមុនគេចង់ឲ្យទៅពីនេះ៨០៨ ចង់ឲ្យខ្ញុំទៅដល់ស្វាយរៀងនោះ ហើយយើងធាត់ដំណើរ ដើរផ្ទាល់ ។ ប៉ុន្តែគ្រាន់ថា អត់ចាយលុយ អត់មានផលប្រយោជន៍មែន ប៉ុនគេប្រើបាន នេះត្រង់គំនិតនឹង ។

បូលី : ហេតុអីបានជាគេមិនឲ្យមានប្រាក់កាសចាយ កាលនឹង?

ភាព : មានដែរ មិនមែនអត់ទេ តែគ្រាន់យើងបង្កើតមិនបាន បង្កើតវាមិនកើត ។

សែ : យើងអត់សេដ្ឋកិច្ចនឹងនរ ហិរញ្ញវត្ថុអត់មានចេញ ចឹងអត់មានការរីកចំរើន ។

ភាព : យើងអត់សេដ្ឋកិច្ច យើងអត់ធ្វើហិរញ្ញវត្ថុបានទេ ប្រទេសវាមានតែមួយកន្លែង ដល់យើងនៅក្រៅច្បាប់ យើងបង្កើតលុយអត់បានវាអត់មានអ្នកទទួលស្គាល់ដល់ចឹងទៅមិនមែនអត់ទេលុយចាយ ។ ប៉ុន្តែក្នុងនោះរបបសម័យនោះ គេបើករបបគ្រប់គ្រាន់ អង្ករ អំបិល ខ្ទាញ់ ប៊ីចេង ស្ករ ទឹកត្រី ប្រហុក សៀង កាពិ ថាមួយចប់គ្រឿងហូបឲ្យទាំងអស់ សំលៀកបំពាក់ គឺមួយឆ្នាំស្រ្តី២កំប្លេរ ចឹងហើយអត់មាននេះទេ បើកតាំងពីខោទ្រនាប់ អាវទ្រនាប់ឲ្យមួយចប់ កូនក្មេងបើកអាអាវអៀម អាវអីមួយឲ្យទៀត ក្រមាក៏បើកឲ្យប្រើ ។ ឆ្នាំង ចានវាអត់មាន លំបាកអីថាទៅទិញ ហើយគ្រាប់ដំណាប់បើកឲ្យ ដីបើកឲ្យ ម្សៅមីបើកឲ្យ មេនំប៉័ងបើកឲ្យ ធ្វើហូបខ្លួនឯងទៅ ម្សៅពងទា ចង់ធ្វើនំពងទានឹងរៃធ្វើពងទាទៅ ម្សៅពងទាបើកមួងមួយការ៉ុង ចែកគ្នាបានមួយគ្រួសារ២-៣គីឡូនឹង បើកពងទា បើកស្ករ បើកដោះគោបើកខ្ទាញ់ ហើយស្រេច ធ្វើហូបខ្លួនឯងទៅ ។ អាកន្លែងនេះហើយដែលហ៊ានលះ

បង់ប្ដីទាំងចោលរាប់ឆ្នាំ នោះប្រពន្ធនៅក្រោយមានពិបាកស្អីទេ ដេកពេទ្យអត់អស់លុយទេ ថ្នាំពេទ្យស្រេច អ្នកអត់ ទឹកដោះកូន ទៅបើកទឹកដោះគោឃុំងមក អត់មានពិបាកទេ ឲ្យតែទៅប្រាប់កងពលៗ ទៅប្រាប់អ្នកឃុំងក្រោយគេបើកឲ្យហើយ កន្លែងនេះឯងដែលតស៊ូបានកន្លងមក ។

បូលី : អត់មានប្រាក់ខែក៏មានទឹកចិត្តតស៊ូដែរ?

ភាព : ចា៎! មានទឹកចិត្តតស៊ូ ។

សែ : ត្រូវរបួសហើយ ក៏នៅតែទៅទៀត ។

ភាព : ត្រូវរបួសហើយមកដេកពេទ្យរដ្ឋ អត់មានលំបាក ។

បូលី : បាន តា ចែម ជួយ?

ភាព : ចា៎!

បូលី : តា ចែម យាយ ស៊ុន?

ភាព : មិនពិបាកទេ ប្ដីទៅជួនកាលមួយឆ្នាំក៏មានដែរ ៦ខែ ៧ខែក៏មានដែរ ពេលប្ដីទៅបាត់របបប្ដីត្រូវខែចូលឆ្នាំ ខែភ្ជុំនឹង គឺត្រូវគេបើកឲ្យនៅប្រពន្ធកូននេះ អង្ករដំណើបទឹកដោះគោ មី ស្អីៗមួយប្រដាប់ហូបនឹងសម្រាប់ហូបនឹង របបយើងផ្សេង ប្រពន្ធកូនផ្សេង របបប្រពន្ធកូនផ្សេងគេបើករបបប្ដីជំនួសឲ្យដាក់ហូបនៅនេះ ប្ដីទៅហូបក្នុង ។ ប្ដីទៅក្នុងស្ពាយលុយ ស្ពាយសារ៉ុងអីទៅខ្លួនឯងដោះអង្ករចាព្រៃប្រជាជនហូបនោះហើយ ចាយសុទ្ធតែមាសសន្ទឹកកង់ទ័ពនោះ ។

សែ : អត់លុយចាយ ប៉ុនចាយមាស ។

ភាព : អត់ដុល្លាទេ ប៉ុនសុទ្ធតែលុយបាត ។

បូលី : អានឹងក្រោយ៧៩?

ភាព : ចា៎! ក្រោយ៧៩ ។

បូលី : ខ្ញុំចង់សួរចន្លោះនេះ ចន្លោះ៧៥-៧៩ តើការដែលបំបាត់កម្មសិទ្ធិឯកជននឹងល្អ សម្រាប់ប្រជាជន ឬមិនសូវល្អ?

ភាព : មិនល្អទេ ។

សែ : មិនល្អយើងវាមនោគមន៍នឹងទទួកយូរមកហើយ ដល់បាត់ចឹង យកទៅសមូហភាពវ៉ូនឹងយកមកជះឥទ្ធិពលមិនគ្រប់គ្រាន់ទេ សូម្បីតែខ្ញុំដឹកនាំតែអនុសេនាធំនឹង គ្រាន់តែហូបបាយរួមនឹងបើយើងហូបជំនិតឲ្យហូបស្រុះគ្នានិងព្រមគ្នា បងប្អូនហូបហូបក៏មិនគ្រប់គ្រាន់ ហ្នឹងអ្នកធ្វើផ្ទាល់ខ្លួនឯងនឹង ក៏ចេះមានអ៊ីៗផ្សេងៗចេះតែជួយទៀត ព្រោះខ្លួនអ្នកដឹកនាំនឹង ។

ភាព ៖ វាខុសធ្ងន់ត្រង់កន្លែងនឹង ខុសធ្ងន់ត្រង់បាយឆ្នាំងរួមនឹងឯង បើសិនជាឲ្យប្រជាជនប្រកបមុខរបរខ្លួនឯង បាយឯកជនទៅ យើងធ្វើការអ៊ីជារួមជាអត់មានបញ្ហាទេ ផលប្រយោជន៍យកមកដាក់រួម ដល់ចឹងទៅវាប៉ះពាល់ អារម្មណ៍ប្រជាជនក៏មិនសូវសប្បាយ ហើយការផ្សាររបស់គាត់មិនគ្រប់គ្រាន់ទេ ព្រោះធ្វើរួមប្រមូលទៅដាក់ជង្រុករួម ឆ្នាំងរួម ខ្ញុំមកហូបបបរ បើគាត់ដាំស្រូវ សួនស្រូវខ្លួនគាត់ ជង្រុកខ្លួនគាត់ គាត់ហូបបាយ ហើយកម្លាំងយកទៅប្រើអីក៏គាត់ធ្វើបាន ។ តែអានេះដល់មកធ្វើរួមហើយ ធ្វើការរួមទៀត ហូបអត់គ្រប់គ្រាន់ សុខភាពគាត់យ៉ាប់ ប្រជាជនមិនពេញចិត្ត ។

សែ ៖ នេះនៅពេល៧៧ៗនឹង កងទ័ពអាចផ្សព្វផ្សាយនឹងវិធានការណ៍នឹងដឹងៗ ហើយយើងចង់ដកក្រុមក្រសួងត្រួតពិនិត្យទៀតទៅដល់សហករណ៍ទៀត ហើយយកកងទ័ពនឹងទៅដឹកនាំក្នុងសហករណ៍នឹងវិញ ធ្វើអត់ទាន់ ផែនការនឹងចាប់ផ្ដើមសកម្មភាពផ្ទៃក្នុងវាវង្គោះវង្គើលបណ្ដោយអាគម្រោងការនឹងបើក ។ ព្រោះយើងដើរតែមួយច្រកពេក វាអត់មានអាកាសែតសាធារណៈនឹងផង តាមតែសេចក្ដីរាយការណ៍របស់បុគ្គលល្អណាស់ៗ តែឆ្នាំងស្ងួតរហូត ។

ភាព ៖ អានឹងមកពីបេះ តាមខ្ញុំវិភាគទៅ សំខាន់ភូមិឃុំស្រុក មុខមាត់ពេក ។

បូលី ៖ មុខមាត់យ៉ាងម៉េច?

ភាព ៖ ចង់រីកមុខរីកមាត់ថាខ្លួននឹង បានដឹកនាំល្អ ធ្វើល្អ តែគៀបសង្កត់ប្រជាពលរដ្ឋ ធម្មតារបាយការណ៍គេធ្វើស្រូវក្នុងមួយហិចតា៣តោន យើងតំឡើងឡើងដល់៣តោនកន្លះ ។ ពីមុនគេឲ្យធ្វើតែមួយហិចតាមួយតោនកន្លះទេ យើងរាយការណ៍បាន២តោន ឬ២តោនកន្លះ ដល់ហើយទិសដៅទៅមុខទៀត ។ គេធ្វើរាយការណ៍អនុវត្តន៍បានហើយ គេធ្វើទិសដៅបន្ដរបស់គេអនុវត្តបន្ត គេថាប្ដេជ្ញាធ្វើស្រែឲ្យបានម៉ាហិចតា៣តោន ទៅ៣តោនកន្លះប្រជាជនយើង (ស្ដាប់មិនបាន) ហើយមិនមែនប្រជាជនស្ម័គ្រចិត្តទេ អនុម័តត្រឹមឃុំស្រុកឃុំនឹងតែម្ដង គេគិតឃើញចឹង ។ ចង់បានតំណែងតែរាយការណ៍មកថ្នាក់លើទៅ ខេត្តនឹងធ្វើបានច្រើនមិនមុខមាត់តួនាទីមិនឡើងទៀត ស្រុកគេមិនរាយការណ៍មកគេចង់បានការផ្សារខេត្តគេមិនបេះខំតទៅទៀត ឃុំគេចង់តួនាទីទៀតគេមិនធ្វើ ភូមិគេចង់បានឡើងតួនាទីទៀតគេមិនធ្វើ យូរទៅអាភូមិនឹងស្រេចតែខ្លួនឯងលែងគិតដែរ អត់ទេ យកអំណាចម៉ង ។

បូលី ៖ ចឹងការដែល ។

ភាព ៖ និយាយពីសម្លាប់ប្រជាជនផ្ទាល់ ប៉ុល ពត មិនបានសម្លាប់ទេ ពួកអាខាងក្រោមនឹងឯង ដែលជាអ្នកសម្លាប់ផ្ទាល់ដែលចាប់វ៉ៃធ្វើបាបប្រជាជនគាស់ដំឡូង លួចដាំបាយ លួចស្ងោរដំឡូង មិនមែន ប៉ុល ពត អ្នកបញ្ជាទេ វាទេអ្នកធ្វើការពិត ។

បូលី ៖ មីងគិតថាការដែលគ្រាន់តែលួចគាស់ដំឡូងហូបនឹង គួរមានទោសស្លាប់ទេ?

ភាព ៖ អត់មានទេ ព្រោះដំណាំគាត់ដាំខ្លួនឯងនឹង គាត់អត់លួចរបស់គេផងនឹង គាត់ដាំជុំវិញផ្ទះជាការឆ្លាតរបស់គាត់ ពីការងាររួម គាត់ឆ្លាតកប់នៅក្បែរផ្ទះគាត់ គេបានរួមផ្សំទេ នេះបន្ទាប់បន្សំកំហុសយើងធ្វើការណែនាំគាត់ទៅ ។

បូលី ៖ ខ្ញុំលើកឧទាហរណ៍មួយ ខ្ញុំទៅសម្ភាសន៍ប្រជាជនម្នាក់នៅខាងកោះញ៉ែក គាត់កូនស្រីគាត់មានផ្ទៃពោះ ឃ្លាន ប្តីអាណិតប្រពន្ធ ទៅចាប់មាន់មួយថាយកមកស្ងោរទៅលួចមាន់យកមកស្ងោរឲ្យប្រពន្ធហូប គេសួរថាមានលួចមាន់ហូបអត់ ។ អត់មានទេ បើអត់មានមែនថា តើក្នុងពោះនឹងមានអត់ បើអត់មានចាំគេឲ្យរួចខ្លួន ។ ហើយវះទៅក៏ស្លាប់ទៅទាំងម្តាយទាំងកូន ។ មីងគិតថាការលួចមាន់មួយយកមកហូប គួរមានទោសដល់ថ្នាក់ស្លាប់ទេ?

ភាព ៖ អត់ទេ ។

បូលី ៖ គាត់ជាចោរទៅលួចមាន់ តើមានទោសគួរស្លាប់ទេ?

ភាព ៖ មិនស្លាប់ទេ ជីវិតមាន់មិនស្មើជីវិតពីរទាំងនៅផ្ទៃផង ទាំងនៅក្រៅផងទេ ។ មនុស្សភ្នែកបួនយើងគិត មិនមែនភ្នែកពីរដូចយើងនៅខាងក្រៅទេ វាអត់ត្រូវមានទោសទេ ។

សែ ៖ ប៉ុនយើងថ្កោលទោសមកវាទៅលើ ប៉ុល ពត ដឹកនាំសង្គម វាខ្វះសមត្ថភាពចុះដល់បាត ។

ភាព ៖ កន្លែងនឹងវាអត់រាយការណ៍ទេ ជឿថាអត់រាយការណ៍លុបបំបាត់ដានតែម្តង ហើយការពិតអាក្បាលឆ្អឹង រឿងកាប់សម្លាប់នឹង ឲ្យសរុបទៅវាតាំងពីសង្គ្រាមជំនាន់យន្តហោះទម្លាក់ផងអីផង សព្វគ្រប់បែបយ៉ាង ។ ហ្នឹង៣០០យប់ ៣០០ថ្ងៃ ស្មានតែតិចណាស់ យើងគិតទៅបូកសរុបនឹងអ្នកស្លាប់សមរភូមិផង ទាំងទាហាន ទាំងអ្នកក្រៅ មិនមែនតែក្នុងកាប់សម្លាប់ក្នុងរណ្តៅយន្តហោះទេ គេប្រមូលឆ្អឹងសព្វគ្រប់ក្បាលសព្វគ្រប់ ខ្ញុំវិភាគឃើញហើយ ។

បូលី ៖ ខាងកន្លែងខ្ញុំស្រាវជ្រាវឃើញមន្ទីរសន្តិសុខ ដែលជាគុក ជិត២០០កន្លែងនៅទូទាំងប្រទេសនៅក្នុងសម័យ៣ឆ្នាំ ។ រណ្តៅសាកសពដែលមានជិត២ម៉ឺនរណ្តៅ ដែលនៅជិតៗមន្ទីរសន្តិសុខនឹង នៅទូទាំងប្រទេស ដែលរណ្តៅទាំងអស់នោះ តាមការសម្ភាសន៍ជាមួយប្រជាជនដែលធ្លាប់បានឃើញ ធ្លាប់បានដឹងនៅក្នុងម៉ុំៗនឹង ជារណ្តៅដែលគេជីកដើម្បីកប់អ្នកទោសដែលគេយកទៅសម្លាប់ចោល ។ ហើយអ្នកស្រាវជ្រាវម្នាក់ ដែលគាត់រាប់សាកសពនៅក្នុង

រណ្ដៅនឹង តែយើងរាប់មិនអស់ទេ យើងរាប់តែមួយចំនួន ធ្វើជាគំរូ ហើយធ្វើការប៉ាន់ស្មានមើល វាអាចមានប្រហែលជាមួយលាននាក់ដែលស្លាប់នៅក្នុងរណ្ដៅនឹង សម័យ៣ឆ្នាំ។ ឃើញថា វាមានចំនួនច្រើន។ ពូ មីង គិតថាហេតុអីបានជាវាមានការកាប់សម្លាប់វាពេលជាលនៅទូទាំងប្រទេសនេះច្រើនម៉េច?

ភាព : ខ្ញុំពិបាកសន្និដ្ឋាន ព្រោះយើងវាមិនបានជួបប្រទះ ហើយយើងក៏មិនបានឃើញសកម្មភាពអស់ទាំងនេះ យើងពិបាកធ្វើការសន្និដ្ឋានណាស់។ ដូចខ្ញុំនិយាយប្រាប់ប្អូនឯងអង្គភាពកងទ័ពជារឿងផ្សេង ពីមូលដ្ឋានឆ្ងាយណាស់។

បូលី : បាទ! អានឹងខ្ញុំជឿថាចឹង ពីព្រោះខ្ញុំសួរកងទ័ព អ្នកខ្លះឪពុកខ្លួនឯងជាប់គុករត់យកសំបុត្រតា ប្រើឲ្យយកសំបុត្រ ខ្ញុំបានសម្ភាសន៍និរសារបស់តា ម្នាក់នៅខាងជុំគិរី យកសំបុត្រមកឲ្យគេស្រាប់តែមើលទៅឃើញឪខ្លួនឯងនៅក្នុងគុក រត់មកជួបតាមវិញ បានតា ឲ្យដោះលែង។ អត់ដឹងថានៅខាងក្រោមានរឿងអីកើតឡើងទេ។

ភាព : អត់ដឹងទេ សូម្បីតែ តា គាត់អ្នកឈរជើងនឹងអត់ដឹងផង។

បូលី : ហើយខ្ញុំឆ្ងល់ថា ហេតុអីបានជាមានការចាប់ខ្លួនសម្លាប់ៗច្រើនម៉េះ?

សែ : គេមានសិទ្ធិ ធ្វើនឹងដូចថាកំបាំងជាជំនាន់ ប៉ុនសំខាន់ធ្វើនឹង សំខាន់ គឺសហករណ៍ ហើយនឹងស្រុក ចោលតំបន់តិចណាស់។

ភាព : អ្នកដឹកនាំវាប្រើអំណាចផ្ដាច់ការតែម្ដង វាធ្វើលុបបំបាត់មិនបាច់រាយការណ៍។

សែ : ពួកខ្ញុំគ្រាន់បែកភ្នំពេញឡើងចូលទៅលេងស្រុកលេងអីនឹងចាប់យកម៉ូតូបាត់រូបអស់២-៣នាក់ អានឹងទាហាន កងទ័ពប្រដាប់អាវុធ នៅស្រុកនឹងទៅមើលម៉ែមើលឪនឹង នៅបាត់ទៀតទៅចូលដល់ក្នុងតំបន់ គឺបាត់ម៉ង ទ័ពស្រុកគេមានអំណាចម៉ង អានឹងខ្ញុំនៅអាល់អែកដែរនឹងជីវិតតស៊ូ យូរអត់មានគិតរឿងចង់ទៅលេងបងប្អូន។

ភាព : ឃើញខ្ញុំនៅភ្នំពេញ ខ្ញុំឲ្យម៉ែខ្ញុំឲ្យទៅលេង ហើយខ្ញុំក៏មិនបានទៅលេងមិនមូលហេតុអី។

សែ : បេះចងកម្មក្នុងទៅចងកម្មក្នុងមក។

បូលី : ថ្នាក់ត្រឹមមេឃុំ មានសិទ្ធិសម្លាប់មនុស្សដោយមិនបាច់មានការជំនុំជម្រះ?

ភាព : ចាំ!

បូលី : អត់មានតុលាការអីកាត់ទោសទេ ហេតុអីបានជាគេធ្វើចឹងមីង?

ភាព : អត់ទេ ខ្ញុំមិនដឹងដែរ ព្រោះមិនអាចដឹង រឿងនឹង វិនិច្ឆ័យវាមិនត្រូវ។

សែ ៖ បើខ្ញុំនិយាយៗចេះ និយាយមនុស្សដែលប្រព្រឹត្តអំពើអាក្រក់ហើយឃោរឃៅ ពេលសភាព ការណ៍ដែលក្រឡាប់នៅក្នុងប្រទេស ពួអណ្ដាតភ្លើងដែលឆេះសន្ធោមករត់ចោលស្រុកហើយ អាមនុស្សនៅក្នុងស្រុកការពារប្រទេសអានឹងគឺល្អ ។ ហេតុអីបាននៅ ដែលហ៊ានយកជីវិតនៅ ពាំ ហើយនៅប្រយុទ្ធមិនស្ដាយជីវិតគឺមនុស្សនឹងត្រង់ អាទៅស្រែកនៅប៉ារីស នៅតូក្យូ នៅ បាងកក នៅប្រទេសក្រៅនោះ សុទ្ធតែពួកអានឹងឯង ហើយត្រឡប់មកវិញប្រែត្រកូល ឃើញច្រើនចឹង ដែលខ្ញុំថាខ្ទួនមួយពាក់អាវ២-៣ជាន់នោះ វាមានចឹងៗបានមជ្ឈិមបក្ស ២១រូបក្បត់អស់១១រូប ១២រូប នៅសល់តែ៩នាក់ទេ ។

បូលី ៖ ក្នុងចំណោម២១រូប?

សែ ៖ នៅសល់តែ៩នាក់ទេ ។

បូលី ៖ ៩ មានពីណាខ្លះ មានតា ប៉ុល ពត មួយ?

សែ ៖ បាទ! ។

បូលី ៖ នួន ជា?

សែ ៖ នួន ជា នៅ ។

បូលី ៖ អៀង សារី?

សែ ៖ ខៀវ សំផន, តា ជួន ជឿន ។

បូលី ៖ បាន៦ហើយ?

សែ ៖ ៦ នៅ៣ទៀត សុន សេន ។

បូលី ៖ ២ទៀត?

សែ ៖ ២ទៀត នៃក! ។

បូលី ៖ តា ពក?

សែ ៖ ហ្នឹងហើយ នៅមួយទៀត ។

បូលី ៖ មិនមែន អៀង ធីរិទ្ធ?

សែ ៖ អ្នកស្រី អៀង ធីរិទ្ធ ដែរ ព្រោះយាយ គាត់ជាប់ដែរ យាយ ខៀវ ប៊ុណ្ណារីដែរនឹង គាត់ អ្នកស្នេហាជាតិដែរ នៅដែរ ។

បូលី ៖ មាតា បដិវត្តន៍ ខៀវ ប៊ុណ្ណារី?

សែ ៖ បាទ! យាយនឹង តាំងពីសម័យអន្តម្ចាស់នោះ គាត់ក្រសួងសហជីវនីតាំងពីដើមមក ខ្ញុំនៅ ភ្នំពេញខ្ញុំស្គាល់ ។

បូលី : សហជីវនីយ៉ាងម៉េច?

សែ : គាត់ខាងក្រសួងដែរ ។

បូលី : នារី?

សែ : បាទ! មន្ត្រី ។

ភាព : នារី ដូចក្រសួងកិច្ចការនារីយើងសព្វថ្ងៃនឹង ។

បូលី : មើលការខុសត្រូវនារីទូទាំងប្រទេស?

សែ : ហ្នឹងហើយដែលចិញ្ចឹម តា ពត ឲ្យទៅរៀននោះ យាយនឹងដែលមានប្រាក់បៀវត្សរ៍កាលនៅកម្លោះក្រមុំនោះ ។ ឲ្យ សាឡុត ស ខំរៀន មុនដំបូងរៀនខាងតិចណិចទេតានឹង ។ ប៉ុនដល់រឿងការវិនិច្ឆ័យសង្គម ហើយនឹងអាជួរក្នុងបក្សប្រចូកប្រចល់នឹង ដែលអគ្គាធិប្បាយនឹងសំខាន់ ស៊ីវ ហេង មនុស្សដែលមិនត្រឹមត្រូវទេ ។ នេះ លោក សម សារី នេះក៏ខ្មែរក្រហមដែរ ។

បូលី : ចឹង?

សែ : បាទ! អ៊ិន តាំ នេះក៏ខ្មែរក្រហមដែរ ប៉ុនសុទ្ធពួកវង្វេងធាតុ វាត្រឡប់យករូបតែខ្លួនឯង ចឹងបានចង់កម្មមកពួកនេះវិញ ។

បូលី : អ្នកដែលសម្លាប់គេ ដែលរត់ទៅនៅស្រុកក្រៅអីចឹងទៅ?

សែ : បាទ! ភាគច្រើនគឺចឹង ។

បូលី : ដូរឈ្មោះទៅជាដេវី ម៉ៃឃីលអីអស់ ។

សែ : បាទ! ខ្ញុំវិភាគមិនខុសទេ ។ ខ្ញុំឃើញចេះ ឃើញ ប៉ុល ពត មិនសរសើរអីគាត់ទេ គ្រាន់សភាពការណ៍ទល់មុខចឹង វាលំអៀងអីផ្សេងៗ គ្រាន់បោះជើងចូលថៃមួយចំហៀងមិនព្រមគាត់សុខចិត្តគៀមនៅតែទ្វារព្រំដែននឹងរហូត មិនដឹងម៉េចគាត់ ។ តាំងសម្បថខ្លួនគាត់ម៉េចចឹងទេ ប៉ុនបើទៅបារីស ទៅស៊ីស ទៅ ព្រោះគាត់មានកិច្ចការងាររបស់គាត់មួយទៅនឹង ។

ភាព : គាត់លាលែង គាត់សុំទៅស៊ីសវិញតើ ប៉ុនតាមិនឲ្យទៅ ។

បូលី : គាត់លាលែងឆ្នាំប៉ុន្មាន?

ភាព : ឆ្នាំ៩៥ ។

បូលី : ឆ្នាំ៩៥?

ភាព : ចា៎! ៩៥ ៩៦ ៩៧ ។

សែ : ហ្នឹងគាត់ខ្សោយនេះហើយ ខ្សោយជង្គើមហើយ ប៉ុនប្រើថាមពលអ៊ុកស៊ីសែនជួយ ។

បូលី ៖ គាត់ចាប់ផ្ដើមប្រើអានឹងតាំងពី៩៥មកហើយ?

ភាព ៖ បាទ! ៩៥ ៩៦ ។

បូលី ៖ គាត់មានជម្ងឺអី ខ្សោយដង្ហើមនឹង?

ភាព ៖ គាត់ប្រើអ៊ុនស៊ីសែនជាប់ មិនដឹងរោគគាត់អី ។

សែ ៖ ខួរក្បាលវិភាគច្រើនពេក ។

បូលី ៖ ខ្សោយបេះដូង?

សែ ៖ បាទ!

បូលី ៖ ឬក៏បេះដូងរីកក៏អីចឹង?

ភាព ៖ គាត់ចង់អស់អ៊ុកស៊ីសែន គាត់សុំទៅដាក់អ៊ុកស៊ីសែនវិញ គាត់ថាគាត់សុំសម្រាកពីការងារ ។ ដល់ហើយគេរៀបចំ៩៩ថ្មីនេះ ជំនួសមុខគាត់ តា សូ សារឿន នេះយកមកធ្វើ៩៩ថ្មី គេហៅ៩៩៧ ។

បូលី ៖ ៩៩នឹងជាអី?

សែ ៖ គណៈកម្មការខាងលើ ។

បូលី ៖ ដឹកនាំ?

សែ ៖ បាទ! ដឹកនាំកិច្ចការងារប្រទេស ។

បូលី ៖ មន្ទីរ៩៩ ឬជាអី?

សែ ៖ អត់ទេ គណៈកម្មការតំណាងឲ្យជំនួសមុខ គាត់នៅចាំមើលសិន ។

បូលី ៖ គណៈកម្មការ៩៩នឹង មានសមាជិកពីណាគេខ្លះ?

សែ ៖ មិនដឹងអ្នកណាៗ ច្របូកច្របល់ច្រើនពេក ។

ភាព ៖ មាន តា ម៉ុន, តា រឿន ប្រធាន ។

បូលី ៖ តា រឿន ប្រធាន សូ សារឿន ប្រធាន?

ភាព ៖ ប៉ុន្មានរូបទេ ខ្ញុំភ្លេច ខ្ញុំចូលរួមកម្មវិធីប្រកាសដែរ មករៀននៅនឹង ។

បូលី ៖ គេប្រកាសនៅឆ្នាំប៉ុន្មាន?

ភាព ៖ ខ្ញុំភ្លេចមិនដឹង៩៥ ឬ៩៦ ។

បូលី ៖ ប្រហែលជា៩៥ ពីព្រោះ៩៦ វាមានកើតព្រឹត្តិការណ៍សម្លាប់ សុន សេន នេះ?

ភាព ៖ ហ្នឹងហើយ៩៥ ពីត្រឹមវៃរំដោះព្រះវិហារបាន ។

សែ ៖ សុន សេន មកពីគាត់ទាំងអស់ទេ ទំនាស់ជាមួយ០៥តាំងពីសម័យសង្គ្រាមនោះ ខ្ញុំដឹងទំនាស់ ។

បូលី ៖ ទំនាស់យ៉ាងម៉េច?

ភាព ៖ ទំនាស់ត្រង់ថា អារម្មណ៍របស់គាត់នឹង វាបញ្ញាជន ហើយ០៥វាកសិករ ដល់ចឹងថ្វីអារុំធអីផ្សេងៗគាត់វាកម្រិតទាប ហើយ ប៉ុល ពត នេះគាត់យកចិត្តទុកដាក់លើ០៥នេះដាង ដល់ពេលដែលចាញ់វៀតណាមដែលចូលមក៧៩នេះ ០៥ដិះដីរទៅញកន្លែងតា សុន សេន នៅខាងកើតនឹងអត់ឲ្យចូល ។ ចាត់ទុកគាត់ជាមនុស្សរដទៃវិញ ។

បូលី ៖ នៅទន្លេល្ពៅនឹង?

សែ ៖ បាទ! កាលមុននៅរតនគិរីនោះ វាមានទំនាស់ពីនឹងមក ។

បូលី ៖ សុន សេន គាត់នៅរតនគិរីដែរកាលនឹង?

សែ ៖ សុន សេន យើងនៅក្រចេះ ។ កាលនឹងនៅក្រចេះ មិននៅទីក្រុងទេ ។

ភាព ៖ ០៥ទៅពីរតនគិរីទៅជួប ដិះដីរទៅ ។

សែ ៖ ដល់ទៅជួប អត់ឲ្យចូល ។

បូលី ៖ អត់ឲ្យចូល?

ភាព ៖ អត់ឲ្យចូលជួបសោះ ។

សែ ៖ គាត់ថានឹងកងនឹងវាទៅជាដោយខ្មែក អត់ទុកចិត្ត នេះទៅចេះវិញទៅ ។ ប៉ុនដល់កងនឹងទៅយកពីក្រចេះមក កងនឹងទៅសែង ។

ភាព ៖ ទៅសែង សុន សេន មក ។

សែ ៖ ដែលហើមជើងហើមដៃ ។

ភាព ៖ តា ពក អីទៅតែកង០៥ ទៅយក ។

សែ ៖ ខ្ញុំនឹងហើយទៅយក ។

បូលី ៖ ចឹងអាកាលដែលវៀតណាមជិតវ៉ៃចូល៧៩?

សែ ៖ ហ៎! វ៉ៃចូលហើយ ទៅយកមកពីក្នុងមក តែពីរនាក់នឹង ដែលយកមក ។

បូលី ៖ ចឹង សុន សេន មិនមែនរត់មកព្រំដែនមកជាមួយ?

ភាព ៖ អត់ទេៗ កម្លាំងចុះពីលើភ្នំទៅទទួល ។

សែ ៖ គាត់គេចចេញពីទីក្រុងមក ទៅយើងខាងក្រចេះនឹង ។

ភាព ៖ យកពីនេះទៅ យកមី យកត្រីខ យកអន្លង់អី យកទៅទទួលមកនឹង តា គង់ អីហូបតែថ្ងៃ ឃ្លោកនឹង ។

សែ ៖ ពួកខ្ញុំនឹងហើយអ្នកទៅយកកម្លាំងទៅសែងទៅអី តា សេន នឹងមក ដល់លើភ្នំ ដើរអត់រួច ។ ហើយកង០៥នឹង អ្នកឲ្យទៅយកនឹង ។

បូលី ៖ ចឹង តា សុន សេន ជាមួយ តា ពក នៅក្រចេះនោះ ពេលដែលវៀតណាមវៃបាន ភ្នំពេញហើយនឹង?

ភាព ៖ ចាំ! ទៅយកមិនចេះជិតណា ។

សែ ៖ ដួរចិត្តគាត់លំអៀង ជាមួយតា០៥ សុន សេន ។

បូលី ៖ ចឹង សុន សេន នឹងគាត់មិនពេញចិត្តជាមួយតា០៥?

សែ ៖ បាទ! គ្រាន់ជីវប្រវត្តិ សុន សេន នឹងគាត់ខ្មែរកម្ពុជាក្រោមតើ ។

ភាព ៖ គាត់ក៏រៀងនេះដែរ គានឹងរយៈជាមួយយួនខ្លាំងដែរនឹង ។

សែ ៖ បម្រុងឲ្យទៅស្រុកកម្ពុជាក្រោមវិញ គានឹង មុនទៅដឹកនាំ ប្រជុំដឹកនាំគាប្រុងឲ្យទៅ រៀបចំ កម្លាំងឲ្យទៅ ។

ភាព ៖ កាលមុនស្លាប់នឹង តា ឆន ប្អូនថ្លៃគាត់នឹងដែលទៅសារភាពមុននឹងយកសារមក យកមកជួប ឲ្យ សុន សេននឹង ប៉ុនយកមក០៥ចាប់បាន ។ ចាប់គានឹង គេឲ្យតា សុន សេន ចូលទៅ ក្នុងទៅ គេឲ្យគ្រប់គ្រងនៅកម្ពុជាក្រោម ។

សែ ៖ ហ្នឹងហើយ នៅបក្សពលករ ឬបក្សស្អីគេ ។

ភាព ៖ នៅបក្សអីគេ ។

បូលី ៖ (ស្តាប់មិនបាន) ពីរដ្ឋាភិបាល ឬពីវៀតណាម?

សែ ៖ ពីខាងក្រោមមក ។

ភាព ៖ មិនដឹងពីខាងណាទេ ឆន អ្នកនាំមក ព្រោះមុននឹងទៅនឹង អា តា ឆន, សុន សេន អ្នកឲ្យ ទៅដែរនឹង ប្អូនថ្លៃ ។

បូលី ៖ ឆន នឹងចុះចូលមុន?

ភាព ៖ ចុះចូលមុន ។

បូលី ៖ ឆន នឹងប្អូនថ្លៃ?

ភាព ៖ ប្អូនថ្លៃគាត់ ។

សែ ៖ ឆន នៅ៨០២នឹង ។

បូលី ៖ តា ឆន ៨០២?

ភាព ៖ ចា៎! ប្អូនថ្លៃ តា សុន សេន ។

បូលី ៖ ចឹង តា ឆន នេះប្អូនថ្លៃ តា សុន សេន?

ភាព ៖ ចា៎!

សែ ៖ ហើយ ឆន នេះតាំងពីប្រវត្តិពីដើមមកលើការផ្គត់ផ្គង់គ្រប់គ្រង០៥នេះទេ ។

បូលី ៖ ព្រោះ៨០២នេះ បំបែកចេញពី៨០១ដែរ?

សែ ៖ បាទ! ជាគំនិតរបស់គាត់ សុទ្ធតែធ្វើមេបញ្ជាការផ្សេងៗសុទ្ធតែគាត់រៀបចំឲ្យទាំងអស់ ដល់បាន ។

បូលី ៖ ហើយ ឆន នឹងប្រពន្ធគាត់ឈ្មោះអី?

ភាព ៖ ឈ្មោះស្អីទេ ប្អូន សុន សេន ខ្ញុំភ្លេចឈ្មោះបាត់ហើយ យូរហើយមិនដឹងឈ្មោះអី ។

បូលី ៖ ហើយអត្ថន័យនៅក្នុងសំបុត្រនឹងវាយ៉ាងម៉េច ដឹងទេ ដឹងតា០៥ចាប់បាននឹង?

ភាព ៖ គាត់គ្រាន់ប្រាប់យើងថា សំបុត្រត្រូវហៅទៅកម្ពុជាក្រោម មានរយៈគេមកពីនឹង គាត់ថាចឹង

សែ ៖ ព្រោះខ្មែរកម្ពុជាក្រោមគេនឹងសេរីហើយ នឹងវៀតណាមហើយចឹង ។

ភាព ៖ គាត់ប្រាប់ថានេះ សំបុត្រនៅហោជៅអាវ អាចមានរាយការណ៍ឲ្យ តា ដែរ តែ តា មិនជឿខ្លាចយើងសរសេរក្លែងបន្លំ ។

បូលី ៖ ហើយហេតុផលអី ដែលគេសម្លាប់ សុន សេន?

ភាព ៖ អត់ដឹង គ្មានដឹងរឿងទេ ស្រាប់តែឮស្លាប់ហើយបានដឹងខ្ញុំ អត់មានដឹងរឿងហេតុផលអីផង ។

បូលី ៖ អ្នកណាគេអ្នកសម្លាប់ តា សុន សេន?

ភាព ៖ ផ្ទាល់ដៃក៏មិនដឹង ព្រោះគាត់នៅនេះៗនៅលើភ្នំដាំនេះ ហើយខ្ញុំនៅទំនប់ដាច់នោះម៉េចដឹងរឿង ។

សែ ៖ ខ្ញុំទៅគ្រប់គ្រងមន្ទីរជុំវិញកើតនឹងដែរ ។

បូលី ៖ អ្នកណាគេជាអ្នកបញ្ជាមក?

ភាព ៖ វាមិនដឹង ។

សែ ៖ វាពិបាកណាស់រឿងរ៉ាវ ។

បូលី ៖ អ្នកដែលអាចបញ្ជាសម្លាប់ សុន សេន បាន មិនអាចតូចទេមើង?

ភាព ៖ ចា៎!

បូលី ៖ អ្នកតូចមិនហ៊ានបញ្ជាដល់ថ្នាក់សម្លាប់ សុន សេន មេបញ្ជាការកងទ័ពមួយទាំងមូល ។

ភាព ៖ មិនដឹងៗមុខថាអ្នកណាអ្នកសម្លាប់ពិតប្រាកដ ខ្ញុំមិនដឹងៗថាគាត់ស្លាប់អស់ ។

បូលី ៖ ១១នាក់ទាំងអស់?

ភាព ៖ ចាំ!

បូលី ៖ ទាំងកូនទាំងប្រពន្ធទាំងអ្នកបើកឡានទាំងអស់?

ភាព ៖ ទាំងអស់ ។

បូលី ៖ ហើយពូសួរថា កូនស្រីត្រូវគេរំលោភទៀត មុននឹងសម្លាប់?

ភាព ៖ អត់អាចទេ មិនអាចនៅមានពេលរំលោភទៀត ព្រោះយប់ចឹងខ្លាចប្រទូសប្រទះទៅវារបូតខោ បើរំលោភមិនអាចទេ ព្រោះវាប្រាវៗយកតែម្តងបើយើងប៉ាន់ស្មាន ហើយអ្នកណានៅមានពេលរំលោភ ។

បូលី ៖ ពូសួរថាអូរទៅដល់មាត់ស្ទឹង ហើយបានយកមកវៃចោល បានគេយកសពនឹងមកដុតរួមគ្នា ។

សែ ៖ ប្អូនបានទៅដល់ពួក៩២០ទៅសួរដឹងរឿងរ៉ាវ ។

ភាព ៖ គេអ្នកឡើងទៅដល់បានដឹង ឯងមិនដឹងទេ បើកងទ័ពខាងខ្ញុំក៏អត់ដឹងដែរ ។

បូលី ៖ ខ្ញុំសម្ភាសន៍ជាមួយបងប្អូនពូមីងនៅអន្លង់វែងយើងនឹង គាត់ថា តា០៥ និង តា០៦ នេះជាអ្នកបញ្ជាឲ្យមក ។ ប៉ុល ពត បញ្ជា តា ០៥, ០៦ មកចាប់ សុន សេន?

សែ ៖ អត់ទេ ។

បូលី ៖ ប៉ុន្តែដោយសារ តា០៥, ០៦ នេះមានគំនុំជាមួយ សុន សេន ក៏ធ្វើជ្រុលលើសបញ្ជាសម្លាប់តែម្តង ។ សម្លាប់ហើយទៅប្រាប់ ប៉ុល ពត វិញ ថាស្លាប់ហើយ ចឹងប៉ុល ពត ថាមិត្តឯងនេះធ្វើខុសធ្ងន់ណាស់ យើងចាញ់ប៉ុន្នេះ ។ ពេលដែលសម្លាប់ សុន សេន នេះ តាម៉ុក ក៏ចាប់០៥,០៦នេះ ដាក់ទ្រុងសារិកាកែវ ហើយយកទៅកប់ទាំងរស់ កប់ឈរទៀត ។ អានឹងអ៊ីដែលខ្ញុំពូពីពូមីង ដែលគាត់បានប្រាប់ ដែលគាត់នៅជិតកន្លែងនឹង ។

ភាព ៖ គេអ្នកនៅជុំវិញ តា កន្លែង តា ។

បូលី ៖ ហ្នឹងគេនិយាយចឹង ពូយល់ឃើញម៉េចដែរ?

សែ ៖ វិភាគត្រូវដែរ ព្រោះខ្ញុំនៅឆ្ងាយ រឿងរ៉ាវរបស់គេ ។

ភាព ៖ អត់ដឹងម៉េច បើយើងនៅឆ្ងាយពីគាត់ បើយើងនៅទំនប់ដាច់ ប្អូនឯងមើលជិតណា ។

បូលី ៖ ដំណើរដើរទេងគឺវាចេញមកពីចេះ ដែលខ្ញុំពូគេនិយាយ តា ប៉ុល ពត នេះបញ្ជាឲ្យ តា ម៉ុក និង តា សុន សេន ទៅបញ្ចុះបញ្ចូលខាងប៉ៃលិនកុំឲ្យផ្តាច់ខ្លួន ប៉ុន្តែពេលដែលទៅដល់នឹងវាបរាជ័យៗនេះក៏ចាប់ តា ម៉ុក និង តា សុន សេន នេះឃុំខ្លួនមួយរយៈ ប្រហែលជា២-

៣ខែ តែ តា ម៉ុក គាត់អាចដោះខ្លួនរួចមកបាន។ ហើយក៏លែងមកវិញទេ។ តែក្រោយមកទៀត ដូចថាពួកថា សុន សេន មានគម្រោងផែនការចង់ចុះចូលរដ្ឋាភិបាល ចឹង តា ប៉ុល ពត នេះបញ្ជា០៥, ០៦ មកចាប់ខ្លួន សុន សេន តែ២នាក់នេះធ្វើជ្រុល គឺសម្លាប់តែម្តងដោយសារគំនុំផ្ទាល់ខ្លួនផង។

សែ ៈ ខ្ញុំដឹងតែ តា សុន សេន នេះមានគម្រោងការ ចង់ដឹកនាំកម្ពុជាក្រោម។

ភាព ៈ តា សុន សេន នៅលិចនឹង ប៉ុល ពត ប្រើ តា ម៉ុក ឲ្យទៅយកតា សុន សេន ទៅសំរួល ខាងនោះ នៅបន្ទប់ពួកខាង តា មុត តាអីនោះ តា អ្នកនៅនោះនឹង។ តា សុន សេន គាត់នៅនោះស្រេច។

សែ ៈ កាលនោះគេវៃនោះមុន គេបុករុកនោះមុន ប៉ុល ពត គ្មានអំណាចធានាសុវត្ថិភាពនៅនោះមុន តា គាត់ទៅខ្លួនគាត់ ទៅតាំងពិការ។

ភាព ៈ តា ទៅយក សុន សេន មកតើ។

សែ ៈ ប៉ុន្តែវាអាចមានប្រតិកម្ម ត្រង់ថា តា ពត បញ្ជាយ៉ាងម៉េចៗ តា អាចមានថ្នាក់ចិត្តច្រើនដែរ ខ្ញុំគ្រាន់ដឹងសាច់រឿងទេ គាត់សុខចិត្តវាលូនមកទាំងជើងពិការនឹង បានមកជួបកងកម្លាំង គេគាំទ្រគាត់គេយកគាត់មកដល់នេះវិញ។

បូលី ៈ គាត់វាលូនយ៉ាងម៉េច គាត់វាចេញពីកន្លែងឃុំឃាំងមក?

សែ ៈ មិនឃុំឃាំងអីទេ សមរភូមិ ចុះគាត់មេបញ្ជាការ តា ម៉ុក សម្រាប់បញ្ជាការទូទាំងប្រទេស សុន សេន គាត់ក្រសួងការពារជាតិតើ តួនាទីខុសគ្នា។

ភាព ៈ បើកាលនោះគេកំពុងច្របូកច្របល់អុកឡុកពេញនឹង។

សែ ៈ តា បានអគ្គបញ្ជាការ។

បូលី ៈ ចឹងមិនមែន សុន សេន?

សែ ៈ មិនមែន សុន សេន ទេ ក្រសួងការពារជាតិ។

បូលី ៈ ដំណែងក្រសួងខ្យល់?

សែ ៈ បាទ! តា ទេ ដែលក្រឡឹងជុំវិញនេះ កន្លែងណាដែលស្មុគស្មាញលំបាកយក តា ទៅ គាត់ដោះស្រាយបញ្ហា ទោះបីពិការហើយក៏ដោយ។

ភាព ៈ តា គាត់ទៅតែប្រជុំកងទ័ព ហើយដល់ពេលសភាពការណ៍អុកឡុកចឹងទៅ គាត់បណ្តុះខ្លួនចេញមកជាមួយ តា សុន សេន អត់មានជាប់គុកទេ។ គ្រាន់បណ្តោះខ្លួនក្នុងនាមវាលំបាក ដូចថាវាចង់ចូលអន្ទាក់គេណាចឹងទេ ទម្រាំគេចផុតមក បានជួបកម្លាំងប្រដាប់អាវុធជួបមក។

សែ ៖ កាលនឹងមាន តា ភីម, មាន លោក ដន អីគេ បម្រុងចូលមកក្នុងនេះជាមួយរដ្ឋាភិបាលនេះ វាមានការលំអៀងច្រើនដែរ ។

ភាព ៖ រកចាប់ តា ដាក់គុក ។

សែ ៖ ចាប់ តា ដាក់គុក ពួកអានេះទៅទាំងអស់នឹង បក្សខាងលិច បក្សខាងកើតឥឡូវ ។

ភាព ៖ មុននឹងគាត់ចេញទៅ គាត់ហៅមេបញ្ជាការមកប្រាប់ហើយបាត់ហើយ គាត់ថា តា គាត់ហៅតែ បងទេ ។

សែ ៖ ហៅ តា ពត ហៅបង គាត់គោរពតែ តា ពត មួយនឹង ។

ភាព ៖ ហៅបងៗ ប្រើខ្ញុំទៅលិច ទៅសម្រុះសម្រួលខាងប៉ៃលិនៗកំពុងច្របូលច្របល់ថា ចង់សារភាពអីចឹង ថាតា មុត មេខ្លោងខាងសារភាពទៀតនោះណា ។

បូលី ៖ អ៊ូ! តា មុត មាស មុត?

ភាព ៖ តា មុត កូនប្រសារគាត់ ។

បូលី ៖ តា មុត មេខ្លោងមែនហើយអត់ទេ?

ភាព ៖ អត់ទេ ។ តា មុត មកប្រជុំនេះដែរតើ មុនសមាហរណកម្មនេះ មកជួបគ្នាដែរនឹង ។ ដល់ចឹង ក៏គាត់ថាគាត់ទៅលិច បើសិនជាបាត់គាត់រយៈពេលតែ១០ថ្ងៃ ឬកន្លះខែឲ្យទៅតាម គាត់មិនដល់១០ថ្ងៃ ត្រឹមម៉ាអាទិត្យ បាត់គាត់មួយអាទិត្យឲ្យទៅតាម ព្រោះគាត់ទៅអាចរយៈតែ៣ថ្ងៃទេ តែលើសពី៣ថ្ងៃទៅឲ្យខាងនោះទៅតាម ។ គ្មានអ្នកណាបាននៅស្ងៀមនោះចាំតែមើល៣ថ្ងៃ ៤ថ្ងៃ តា ដល់វិញមានអី ។

សែ ៖ តែពួកខ្ញុំនេះ មិនបាច់ទៅតាមផ្លូវ (ស្តាប់មិនបាន) កាត់ពីនេះទៅឡើងទៅដល់ តែ៣ថ្ងៃដល់បាត់ឥឡូវនឹង ។

បូលី ៖ តាមសម្តីអ្នកយាមតាម្នាក់ ព្រោះតា គាត់ដាច់ជើង ឈ្មោះ ម៉ៅ ដែលឮឈ្មោះ?

ភាព ៖ ម៉ៅ ចៅគាត់ ។

បូលី ៖ ម៉ៅ ចៅបង្កើត ហើយចៅអី?

ភាព ៖ ចៅបង្កើតដឹង ម៉ៅ ។

បូលី ៖ ប៉ុន្តែមិនមែន ម៉ៅ អ្នកនិយាយទេ គឺពួកម៉ាក់ ម៉ៅ ធ្វើការជាមួយគ្នាដែលគេជួបគ្នាគេប្រាប់គ្នា ថា ម៉ៅ អ្នកអៀវតាមក ជាមួយនឹង សុន សេន, ខៀវ សំផន អី ។ ពេលដែលមកដល់តាមផ្លូវនេះ គឺខាង អៀង សារី, អ៊ី ឈាន នឹង គេបញ្ជាឲ្យកូនចៅមកបាញ់ តា ម៉ុកចោល ប៉ុន្តែពេលកងទ័ពមកដល់ តា គាត់និយាយម៉េចទេ ពួកនឹងគេទន់ចិត្តមិនត្រឹមតែមិន

បាញ់ចោល ថែមទាំងអៀវ តា ដល់ព្រំដែនថៃ ហើយ តា គាត់ឲ្យលុយពួកនឹងត្រឡប់ទៅវិញទៅ ព្រោះគាត់ស្តាយលុយមួយសាក់កាដូទៅដែរ ។ ដល់មកដល់នេះ ម៉ៅ ទូរស័ព្ទមក ប៉ុល ពត ថា តា មកដល់ព្រំដែនហើយ ឲ្យយកឡានមកទទួល ប៉ុល ពត ថាយកសាំង ប៉ុន្មានលីត្រនឹង ដុតទាំងឡាន ដុតទាំងមនុស្សចោលម៉ង ព្រោះបរាជ័យ ។ កន្លែងនឹងដែល តា គាត់ខឹង ហើយខឹងពីណាត្រូវជូនគ្នាសម្លាប់ សុន សេន ផង តា ម៉ុក ក៏ចាប់ ប៉ុល ពត តែម្តងទៅ ។ នេះ តាមខ្ញុំឮសម្តីគេនិយាយ ។

ភាព : គេមានការប្រជុំដែរ ប៉ុនយើងចង់និយាយថា ថ្នាក់លើៗយើងអត់ដឹងទេ ក្រោយពី តា មកពីនោះវិញ ប្រជុំកន្លែង ប៉ុល ពត នឹងឯង គ្រប់កងពលទាំងអស់ទៅចូលរួមប្រជុំទៀតចឹងទៅ ។ ហើយ តា០៥នេះ គាត់អត់បានចូលរួមទេ គាត់នៅព្រះវិហារ ។

បូលី : ប្រជុំកន្លែងណា?

ភាព : កន្លែងផ្ទះ ប៉ុល ពត ។

សែ : ប្រោក ។

បូលី : ក្បាលទន្សោង?

សែ : អឺ! ក្បាលទន្សោងនឹង ប្រជុំនឹង ថាឲ្យទៅនៅកន្លែងនឹង ព្រោះ តា គាត់នៅខាងលិច ។

ភាព : ដល់សភាពការណ៍ខាងយើងនៅឆ្ងាយណាស់ យើងក្តាប់ប្រយោជន៍ សំខាន់គេអ្នកប្តុសគល់ទេ បានគេទទួលពត៌មានច្បាស់ ហើយគេបានឃើញខ្លះ បើយើងឮតែតាមខ្យល់ ឮតាមតែអ្នកផ្តល់ពត៌មានវាអត់ច្បាស់ទេ ធម្មតាទេក្អែកមួយវាទៅជាក្អែក១០ គេឃើញប៉ុននេះគេទៅនិយាយហួសប៉ុននោះក៏មានដែរ វាលំបាក អាយកនឹងវាមិនមែនជាផ្លូវការទេ ចឹងបានថាសភាពការណ៍ប្រែប្រួលមួយរយៈដែលបែកបាក់ប្រទេសនឹង ខ្មែរក្រហមខ្ញុំក្តាប់មិនបាន មិនដឹងថា អ្នកណាខុសធ្ងន់ជាងអ្នកណា ហើយក៏មិនដឹងថាអ្នកណាក្បត់ អ្នកណា ។

សែ : ខ្ញុំគ្រាន់ឃើញស្ថានការណ៍នឹង ដែលខ្ញុំបម្រុងសមាហរណកម្មមុន ខ្ញុំឃើញថាផ្ទៃក្នុងថ្នាក់ខាងលើបំផុតហើយមានការរង្គោះរង្គើលគ្នាសង្គ្រាមមិនអាចទទួលជ័យជំនះទេ ខ្ញុំគ្រប់គ្រងកម្លាំងកងខ្ញុំវាចំនួនជាង២០០០នាក់ដែរ ចង់សមាហរណកម្មមុនបោះឆ្នោត ប៉ុនគេឃាត់ មើលទៅគេអត់មានផលប្រយោជន៍អីទៀតទេ ទឹកចិត្តអ្នកចំបាំងវាត្រូវតែបង្រួបបង្រួមជាតិ ។

ភាព : ខ្ញុំមានតែខ្ញុំស៊ូមិនចេញពីនេះ គេផ្អើលរត់ឡើង២-៣យប់ ខ្ញុំចូលវេចនំការក្មេងនៅកន្លែងខ្ញុំ ។

បូលី : កាល៩៨ គេរត់ទៅភូណយ បាយតាប់អីនឹង?

ភាព : ចា៎! គេរត់ស្រួលចុះស្រួលឡើងអស់២យប់ហើយ ។ ខ្ញុំនៅក្មេងៗដឹកទឹកវេចនំការចូលរោង ថ្ងៃនេះ ខ្ញុំមានចេញទៅណា ។

សែ : គេចង់ចោទខ្ញុំទៀត ។

ភាព : មិនមែនចង់ទេ គេចោទ ។

សែ : ថាចុះម៉េច កងនេះមិនចេញ ។

ភាព : ហើយខ្ញុំការហើយខ្ញុំដាក់បាសហើយទៀត ថ្ងៃនោះ ។

បូលី : ដែលគេរត់ ព្រោះប្រៀបនឹង?

ភាព : ហ្នឹងហើយ តា ដេរ មកតាមពង់ ចុះស្អិកន្ទែងហ្អែងអីក៏ក្ដុងក្ដាំងសម្បើមបាសអាណា ថាម្ដុំពួកខ្ញុំ គាត់បញ្ចោរដេរពីនោះមក ។ ដល់ពេលការហើយគេរត់ឡើងលើភ្នំនឹង ខ្ញុំអត់ទាន់ចេញទេ ។ គ្រួសារខ្ញុំគេមកធ្វើការនៅនេះ ខ្ញុំនៅភូមិនៅឡើយ នៅប្រមូលអីវ៉ាន់ប្រដាប់ការនឹងដល់មកនេះ បង គង់ គាត់ស្ដីឲ្យមានអ្នករាយការណ៍ឲ្យ គង់ ថា ខ្ញុំនេះត្រៀមរៀបចំអត់ឡើងភ្នំទេ សម្រាប់ចេញចាំថាទៅជាមួយ ទុយ ប៊ុយរ៉េត ណានៅប្រកលំទងចាស់ ខ្ញុំអត់ដឹងទុយ ប៊ុយរ៉េត មកផងនឹង ។ មកអត់ហៅ អត់ដឹង វាអត់ដឹង ។ ដល់ចឹងគេចោទខ្ញុំស្រេចដល់ឡើងដល់លើភ្នំគេឡើងទៅមុន ខ្ញុំទៅដល់លើភ្នំ ស្រាប់តែគេថាអឺ! ក្រែងទៅក្នុង មកនេះដែរ ។ នោះស្ដាយអស់ទាស់ បើសិនដឹងចោទប្រកាន់ចឹង អញទៅម៉ង អញខ្ជិលនៅ ។

សែ : តេស្ដ គាត់តេស្ដមកគាត់ថាកងឯងបើថាមិនកើតទេ ទៅរមៀតទៅ មិនបាច់ឡើងភ្នំទេ ឡើងភ្នំវាលំបាកណាស់ ។

ភាព : បើកាលនោះទៅរមៀត តាមគាត់ប្រាប់បាត់ហើយ ។

សែ : គាត់ឲ្យទៅតើ គោក្របីវាច្រើន មួយគ្រួ ខ្ញុំវា៧-៨គោនោះ សុទ្ធកូនកាត់ផង ។

ភាព : ការពិតទៅ គាត់ដេញដែរ ទៅដល់លើភ្នំ តា ម៉ុក គាត់ថា រត់ធ្វើស្អី ម៉េចក៏មិនទៅនៅផ្ទះហើយខ្មែរគ្នាឯងនឹងរត់ធ្វើអី ឲ្យតែគេមកៗទៅ កុំឲ្យតែគេបាញ់សម្លាប់បានហើយ ប្រាប់ថាយើងប្រជាពលរដ្ឋ យើងអត់មានដឹងរឿងទេ ហ្នឹងហើយចុះចូលសុខស្រួលហើយ កុំចោលផ្ទះសម្បែង ដឹកកូនជញ្ជូនចៅនាំគ្នាចុះវិញ គាត់ដេញតើ ។ ប៉ុនយើងវាមិនហ៊ាន ធម្មតាយើងឡើងហើយ ចុះមកវាខ្លាច មិនហ៊ាន ។ បើមិនរត់កាលនោះទាំងអស់នោះ ពួកខាងនេះឲ្យទៅខាងរមៀតខាងអីនោះវាចប់បាត់ហើយ ។

បូលី : ហើយកាលនឹងមីងទៅខាងណា?

ភាព : ឡើងទៅលើភ្នំនឹងគេ ក្រោយគេហើយទៅឡើងតាមគេទៀត ។

សែ : ទើបដល់នេះ នេះដល់ស្ពានថ្មនេះផ្ទះអាវុធមកនេះបាត់ហើយមកខ្ញុំលាន់គគ្រឹក ។

ភាព : ខ្ញុំទៅដល់ស្ពានថ្ម ស្ពានអូរជីកនឹង ដល់នឹងផ្ទះអាវុធបាត់ ។

សែ : ចុះសុទ្ធតែកូនស្រីតូចៗ កាលនឹង ហើយគោ៧-៨ ។

ភាព : វេទនាណាស់អូន កាលតស៊ូនេះវាអស់ ។ ចឹងបានក្រោយសមាហរណកម្មមក គណបក្សនយោបាយផ្សេងគេធ្វើនយោបាយ ខ្ញុំឲ្យចូលក្នុងគណបក្សគេចេះចុះ ខ្ញុំថាអើយ!ខ្ញុំបួសឆ្អែតហើយលោកអើយលោក ខ្ញុំរៀង ខ្ញុំចាល់ហើយ ខ្ញុំមិនធ្វើការងារអីទៀតទេ ខ្ញុំនិយាយចឹងខ្ញុំនិយាយចឹង ហើយគេចេះតែណែនាំខ្ញុំថាមិនបាច់ទេ សាលានយោបាយក្រោយខ្ញុំមិនបាច់មកធ្វើនយោបាយដាក់ខ្ញុំ ។ ខ្ញុំឆ្អែតហើយនយោបាយ អញឯងទើបកើតក្រោយខ្ញុំមកធ្វើនយោបាយដាក់ខ្ញុំវាមិនត្រូវទេ ខ្ញុំថាអត់ធ្វើអត់ហើយ ។ គេថាឲ្យតែពិតអត់ធ្វើ ។ ដល់ខ្ញុំមកឈរឈ្មោះក្រុមប្រឹក្សាឃុំគេផ្ដាញ់ខ្ញុំ ។ ខ្ញុំថាទៅណាអត់ទៅទេ អ្នកណាគ្នាច្រើនទៅហើយសព្វថ្ងៃខ្ញុំដើរតាមអ្នកចាញ់គេពិបាកណាស់ ។ ខ្ញុំថាដើរជាមួយអ្នកចាញ់ពិបាកណាស់ ខ្ញុំសុខចិត្តដើរជាមួយអ្នកឈ្នះហើយ ។ មិនមែនធម្មតាទេឆ្អែតហើយ ប្អូនឯងដឹងហើយពីអាយុ១៦ ១៧ឆ្នាំមកទល់សព្វថ្ងៃ៥៨ វាអស់និយាយហើយ គ្រប់បែបបត់ទៅ ។

បូលី : មែនទែនទៅ បើខ្ញុំចង់សួរលំអិតទៀត មានសំនួរច្រើនទៀត ក្រែងជួបមីងមួយពេលយ៉ាងហោចមួយម៉ោងទៀតដែរ ប៉ុន្ដែមើលទៅដូចជាមិនចង់រំខានពូមីងទៀតទេ ។

ភាព : ចង់សួរពីក្រោយពីសមាហរណកម្មទៀត?

បូលី : បាទៗ សួរមុំជិតៗសមាហរណកម្មនឹង ឥឡូវនេះវាជិតអស់ថ្ម ម៉ោងក៏ជ្រេ ចាំមើលថ្ងៃក្រោយចាំមើលម៉េចៗខ្ញុំនឹងបន្ដភាគទី៤ ។ខ្ញុំគិតថាត្រូវឲ្យពូមីងសម្រាកប៉ុននឹងចុះ ព្រោះពូមីងហត់ហើយអង្គុយយូរហើយ ។ ដែលបានផ្ដល់ឱកាសឲ្យខ្ញុំសម្ភាសន៍៣ពេល មីង ពូ បានសាច់រឿងច្រើនណាស់ ។ ចាំមើលខ្ញុំមកលើកក្រោយ ខ្ញុំនឹងឆ្លៀតចូលលេងពូមីងទៀត ។

ភាព : តែកន្លែងខ្លះក៏ច្បាស់កន្លែងខ្លះក៏អត់ដែរណា ខ្ញុំចង់និយាយថាការនិយាយនេះខ្លះយើងស្ដាប់ប្រយោល ខ្លះយើងរស់នៅជាក់ស្ដែងចឹងទេ ។ អាប្រយោលនេះវាមិនសូវច្បាស់លាស់គ្រាន់តាមការដឹងៗរបស់យើង ។

បូលី : មិនអីទេ ពីព្រោះពត៌មានទាំងអស់នេះ ខ្ញុំយកទៅផ្ទៀងផ្ទាត់ជាមួយឯកសារ និងពត៌មានដែលបានមកពីពូមីងផ្សេងៗទៀត ប្របាច់បញ្ចូលគ្នា ។ បន្ទាប់មក គេមានគណកម្មការពិនិត្យទៀតពូដាន់ណា គាត់នឹងបង្កើតគណកម្មការមួយ ដើម្បីពិនិត្យមើលសៀវភៅនឹង ដែលតាចាស់ៗធំៗ ដែលគាត់នៅផ្ទាល់ នៅជិត តា ម៉ុក ជិតអីនឹង អានឹងគាត់ដឹងរឿងច្បាស់លាស់ចឹងទៅ

គាត់នឹងសហការគ្នាមើលសៀវភៅនឹង នេះតាមសម្ដីគាត់និយាយ ។ ចឹងវាមានឆ្លងកាត់ច្រើនដំណាក់ ដើម្បីឲ្យវាច្បាស់លាស់បានយើងបោះពុម្ពចេញ ។

ភាព : យើងចង់និយាយថា នាំគ្នាត្រួតពិនិត្យហើយ អ៊ីដែលមិនសមស្រម វាមិនសូវច្បាស់លាស់ គាត់គូសចោលអត់ឲ្យដាក់ កន្លែងណាត្រឹមត្រឹមដែលដឹងពុទាំងអស់គ្នាសមស្របហើយ គាត់ឲ្យយក គាត់ទុក ។ អានឹងវាល្អម្យ៉ាងដែរ ហើយក៏ងាយស្រួលដល់ប្អូនអ្នករៀបចំឯកសារដែរបណ្ណាល័យ ។

សែ : ប៉ុនគ្រាន់យើងផ្ញើយើងថា មនុស្សដែលស្លាប់ទៅហើយ យើងកុំមើលឃើញតែកំហុសគ្នាដែលងាប់ទៅហើយនឹងទាំងអស់ពេក វាមានលក្ខណៈសម្បត្តិដែរ អានឹងដែលយើងបានពុគ្រប់កន្លែង ។

បូលី : មូលហេតុនឹងហើយ ដែលខាងក្រុមខ្ញុំនេះ មិនសម្ភាសន៍តែអ្នកនៅលើទេ គឺចុះមកដល់ខាងក្រោមៗទៀត ដើម្បីសុំយោបល់ពីខាងក្រោម ពីប្រជាជនគាត់មានយោបល់យ៉ាងម៉េច ចិត្តគាត់គិតយ៉ាងម៉េច មិនមែនចេះតែអ្នកលើថា ជួនកាលគាត់ប៉ះគ្នា គាត់ខឹងគ្នា គាត់ថាតាអាក្រក់ចឹងទៅ ។

សែ : អត់ទេ ដូចប្រជុំដែលកាត់ទោសលើកទី១នោះ អ្នកដែលមកផ្ញើយំផ្ញើស្រែកអី សុទ្ធតែពួកពុតាមគេទេ អាតួអង្គរឿងពិតនោះវាមិនទាន់ចូលដល់ទេ ។ ចឹងបានមើលទៅវាសំដៅរបបនឹងដែលវាបរាជ័យហើយ វាចេះតែថ្កោលទោសទាំងអស់នឹង អាសច្ចៈធម៌វាអត់ឃើញទេ ។

ភាព : អាខ្លួនឯងអត់មានជាប់សាច់រឿងម៉ាតិចក៏កំសត់ជាងគេអាជាប់សាច់រឿងទៅទៀត ។

បូលី : ពូចង់បោះពុម្ពទេ អត្ថបទដែលពូចងក្រង?

សែ : មិនទាន់ទេ ។

បូលី : បើពូចង់បោះពុម្ពខ្ញុំអាចជួយបោះពុម្ពនៅក្នុងទស្សនាវដ្ដីបាន ទស្សនាវដ្ដីស្វែងរកការពិត គ្រាន់តែខ្ញុំយកអត្ថបទពីពូទៅ យើងយកទៅវ៉ៃចូលកុំព្យូទ័របោះពុម្ពក្នុងទស្សនាវដ្ដី ។

សែ : អានឹងចាំមើលហៅថាដំណើរផ្លូវជីវិតរបស់ខ្លួន ។

បូលី : បាទ! ជីវិតរបស់មនុស្សម្នាក់ៗ ។

សែ : ដែលអ៊ីដែលវាត្រឹមត្រូវ ដែលមិនត្រឹម ខ្ញុំបញ្ជាក់ហេតុផលដែរ អានេះវាទទួលការបរាជ័យនឹងទទួលការជ័យជំនះនឹងក្នុងដំណើរជីវិតរបស់ខ្លួន ផ្ញើចឹងខ្លាចវាប៉ះពាល់ដល់គេដល់ឯង ។

បូលី : ចឹងខ្ញុំអរគុណមីងពូច្រើន ដែលបានផ្ដល់បទសម្ភាសន៍ ។

«ចប់»